# ស្វែងយល់ទស្សនៈសាធារណជន
# ចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា

ខែ មករា ឆ្នាំ ២០១១

ក្រសួងបរិស្ថាន
នាយកដ្ឋានប្រែប្រួលអាកាសធាតុ

# សេចក្តីថ្លែងអំណរគុណ

ក្រសួងបរិស្ថាន សូមថ្លែងអំណរគុណចំពោះអង្គការ Oxfam ជំនួយអភិវឌ្ឍន៍ដាណឺម៉ាក (Danida) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំប្រទេសកម្ពុជា (UNDP) ដែលបានផ្តល់ការគាំទ្រខាងហិរញ្ញវត្ថុ និងបច្ចេកទេសសំរាប់ការសិក្សាអំពីចំណេះដឹង ឥរិយាបថ និងការអនុវត្ត (KAP)។ ក្រសួងបរិស្ថានសូមថ្លែងអំណរគុណជាពិសេស ចំពោះសមាជិកនិងទីប្រឹក្សាបច្ចេកទេសដែលរួមមាន លោកស្រី Macarena Aguilar កញ្ញា សេង បុប្ផា លោក Jacob Kahl Jepsen លោក អ៊ុយ កាម៉ាល លោកស្រី Mona Laczo លោកស៊ុំ ធី និងលោកបណ្ឌិត ទិន ពន្លក។

ក្រសួងបរិស្ថាន ក៏សូមសំដែងអំណរគុណចំពោះអង្គការ BBC World Service Trust ដែលបានចាត់ចែងអនុវត្តការងារទៅតាមចំណុចគោលដៅស្រាវជ្រាវ និងដោយមានការចូលរួមពីជំនួយការឯករាជ្យមួយចំនួនផងដែរ។

របាយការណ៍នេះត្រូវបានរៀបរៀងចងក្រង និងវិភាគដោយក្រុមស្រាវជ្រាវ និងសិក្សានៃអង្គការ BBC World ServiceTrust នៅកម្ពុជា និងនៅចក្រភពអង់គ្លេស។ របាយការណ៍នេះត្រូវបានចងក្រងដោយ កញ្ញា Miriam Burton ដោយមានការរួមចំណែកពី កញ្ញា Susan Cooke លោក ប៊ី វីរៈ លោកស្រី Lizz Frost Yocum លោកស្រី ជីវ លីនណា កញ្ញា Anna Godfrey និងលោកស្រី Patricia Doherty ដោយផ្អែកលើការវិភាគ ដែលរៀបរៀងដោយ លោក ចែម វុទ្ធី លោក អ៊ុយ សារ៉េត លោក ត្រាក់ ពិសិដ្ឋ លោក ហេង ភស្សត្តី និង កញ្ញា Anna Colom។

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** .................... ii

**មាតិកា** .................... iii

**បញ្ជីតារាង** .................... vii

**អារម្ភកថា** .................... xii

**សេចក្តីសង្ខេប** .................... xiv

**សាវតានៃការស្រាវជ្រាវ** .................... 1

**ការយល់ឃើញ និងការទទួលបានព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ ៖ តើយើងបានដឹងអ្វីខ្លះហើយ** ? .................... 2

**វិធីសាស្ត្រស្រាវជ្រាវ** .................... 6

ការរៀបចំការស្រាវជ្រាវតាមបែបគុណវិស័យ .................... 6

ការរៀបចំការស្រាវជ្រាវបែបបរិមាណវិស័យ .................... 6

ស្ថានភាពប្រជាសាស្ត្រសង្គម នៃសំណាក ក្នុងការអង្កេត .................... 8

ដែនកំណត់ និងបទពិសោធន៍នៃការសិក្សា .................... 9

*ភាពលម្អៀងទៅរកអ្វី ដែលសង្គមចង់បាន* .................... 9

*ភាពលម្អៀង ដោយសារការមិនជំទាស់* .................... 9

*ដែនកំណត់ រវាងទិន្នន័យគុណវិស័យ និងទិន្នន័យបរិមាណវិស័យ* .................... 9

*ដែនកំណត់ នៃសំណាកនៅក្នុងការអង្កេត* .................... 10

*សុពលភាព នៃព័ត៌មាន* .................... 11

*ការវិភាគ* .................... 12

**របកគំហើញសំខាន់ៗ** .................... 14

**តើប្រជាជនកម្ពុជាយល់ដឹង និងគិតយ៉ាងណាខ្លះអំពី** .................... 14

**ការប្រែប្រួលអាកាសធាតុ**? .................... 14

បទពិសោធន៍អំពីការប្រែប្រួលធាតុអាកាសនិងបរិស្ថាន .................... 15

គ្រោះធម្មជាតិ .................... 15

*ព័ត៌មានអំពីគ្រោះធម្មជាតិ* .................... 16

ការប្រែប្រួលធាតុអាកាស .................... 20

ការប្រែប្រួលបរិស្ថាន .................... 22

ចំណេះដឹងនិងការយល់ដឹងអំពី "ការប្រែប្រួលអាកាសធាតុ"......23
*ពាក្យ ការប្រែប្រួលអាកាសធាតុ*......23
*ប្រភពព័ត៌មាន នៃបច្ចេកស័ព្ទការប្រែប្រួលអាកាសធាតុ*......25
*ការយល់ដឹងពីមូលហេតុ នៃការប្រែប្រួលអាកាសធាតុ*......27
*ការប្រែប្រួលធាតុអាកាស និងសកម្មភាពមនុស្ស*......29
*ការយល់ដឹងអំពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ*......31
កង្វល់អំពីការប្រែប្រួលធាតុអាកាស និងបរិស្ថាន......33
*ជីវិតគ្រួសារ ការងារ និងកសិកម្ម*......34
*ការចិញ្ចឹមជីវិត និងការប្រែប្រួលអាកាសធាតុ*......36
*ធនធានទឹក និងការប្រែប្រួលអាកាសធាតុ*......37
*សុខភាព និងការប្រែប្រួលអាកាសធាតុ*......39
*តើប្រជាជនកម្ពុជា គិតថាខ្លួនគេអាចឆ្លើយតបបែបណា?*......40
*តើប្រជាជនកម្ពុជាបានធ្វើអ្វីខ្លះ ក្នុងការឆ្លើយតប?*......42
*ការឆ្លើយតប របស់សហគមន៍ទៅនឹងការប្រែប្រួលធាតុអាកាស*......43
*តើប្រជាជនឆ្លើយតបបែបណាទៅនឹងផលប៉ះពាល់មកលើការងាររបស់ពួកគេ?*......44
*កម្រិត នៃការជឿទុកចិត្តលើខ្លួនឯង និងការជឿទុកចិត្តជារួម នៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ*......45
*ទស្សនៈវិជ្ជមាន អំពីសមត្ថភាពក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ*......46
*ធនធានចាំបាច់ ដើម្បីជួយប្រជាជននៅក្នុងការដោះស្រាយបញ្ហា*......46
*តើអ្នកណាខ្លះធ្វើការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ?*......46
**ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងប្រភពព័ត៌មាន**......47
ប្រភពព័ត៌មាន......47
*ប្រភពព័ត៌មាន ដែលទុកចិត្ត*......48
ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ......49
ការរួមបញ្ចូលនៃប្រព័ន្ធផ្សព្វផ្សាយ......50
*ទម្លាប់ប្រើប្រាស់វិទ្យុ*......51
*ស្ថានីយ៍វិទ្យុ*......51
*រយៈពេល និងម៉ោងនៃការស្ដាប់វិទ្យុ*......51
*កម្មវិធីសំណេះសំណាលតាមទូរស័ព្ទ*......52
*ការទូរស័ព្ទចូលក្នុងកម្មវិធីសំណេះសំណាលតាមទូរស័ព្ទ*......52

*ទម្លាប់មើលទូរទស្សន៍* ..... 53
*រយៈពេល និងម៉ោងនៃការមើលទូរទស្សន៍* ..... 53
*ប៉ុស្តិ៍ទូរទស្សន៍* ..... 54
*ការប្រើប្រាស់ទូរស័ព្ទចល័ត* ..... 54
*ការប្រើប្រាស់សេវាទូរស័ព្ទ* ..... 55
*ភាពជាម្ចាស់លើទូរស័ព្ទចល័ត* ..... 55
*បណ្តាញទូរស័ព្ទចល័ត* ..... 56
*មុខនាទីនៃទូរស័ព្ទចល័ត* ..... 56
*ការផ្ញើសារ* ..... 57
*សារព័ត៌មានបោះពុម្ព (Print Media)* ..... 57
*ការប្រើប្រាស់អ៊ីនធឺណែត* ..... 57
*ឌីវីឌី និងវីស៊ីឌី (DVD and VCD)* ..... 58
*ការផ្សព្វផ្សាយតាមរយៈសកម្មភាពផ្ទាល់* ..... 58
*ចំណាប់ចំណូលចិត្តលើការផ្សព្វផ្សាយផ្ទាល់* ..... 58
**តើបុគ្គលសំខាន់ៗនៅកម្ពុជាដឹង និងយល់អ្វីខ្លះអំពីការប្រែប្រួលអាកាសធាតុ**? ..... 59
ការយល់ដឹង អំពីការប្រែប្រួលអាកាសធាតុ ..... 59
*ការយល់ដឹងអំពីបច្ចេកស័ព្ទ* ..... 60
*ការយល់ឃើញអំពីមូលហេតុ* ..... 61
*ការយល់ឃើញអំពីផលប៉ះពាល់* ..... 63
តើសាធារណជនយល់បែបណា អំពីការប្រែប្រួលអាកាសធាតុ? ..... 65
តើការទទួលខុសត្រូវស្ថិតនៅឯណា? ..... 66
តើត្រូវឱ្យមានការឆ្លើយតបអ្វីខ្លះ? ..... 68
បុគ្គលសំខាន់ៗគិតតាមក្រុម ..... 70
*តំណាងពីរដ្ឋាភិបាលសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភា* ..... 70
*អភិបាលខេត្ត* ..... 74
*ប្រធានក្រុមប្រឹក្សាឃុំ* ..... 78
*ប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិ* ..... 82
*បុគ្គលដែលមានប្រជាប្រិយភាព* ..... 85
*តំណាងពីប្រព័ន្ធផ្សព្វផ្សាយ* ..... 90
*តំណាងពីអង្គការមិនមែនរដ្ឋាភិបាល* ..... 93

*មេដឹកនាំសាសនា* ........................................................................ 95
**សេចក្តីសន្និដ្ឋាន** ........................................................................ 98
**អនុសាសន៍** ........................................................................ 99
**ឯកសារពិគ្រោះ**........................................................................ 106
ឧបសម្ព័ន្ធ១៖ វិធីសាស្រ្ត ........................................................................ 108
ឧបសម្ព័ន្ធ២៖បញ្ជីតារាង........................................................................ 115

# បញ្ជីតារាង


តារាង១: ប្រជាសាស្ត្រ ........ 115

តារាង២: ប្រជាសាស្ត្រ (ផ្តោតលើភេទ និង ទីកន្លែង) ........ 116

តារាង៣: គ្រោះធម្មជាតិដែលកើតឡើងកាលពីឆ្នាំកន្លងទៅ (តារាងប្រេកង់) ........ 117

តារាង៤: "ខាងក្រោមនេះគឺជាគ្រោះធម្មជាតិមួយចំនួន តើអ្នកធ្លាប់ជួបវាដែរឬទេ កាលពីឆ្នាំមុន?" ........ 118

តារាង៥: "ក្នុងចំណោមគ្រោះធម្មជាតិដែលអ្នកបានជួបប្រទះ តើគ្រោះធម្មជាតិណាមួយដែលមានឥទ្ធិពលលើជីវិតរបស់អ្នកខ្លាំងជាងគេ?" ........ 119

តារាង៦: តើអ្នកធ្លាប់បានទទួលព័ត៌មានអំពីគ្រោះធម្មជាតិដែលអ្នកបានកត់សម្គាល់ដែរឬទេ? ........ 120

តារាង៧: តើជាទូទៅអ្នកធ្លាប់ទទួលព័ត៌មានពីការព្យាករណ៍សីតុណ្ហភាពដែរឬទេ? ........ 121

តារាង៨: តើនៅពេលណាដែលអ្នកទទួលបានព័ត៌មានអំពីគ្រោះធម្មជាតិនេះ? ........ 122

តារាង៩: ប្រភពព័ត៌មានអំពីគ្រោះធម្មជាតិ (តារាងប្រេកង់) ........ 123

តារាង១០: តើអ្នកទទួលព័ត៌មានទាំងនេះមកពីណា? ........ 124

តារាង១១: តើព័ត៌មានទាំងនោះ នឹងអាចជួយអ្នកដោយរបៀបណា ដើម្បីដោះស្រាយជាមួយគ្រោះធម្មជាតិ? .. 125

តារាង១២: សូមគិតពីក្នុងឆាកជីវិតដែលអ្នកបានជួបប្រទះ (តាំងពីកើតរហូតដល់បច្ចុប្បន្ន) ហើយខ្ញុំនឹងអានឃ្លា ឬប្រយោគ ខាងក្រោមនេះសូមប្រាប់ខ្ញុំថា "ត្រូវ" ឬ "ខុស" ........ 126

តារាង១៣: សូមគិតពីក្នុងឆាកជីវិតដែលអ្នកបានជួបប្រទះ (តាំងពីកើតរហូតដល់បច្ចុប្បន្ន) ហើយខ្ញុំនឹងអានឃ្លា ឬប្រយោគ ខាងក្រោមនេះសូមប្រាប់ខ្ញុំថា "ត្រូវ" ឬ "ខុស" (ផ្នែកទី១) ........ 127

តារាង១៤: សូមគិតពីក្នុងឆាកជីវិតដែលអ្នកបានជួបប្រទះ (តាំងពីកើតរហូតដល់បច្ចុប្បន្ន) ហើយខ្ញុំនឹងអានឃ្លា ឬប្រយោគ ខាងក្រោមនេះសូមប្រាប់ខ្ញុំថា "ត្រូវ" ឬ "ខុស" (ផ្នែកទី២) ........ 128

តារាង១៥: តើអ្នកអាចប្រាប់ខ្ញុំអំពីធនធានធម្មជាតិនៅប្រទេសកម្ពុជា ចំនួន ៣ យ៉ាងដែលសំខាន់ៗ? ........ 129

តារាង១៦: អ្វីដែលជាអទិភាពសម្រាប់កម្ពុជា? ........ 130

តារាង១៧: តើអ្នកធ្លាប់ឮពាក្យ "ការប្រែប្រួលអាកាសធាតុ" ដែរឬទេ? ........ 131

តារាង១៨: តើអ្នកធ្លាប់ឮពាក្យ "ការឡើងកម្តៅផែនដី" ដែរឬទេ? ........ 132

តារាង១៩: ប្រសិនបើអ្នកធ្លាប់ឮពាក្យទាំងពីរនេះ តើពាក្យមួយណាដែលអ្នកធ្លាប់ឮច្រើនជាងគេ? ........ 133

តារាង២០: សូមអ្នកប្រាប់ខ្ញុំថា តើអ្នកយល់ថាពាក្យ (ការប្រែប្រួលអាកាសធាតុ)មានន័យយ៉ាងដូចម្តេច? ........ 134

តារាង២១: សូមអ្នកប្រាប់ខ្ញុំថា តើអ្នកយល់ថាពាក្យ (ការឡើងកម្តៅផែនដី) មានន័យយ៉ាងដូចម្តេច? ........ 135

តារាង២២: តើអ្នកអាចប្រាប់ខ្ញុំ ថាតើអ្នកធ្លាប់ឮពាក្យ (ការប្រែប្រួលអាកាសធាតុ/ការឡើងកម្តៅផែនដី) មកពីណា? ........ 136

តារាង២៣: តើមូលហេតុអ្វីខ្លះ ដែលធ្វើឲ្យ ធាតុអាកាសនៅកម្ពុជាមានការប្រែប្រួល? (តារាងប្រេកង់)............. 137
តារាង២៤: តើមូលហេតុអ្វីខ្លះ ដែលធ្វើឲ្យ ធាតុអាកាសនៅកម្ពុជាមានការប្រែប្រួល?.................................... 138
តារាង២៥: មានមនុស្សខ្លះនិយាយថា "សកម្មភាពមនុស្សជាមូលហេតុធ្វើឲ្យមានការប្រែប្រួលអាកាសធាតុនៅលើពិភពលោក" តើអ្នកយល់ព្រម ឬ មិនយល់ព្រមកម្រិតណាជាមួយប្រយោគខាងលើនេះ?.............................. 139
តារាង២៦: តើអ្នកគិតថាសកម្មភាពរបស់អ្នកបានរួមចំណែកក្នុងការធ្វើឲ្យមានការប្រែប្រួលអាកាសធាតុដែរឬទេ? .............................................................................................................................................. 140
តារាង២៧: តើសកម្មភាពរបស់អ្នកចូលរួមធ្វើឲ្យមានការប្រែប្រួលអាកាសធាតុដែរឬទេ? ............................... 141
តារាង២៨: តើសកម្មភាពរបស់អ្នក ចូលរួមធ្វើឲ្យមានការប្រែប្រួលអាកាសធាតុយ៉ាងដូចម្ដេច? ...................... 142
តារាង២៩: នៅពេលបច្ចុប្បន្ននេះ តើអ្នកគិតថាការប្រែប្រួលអាកាសធាតុជះឥទ្ធិពលដល់ប្រទេសកម្ពុជាដែរឬទេ? .............................................................................................................................................. 143
តារាង៣០: តើអ្នកគិតថាការប្រែប្រួលអាកាសធាតុនឹងជះឥទ្ធិពលដល់ប្រទេសកម្ពុជាទៅថ្ងៃអនាគតដែរឬទេ? . 144
តារាង៣១: តើការប្រែប្រួលអាកាសធាតុធ្វើឲ្យប៉ះពាល់ (ឬនឹងប៉ះពាល់) ដល់ប្រទេសកម្ពុជាយ៉ាងដូចម្ដេចខ្លះ? 145
តារាង៣២: តើការប្រែប្រួលអាកាសធាតុធ្វើឲ្យប៉ះពាល់ (ឬនឹងប៉ះពាល់) ដល់ប្រទេសកម្ពុជាយ៉ាងដូចម្ដេចខ្លះ? 146
តារាង៣៣: តើការប្រែប្រួលអាកាសធាតុធ្វើឲ្យជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នក ឬគ្រួសារជួបផលលំបាកដូចម្ដេចខ្លះ? .............................................................................................................................................. 147
តារាង៣៤: សូមគិតពីការប្រែប្រួលអាកាសធាតុ តើអ្នកគិតថាវាមានផលប៉ះពាល់ដល់មុខរបររបស់អ្នកកម្រិតណា? .............................................................................................................................................. 148
តារាង៣៥: តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាចំពោះប្រយោគដែលថាអ្នកអាចដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុបាន?........................................................................................................... 149
តារាង៣៦: តើអ្នកយល់ស្រប ឬមិនយល់ស្របកម្រិតណាចំពោះប្រយោគដែលថាសហគមន៍របស់អ្នកអាចដោះស្រាយបញ្ហាប្រែប្រួលធាតុអាកាសបាន?................................................................................. 150
តារាង៣៧: លទ្ធភាពទទួលបានទឹកប្រើប្រាស់.................................................................................... 151
តារាង៣៨: គុណភាពទឹកប្រើប្រាស់.................................................................................................. 152
តារាង៣៩: តើអ្នកគិតថាអ្នក និងគ្រួសាររបស់អ្នកមានទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ (ផឹក ដាំស្ល បោកគក់) ដែរឬទេ? ........................................................................................................................ 153
តារាង៤០: តើអ្នកគិតថាអ្នក និងគ្រួសាររបស់អ្នកមានទឹកដែលអ្នកត្រូវការដើម្បីធ្វើការងារចិញ្ចឹមជីវិតរបស់អ្នកដែរឬទេ? ........................................................................................................................ 154
តារាង៤១: តើការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់សុខភាពរបស់មនុស្សដែរឬទេ?............................ 155
តារាង៤២: តើការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់សុខភាពរបស់មនុស្សដែរឬទេ?............................ 156

តារាង៤៣: តើប្រជាជនអាចធ្វើអ្វីដើម្បីដោះស្រាយការប្រែប្រួលធាតុអាកាស? (តារាងប្រេកង់) ..................... 157
តារាង៤៤: តើប្រជាជនអាចធ្វើអ្វីដើម្បីដោះស្រាយការប្រែប្រួលធាតុអាកាស? (ផ្នែកទី ១) ............................ 158
តារាង៤៥: តើប្រជាជនអាចធ្វើអ្វីដើម្បីដោះស្រាយការប្រែប្រួលធាតុអាកាស? (ផ្នែកទី ២) ............................ 159
តារាង៤៦: តើអ្នក ឬនរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នក បានដោះស្រាយជាមួយ ការប្រែប្រួលធាតុអាកាសដែរឬទេ? ........................................ 160
តារាង៤៧: តើអ្នក ឬពួកគេបានធ្វើអ្វីខ្លះដើម្បីឆ្លើយតប? ........................................ 161
តារាង៤៨: តើអ្នក ឬពួកគេបានធ្វើអ្វីខ្លះដើម្បីឆ្លើយតប? ........................................ 162
តារាង៤៩: តើមាននរណាម្នាក់នៅក្នុងសហគមន៍របស់អ្នកបានដោះស្រាយជាមួយ ការប្រែប្រួលធាតុអាកាសដែរឬទេ? ........................................ 163
តារាង៥០: តើពួកគេបានធ្វើអ្វីខ្លះ? ........................................ 164
តារាង៥១: តើពួកគេបានធ្វើអ្វីខ្លះ? ........................................ 165
តារាង៥២: ប្រសិនបើការប្រែប្រួលធាតុអាកាសកាន់តែខ្លាំង តើអ្នកមានវិធីសាស្ត្រដោះស្រាយយ៉ាងដូចម្តេចខ្លះទៅនឹងផលប៉ះពាល់ទាំងនេះលើមុខរបររបស់អ្នក? ........................................ 166
តារាង៥៣: តើធនធានអ្វីដែលគេត្រូវការដើម្បីជួយប្រជាជនដោះស្រាយការប្រែប្រួលអាកាសធាតុ? ............... 167
តារាង៥៤: តើធនធានអ្វីដែលគេត្រូវការដើម្បីជួយប្រជាជនដោះស្រាយការប្រែប្រួលអាកាសធាតុ? (យេនឌ័រ) . 168
តារាង៥៥: តើធនធានអ្វីដែលគេត្រូវការដើម្បីជួយប្រជាជនដោះស្រាយការប្រែប្រួលអាកាសធាតុ? (ទីកន្លែង) . 169
តារាង៥៦: តើធនធានអ្វីដែលគេត្រូវការដើម្បីជួយប្រជាជនដោះស្រាយការប្រែប្រួលអាកាសធាតុ? ............... 170
តារាង៥៧: តើអ្នកយល់ស្របកម្រិតណា ចំពោះគំនិតដែលលើកឡើងថាការប្រែប្រួលធាតុអាកាសធ្វើឲ្យមានផលប្រយោជន៍ជាច្រើនសម្រាប់អ្នក និងគ្រួសាររបស់អ្នក? ........................................ 171
តារាង៥៨: តើអ្នកយល់ស្របកម្រិតណា ចំពោះគំនិតដែលលើកឡើងថា អ្នកអាចស្វែងរកព័ត៌មានដែលអ្នកត្រូវការដើម្បីដោះស្រាយបញ្ហាប្រែប្រួលធាតុអាកាសបាន? ........................................ 172
តារាង៥៩: តើអ្នកយល់ស្របកម្រិតណា ចំពោះគំនិតដែលលើកឡើងថា សហគមន៍របស់អ្នកអាចដោះស្រាយបញ្ហាប្រែប្រួលធាតុអាកាសបាន? ........................................ 173
តារាង៦០: តើអ្នកយល់ស្របកម្រិតណា ចំពោះគំនិតដែលលើកឡើងថាសហគមន៍របស់អ្នកមានធនធាន (លុយ មនុស្ស និងធនធានរូបសាស្ត្រ) ដែលពួកគេត្រូវការដើម្បីដោះស្រាយបញ្ហាការប្រែប្រួលធាតុអាកាស? ........... 174
តារាង៦១: តើអ្នកយល់ស្របកម្រិតណា ចំពោះគំនិតដែលលើកឡើងថាសហគមន៍របស់អ្នក ដោះស្រាយបញ្ហាគ្រោះរាំងស្ងួតបាន? ........................................ 175
តារាង៦២: តើអ្នកយល់ស្របកម្រិតណា ចំពោះគំនិតដែលលើកឡើងថាសហគមន៍របស់អ្នកដោះស្រាយបញ្ហាគ្រោះទឹកជំនន់បាន? ........................................ 176

តារាង៦៣: តើអ្វីជាឧបសគ្គសម្រាប់អ្នកក្នុងការទប់ទល់ជាមួយការប្រែប្រួលធាតុអាកាស?............................177
តារាង៦៤: តើអ្នកស្គាល់ អង្គការ ស្ថាប័នរដ្ឋាភិបាល ឬបុគ្គលណាម្នាក់ ដែលធ្វើការងារដើម្បីដោះស្រាយជាមួយការប្រែប្រួលធាតុអាកាសដែរឬទេ?............................178
តារាង៦៥: តើអ្នកណាដែលមានអំណាចក្នុងការដោះស្រាយជាមួយការប្រែប្រួលធាតុអាកាស?............................179
តារាង៦៦: តើអ្នកណាដែលមានអំណាចក្នុងការដោះស្រាយជាមួយការប្រែប្រួលធាតុអាកាស?............................180
តារាង៦៧: តើមានអ្វីខ្លះដែលអ្នកគិតថា រដ្ឋាភិបាលអាចជួយអ្នកក្នុងការដោះស្រាយបញ្ហាការប្រែប្រួលធាតុអាកាស?............................181
តារាង៦៨: តើរដ្ឋាភិបាលអាលធ្វើអ្វីបានខ្លះ?............................182
តារាង៦៩: ជាទូទៅ តើអ្នកទទួលព័ត៌មានផ្សេងៗពីប្រភពណាខ្លះ ហើយប្រភពណាដែលអ្នកមានទំនុកចិត្ត?...183
តារាង៧០: ជាទូទៅ តើអ្នកទទួលព័ត៌មានផ្សេងៗពីប្រភពណាខ្លះ ហើយប្រភពណាដែលអ្នកមានទំនុកចិត្ត?...184
តារាង៧១: តើអ្នកធ្លាប់ប្រើអ៊ិនធឺណែតដែរឬទេ?............................185
តារាង៧២: តើនៅពេលណាដែលអ្នកបានស្តាប់វិទ្យុចុងក្រោយបំផុត?............................186
តារាង៧៣: កម្មវិធីវិទ្យុ............................187
តារាង៧៤: ស្ថានីយ៍វិទ្យុ............................188
តារាង៧៥: ការស្តាប់វិទ្យុតាមថ្ងៃ............................189
តារាង៧៦: ការស្តាប់វិទ្យុតាមម៉ោង............................189
តារាង៧៧: ការស្តាប់វិទ្យុ (រយៈពេលស្តាប់)............................190
តារាង៧៨: តើអ្នកធ្លាប់ស្តាប់កម្មវិធីសំណេះសំណាលតាមទូរស័ព្ទដែរឬទេ?............................191
តារាង៧៩: តើអ្នកធ្លាប់ទូរស័ព្ទចូលកម្មវិធីសំណេះសំណាលតាមទូរស័ព្ទដែរឬទេ?............................191
តារាង៨០: ហេតុអ្វីអ្នកទូរស័ព្ទចូលកម្មវិធីសំណេះសំណាលតាមទូរស័ព្ទ?............................191
តារាង៨១: តើនៅពេលណាដែលអ្នកបានមើលទូរទស្សន៍ចុងក្រោយបំផុត?............................192
តារាង៨២: តើជាធម្មតា អ្នកមើលកម្មវិធីអ្វីខ្លះ?............................193
តារាង៨៣: តើជាធម្មតា អ្នកមើលទូរទស្សន៍នៅថ្ងៃណាខ្លះ?............................194
តារាង៨៤: តើអ្នកមើលទូរទស្សន៍ប៉ុន្មានដងក្នុងមួយថ្ងៃ? ហើយមើលម្តងៗ រយៈពេលប៉ុន្មាន?............................194
តារាង៨៥: តើជាធម្មតា អ្នកមើលទូរទស្សន៍នៅម៉ោងប៉ុន្មានដែរ?............................195
តារាង៨៦: តើជាធម្មតា អ្នកមើលប៉ុស្តិ៍ណាខ្លះ?............................195
តារាង៨៧: តើអ្នកចូលចិត្តមើលប៉ុស្តិ៍ណាជាងគេ?............................196
តារាង៨៨: តើអ្នកអាចទំនាក់ទំនងគ្នាបានតាមទូរស័ព្ទដែរឬទេ?............................197

តារាង៨៩: តើអ្នកអាចទំនាក់ទំនងគ្នាបានតាមរយៈទូរស័ព្ទរបស់អ្នកណា?....................................................198
តារាង៩០: តើអ្នកប្រើប្រព័ន្ធទូរស័ព្ទរបស់ក្រុមហ៊ុនណាខ្លះ?.........................................................................199
តារាង៩១: មុខងារទូរស័ព្ទ (តារាងប្រេកង់)...................................................................................................200
តារាង៩២: មុខងារទូរស័ព្ទ .............................................................................................................................201
តារាង៩៣: តើប្រើសារប្រភេទណា?..................................................................................................................202
តារាង៩៤: តើអ្នកបានប្រើអ៊ិនធឺណែត ចុងក្រោយបំផុតនៅពេលណា? .........................................................203
តារាង៩៥: តើអ្នកប្រើអ៊ិនធឺណែតដើម្បីអ្វី?......................................................................................................204
តារាង៩៦: តើអ្នកប្រើអ៊ិនធឺណែតនៅកន្លែងណា?..........................................................................................205
តារាង៩៧: តើនៅពេលណាដែលអ្នកបានមើល VCD/DVD ចុងក្រោយបំផុត?..............................................206
តារាង៩៨: តើជាធម្មតា អ្នកមើលកម្មវិធីអ្វីខ្លះ?..............................................................................................207
តារាង៩៩: តើជាធម្មតា អ្នកមើលនៅឯណា? (តារាងប្រេកង់).........................................................................208
តារាង១០០: តើជាធម្មតា អ្នកមើលនៅឯណា?..............................................................................................209
តារាង១០១: តើអ្នកធ្លាប់ដឹង ឬឮពីសកម្មភាពចុះអប់រំផ្ទាល់នៅក្នុងសហគមន៍ដែរឬទេ? ................................210
តារាង១០២: នៅពេលណាដែលអ្នកបានចូលរួមជាចុងក្រោយគេក្នុងសកម្មភាពអប់រំតាមសហគមន៍?............211
តារាង១០៣: តើអ្នកធ្លាប់បានចូលរួមសកម្មភាពអប់រំតាមសហគមន៍ដូចខាងក្រោមនេះដែរឬទេ? ...................212

# អារម្ភកថា

ការប្រែប្រួលអាកាសធាតុលែងជារឿងអរូបតកថាទៀតហើយ។ វាកំពុងតែកើតឡើង ហើយយើងទាំងអស់គ្នាដែលរស់នៅប្រទេសកម្ពុជា ងាយរងគ្រោះនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ដោយសារតែសមត្ថភាពបន្សាំរបស់យើងនៅមានកម្រិត។ ការឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុកំពុងក្លាយជាអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចដែលមានបង្ហាញជាភស្តុតាងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣។

បទពិសោធន៍នៅជុំវិញពិភពលោកបានបង្ហាញថា ការងារលើកកម្ពស់ចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុគឺជាបញ្ហាប្រឈមមួយ។ ការដែលមានអាទិភាពច្រើនប្រកួតប្រជែងគ្នា អាចជាឧបសគ្គមួយក្នុងការធ្វើឲ្យសាធារណជន ចាត់ទុកការប្រែប្រួលអាកាសធាតុជាបញ្ហាដែលត្រូវដោះស្រាយជាបន្ទាន់ ជាពិសេសនៅតាមបណ្តាប្រទេសអភិវឌ្ឍតិចតួចដូចប្រទេសកម្ពុជា ។

ចាប់តាំងពីប្រទេសកម្ពុជា ផ្តល់សច្ចាប័នលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ក្នុងឆ្នាំ១៩៩៥ យើងបានខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) របស់កម្ពុជាស្ថិតក្នុងចំណោមកម្មវិធីសកម្មភាព ដែលត្រូវបានអនុម័តដំបូងគេបង្អស់នៅទូទាំងពិភពលោក ហើយយើងក៏ត្រៀមនឹងបញ្ចប់របាយការណ៍ជាតិលើកទីពីរក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុផងដែរ។ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ត្រូវបានបង្កើតឡើង ក្នុងតួនាទីជាស្ថាប័នរៀបចំគោលនយោបាយប្រែប្រួលអាកាសធាតុ ដោយមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធានកិត្តិយស។ នាយកដ្ឋានប្រែប្រួលអាកាសធាតុរបស់ក្រសួងបរិស្ថាន ដែលជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ បានបង្កើតសមិទ្ធផលជាច្រើនក្នុងការសម្របសម្រួលគោលនយោបាយ និងកម្មវិធីនានា ដែលមានភាពចាំបាច់សម្រាប់ឆ្លើយតបទៅនឹងឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។

ទោះជាយ៉ាងណាក៏ដោយ របាយការណ៍ដែលអ្នកមានក្នុងដៃនេះបង្ហាញថាចំណេះដឹង និងការយល់ដឹងរួមរបស់ប្រជាជនកម្ពុជាអំពី វិទ្យាសាស្ត្របឋម មូលហេតុ និងផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុនៅមានកម្រិតនៅឡើយ។

យើងខ្ញុំជឿជាក់ថា ឥឡូវនេះគឺជាដំណាក់កាលសមស្រប សម្រាប់កិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីធានាថាប្រជាជនកម្ពុជាទាំងអស់អាចទទួលបាន ព័ត៌មានគួរឲ្យទុកចិត្តបានអំពីការប្រែប្រួលអាកាសធាតុ។ យើងក៏ដឹងដែរថា ព័ត៌មានដែលត្រូវចែករំលែកត្រូវតែមានភាពពាក់ព័ន្ធ និងងាយយល់ ហើយមានគោលបំណងច្បាស់លាស់។

ការសិក្សានេះធ្វើឡើងដោយមានការសហការជាមួយអង្គការ BBC World Service Trust និងបានទទួលការគាំទ្រពីអង្គការ Oxfam Danida និង UNDP ដើម្បីផ្សព្វផ្សាយព័ត៌មាន និងដាក់បញ្ចូលមតិយោបល់ និងសេចក្តីត្រូវការរបស់ប្រជាជនកម្ពុជាក្នុងសកម្មភាព និងការពិភាក្សារបស់យើងអំពីការប្រែប្រួលអាកាសធាតុ។ ក្រុមអ្នកស្រាវជ្រាវរបស់អង្គការ BBC World Service Trust បានធ្វើដំណើរទៅកាន់ ២៤ខេត្ត/ក្រុង ក្នុងប្រទេសកម្ពុជា និងបានសម្ភាសប្រជាពលរដ្ឋប្រុសស្រី ក្នុងសហគមន៍គ្រប់លំដាប់ថ្នាក់រួមមានកសិករ អ្នកនេសាទ គ្រូបង្រៀន ធុរជន មេផ្ទះ ប្រធានភូមិ និងមន្ត្រីរដ្ឋាភិបាល។ ក្រុមអ្នកស្រាវជ្រាវបានសាកសួរសហគមន៍ និងអាជ្ញាធរ អំពីបទពិសោធន៍របស់ពួកគេ ទាក់ទងនឹងការប្រែប្រួលធាតុអាកាសក្នុងឆ្នាំកន្លងទៅ និងក្នុងអតីតកាល តាមតែពួកគេអាចចាំបាន។ ក្រុមអ្នកស្រាវជ្រាវបានសាកសួរអំពីចំណេះដឹង និងការយល់

ឃើញរបស់ពួកគេ នៅពេល ពួពាក្យខុសៗគ្នា ដែលគេប្រើសម្រាប់ពិពណ៌នា ការប្រែប្រួលអាកាសធាតុ។ ក្រុមអ្នកសិក្សាស្រាវ ក៏កត់សម្គាល់ផងដែរអំពីមនុស្ស និងអ្វីដែលប្រជាពលរដ្ឋជឿទុកចិត្ត និងពឹងផ្អែកក្នុងការធ្វើសេចក្តីសម្រេចប្រកបដោយការយល់ដឹង អំពីកិច្ចការនានា ដែលជះឥទ្ធិពល លើការរស់នៅរបស់ពួកគេ។

លទ្ធផលនៃការសិក្សានេះឥឡូវស្ថិតនៅក្នុងដៃរបស់អ្នកហើយ។

ការសិក្សារបស់យើងក្រោមចំណងជើង*ស្វែងយល់ទស្សនៈសាធារណជន ចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា* គឺជាកិច្ចប្រឹងប្រែងថ្នាក់ជាតិដំបូងគេបង្អស់មួយ។ យើងប្រមូលបានទិន្នន័យជាច្រើន ហើយបានវិភាគទិន្នន័យទាំងនោះយ៉ាងហ្មត់ចត់ ។ អ្វីដែលជាប្រការសំខាន់បំផុតនោះ គឺការសិក្សានេះនឹងផ្តល់អនុសាសន៍មានអត្ថប្រយោជន៍ និងប្រកបដោយភាពច្នៃប្រឌិតយ៉ាងច្រើន សម្រាប់កិច្ចផ្តួចផ្តើមបង្កើនការយល់ដឹងនៅថ្នាក់ជាតិ និងនៅមូលដ្ឋាន ដោយប្រើប្រព័ន្ធផ្សព្វផ្សាយសាធារណៈ និងការផ្សព្វផ្សាយនៅតាមមូលដ្ឋាន ដែលយើងសង្ឃឹមថាលោកអ្នកនឹងចាប់អារម្មណ៍។

ប្រសិនបើអង្គការ ឬក្រសួងរបស់លោកអ្នកកំពុងធ្វើការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ហើយមានបំណងបង្កើនការយល់ដឹងរបស់ប្រជាជន របាយការណ៍នេះនឹងផ្តល់ឲ្យលោកអ្នកនូវគំនិត និងទិន្នន័យគោលសម្រាប់វាយតម្លៃប្រសិទ្ធភាពនៃសកម្មភាពរបស់លោកអ្នក។ ប្រសិនបើលោកអ្នក ជាអ្នកធ្វើការក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ ឬពាណិជ្ជកម្ម ការសិក្សានេះនឹងជួយលោកអ្នកក្នុងការបង្កើតខ្លឹមសារ ដែលផ្តោតចំគោលដៅជាងមុន ដើម្បីទទួលបានជោគជ័យក្នុងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ។ ប្រសិនបើលោកអ្នកជាអ្នកអាន ដែលចង់ដឹង ចង់យល់ នោះខ្ញុំសង្ឃឹមថា លោកអ្នកនឹងទទួលបានការបំផុសគំនិត ពីទស្សនៈ និងសក្ខីកម្មរបស់ប្រជាពលរដ្ឋយើង ដែលបានចងក្រងក្នុងសៀវភៅនេះ ដូចដែលយើងជាអ្នករៀបរៀងបានទទួលដែរ។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមថាសកម្មភាពបន្ទាប់ក្រោយការសិក្សានេះ នឹងជួយកសាងសង្គមកម្ពុជាឲ្យរឹងមាំជាងមុន ដែលអាចបន្សាំ នឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងអាចចូលរួមក្នុងកិច្ចប្រឹងប្រែងរួមគ្នា ដើម្បីកាត់បន្ថយការបញ្ចេញ ឧស្ម័នផ្ទះកញ្ចក់។

ភ្នំពេញ ខែមករា ឆ្នាំ២០១១

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**បណ្ឌិត ម៉ុក ម៉ារ៉េត**

# សេចក្តីសង្ខេប

ក្នុងឆ្នាំ២០១០ ក្រសួងបរិស្ថាន និងក្រុមអ្នកស្រាវជ្រាវរបស់អង្គការ BBC World Service Trust បានធ្វើការស្រាវជ្រាវនៅ ២៤ ខេត្ត/ក្រុង ទូទាំងប្រទេសកម្ពុជា ដើម្បីស្វែងយល់ពីការយល់ដឹងរបស់សាធារណជនអំពីការប្រែប្រួលអាកាសធាតុ។ ការស្រាវជ្រាវរួមមានការអង្កេតជាលក្ខណៈតំណាងនៅទូទាំងប្រទេស លើប្រជាជនកម្ពុជាចំនួន ២៤០១ នាក់ និងការសម្ភាស ស៊ីជម្រៅជាមួយបុគ្គលសំខាន់ៗ ចំនួន ១០១ នាក់ មកពីប្រព័ន្ធផ្សព្វផ្សាយ ឧស្សាហកម្ម មន្ត្រីរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត អង្គការមិនមែនរដ្ឋាភិបាល បុគ្គលដែលមានប្រជាប្រិយភាព មេដឹកនាំនៅមូលដ្ឋាន ដែលរួមមានប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ ប្រធានភូមិ ចាស់ព្រឹទ្ធាចារ្យ និងមេដឹកនាំសាសនា ។

**ប្រជាជនកម្ពុជាជឿថាធាតុអាកាសកំពុងប្រែប្រួល** [១] ប៉ុន្តែរបកគំហើញបង្ហាញថា ការយល់ដឹងរបស់ ប្រជាជនអំពីអ្វីដែលបានបង្កឲ្យធាតុអាកាសប្រែប្រួលនៅមានភាពខ្វះខាត។

**អ្នកផ្តល់សម្ភាសន៍ស្ទើរ តែទាំងអស់ យ៉ាងហោចណាស់ស្គាល់ពាក្យមួយក្នុងចំណោមពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី"។** អ្នកផ្តល់សម្ភាសន៍ភាគច្រើនឆ្លើយថា ប្រព័ន្ធផ្សព្វផ្សាយ និងការនិយាយពីមាត់មួយទៅមាត់មួយ គឺជាប្រភពនៃការស្គាល់ពាក្យទាំងពីរនេះ។ ប៉ុន្តែ ពាក្យបច្ចេកទេសពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុហាក់ដូចជាមានការយល់ដឹងតិចតួច ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍។ អ្នកផ្តល់សម្ភាសន៍ភាគច្រើនផ្សារភ្ជាប់ពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី" ទៅនឹងការបាត់បង់ព្រៃឈើនៅមូលដ្ឋាន ជម្ងឺ និងកំណើនសីតុណ្ហភាព។

**អ្នកផ្តល់សម្ភាសន៍ភាគច្រើនផ្សាភ្ជាប់ការប្រែប្រួលធាតុអាកាស ដែលពួកគេបានជួបប្រទះ ទៅនឹងការបាត់បង់ព្រៃឈើនៅកម្ពុជា។** អ្នកផ្តល់សម្ភាសន៍ចំនួន ៦៧% នៅក្នុងការអង្កេតនេះ យល់ថាការបាត់បង់ព្រៃឈើនៅកម្ពុជាគឺជាមូលហេតុដែលធ្វើឲ្យធាតុអាកាសប្រែប្រួល ហើយបុគ្គលសំខាន់ៗទាំងអស់ផ្សារភ្ជាប់ការប្រែប្រួលអាកាសធាតុទៅនឹងការបាត់បង់ព្រៃឈើ។ ការបាត់បង់ព្រៃឈើជាកង្វល់មួយសម្រាប់បុគ្គលសំខាន់ៗ ដោយសារពួកគេយល់ឃើញថា ដើមឈើមានតួនាទីយ៉ាងសំខាន់ ក្នុងការនាំមកនូវទឹកភ្លៀង ការរក្សាទឹកក្រោមដី ការពារមនុស្ស និងទ្រព្យសម្បត្តិពីខ្យល់ព្យុះ និងទឹកជំនន់។

**ការយកចិត្តទុកដាក់លើផលប៉ះពាល់នៃការប្រែប្រួលធាតុអាកាស ខ្លាំងជាងការយកចិត្តទុកដាក់លើមូលហេតុដែលបង្កឲ្យមានការប្រែប្រួលនេះ។** ប្រជាជនកម្ពុជានិយាយថាធាតុអាកាស និងបរិស្ថានរបស់ពួកគេកំពុងប្រែប្រួល ហើយប្រជាជនមានអារម្មណ៍ថា កំពុងទទួលឥទ្ធិពលនេះ។ ពួកគេគិតថា បាតុភូតធាតុអាកាសធ្ងន់ធ្ងរ កើតឡើងញឹកញាប់ជាងមុន និងធ្ងន់ធ្ងរជាងសព្វដង ហើយសីតុណ្ហភាពក៏កើនឡើងផងដែរ។ ប្រជាជនភាគច្រើនផ្សាភ្ជាប់ការប្រែប្រួលធាតុអាកាសទៅនឹងជម្ងឺ ផលលំបាកក្នុងការដាំដំណាំ គ្រោះរាំងស្ងួត កំណើនសីតុណ្ហភាព ទិន្នផលថយចុះ និងកង្វះទឹក។ អ្នកផ្តល់សម្ភាសន៍ស្ទើរតែទាំងអស់និយាយថាការងាររបស់ពួកគេ រងឥទ្ធិពលពីការប្រែប្រួលធាតុអាកាស ហើយភាគច្រើននិយាយថាពួកគេខ្វះទឹកសម្រាប់ការងាររបស់ពួកគេ។

---

[១] របកគំហើញបង្ហាញថាអ្នកផ្តល់សម្ភាសន៍មួយចំនួនតូចយល់ពីមូលដ្ឋានវិទ្យាសាស្ត្រ នៃការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ ចម្លើយតបនឹងសំណួរមួយចំនួននៅក្នុងការអង្កេតនេះ បង្ហាញថាប្រជាជនបានសង្កេតឃើញធាតុអាកាសប្រែប្រួលជាធម្មតាទៅហើយ ហើយអ្នកផ្តល់សម្ភាសន៍នៅក្នុងការអង្កេតនេះបានពោលថា ធាតុអាកាសបានប្រែប្រួល។ លើសពីនេះពាក្យមួយនៅក្នុងភាសាខ្មែរ ដែលបកប្រែពាក្យ 'អាកាសធាតុ-climate' និង 'ធាតុអាកាស-weather' បានធ្វើឲ្យមានការលំបាកកំណត់ថាតើអ្នកផ្តល់សម្ភាសន៍សំដៅទៅរកពាក្យណាមួយ។ អាស្រ័យហេតុនេះនៅក្នុងរបាយការណ៍នេះយើងប្រើពាក្យ 'ធាតុអាកាស-weather' លើកលែងតែយើងដឹងច្បាស់ថាអ្នកឆ្លើយសំដៅទៅពាក្យ'អាកាសធាតុ-climate'។

**បុគ្គលសំខាន់ៗទាំងអស់និយាយថាពួកគេបានសង្កេតឃើញធាតុអាកាសមានការប្រែប្រួល ក្នុងការរស់នៅប្រចាំថ្ងៃរបស់ពួកគេ។** ការប្រែប្រួលទាំងនោះរួមមានរដូវកាលមិនសូវទៀងទាត់ ទឹកភ្លៀងធ្លាក់តិចជាងមុន សីតុណ្ហភាពក្តៅជាងមុន មានព្យុះច្រើនជាងមុន ទឹកជំនន់ ញឹកញាប់ និង ធ្ងន់ធ្ងរជាងមុន ហើយផ្គរនិងរន្ទះមានញឹកញាប់ជាងមុន។

**អ្នកផ្តល់សម្ភាសន៍ភាគច្រើនមានការយល់ដឹងអំពីបាតុភូតទាំងនេះ តាមរយៈបទពិសោធន៍ ប៉ុន្តែមិនដឹងពីមូលដ្ឋានវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុពិភពលោកទេ។** មានតែអ្នកផ្តល់សម្ភាសន៍មួយចំនួនតូចប៉ុណ្ណោះ ដែលផ្សារភ្ជាប់ការប្រែប្រួលធាតុអាកាស ទៅនឹងការបំពុលពីវិស័យឧស្សាហកម្ម ឬពីការប្រើប្រាស់យានយន្ត ហើយមតិយោបល់របស់បុគ្គលសំខាន់ៗបង្ហាញនូវការយល់ឃើញខុសមួយចំនួន អំពីកត្តាទាំងនេះ។ នៅពេលសួរបន្ថែម ៧២% នៃអ្នកផ្តល់សម្ភាសន៍ក្នុងការអង្កេតនេះឯកភាពថា សកម្មភាពមនុស្សកំពុងបង្កឲ្យមានការប្រែប្រួលធាតុអាកាសនៅជុំវិញពិភពលោក។ អ្នកផ្តល់សម្ភាសន៍មួយភាគបី(៣៣%) និយាយថាសកម្មភាពរបស់ពួកគេផ្ទាល់រួមចំណែកដល់ការប្រែប្រួលអាកាសធាតុ។

បុគ្គលសំខាន់ៗភាគច្រើន ផ្សារភ្ជាប់ការប្រែប្រួលអាកាសធាតុទៅនឹងការបំពុលនៅក្នុងមូលដ្ឋាន ដែលបណ្តាលពីរោងចក្រឧស្សាហកម្ម យានយន្ត គ្រឿងយន្ត ការប្រើប្រាស់សារធាតុគីមីជាពិសេសជីគីមី និងការបញ្ចេញផ្សែងពីរថយន្ត និងយានយន្តដទៃទៀត។ មានតែបុគ្គលសំខាន់ៗមួយចំនួនប៉ុណ្ណោះ ដែលភាគច្រើនជាមន្ត្រីរដ្ឋាភិបាលនៅថ្នាក់ជាតិ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល បង្ហាញពីចំណងទាក់ទងដោយផ្ទាល់រវាងមូលហេតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

**ប្រជាជនមិនប្រាកដថាតើការប្រែប្រួល ដែលពួកគេជួបប្រទះជារៀងរាល់ថ្ងៃនឹងមានឥទ្ធិពលរយៈពេលវែងឬយ៉ាងណាទេ។** ក្នុងចំណោមអ្នកដែលស្គាល់ពាក្យ "ការប្រែប្រួលអាកាសធាតុ" មាន៩៨% និយាយថាការប្រែប្រួលអាកាសធាតុកំពុងមានឥទ្ធិពលមកលើប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ន ហើយ៧៥% និយាយថាការប្រែប្រួលអាកាសធាតុនឹងមានឥទ្ធិពលមកលើកម្ពុជានៅពេលអនាគត។ ប៉ុន្តែ ២២% និយាយថាពួកគេមិនដឹងថាតើកម្ពុជានឹងរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុនៅពេលអនាគត ឬយ៉ាងណាទេ។ ភាពមិនប្រាកដប្រជានេះអាចមានផលប៉ះពាល់ដល់យុទ្ធសាស្ត្រដោះស្រាយ ដែលប្រជាជនរៀបចំឡើងដើម្បីឆ្លើយតបនឹងឥទ្ធិពលនៃការប្រែប្រួលធាតុអាកាស មកលើជីវិត និងការរស់នៅរបស់ពួកគេ។

ទោះបីបុគ្គលសំខាន់ៗជាច្រើនព្រួយបារម្ភអំពីផលប៉ះពាល់ដែលអាចកើតមាន បណ្តាលមកពីការប្រែប្រួលអាកាសធាតុនៅកម្ពុជាក៏ដោយ ក៏អ្នកទាំងនោះភាគច្រើនគិតថាប្រទេសកម្ពុជានៅពុំទាន់រងផលប៉ះពាល់ធ្ងន់ធ្ងរដូចប្រទេសដទៃនោះទេ។ សូម្បីក្នុងចំណោមអ្នកដែលមានការយល់ដឹងតិចតួចអំពីការប្រែប្រួលអាកាសធាតុក៏ដោយ ក៏ពួកគេយល់ថា នៅពេលណាមួយប្រទេសកម្ពុជានឹងជួបប្រទះផលប៉ះពាល់ទាំងនេះ ដូចដែលប្រទេសដទៃបានជួបប្រទះរួចមកហើយ។

**អ្នកផ្តល់សម្ភាសន៍ជាច្រើននិយាយថាពួកគេពុំបានទទួលព័ត៌មានគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅឡើយទេ។** អ្នកផ្តល់សម្ភាសន៍មួយភាគបួននិយាយថា ពួកគេមិនដឹងថាត្រូវឆ្លើយតបនឹងការប្រែប្រួលធាតុអាកាសដោយរបៀបណានោះទេ។ ចំណែកឯការផ្តល់យោបល់សម្រាប់ការឆ្លើយតបវិញ គឺពួកគេផ្តោតលើវិធានការរយៈពេលខ្លី។ អ្នកផ្តល់សម្ភាសន៍ច្រើនជាងពាក់កណ្តាលយល់ថា ពួកគេមិនអាចឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាសបានទេ (៥៩%) ហើយពុំមានព័ត៌មានគ្រប់គ្រាន់ ដើម្បីការឆ្លើយតបទេ (៥២%)។ អ្នកផ្តល់សម្ភាសន៍កំណត់ឧបសគ្គសំខាន់បំផុតចំនួន ៣ នៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដែលរួមមានការខ្វះខាតប្រាក់ ខ្វះឧបករណ៍ និងខ្វះព័ត៌មាន។ ស្ត្រី ប្រជាជនរស់នៅជនបទ ប្រជាជនក្រីក្រ និងអ្នកដែលមានការសិក្សាតិចតួច និយាយថាពួកគេខ្វះព័ត៌មានច្រើនជាងអ្នកដទៃ ដើម្បីធ្វើការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ មតិយោបល់របស់ប្រធានភូមិ និងប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់បញ្ជាក់ឲ្យឃើញថាការខ្វះខាតព័ត៌មានគឺពិតប្រាកដមែន។

**ការផ្សព្វផ្សាយព័ត៌មាន ដែលពាក់ព័ន្ធ និងទាន់ពេលវេលា នឹងមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការធ្វើឲ្យប្រជាជនអាចឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស។** ប្រជាជនកម្ពុជាស្ទើរតែទាំងអស់ (៩៣%) បានជួបប្រទះបាតុភូតធាតុអាកាសកាសធ្ងន់ធ្ងរ យ៉ាងហោចណាស់មួយលើក ក្នុងមួយឆ្នាំមុនការអង្កេតនេះ ប៉ុន្តែមួយភាគបីនៃប្រជាជនទាំងនោះ មិនបានទទួលព័ត៌មានអំពីបាតុភូតនេះទេ។ ក្នុងចំណោមអ្នកដែលបានទទួលព័ត៌មាន ភាគច្រើនបានទទួលក្នុងពេលកំពុងមានបាតុភូត ឬនៅក្រោយពេលបាតុភូតកើតឡើង។

ក្នុងចំណោមប្រជាជនកម្ពុជា១០នាក់ លើសពី៨នាក់ គឺជាអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ហើយប្រព័ន្ធផ្សព្វផ្សាយជាសាធារណៈជាប្រភពព័ត៌មាន ដែលប្រជាជនទុកចិត្តជាងគេ។ ប្រជាជនភាគច្រើនមើលទូរទស្សន៍ និងស្តាប់វិទ្យុ ហើយប្រជាជនស្ទើរតែទាំងអស់មានទូរស័ព្ទដៃ។

បុគ្គលសំខាន់ៗនិយាយថា **ប្រព័ន្ធផ្សព្វផ្សាយមិនសូវយកចិត្តទុកដាក់ ចំពោះការប្រែប្រួលអាកាសធាតុទេ ហើយគេចាត់ទុកការប្រែប្រួលអាកាសធាតុគ្រាន់តែជាបញ្ហាបរិស្ថានមួយប៉ុណ្ណោះ។** គ្រប់តំណាងពីប្រព័ន្ធផ្សព្វផ្សាយបានឯកភាពថាយើងចាំបាច់ត្រូវធ្វើការលើប្រធានបទការប្រែប្រួលអាកាសធាតុ ដោយផ្តើមចេញពីទស្សនៈថ្មីៗខុសពីមុន ត្រូវផ្តល់ការបណ្តុះបណ្តាលដល់អ្នកសារព័ត៌មានអំពីប្រធានបទនេះ និងផ្តល់ការណែនាំអំពីរបៀបធ្វើការលើប្រធានបទនេះ។

**ប្រជាជនកម្ពុជាសង្ឃឹមលើរដ្ឋាភិបាល នាយករដ្ឋមន្ត្រី និងអង្គការមិនមែនរដ្ឋាភិបាល ជាអ្នកចេញមុខដោះស្រាយ ការប្រែប្រួលធាតុអាកាស។** ប៉ុន្តែភាពខ្វះការយល់ដឹងរបស់សាធារណជនអំពី បុគ្គល ឬអង្គការណាដែលកំពុងធ្វើការឆ្លើយតបទៅនឹងបញ្ហានេះ ឆ្លុះបញ្ចាំងឲ្យឃើញថាពួកគេមិនបានដឹងថាមានកម្មវិធីថ្នាក់ជាតិ និងមូលដ្ឋានណា ដែលធ្វើការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនោះទេ។ មតិយោបល់ពីបុគ្គលសំខាន់ៗបង្ហាញថា អ្នកដែលស័ក្តិសមបំផុតក្នុងការផ្តល់ព័ត៌មានដល់សហគមន៍អំពីបញ្ហានេះ មានដូចជាប្រធានភូមិ ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ និងបុគ្គលសាសនា ក៏នៅមិនទាន់ទទួលបានព័ត៌មានឲ្យបានគ្រប់គ្រាន់អំពីបញ្ហានេះ ដូចមន្ត្រីរដ្ឋាភិបាលនៅថ្នាក់ជាតិនោះទេ។ អភិបាលខេត្តអាចដើរតួនាទីសំខាន់ពីព្រោះថាក្នុងចំណោមបុគ្គលសំខាន់ៗទាំងអស់ដែលបានផ្តល់សម្ភាសន៍ អភិបាលខេត្តបង្ហាញពីទំនាក់ទំនងខុសៗគ្នាច្រើនជាងគេ រវាងការប្រែប្រួលអាកាសធាតុជាមួយបញ្ហាផ្សេងទៀតក្នុងសង្គម។

**ដូច្នេះ ប្រជាជនកម្ពុជាជាច្រើនសម្រេចចិត្តអំពីរបៀបឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយពុំបានទទួលព័ត៌មាន ឬការគាំទ្រពីប្រភពណាមួយ ក្រៅពីសហគមន៍របស់ពួកគេផ្ទាល់នោះទេ។** ភាពស្របស្រួលគ្នាល្អ រវាងការធ្វើផែនការគម្រោងប្រែប្រួលអាកាសធាតុ និងការផ្តល់ព័ត៌មាន ពីរដ្ឋាភិបាលថ្នាក់ជាតិទៅដល់ថ្នាក់ភូមិ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋ ដែលបច្ចុប្បន្ននេះកំពុងមានផលលំបាកក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

# សាវតានៃការស្រាវជ្រាវ

ការប្រែប្រួលអាកាសធាតុស្ថិតក្នុងចំណោមកិច្ចការសំខាន់ៗបំផុត នៅក្នុងរបៀបវារៈនយោបាយ និងសេដ្ឋកិច្ចពិភពលោក។ ប្រជាជនក្រីក្របំផុត គឺជាអ្នកងាយរងគ្រោះជាងគេពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ ដោយសារកត្តាសេដ្ឋកិច្ច រូបវន្ត និងសង្គម។ ការឆ្លើយតបរបស់ពួកគេទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានរារាំងដោយការខ្វះព័ត៌មានដែលការពាក់ព័ន្ធ និងមានអត្ថប្រយោជន៍ ហើយជារឿយៗពួកគេពុំមានសម្លេង ក្នុងការជជែកវែកញែកអំពីការប្រែប្រួលអាកាសធាតុនៅឆាកអន្តរជាតិឡើយ។

នៅក្នុងបរិបទនេះ ក្រោមការគាំទ្រពីអង្គការ Oxfam Danida និង UNDP នាយកដ្ឋានប្រែប្រួលអាកាសធាតុកម្ពុជារបស់ក្រសួងបរិស្ថាន បានជ្រើសរើសក្រុមសិក្សា និងស្រាវជ្រាវ នៃអង្គការ BBC World Service Trust ឲ្យធ្វើការសិក្សាមួយនៅទូទាំងប្រទេស ដើម្បីស្វែងយល់ពីចំណេះដឹង ឥរិយាបថ និងការអនុវត្ត ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ការសិក្សានេះមានគោលបំណង:

១. ស្វែងយល់អំពីចំណេះដឹង និងការយល់ឃើញរបស់ប្រជាជនកម្ពុជាអំពីការប្រែប្រួលអាកាសធាតុ។
២. កំណត់វិធីសាស្ត្រផ្សេងៗ ដែលប្រជាជនកម្ពុជាប្រើប្រាស់ ដើម្បីពន្យល់ពីមូលហេតុនៃការប្រែប្រួលធាតុអាកាស និងផលប៉ះពាល់ពីការប្រែប្រួលទាំងនោះមកលើការរស់នៅរបស់ពួកគេ។
៣. ស៊ើបអង្កេតអំពីឧបសគ្គនានា ដែលរារាំងដល់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ របស់បុគ្គល និងសហគមន៍ និងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ថ្នាក់ខេត្តនិងថ្នាក់ជាតិ។
៤. វាយតម្លៃអំពីលំនាំ និងចំណង់ចំណូលចិត្តរបស់អ្នកផ្តល់សម្ភាសន៍ ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ។
៥. ផ្តល់អនុសាសន៍អំពីវិធីល្អៗ សម្រាប់ប្រាស្រ័យទាក់ទងជាមួយសាធារណជនកម្ពុជា អំពីការប្រែប្រួលអាកាសធាតុ

ការសិក្សានេះបានប្រមូលផ្តុំ និងចងក្រងបទពិសោធន៍នៅទូទាំងប្រទេស ដែលទាក់ទងនឹងការយល់ឃើញរបស់ប្រជាជន អំពីការប្រែប្រួលអាកាសធាតុ បរិស្ថាន និងធនធានធម្មជាតិ។ របាយការណ៍នេះប្រើប្រាស់របកគំហើញទាំងនេះ ដើម្បីផ្តល់អនុសាសន៍ សម្រាប់ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ហើយនិងធ្វើឲ្យអ្នកបង្កើតគោលនយោបាយ និងសាធារណជនទូទៅចូលរួម ក្នុងកិច្ចសន្ទនា និងសកម្មភាពដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់មូលដ្ឋានថ្នាក់ជាតិ និងអន្តរជាតិ។

# ការយល់ឃើញ និងការទទួលបានព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ ៖ តើយើងបានដឹងអ្វីខ្លះហើយ?

ដើម្បីប្រាស្រ័យទាក់ទងស្តីពីការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព គេត្រូវដឹងថាតើប្រជាជនយល់ដឹងបែបណាអំពីការប្រែប្រួលអាកាសធាតុ និងត្រូវស្វែងយល់ពីមធ្យោបាយរបស់ពួកគេក្នុងការទទួលព័ត៌មានទាក់ទងនឹងប្រធានបទនេះ។

ការស្រាវជ្រាវនៅសហរដ្ឋអាមេរិកបានបង្ហាញថាការយល់ដឹងមានកម្រិត អំពីការប្រែប្រួលអាកាសធាតុ អាចជាឧបសគ្គសម្រាប់ប្រជាជន ក្នុងការបែងចែករវាងយុទ្ធសាស្ត្រឆ្លើយតបដែលមានប្រសិទ្ធភាព និងយុទ្ធសាស្ត្រដែលគ្មានប្រសិទ្ធភាព។[២] ដូចគ្នានេះដែរ កង្វះព័ត៌មានសមស្របអំពីការប្រែប្រួលអាកាសធាតុ ត្រូវបានមើលឃើញថាជាឧបសគ្គចម្បង ក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើជីវភាពរបស់ប្រជាជន នៅទ្វីបអាហ្វ្រិកខាងត្បូងវាលខ្សាច់សាហារ៉ា។[៣,៤] ទោះបីជាយ៉ាងណាក៏ដោយ ការយល់ដឹងរបស់សាធារណជនអំពីការប្រែប្រួលអាកាសធាតុនៅតែជាប្រធានបទមួយថ្មី សម្រាប់ការស្រាវជ្រាវ ហើយកត្តាមួយចំនួនបានរារាំងដល់ការយល់ដឹងនេះ។ កម្ពុជាក៏ជួបបញ្ហានេះដែរ។

ជាបឋមមានការសិក្សាស្រាវជ្រាវតិចតួចប៉ុណ្ណោះ ដែលបានសិក្សាពាក់ព័ន្ធនឹងការស្វែងយល់ នូវការយល់ដឹងរបស់ប្រជាជនអំពីពាក្យការប្រែប្រួលអាកាសធាតុ។ ការស្រាវជ្រាវក្នុងប្រទេសច្រើនជាង១០នៅទ្វីបអាហ្វ្រិកបានរកឃើញថា ប្រជាជនយ៉ាងច្រើន

### កង្វះបច្ចេកស័ព្ទ

ការស្រាវជ្រាវថ្មីៗជាច្រើន ស្តីអំពីការយល់ដឹងរបស់សាធារណជន លើការប្រែប្រួលអាកាសធាតុនៅកម្ពុជា នៅមានកម្រិត ដោយសារគម្លាតរវាងការយល់ដឹង ពីពាក្យបច្ចេកទេស របស់ការប្រែប្រួលអាកាសធាតុ ក្នុងចំណោមសាធារណជនជាមួយនឹងអ្នកជំនាញបច្ចេកទេសដែលជាអ្នកស្រាវជ្រាវ និងមន្ត្រីរដ្ឋាភិបាល។

ការស្រាវជ្រាវ ដែលបានអនុវត្តកន្លងមកពុំទាន់គ្រប់គ្រាន់នៅឡើយទេ ដើម្បីស្វែងយល់អំពីវិធីដែលប្រជាជនយល់ដឹងពីពាក្យការប្រែប្រួលអាកាសធាតុ ដែលនាំឲ្យមានការបកស្រាយខុសនូវទិន្នន័យពីការស្រាវជ្រាវ។

ជាញឹកញាប់ការស្រាវជ្រាវមិនបានគិតគូរ អំពីប្រការ ដែលថាការឆ្លើយតប របស់អ្នកឆ្លើយសំណួរ អាស្រ័យលើការបកស្រាយ របស់ពួកគាត់អំពី "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី" ហើយការយល់ដឹង អំពីវាក្យស័ព្ទទាំងនេះ មានភាពខុសគ្នាយ៉ាងខ្លាំង រវាងមន្ត្រីរដ្ឋាភិបាល និងកសិករទូទៅ។

---

[២] ការប្រែប្រួលអាកាសធាតុ ក្នុងគំនិតរបស់ប្រជាពលរដ្ឋអាមេរិច A Leiserowitz et al, មជ្ឈមណ្ឌល សម្រាប់ទំនាក់ទំនងការប្រែប្រួលអាកាសធាតុ នៃសាកលវិទ្យាល័យ George Mason ឆ្នាំ ២០០៩

[៣] ការវិភាគទ្រង់ទ្រាយតូច នៃការបន្សាំរបស់កសិករទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងអាហ្វ្រិកខាងត្បូង Nhemachena, C., និង R. Hassan, IFPRI ឯកសារពិភាក្សា លេខ ៧១៤ ទីក្រុង Washington, DC: វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិឆ្នាំ ២០០៧

[៤] ទស្សនទាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្នុងទ្វីបអាហ្វ្រិក David J Maddison ឯកសារពិភាក្សាស្រាវជ្រាវគោលនយោបាយរបស់ធនាគារពិភពលោក លេខ ៤០៣៨ ឆ្នាំ២០០៧

មិនស្គាល់ពាក្យ "ការប្រែប្រួលអាកាសធាតុ" នោះទេ។[៥,៦] ប្រការនេះធ្វើឲ្យមានការលំបាកក្នុងការធ្វើសេក្តីសន្និដ្ឋាន ដោយផ្អែកតែលើយោបល់នៅលើឆាកអន្តរជាតិ និងនៅថ្នាក់ជាតិអំពីបញ្ហានេះ។

នៅប្រទេសកម្ពុជាកង្វះភាពច្បាស់លាស់ អំពីការយល់ដឹងរបស់សាធារណជន ក្នុងការប្រើប្រាស់ពាក្យដូចជា "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី" ធ្វើឲ្យពិបាកបកស្រាយរបកគំហើញជាច្រើន នូវការយល់ដឹងជាសាធារណៈ អំពីការប្រែប្រួលអាកាសធាតុ។ លើសពីនេះ មកទល់បច្ចុប្បន្ន ប្រទេសកម្ពុជាពុំទាន់មានវិធីសាស្ត្រថ្នាក់ជាតិ សម្រាប់សិក្សាចំណោតនេះនៅឡើយទេ។[៧] ទោះបីការស្រាវជ្រាវលើការយល់ឃើញ របស់ប្រជាជនអំពីការប្រែប្រួលអាកាសធាតុត្រូវអនុវត្តនៅកម្ពុជាក៏ដោយ វាគ្រាន់តែជាទម្រង់ នៃការសិក្សាខ្នាតតូច ដែលភាគច្រើនមានភាពលម្អៀង ដោយសារតែការជ្រើសរើសសំណាកនៅតែទីក្រុង។

ទោះជាយ៉ាងណាក៏ដោយ យើងអាចធ្វើការសន្និដ្ឋាន ដែលមានប្រយោជន៍ខ្លះៗពីការស្រាវជ្រាវ ដែលមានស្រាប់។ ដើម្បីគាំទ្រ ដល់ការបង្កើតកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា(NAPA) [៨] ការអង្កេតលើ អ្នកចូលរួមចំនួន ៦៨៤ គ្រួសារ នៅក្នុងខេត្តចំនួន ១៧ ត្រូវបានធ្វើឡើង។ ការស្រាវជ្រាវនោះបានរកឃើញថា ទោះបីប្រជាជនដឹងយ៉ាងច្បាស់អំពីគ្រោះថ្នាក់ ដែលបង្កដោយគ្រោះរាំងស្ងួតទឹកជំនន់ និងការខ្វះខាតទឹកក៏ដោយ ក៏សមត្ថភាពរបស់ពួកគេក្នុងការបន្សាំនៅមានកម្រិតកំណត់នៅឡើយ ដោយសារកង្វះមូលធនសង្គម និងធនធានហិរញ្ញវត្ថុ។ ការសិក្សានោះបង្ហាញថាវិធីបន្សាំមួយចំនួនតូច ដែលប្រជាជនកំពុងប្រើប្រាស់បច្ចុប្បន្ននេះពុំគ្រប់គ្រាន់ សម្រាប់ពុះពារនឹងការប្រឈម ដែលបង្កដោយការប្រែប្រួលអាកាសធាតុឡើយ។ កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុចែងថា "ប្រជាជនប្រហែលជាស៊ាំនឹងស្ថានភាព ដែលមានការបាត់បង់ជីវិត ខូចខាតទ្រព្យសម្បត្តិ និងដំណាំកសិកម្មជារៀងរាល់ឆ្នាំ ប៉ុន្តែភាពស៊ាំបែបនេះមិនមែនបញ្ជាក់ថាជាការបន្សាំដោយជោគជ័យនោះឡើយ"។

របកគំហើញពីការសិក្សាមួយចំនួន[៩,១០] បង្ហាញពីកម្រិតទាបជាទូទៅ នៃការយល់ដឹងអំពីមូលហេតុ និងផលប៉ះពាល់ជាក់លាក់ នៃការប្រែប្រួលអាកាសធាតុ។ ការសិក្សាទាំងនោះបង្ហាញថាប្រជាជនកម្ពុជាយល់ពាក្យ "ការប្រែប្រួលអាកាសធាតុ"[១១] នៅក្នុងបរិបទ នៃការប្រែប្រួលធាតុអាកាស នៅមូលដ្ឋានជាងការប្រែប្រួលអាកាសធាតុលើពិភពលោក និងបង្ហាញពីការជាប់ទាក់ទង នៃការប្រែប្រួលទាំងនោះទៅនឹងការបាត់បង់ព្រៃឈើនៅមូលដ្ឋាន។ របកគំហើញទាំងនេះមានឆ្លុះបញ្ចាំង

---

[៥] ការជជែកអំពីអាកាសធាតុ នៅទ្វីបអាហ្វ្រិក BBC World Trust 2010

[៦] ខ្យល់បក់ក្តៅ ឬត្រជាក់? ឥរិយាបទរបស់អាហ្វ្រិកខាងត្បូង ចំពោះការប្រែប្រួលអាកាសធាតុ J. Seager, 2008, ការពិនិត្យឡើងវិញរបស់ HSRC ទ្វីបអាហ្វ្រិក

[៧] ការសិក្សានោះចែងពិស្តារនៅក្នុង*កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ*ក្រសួងបរិស្ថានកម្ពុជាភ្នំពេញកម្ពុជា(២០០៦) ជាការស្រាវជ្រាវទូលំទូលាយបំផុតដែលបានអនុវត្តរហូតមកដល់ពេលនេះដោយបានអង្កេតប្រជាជនចំនួន៦៨៤គ្រួសារក្នុង១៧ខេត្ត។

[៨] កម្មវិធីសកម្មភាពបន្សាំជាតិ ចំពោះការប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថានកម្ពុជា ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ឆ្នាំ២០០៦

[៩] Ibid.

[១០] ទស្សនទានសាធារណជន ចំពោះការប្រែប្រួលអាកាសធាតុ ក្នុងប្រទេសកម្ពុជា ជំនួយវិហារដាណឺម៉ាក និងវិហារគ្រីះ កម្ពុជា ឆ្នាំ២០០៩

[១១] ទោះបីពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "កំណើនកម្តៅពិភពលោក" ត្រូវបានដាក់ក្នុងអភន្តរសញ្ញាក៏ដោយ វាបង្ហាញពីសេចក្តីយោងទៅពាក្យខ្មែរ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី"។ សេចក្តីលម្អិតមានបង្ហាញជូននៅទំព័រទី២៣ នៃផ្នែកនេះស្តីពីការបកស្រាយពីការប្រែប្រួលអាកាសធាតុ។

នៅក្នុងការសិក្សាមួយធ្វើឡើងនៅចក្រភពអង់គ្លេសក្នុងឆ្នាំ២០០៤ [១២] និងដោយការសិក្សាមួយនៅឆ្នាំ២០១០ស្តីពីការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសចំនួន១០នៅទ្វីបអាហ្វ្រិក [១៣]។

ការស្រាវជ្រាវភាគច្រើននៅកម្ពុជាបង្ហាញថាប្រជាជនជឿថាធាតុអាកាសកំពុងប្រែប្រួលហើយការសិក្សាចំនួនពីរ [១៤], [១៥] រកឃើញថាប្រជាជនភាគច្រើនគិតថាពួកគេរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ការអង្កេត i-Trak ដោយ Indochina បានធ្វើការសំគាល់ពីចំណងទាក់ទងមួយដែលមានប្រជាប្រិយភាពរវាងពាក្យ "ការប្រែប្រួលអាកាសធាតុ" និងសុខភាព [១៦] ចំណែកការសិក្សាមួយផ្សេងទៀត [១៧] បង្ហាញពីកង្វល់ក្នុងចំណោមកសិករអំពីការប្រែប្រួលនៃរបបទឹកភ្លៀង ការថយចុះនៃកម្រិតភ្លៀងធ្លាក់ គ្រោះរាំងស្ងួត ការថយចុះទិន្នផលកសិកម្ម និងកង្វះទឹកសម្រាប់កសិកម្ម។

លទ្ធផលពីការអង្កេតខ្នាតតូចមួយ [១៨] ដែលធ្វើឡើងក្នុងចំណោមអ្នកទូរស័ព្ទចូលមក សំណេះសំណាល តាមវិទ្យុក្នុងកម្មវិធី *ការជជែកអំពីផែនដី* នៃមជ្ឈមណ្ឌលព័ត៌មានឯករាជ្យកម្ពុជា (CCIM) បង្ហាញថាយុវជនកម្ពុជា ដែលមានការសិក្សាកម្រិតឧត្តម មានចំណាប់អារម្មណ៍លើកិច្ចការនានា ដូចជាការកាប់ឈើល្មើសច្បាប់ និងការចោលសំណល់ និងចង់បានព័ត៌មានបន្ថែមទៀត អំពីបញ្ហាស្រដៀងគ្នានេះ។

កម្មវិធីនានា ដូចជាកម្មវិធីវិទ្យុសំណេះសំណាលតាមទូរស័ព្ទ នៃមជ្ឈមណ្ឌលព័ត៌មានឯករាជ្យកម្ពុជា បង្ហាញពីតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយលើការបង្កើនការយល់ដឹង និងផ្តល់ព័ត៌មាន អំពីការប្រែប្រួលអាកាសធាតុ។ ប៉ុន្តែការចេញផ្សាយថ្មីមួយ [១៩] បង្ហាញថាអ្នកសារព័ត៌មាន ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ប្រឈមនឹងការលំបាកមួយចំនួន ក្នុងការធ្វើសេចក្តីរាយការណ៍របស់ខ្លួន អំពីការប្រែប្រួលអាកាសធាតុ។

របាយការណ៍គូសបញ្ជាក់ពីកង្វះខាតការបណ្តុះបណ្តាល កង្វះការគាំទ្រពីនាយកនិពន្ធ កង្វះខាតក្នុងការទទួលបានព័ត៌មាន និងស្វែងរកជួបមនុស្ស ដែលត្រូវសម្ភាសន៍។ របាយការណ៍ ក៏បានបញ្ជាក់ថាការបង្កើតកម្មវិធី អំពីការប្រែប្រួលអាកាសធាតុត្រូវតែបញ្ជ្រាតចូលក្នុងវិស័យផ្សេងៗ ដែលអាចដោះស្រាយបញ្ហា នយោបាយសេដ្ឋកិច្ច និងមានការចាប់អារម្មណ៍ ពីប្រជាពលរដ្ឋ ដោយងាកចេញពីការបង្កើត កម្មវិធីបរិស្ថានសុទ្ធសាធ។ របាយការណ៍នេះបានសង្កត់ធ្ងន់ថាទោះបី

---

[១២] ការវាស់ស្ទង់ការយល់ដឹង នៃការប្រែប្រួលអាកាសធាតុ របាយការណ៍ដំណាក់កាលទី ១ របស់គម្រោង ESPACE៖ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់ចំណេះដឹងសហគមន៍ ក្នុង West Sussex នៃ West Sussex County ក្នុងចក្រភពអង់គ្លេស ឆ្នាំ២០០៥

[១៣] ការជជែកអំពីអាកាសធាតុ នៅទ្វីបអាហ្វ្រិក BBC World Trust 2010

[១៤] ការសង្កេតថ្នាក់ជាតិ៖ ទស្សនទាន នៃការប្រែប្រួលអាកាសធាតុ ក្នុងប្រទេសកម្ពុជា Elizabeth Smith និង Nop Polin, Geres ឆ្នាំ២០០៧។ អ្នកឆ្លើយសំណួរ ចំនួន ៩៧% ដែលធ្លាប់លឺពាក្យថា "ការប្រែប្រួលអាកាសធាតុ" ជឿជាក់ថាពួកអាចទទួលឥទ្ធិពល ហើយ ៦១% នៃអ្នកទាំងនេះ មានការព្រួយបារម្ភយ៉ាងខ្លាំង អំពីការប្រែប្រួលអាកាសធាតុ។

[១៥] សូមមើល កំដៅមានការកើនឡើង, ការសង្កេត I-TRAK ការស្រាវជ្រាវឥណ្ឌូចិន ឆ្នាំ២០១០: **http://www.indochinaresearch.com/i-trak/reports.php** ក្នុងប្រទេសកម្ពុជា មានប្រជាជនចំនួន ២០០ ក្នុងទីក្រុងភ្នំពេញ ត្រូវបានសង្កេត

[១៦] Ibid.

[១៧] ទស្សនទាន នៃការប្រែប្រួលអាកាសធាតុ ក្នុងប្រទេសកម្ពុជារបស់ Geres ខែធ្នូ ឆ្នាំ២០០៩ បានធ្វើឡើង ក្នុងខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង និងខេត្តស្វាយរៀង។

[១៨] សូមអានអនុសាសន៍របស់ប្រជាពលរដ្ឋ ស្តីពីការប្រែប្រួលអាកាសធាតុតាមរយៈការជជែកតាមវិទ្យុដោយមជ្ឈមណ្ឌលព័ត៌មានឯករាជ្យកម្ពុជា ឆ្នាំ២០០៩។

[១៩] ពេលត្រូវបន្សាំ? ការផ្សាយព័ត៌មាន អំពីការប្រែប្រួលអាកាសធាតុ ក្នុងប្រទេសមិនមែនឧស្សាហកម្ម ដោយ Mike Shanahan ឆ្នាំ២០០៩។

ព័ត៌មាន អំពីការប្រែប្រួលអាកាសធាតុមានផ្សាយកាន់តែច្រើនឡើង នៅក្នុងប្រទេសមិនមែនឧស្សាហកម្មក៏ដោយ ក៏បរិមាណ និងគុណភាព នៃសេចក្តីរាយការណ៍មិនស្របគ្នាជាមួយទំហំ នៃបញ្ហាឡើយ។

របាយការណ៍នេះ ក៏បានបង្ហាញ អំពីការពឹងផ្អែកលើរបាយការណ៍នានាមកពីភ្នាក់ងារសារព័ត៌មានលោក ខាងលិច ជាងសារព័ត៌មាន ដែលពាក់ព័ន្ធនៅតាមតំបន់ ក៏ដូចជាព័ត៌មាន ដែលមានចុះផ្សាយតិចតួច អំពីវិធានការណ៍បន្សាំ។ ក្នុងន័យ នេះ បង្ហាញថា អ្នកទទួលព័ត៌មាន ជាពិសេស នៅក្នុងប្រទេសក្រីក្រមិនបានទទួលសេវាគ្រប់គ្រាន់ឡើយ។ ចំណុចចុងក្រោយ របាយការណ៍បានបញ្ជាក់ផងដែរពីតួនាទីសំខាន់ប្រកបដោយសក្តានុពល នៃកម្មវិធីផ្សេងៗ ដែលមិនផ្តោតលើព័ត៌មាន (ដូច ជាកម្មវិធីជជែកកំសាន្ត ល្ខោន និងការប្រកាសផ្សាយសេវាសាធារណៈ) ដែលអាចដើរតួនាទី ក្នុងការផ្តល់ព័ត៌មាន ដល់ សាធារណជនអំពីការប្រែប្រួលអាកាសធាតុ។

ទោះជាយ៉ាងណាក៏ដោយ រាល់ការផ្តល់ព័ត៌មានត្រូវតែពិចារណាលើការយល់ដឹង របស់ប្រជាជន អំពីការប្រែប្រួល អាកាសធាតុ។ ជាអកុសលសហគមន៍អ្នកស្រាវជ្រាវមិនមានការឯកភាពគ្នាឡើយ អំពីអ្វីខ្លះជា "ចំណេះដឹង" អំពីការប្រែប្រួល អាកាសធាតុ។ ប្រសិនបើមាននរណាម្នាក់នៅកម្ពុជាធ្វើការកំណត់បានត្រឹមត្រូវអំពីផលប៉ះពាល់នានា ដែលអាចកើតចេញពី "ការប្រែប្រួលអាកាសធាតុ" (នៅពេលដែលពាក្យ "អាកាសធាតុ" និង "ធាតុអាកាស" ស្ទើរតែដូចគ្នាជាភាសាខ្មែរ) ប៉ុន្តែមិន យល់អំពីមូលហេតុ នៃការប្រែប្រួលអាកាសធាតុពិភពលោក តើយើងអាចនិយាយបានទេថាបុគ្គលនោះមាន "ការយល់ដឹង តាមរយៈបទពិសោធន៍" អំពីការប្រែប្រួលអាកាសធាតុ ឬគ្រាន់តែថាពួកគេបានដឹង ច្រើនត្រឹមតែលក្ខខ័ណ្ឌធាតុអាកាស?

នៅពេល ដែលការយល់ដឹង របស់ប្រជាពលរដ្ឋភាគច្រើន អំពីការប្រែប្រួលអាកាសធាតុ ផ្សារភ្ជាប់នឹងការប្រែប្រួល នានា ដែលពួកគេសំគាល់ឃើញនៅជុំវិញខ្លួន (ជាពិសេសការប្រែប្រួលនានា ដែលប៉ះពាល់ដល់ជីវភាព និងជីវិតរបស់ពួកគេ) ដូច្នេះសារ ដែលពួកគេទទួលបានអំពីការប្រែប្រួលអាកាសធាតុ ត្រូវតែឆ្លុះបញ្ចាំងអំពីអ្វី ដែលពួកគេធ្លាប់ជួបប្រទះ។



សកម្មភាពប្រជាជនដកសំណាប ប្រភព BBC World Service Trust 2010

# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រចម្រុះតាមបែបបរិមាណវិស័យ និងគុណវិស័យ។

## ការរៀបចំការស្រាវជ្រាវតាមបែបគុណវិស័យ

ការសម្ភាសបែបស៊ីជម្រៅត្រូវបានធ្វើឡើងជាលក្ខណៈបុគ្គលជាមួយមនុស្ស ១០១ រូប ដែលជាតំណាងមកពីប្រព័ន្ធផ្សព្វផ្សាយ ឧស្សាហកម្ម មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ខេត្ត អង្គការមិនមែនរដ្ឋាភិបាល បុគ្គល ដែលមានប្រជាប្រិយភាពអ្នកដឹកនាំនៅមូលដ្ឋាន ដែលរួមទាំងប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ ប្រធានភូមិ ព្រឹទ្ធាចារ្យ នៅក្នុងភូមិ និងមេដឹកនាំសាសនាផងដែរ។

ការសម្ភាសត្រូវបានរៀបចំជាអត្ថបទសរសេរឡើងវិញ ឲ្យដូចអ្វី ដែលអ្នកសម្ភាស និងអ្នកផ្តល់សម្ភាសន៍ បាននិយាយ។ អត្ថបទសរសេរឡើងវិញជាភាសាខ្មែរនេះត្រូវបានប្រែសម្រួលជាភាសាអង់គ្លេស ដើម្បីឲ្យក្រុមអ្នកស្រាវជ្រាវអន្តរជាតិអាចធ្វើការជាមួយគ្នាបាន។ អត្ថបទសរសេរឡើងវិញទាំងនេះត្រូវបានដាក់កូដ ដោយប្រើប្រាស់កម្មវិធី Atlas.ti អនុលោមទៅតាមគំរូកូដ ដែលបានបង្កើតឡើងដោយក្រុមអ្នកស្រាវជ្រាវរបស់ BBC World Service Trust តាមរយៈដំណើរការសហការគ្នាមួយ ដែលប្រើប្រាស់កូដជាលក្ខណៈបើកចំហ សម្រាប់ធ្វើការកំណត់កូដថ្មីៗ និងដើម្បីដាក់បន្ថែមលើកូដ ដែលមានស្រាប់នៅក្នុងតារាងលេខកូដ។ គំរូកូដនីមួយៗត្រូវបានកំណត់ជាក្របខ័ណ្ឌ នៃការវិភាគរួម សម្រាប់សមាជិកក្រុមទាំងអស់ ដែលចូលរួមក្នុងការដាក់កូដ។ ពិន្ទុអំពីកម្រិតទុកចិត្តបានរវាងអ្នកដាក់កូដនីមួយៗ ដែលក្រុមស្រាវជ្រាវទទួលបានគឺ ០,៧៤។ ពិន្ទុនេះបានមកពីការប្រៀបធៀបលទ្ធផលការងារ របស់អ្នកស្រាវជ្រាវម្នាក់ៗនៅក្នុងការដាក់កូដ និងក្នុងការគណនាចំនួនដងជាមធ្យម នៃកូដដូចគ្នា ឬកូដខុសគ្នា ដែលអ្នកស្រាវជ្រាវបានប្រើប្រាស់ នៅក្នុងផ្នែកជ្រើសរើសមួយចំនួននៃអត្ថបទ ដែលបានពីការសម្ភាស។

នៅពេល ដែលបានដាក់កូដទាំងអស់រួចហើយក្រុមអ្នកស្រាវជ្រាវអាចប្រើប្រាស់កម្មវិធី Atlas.ti សម្រាប់ធ្វើការកំណត់ថាតើ កូដនីមួយៗលេចឡើងបែបណា នៅក្នុងចំណោមអត្ថបទសរសេរឡើងវិញដូចអ្វី ដែលបាននិយាយនៅក្នុងការសម្ភាសទាំង ១០១។ កូដខ្លះបានលេចឡើងញឹកញាប់ជាងគេ ដែលបង្កើតជាទិន្នន័យយ៉ាងសំបូរបែប ដែលលេចចេញពីអត្ថបទសរសេរឡើងវិញនេះ។ ទិន្នន័យទាំងនេះផ្តល់ជាប្រធានបទចំបងៗ សម្រាប់ការវិភាគ។ កូដដទៃទៀត ដែលមិនសូវលេចឡើងញឹកញាប់មានន័យថា ចំនួននៃសេចក្តីដកស្រង់ចេញពីអត្ថបទសរសេរឡើងវិញខុសគ្នាមានតិចតួចជាង។ ការប្រមូលយកចំនួននៃសេចក្តីដកស្រង់ចេញពីអត្ថបទសរសេរឡើងវិញ អាចឲ្យក្រុមស្រាវជ្រាវកំណត់ និងពិពណ៌នាអំពីប្រធានបទសំខាន់ៗ សម្រាប់ជ្រើសរើស ដើម្បីបញ្ចូលក្នុងរបាយការណ៍។

## ការរៀបចំការស្រាវជ្រាវបែបបរិមាណវិស័យ

បញ្ជីសំណួរ ក្នុងការអង្កេតបែបបរិមាណវិស័យ នៅតាមគ្រួសារត្រូវបានប្រើប្រាស់ សម្រាប់ប្រមូលយកព័ត៌មានពីសាធារណជនចំនួន ២.៤០១ នាក់ ក្នុងខេត្ត/ក្រុងទាំង ២៤ នៃប្រទេសកម្ពុជា។

ក្រុមមនុស្សជាគោលដៅ ក្នុងការអង្កេតនេះគឺ បុរស និងស្ត្រីកម្ពុជា ដែលមានអាយុពី ១៥ ទៅ ៥៥ ឆ្នាំ ដែលរួមទាំងក្រុមមនុស្សងាយរងគ្រោះដោយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុផងដែរ។

អ្នកផ្តល់សម្ភាសន៍ត្រូវបានជ្រើសរើស តាមរយៈដំណើរការ នៃការកំណត់យកសំណាកជាច្រើនដំណាក់កាល តាមការជ្រើសដោយចៃដន្យ ដែលមានចែងពិស្តារ នៅក្នុងផ្នែកស្តីពីវិធីសាស្ត្រ ក្នុងឧបសម្ព័ន្ធ១។ កម្រិតល្អៀង សម្រាប់សំណាកនៃអ្នកផ្តល់សម្ភាសន៍ទាំង ២.៤០១ នាក់ គឺបូក ឬដក ២% ដោយមានកម្រិតទំនុកចិត្ត៩៥%។

ដោយសារសំណាកពីសហគមន៍តំបន់ឆ្នេរ និងសហគមន៍អ្នកនេសាទ ដែលរួមបញ្ចូល ក្នុងសំណាកដំបូងមានចំនួនតិច ចំនួនអ្នកផ្តល់សម្ភាសន៍ នៅក្នុងសំណាកនេះត្រូវបានបង្កើនឡើង ដើម្បីឲ្យមានចំនួនដល់ ៣៥ នាក់។ នេះជាការកំណត់យកសំណាក ដើម្បីបំពេញតាមគោលបំណង នៃការស្រាវជ្រាវជាងសំណាក ដែលបានពីការជ្រើសរើសដោយចៃដន្យ ហើយបើទោះជារបកគំហើញទាំងនេះត្រូវបានដាក់បញ្ចូល នៅក្នុងរបាយការណ៍ក៏ដោយ ការបញ្ចូលបែបនេះបានធ្វើឡើងដោយមានការកត់សម្គាល់ផងដែរថា ទិន្នន័យអំពីសហគមន៍អ្នកនេសាទទាំងពីរមិនអាចយកទៅប្រៀបធៀបដោយផ្ទាល់ ឬដាក់បញ្ចូលដោយផ្ទាល់ នៅក្នុងការវិភាគជាមួយរបកគំហើញ សម្រាប់សំណាកទាំងមូលបានឡើយ ហើយក៏មិនមែនជាសំណាកដែលតំណាងឲ្យស្ថានភាពរួមនៅក្នុងប្រទេសនោះដែរ។ អាស្រ័យហេតុនេះចំនួនសំណាកសរុបគឺ ២.៤០១ ហើយចំនួនអ្នកឆ្លើយក្នុងសំណាកបន្ថែមមិនមានរួមបញ្ចូលក្នុងតួលេខនេះទេ។ នៅក្នុងតារាងនៃឧបសម្ព័ន្ធនេះទិន្នន័យក្នុងសំណាកបន្ថែមត្រូវបានបញ្ជាក់ច្បាស់ដាច់ដោយឡែកពីតួលេខ នៃសំណាកទាំង ២.៤០១។ (ចំពោះតារាងទិន្នន័យទាំងស្រុងសូមអាន ក្នុងឧបសម្ព័ន្ធ ២) បច្ចេកទេសវិភាគ នៅក្នុងរបាយការណ៍នេះរួមមានការវិភាគស្ថិតិបែបពិពណ៌នា (ប្រេកង់) និងទ្វេរអថេរ (t-tests, z-tests, និង chi-square) សម្រាប់ពិពណ៌នា និងប្រៀបធៀបចំនួននៃរង្វាស់សំខាន់ៗ អំពីចំណេះដឹង ឥរិយាបថ និងការអនុវត្ត ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ Chi-square tests ត្រូវបានប្រើប្រាស់ ដើម្បីពិនិត្យកម្រិត នៃការពាក់ព័ន្ធនឹងអថេរ ដែលមិនមែនជាប៉ារ៉ាម៉ែត្រគោល។ Z-tests ត្រូវបានប្រើប្រាស់ ដើម្បីពិនិត្យមើលភាពខុសគ្នាសំខាន់ៗរវាងសមាមាត្រ នៃចម្លើយនៅក្នុងអនុក្រុមជាក់លាក់ នៃសំណាក។ T-tests ត្រូវបានប្រើប្រាស់ ដើម្បីរកមើលភាពខុសគ្នាសំខាន់ៗ នៃពិន្ទុមធ្យមរវាងអនុក្រុម នៅក្នុងសំណាកនៃការអង្កេតនេះ។

សំណាកនេះត្រូវបានវិភាគជាក្រុមដូចខាងក្រោមនេះ៖

- សំណាកសរុប
- តំបន់ភូមិសាស្ត្រសំខាន់ៗ
- កន្លែងស្នាក់នៅនានា (ទីក្រុង/ជនបទ)
- ភេទ (បុរសស្ត្រី)
- អាយុ (១៥-២៤ឆ្នាំ ២៥-៣៤ឆ្នាំ ៣៥-៤៤ឆ្នាំ ៤៥-៥៥ឆ្នាំ)
- កំរិតវប្បធម៌ៈមិនបានទទួលការអប់រំបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ និងបរិញ្ញាបត្រ
- រង្វាស់សន្ទស្សន៍នៃភាពក្រីក្រៈក្របំផុត ក្រ មធ្យម និង មាន[២០]
- មុខរបរៈ កសិករ ពាណិជ្ជករ អ្នកផ្តល់សេវាផ្សេងៗ កម្មករមានជំនាញ មេផ្ទះ គ្រូបង្រៀន និស្សិត សិស្ស អ្នកគ្រប់គ្រងបច្ចេកទេសវិជ្ជាជីវៈ មន្ត្រីរាជការ កម្មករក្នុងវិស័យព្រៃឈើ អ្នកនេសាទតាមមាត់សមុទ្រ និង អ្នកនេសាទតាមទឹកសាប។

ចំពោះសេចក្តីពិស្តារអំពីវិធីសាស្ត្រស្រាវជ្រាវសូមអានឧបសម្ព័ន្ធ១។

[២០] សូមអានសេចក្តីពិស្តារអំពីរង្វាស់សន្ទស្សន៍នៃភាពក្រីក្រនៅក្នុង*របាយការណ៍ប្រជាសាស្ត្រសង្គមនៃសំណាកក្នុងការអង្កេតនេះ*។

## ស្ថានភាពប្រជាសាស្ត្រសង្គម នៃសំណាក ក្នុងការអង្កេត

មុនមានការបន្ថែមសំណាក ការសម្ភាសបានធ្វើឡើងតែជាមួយមនុស្ស ២.៤០១ នាក់ ប៉ុណ្ណោះ ក្នុងខេត្តទាំង ២៤ នៃប្រទេសកម្ពុជា។

៦៦% នៃអ្នកផ្តល់សម្ភាសន៍ទាំងអស់គឺជាអ្នករស់នៅទីជនបទ ហើយបុរស និងស្ត្រីមានសមាមាត្រស្មើគ្នា នៅក្នុងសំណាក។

១១% នៃអ្នកផ្តល់សម្ភាសន៍ ក្នុងសំណាកមិនបានចូលរៀនឡើយ ៤១% ធ្លាប់រៀននៅថ្នាក់បឋមសិក្សា ២៨% ធ្លាប់បានរៀននៅថ្នាក់មធ្យមសិក្សាបឋមភូមិ ១៦% បានរៀននៅថ្នាក់មធ្យមសិក្សាទុតិយភូមិ និង ៤% មានការសិក្សាថ្នាក់មហាវិទ្យាល័យ។

ដើម្បីវាយតម្លៃអំពីជីវភាព របស់អ្នកផ្តល់សម្ភាសន៍ណាម្នាក់ថារស់នៅក្រោម ឬលើខ្សែបន្ទាត់ នៃភាពក្រីក្រ សំណួរអំពីរង្វាស់សន្ទស្សន៍ នៃភាពក្រីក្រ (PPI) ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីសំណួរ។ បន្ទាប់ពីទទួលបានការឆ្លើយតបពីអ្នកសម្ភាសន៍ និងបានដាក់ចំណាត់ថ្នាក់ សំណាកទាំងអស់ត្រូវបានចែកជាបួនក្រុមខុសគ្នាទៅតាមសន្ទស្សន៍ នៃភាពក្រីក្រ (PPI) ពោលគឺក្របំផុត (ភាគច្រើនស្ថិតនៅក្រោមខ្សែបន្ទាត់ នៃភាពក្រីក្រ) ក្រុមធ្យម និងមាន។[២១]

មានអ្នកផ្តល់សម្ភាសន៍ ចំនួន ១១% ស្ថិតនៅក្នុងក្រុម "ក្របំផុត" ៣៩% ស្ថិតនៅក្នុងក្រុម "ក្រ" ៤០% នៅក្រុម "មធ្យម" និង ១០% ស្ថិតនៅក្នុងក្រុម "មាន"។

- ២១% នៃសំណាកសរុបត្រូវបានចាត់ទុកថាជាយុវជនមានការងារធ្វើ។
- ៨៨% នៃសំណាកសរុបមានដីជាកម្មសិទ្ធិផ្ទាល់ខ្លួន។

  សមាមាត្រ នៃអ្នកឆ្លើយនៅក្នុងក្រុមមុខរបរខុសៗគ្នាមានដូចតទៅ:
- កសិករ ៤៦%
- ពាណិជ្ជករ ១៦%
- អ្នកផ្តល់សេវាផ្សេងទៀត ៤%
- កម្មករមានជំនាញ ៤%
- មេផ្ទះ ៦%
- គ្រូបង្រៀន ២%
- និស្សិត ២%
- សិស្ស ១០%
- អ្នកគ្រប់គ្រងបច្ចេកទេសវិជ្ជាជីវៈ ៤%
- មន្ត្រីរាជការ ៤%
- កម្មករ ក្នុងវិស័យព្រៃឈើតិចជាង ១%
- សហគមន៍អ្នកនេសាទមានតិចជាង ១% នៃសំណាកដំបូង។ នៅក្នុងសំណាកបន្ថែមទាំងពីរលើកមានសហគមន៍អ្នកនេសាទទឹកសាប និងសមុទ្រច្រើនជាង១% នៃចំនួនមនុស្ស ដែលបានសម្ភាសន៍សរុប។

---

[២១] ចំពោះព័ត៌មានបន្ថែមអំពីការរីកចម្រើន នៃសន្ទស្សន៍ភាពក្រីក្រសូមអាន http://progressoutofpoverty.org/

# ដែនកំណត់ និងបទពិសោធន៍នៃការសិក្សា

## ភាពលម្អៀងទៅរកអ្វី ដែលសង្គមចង់បាន

ភាពលម្អៀងទៅរកអ្វី ដែលសង្គមចង់បានសំដៅលើនិន្នាការ នៃអ្នកឆ្លើយតប ក្នុងការផ្តល់ចម្លើយ ដែលស្របទៅនឹងទស្សនៈ របស់អ្នកដទៃ។ ភាពលម្អៀងបែបនេះកើតឡើង នៅពេលអ្នកឆ្លើយតបបានផ្តល់ចម្លើយមិនពិត ប៉ុន្តែត្រូវបានយល់ថាមានលក្ខណៈត្រឹមត្រូវ ឬ អាចទទួលយកបានពីសង្គម។

វិធីសាស្ត្រស្រាវជ្រាវបានប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីទប់ស្កាត់ភាពលម្អៀង នៅក្នុងចម្លើយ កាត់បន្ថយភាពអាម៉ាស់ និងធានារក្សាការសម្ងាត់។ ក្នុងក្រុមស្រាវជ្រាវបុរសសម្ភាសបុរស ហើយស្ត្រីសម្ភាសស្ត្រី។ អ្នកធ្វើសម្ភាស និងសមាជិកទាំងអស់ នៅក្នុងក្រុមការងារបានទទួលការបណ្តុះបណ្តាល អំពីក្រមសីលធម៌ ដែលរួមទាំងរក្សាការសម្ងាត់ និងអនាមិក។ អ្នកផ្តល់សម្ភាសន៍ទាំងអស់ត្រូវបានប្រាប់ឲ្យដឹងអំពីការសិក្សានេះ និងបានស្នើសុំការយល់ព្រមជាមុន ដើម្បីចូលរួមក្នុងការអង្កេតនេះ។ អ្នកផ្តល់សម្ភាសន៍អាចរំលងសំណួរនានា ក្នុងការសិក្សានេះបាន ឬក៏អាចដកខ្លួនចេញពីការសិក្សានេះគ្រប់ពេលទាំងអស់។ រាល់អត្ថបទសរសេរឡើងវិញទាំងអស់ និងបញ្ជីសំណួរត្រូវបានរក្សាទុកយ៉ាងមានសុវត្ថិភាព នៅក្នុងកុំព្យូទ័រមួយក្នុងអំឡុងពេលនៃការប្រមូល ការកែសម្រួល និងការវិភាគទិន្នន័យ។ មានតែអ្នកទទួលខុសត្រូវលើការកែសម្រួល និងវិភាគទិន្នន័យប៉ុណ្ណោះដែលអាចបើកមើលឯកសារទាំងនេះ ដែលមានកំណត់សម្គាល់ជាកូដតែមិនមានជាឈ្មោះឡើយ។

## ភាពលម្អៀង ដោយសារការមិនជំទាស់

ភាពលម្អៀង ដោយសារការមិនជំទាស់សំដៅលើនិន្នាការ របស់អ្នកផ្តល់សម្ភាសន៍ ក្នុងការសម្តែងអាកប្បកិរិយាដែលមានភាពចុះសម្រុងដោយឆ្លើយស្របទៅនឹងសំណួរនានា បើទោះជាខ្លួនឯកភាព ឬមិនឯកភាពក៏ដោយ។ ឧទាហរណ៍នៅក្នុងសំណួរខ្លះ អ្នកស្រាវជ្រាវស្នើឲ្យអ្នកផ្តល់សម្ភាសន៍ចាត់ជាចំណាត់ថ្នាក់ នូវបញ្ហាសំខាន់ៗ ដែលនាំឲ្យចម្លើយអាចមានភាពលម្អៀង ដោយសារការមិនជំទាស់។ ក្នុងន័យនេះបញ្ជីសំណួរត្រូវបានរៀបចំឡើងដោយមានសំណួរមិនដេញ និងមានសំណួរដេញ។ ទោះបីការមិនសួរដេញជាបន្តអាចមានប្រយោជន៍ក៏ដោយ នៅក្នុងករណីនេះអ្នកស្រាវជ្រាវអាចមិនទទួលបានព័ត៌មានខ្លះ ដែលអ្នកឆ្លើយមិនចងចាំនោះឡើយ។ អាស្រ័យហេតុនេះមានសំណួរមួយចំនួនត្រូវសួរឡើងវិញ តាមរយៈបញ្ជីសំណួរ ដែលទាមទារឲ្យមានការសួរដេញបន្ត។

## ដែនកំណត់ រវាងទិន្នន័យគុណវិស័យ និងទិន្នន័យបរិមាណវិស័យ

ការស្រាវជ្រាវផ្នែកគុណវិស័យត្រូវបានរៀបរៀងឡើង ដើម្បីស្វែងយល់ នូវទស្សនៈរបស់បុគ្គលសំខាន់ៗ ដែលនៅទូទាំងសង្គមកម្ពុជា។ ទំហំសំណាក (n=101) ស្រង់យកយោបល់ទូលំទូលាយនានា ក្នុងចំណោមបុគ្គលសំខាន់ៗ។

ដោយហេតុថាការស្រាវជ្រាវផ្នែកគុណវិស័យមិនបានធ្វើឡើង ក្នុងចំណោមសាធារណជន ហើយការអង្កេតបែបបរិមាណវិស័យមិនបានប្រើប្រាស់ ក្នុងចំណោមបុគ្គលសំខាន់ៗ ដូចនេះវាមិនអាចធ្វើទៅបាន ក្នុងការប្រៀបធៀបទស្សនៈ របស់សាធារណជន និងទស្សនៈរបស់បុគ្គលសំខាន់ៗអោយស៊ីសង្វាក់គ្នា។

## ដែនកំណត់ នៃសំណាកនៅក្នុងការអង្កេត

### ទីជនបទដាច់ស្រយាល

ភូមិនានា ដែលត្រូវធ្វើដំណើរលើសពីមួយថ្ងៃពីទីប្រជុំជនសំខាន់ៗ នៅក្នុងខេត្ត ឬភូមិ ដែលមានតិចជាង ២៥ គ្រួសារមិនបានរាប់បញ្ចូល នៅក្នុងការសិក្សានេះទេ ដោយសារការលំបាកផ្នែកភស្តុភារ និងការចំណាយ។ ភូមិផ្សេងទៀតត្រូវបានជំនួសដោយប្រើវិធីជ្រើសចៃដន្យ។

### អ្នកឆ្លើយ ដែលអាចផ្តល់សម្ភាស

ការសិក្សានេះរួមបញ្ចូលតែបុគ្គល ដែលមានវត្តមាននៅក្នុងគ្រួសារនាថ្ងៃអង្កេតនោះប៉ុណ្ណោះ។ ការសិក្សានេះមិនបានរាប់បញ្ចូលអ្នក ដែលធ្វើការនៅឆ្ងាយពីផ្ទះ (ពលករចំណាកស្រុក) ឬអ្នកគ្មានផ្ទះសំបែងផ្ទាល់ខ្លួនទេ ហើយរស់នៅតាមគ្រឹះស្ថាននានា ដូចជាវត្តអារាម រោងចក្រកាត់ដេរ សាលារៀន និងសាកលវិទ្យាល័យឡើយ។ អ្នកដទៃទៀតមកពីគ្រឹះស្ថានផ្សេងៗ ដូចជាពន្ធនាគារ មន្ទីរពេទ្យ ឬយោធាក៏មិនរាប់បញ្ចូលផងដែរ។ អ្នក ដែលគ្មានអាស័យដ្ឋានពិតប្រាកដ (ជនអនាថា ឬគ្មានផ្ទះសំបែង) ក៏មិនបានរាប់បញ្ចូលនៅក្នុងការអង្កេតនេះទេ។

### អ្នកនិយាយភាសាខ្មែរ

ការសិក្សានេះបានធ្វើឡើងជាភាសាខ្មែរ ដូច្នេះមិនបានរួមបញ្ចូលអ្នកមិនអាចនិយាយភាសាខ្មែរនោះឡើយ។

### ក្រុមគោលដៅ និងសំណាកបន្ថែម

នៅក្នុងតួលេខ នៃសំណាកដំបូង ដែលមានអ្នក ផ្តល់សម្ភាសន៍ចំនួន ២.៤០១ ពុំមានចំនួនគ្រប់គ្រាន់ នៃអ្នកផ្តល់សម្ភាសន៍ពីក្នុងចំណោមសហគមន៍អ្នកនេសាទទឹកសាប និងសមុទ្រឡើយ (<៣៥)។ អាស្រ័យហេតុនេះការជ្រើសសំណាក "បន្ថែម" សម្រាប់បំពេញបំណងត្រូវបានធ្វើឡើង ក្នុងចំណោមសហគមន៍អ្នកនេសាទទឹកសាប និងសមុទ្រ ដើម្បីបំពេញបន្ថែមក្នុងចំនួនក្រុមសំណាក ដែលពុំមានទំហំគ្រប់គ្រាន់ សម្រាប់វិភាគ។

គួរកត់សម្គាល់ផងដែរថា សំណាក "បន្ថែម" មិនអាចចាត់ទុកថាតំណាងទូទាំង ប្រទេសបានទេ ដោយសារអ្នកផ្តល់សម្ភាសន៍ត្រូវបានជ្រើសរើស ក្នុងបំណង នៃការបំពេញបន្ថែមប៉ុណ្ណោះ។ ក្នុងន័យនេះសំណាក "បន្ថែម" ត្រូវបានបញ្ចូលក្នុងតារាងទិន្នន័យដាច់ដោយឡែក និងមិនបញ្ចូលទៅក្នុងសំណាកសរុប ២.៤០១ នោះឡើយ។

កាលពីដំបូងមានសំណើឲ្យធ្វើការវិភាគទៅលើក្រុមអ្នកផ្តល់សម្ភាសន៍ ដែលពឹងផ្អែកលើអនុផលព្រៃឈើ សម្រាប់ការចិញ្ចឹមជីវិតរបស់ខ្លួន។ ដោយសារទិន្នន័យអំពីសមាមាត្រប្រជាជនក្នុងក្រុម ដែលពឹងផ្អែកជាសំខាន់លើអនុផលព្រៃឈើសម្រាប់ការចិញ្ចឹមជីវិតនេះមានត្រឹមកម្រិតកំណត់ ដូចនេះសំណាក សម្រាប់ក្រុមនេះត្រូវបានចាត់ទុកថាមិនមានទំហំគ្រប់គ្រាន់ សម្រាប់ការវិភាគឡើយ។ ការកំណត់យកសំណាកបន្ថែមក៏មិនត្រូវបានចាត់ទុកថាសមស្របផងដែរ ដោយសារការលំបាក ក្នុងការធ្វើដំណើរទៅកាន់ទីជនបទដាច់ស្រយាលបែបនេះ។

## សុពលភាព នៃព័ត៌មាន

### គោលគំនិត និងបច្ចេកស័ព្ទ ដែលលំបាកយល់

ការបង្កើតសំណួរ ដែលប្រើប្រាស់គោលគំនិត និងបច្ចេកស័ព្ទ ដែលអ្នកផ្ដល់សម្ភាសន៍ពិបាកយល់គឺជាការប្រឈមមួយ។ នៅក្នុងករណីខ្លះការប្រឈមទាំងនេះអាចដោះស្រាយបាន តាមរយៈការសួរសំណួរបែបគុណវិស័យ ដែលអាចជួយក្នុងការស្វែងយល់ និងកំណត់ អំពីការយល់ខុសបានកាន់តែច្រើនបន្ថែមទៀត។

ដោយសារការស្រាវជ្រាវបែបគុណវិស័យមិនបានធ្វើឡើង ក្នុងចំណោមសាធារណជន ដូច្នេះការយកចិត្តទុកដាក់ជាពិសេសបានផ្ដោតលើរបៀប នៃការលើកសំណួរដោយប្រើប្រាស់គោលគំនិត និងពាក្យដែលលំបាកយល់។ បញ្ជីសំណួរត្រូវបានរៀបចំឡើង តាមរយៈការពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថាន អង្គការ Oxfam និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា (UNDP)។ ការរៀបចំនេះបានផ្អែកលើបទពិសោធន៍ពីការស្រាវជ្រាវដទៃទៀតលើប្រធានបទនេះ ដោយយោងឯកសារពាក់ព័ន្ធ ដែលមានចេញផ្សាយជាសាធារណៈ។ ការស្រាវជ្រាវនេះក៏បានផ្អែកផងដែរ លើបទពិសោធន៍ការងារកន្លងមករបស់អង្គការ BBC World Service Trust លើការប្រែប្រួលអាកាសធាតុ។

បញ្ជីសំណួរនេះត្រូវបានអនុវត្តសាកល្បង និងកែសម្រួលដើម្បីឆ្លើយតបទៅនឹងយោបល់ ដែលទទួលបានពីក្រុមការងារ ដែលជាអ្នកអនុវត្តការសាកល្បងមុននឹងយកទៅអនុវត្ត នៅក្នុងការអង្កេតជាផ្លូវការ។

### ពេលវេលាធ្វើការអង្កេត

ការស្រាវជ្រាវនេះបានធ្វើឡើងនៅរវាងខែឧសភា និងមិថុនាឆ្នាំ២០១០ ជាពេលដែលមានសីតុណ្ហភាពខ្ពស់បំផុត ក្នុងប្រទេសកម្ពុជា ហើយកន្លែងភាគច្រើន នៅក្នុងផ្ទៃប្រទេសកំពុងរងគ្រោះ ដោយសារភាពរាំងស្ងួត។ ភាពក្ដៅខ្លាំងនេះជាចំណែកមួយ ដែលនាំឲ្យមានឥទ្ធិពលលើការកត់សម្គាល់ជាញឹកញាប់ អំពីភាពរាំងស្ងួត និងសីតុណ្ហភាពក្ដៅខ្លាំង ទន្ទឹមនឹងការកត់សម្គាល់ខ្លះៗផងដែរ អំពីទឹកជំនន់។

### ទិន្នន័យបានពីសេចក្ដីរាយការណ៍ផ្ទាល់ខ្លួន

បញ្ជីសំណួរនេះស្នើសុំអ្នកផ្ដល់សម្ភាសន៍ឲ្យប្រាប់ អំពីការយល់ឃើញ របស់ពួកគាត់ទាក់ទងនឹងប្រធានបទប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍អ្នកផ្ដល់សម្ភាសន៍ត្រូវបានសួរថា តើពួកគេមានទឹកគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់ ក្នុងការប្រកបការងារ របស់ខ្លួន ឬសម្រាប់បំពេញតម្រូវការផ្ទាល់ខ្លួនឬទេ។ រង្វាស់អត្តនោមតិបែបនេះមិនមានបំណងប្រើប្រាស់ សម្រាប់ជំនួសការវាយតម្លៃ តាមរយៈសូចនាករជាតិ ឬ អន្តរជាតិបានឡើយ បើទោះជាវាអាចបំពេញបន្ថែម សម្រាប់ការវាយតម្លៃក៏ដោយ។[២២] ដូចគ្នានេះដែរអ្នកផ្ដល់សម្ភាសន៍ត្រូវបានសួរ អំពីបទពិសោធន៍ របស់ខ្លួនទាក់ទងនឹងគ្រោះធម្មជាតិ។

---

២២ សូមអានhttp://earthtrends.wri.org/pdf_library/cp/wat_cou_116.pdf និងhttp://www.fao.org/nr/water/aquastat/countries/cambodia/index.stm

ទោះបីការធ្វើបែបនេះបានផ្អែកលើសំណួរ ក្នុងការអង្កេតថ្នាក់ជាតិ ដែលមានចែង ក្នុងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុក៏ដោយ [២៣] ក៏គួរទទួលស្គាល់ផងដែរថាការនិយមប្រើប្រាស់ពាក្យ "ព្យុះ" អាចខុសពីនិយមន័យវិទ្យាសាស្ត្រ។[២៤]

## ការវិភាគ

### មេគុណកែតម្រូវ

ការកំណត់ចំនួនសំណាកសរុបបានធ្វើឡើងឲ្យស្របនឹងរបាយប្រជាជនទូទាំងប្រទេស។ ទោះជាយ៉ាងណាក៏ដោយពុំមានការកែតម្រូវតាមរយៈមេគុណនោះឡើយ។

ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រខុសពី អ្វីដែលប្រើ ក្នុងជំរឿនប្រជាជនថ្នាក់ជាតិ [២៥] និងបានប្រមូលយកសំណាកតិចជាង ការធ្វើជំរឿនប្រជាជន ដោយសារឧបសគ្គខាងភស្តុភារ និងការចំណាយ។ ការពិចារណា អំពីស្ថានភាពជាក់ស្តែងមានន័យថាចំនួនមុខរបរក៏ត្រូវបានកំណត់មិនសូវពិស្តារ ដូចក្នុងជំរឿនប្រជាជនផងដែរ។ លើសពីនេះ ទិន្នន័យដែលទាក់ទងនឹងសមាមាត្រប្រជាជន ដែលពឹងផ្អែកលើអនុផលព្រៃឈើ សម្រាប់ការចិញ្ចឹមជីវិតក៏ពុំមានឡើយ។

ដោយសារមូលហេតុនេះ ការប៉ុនប៉ងប្រៀបធៀបឲ្យស៊ីគ្នាទៅនឹងស្ថានភាពប្រជាសាស្ត្រ រវាងសំណាករបស់យើង និងស្ថានភាពប្រជាសាស្ត្រ ក្នុងជំរឿនប្រជាជនក៏គ្មានប្រយោជន៍ដែរ។ ទោះជាយ៉ាងណាក៏ដោយការពិនិត្យមើលទិដ្ឋភាពសំខាន់ៗមួយចំនួនតូច នៅក្នុងជំរឿនប្រជាជនអាចមានប្រយោជន៍ផងដែរ។

### កសិករ

ជំរឿនប្រជាជនបានរកឃើញថាប្រជាពលរដ្ឋ ៧១% ដាំដំណាំ និងចិញ្ចឹមសត្វ ដោយមាន ៦៣% ជាកសិករ អ្នកនេសាទ អ្នកបរបាញ់ និងអ្នករកអនុផលព្រៃឈើទ្រង់ទ្រាយតូច សម្រាប់ចិញ្ចឹមជីវិត។

អ្នកផ្តល់សម្ភាសន៍ចំនួន ៤៦% នៅក្នុងសំណាក នៃការអង្កេតនេះគឺជាកសិករ។

### សហគមន៍អ្នកនេសាទ

១% នៃប្រជាជននៅក្នុងជំរឿនប្រជាសាស្ត្រគឺជាអ្នកនេសាទ និងវារីវប្បករ។ តួលេខនេះត្រូវគ្នានឹងសមាមាត្រនៃសំណាក ក្នុងការសិក្សានេះ។

---

[២៣] គ្រួសារសរុបចំនួន៦៨៤នៅក្នុង១៧ខេត្តត្រូវបានអង្កេតអំពីបទពិសោធន៍របស់ពួកគេទាក់ទងនឹងទឹកជំនន់ភាពរាំងស្ងួតខ្យល់ព្យុះការជ្រាបចូលនៃទឹកប្រៃ និងទឹកជោរខ្ពស់ខ្លាំង។សូមអាន http://unfccc.int/resource/docs/napa/khm01.pdf

[២៤] តាមនិយមន័យពីការិយាល័យឧតុនិយមចក្រភពអង់គ្លេសៈ "ព្យុះ" គឺខ្យល់បក់ដោយកម្លាំង១០ (៤៨-៥៥)ម៉ាយ៍សមុទ្រ/ម៉ោង) ឬកម្ប្រួលខ្យល់ដែលមានល្បឿន៦១-៦៨ម៉ាយ៍សមុទ្រ/ម៉ោង។http://www.metoffice.gov.uk/weather/marine/guide/glossary.html

[២៥] សូមអានhttp://celade.cepal.org/khmnis/census/khm2008/

### សិស្ស និងនិស្សិត

នៅក្នុងសំណាកជំរឿនប្រជាជនមានសិស្ស និងនិស្សិត ចំនួន២៥% ចំណែកនៅក្នុងការសិក្សានេះមានត្រឹម ១២% ប៉ុណ្ណោះ ដែលបង្ហាញថាសំណាក ក្នុងការសិក្សានេះមិនមានលក្ខណៈតំណាងទេ។

### ការវិភាគអនុក្រុម

ការវិភាគអនុក្រុមខ្លះៗនៅមានកម្រិតកំណត់ ដោយសារសំណាកមានចំនួនតិច និងធ្វើតែតាមរយៈវិធីខុសគ្នាចំនួនពីរ នៃការយកសំណាកដូច ដែលបានពិភាក្សាខាងលើប៉ុណ្ណោះ។

### ការវិភាគអំពីកម្រិតពាក់ព័ន្ធ នៃមូលហេតុ

ការវិភាគនេះបង្ហាញឲ្យឃើញពីការពាក់ព័ន្ធ នៃអញ្ញាតប្រជាសាស្ត្រខ្លះៗជាមួយចំណេះដឹង ឥរិយាបថ និងការអនុវត្ត ដែលបានពិនិត្យ ក្នុងការសិក្សានេះ ប៉ុន្តែមិនបានបង្ហាញ អំពីទិស នៃទំនាក់ទំនងនេះឡើយ។ អាស្រ័យហេតុនេះ វត្តមាននៃការពាក់ព័ន្ធមិនអាចជាភស្តុតាងបង្ហាញថា អញ្ញាតមួយបង្កជាមូលហេតុនាំឲ្យមានអញ្ញាតមួយទៀតនោះឡើយ។

ការវិភាគបន្ថែមបែបនេះហួសពីវិសាលភាព នៃការសិក្សានេះ ក្នុងការពិនិត្យមើលឲ្យលម្អិតបន្ថែមទៀតអំពីទំនាក់ទំនងទាំងនេះ។ នៅពេលពិនិត្យមើលទំនាក់ទំនង នៃមូលហេតុគេអាចប្រើវិធី វិភាគបែប Multivariate Regression ដើម្បីពិនិត្យមើលឥទ្ធិពល ដែលមិនអាចយល់បាន នៃអញ្ញាតនានា។ ការបង្កើតម៉ូដែលជាទម្រង់សមីការអាចវិភាគភាពខ្លាំង នៃទំនាក់ទំនងនានារវាងក្រុមអញ្ញាត និងអះអាងអំពីវត្តមានទំហំ និងទិសដៅទំនាក់ទំនង នៃមូលហេតុនានា។

### មេរៀន ដែលទទួលបាន

ដោយសារមានមនុស្សមួយចំនួនតូចប៉ុណ្ណោះយល់អំពីគោលគំនិត ឬបច្ចេកសព្ទ ដែលទាក់ទងនឹងប្រធានបទនេះ ការបណ្តុះបណ្តាលអ្នកស្រាវជ្រាវ និងសាកល្បងបញ្ជីសំណួរជាមុនគឺជាកិច្ចការសំខាន់។ ការបណ្តុះបណ្តាលដល់អ្នកស្រាវជ្រាវទាំងអស់ មានសារៈសំខាន់ណាស់សម្រាប់ធ្វើឲ្យលទ្ធផលមានភាពហ្មត់ចត់។

ការស្រាវជ្រាវបែបគុណវិស័យ ដែលធ្វើឡើងក្នុងចំណោមសាធារណជន និងក្នុងចំណោមបុគ្គលសំខាន់ៗអាចផ្តល់លទ្ធភាពឲ្យយើង ធ្វើការប្រៀបធៀបដែលមានលក្ខណៈស៊ីសង្វាក់មួយ អំពីការយល់ដឹង និងការយល់ផ្សេងគ្នា ក្នុងចំណោមប្រជាពលរដ្ឋទូទៅ អ្នកផ្សព្វផ្សាយសំខាន់ៗ និងអ្នកធ្វើសេចក្តីសម្រេចនានា។

ការបន្ថែមពេលវេលា សម្រាប់ការស្រាវជ្រាវដោយធ្វើការសម្ភាសន៍ទាំងក្នុងរដូវប្រាំង និងរដូវវស្សាអាចប្រមូលបានទិន្នន័យ ដែលយកមកប្រើប្រាស់ ក្នុងការពិចារណា អំពីឥទ្ធិពល នៃលក្ខខណ្ឌធាតុអាកាសបច្ចុប្បន្ន មកលើការពិភាក្សាណាមួយ អំពីធាតុអាកាស និងអាកាសធាតុ។

## របកគំហើញសំខាន់ៗ

## តើប្រជាជនកម្ពុជាយល់ដឹង និងគិតយ៉ាងណាខ្លះអំពីការប្រែប្រួលអាកាសធាតុ?

មានវិធីខុសៗគ្នា សម្រាប់ស្វែងយល់ អំពីការប្រែប្រួលអាកាសធាតុ។ ទីមួយគឺការស្វែងយល់តាមបែបវិទ្យាសាស្ត្រ ថាសកម្មភាពមនុស្ស ដូចជាការដុតប្រេងឥន្ទនៈផូស៊ីល សម្រាប់ផលិតថាមពល ធ្វើឲ្យមានកំណើនឧស្ម័ន ស្រូបយកកម្ដៅនៅក្នុងស្រទាប់បរិយាកាស ដែលបង្កឲ្យកម្ដៅផែនដីកើនឡើង និងមានឥទ្ធិពលមកលើប្រព័ន្ធអាកាសធាតុ នៃផែនដី។ វិធីមួយផ្សេងទៀតគឺតាមរយៈការជួបប្រទះដោយផ្ទាល់ពោលគឺ តាមរយៈការឆ្លងកាត់ នៅក្នុងខ្សែជីវិត នូវការប្រែប្រួលរបបទឹកភ្លៀង ដែលមានឥទ្ធិពលមកលើផលដំណាំ តាមរយៈការរងគ្រោះពីឥទ្ធិពល នៃភាពរាំងស្ងួត ទឹកជំនន់ និងគ្រោះមហន្តរាយដទៃទៀត នៃអាកាសធាតុ ដែលអាចបំផ្លាញផ្ទះសម្បែង និងដំណាំ ឬស្ថិត នៅក្នុងស្ថានភាព នៃការរាតត្បាតជំងឺឆ្លង ដូចជាគ្រុនឈាម និងគ្រុនចាញ់។[២៦]

របកគំហើញពីការស្រាវជ្រាវនេះបង្ហាញថា ប្រជាជនកម្ពុជាមួយចំនួនតូចយល់ពីមូលដ្ឋានវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដែលបានធ្វើនិទស្សន៍ បានបង្ហាញឲ្យឃើញកាន់តែជាក់ស្ដែងជាងមុនថា ប្រជាជនកម្ពុជានឹងជួបប្រទះផលប៉ះពាល់ទាំងនោះដោយផ្ទាល់។ នេះជាការពិត ដូច្នេះប្រការសំខាន់គឺត្រូវស្វែងយល់ថាតើប្រជាជនកម្ពុជាបានឆ្លងកាត់ការប្រែប្រួលធាតុអាកាសបែបណា ដែលរួមទាំងគ្រោះធម្មជាតិនានាផងដែរ តើពួកគេពន្យល់បែបណាអំពីបាតុភូតទាំងនោះ ហើយថាតើពួកគេគិតថាពួកគេអាចត្រៀមខ្លួនបែបណា និងឆ្លើយតបបែបណាទៅនឹងបាតុភូតទាំងនោះ។ ដើម្បីផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុទៅកាន់សាធារណជន ប្រការចាំបាច់គឺត្រូវផ្ដោតលើសេចក្ដីពន្យល់ ដែលទាក់ទងនឹងបទពិសោធន៍ផ្ទាល់ ដែលពួកគាត់ជួបប្រទះនឹងការប្រែប្រួលអាកាសធាតុ ជាជាងពឹងផ្អែកតែលើភាសាវិទ្យាសាស្ត្រ ដែលផ្ដល់អត្ថន័យតិចតួចប៉ុណ្ណោះ ដល់ប្រជាជនកម្ពុជាភាគច្រើន។ គោលដៅគួរតែជាការប្រមូលផ្ដុំនូវការយល់ដឹងអំពីបទពិសោធន៍កន្លងមក របស់ប្រជាជនរួមផ្សំ ជាមួយការយល់ដឹងទូលំទូលាយ អំពីមូលដ្ឋានវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុពិភពលោក។

របាយការណ៍ ក្នុងផ្នែកនេះចាប់ផ្ដើមដោយពិនិត្យមើលបទពិសោធន៍ របស់ប្រជាជនកម្ពុជាទាក់ទងនឹងគ្រោះធម្មជាតិថ្មីៗនេះ ក៏ដូចជាការសង្កេត របស់ពួកគេ អំពីការប្រែប្រួលធាតុអាកាស និងការប្រែប្រួលអាកាសធាតុផងដែរ។ បន្ទាប់មករបាយការណ៍នេះពិនិត្យមើលការយល់ដឹង អំពីបច្ចេកស័ព្ទ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុមុននឹងស្វែងយល់អំពីការយល់ឃើញ របស់ប្រជាជន អំពីការប្រែប្រួលធាតុអាកាស ដែលទាក់ទងនឹងជីវិតផ្ទាល់ខ្លួនរបស់ពួកគាត់។ នៅផ្នែកបន្តបន្ទាប់ របាយការណ៍នេះពន្យល់ពិស្ដារ អំពីរបកគំហើញពីការសិក្សា លើការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ បន្ទាប់មកនឹងមានបង្ហាញជូន នូវរបកគំហើញពីការស្រាវជ្រាវបែបគុណវិស័យជាមួយបុគ្គលសំខាន់ៗ។

---

[២៦] សូមអានកម្មវិធីសកម្មភាពជាតិ បន្សាំនឹងការប្រែប្រួលអាកាសធាតុ "... ជម្ងឺឆ្លង ជាពិសេសជម្ងឺគ្រុនចាញ់អាចរាលដាលកាន់តែខ្លាំងនៅក្រោមលក្ខខណ្ឌប្រែប្រួលអាកាសធាតុ។ ដោយមានអត្រាអ្នកស្លាប់ប្រមាណ ៨០០ នាក់ ក្នុងមួយឆ្នាំ ប្រទេសកម្ពុជាមានអត្រាខ្ពស់បំផុតរួចមកហើយ នៃមរណភាពបណ្ដាលពីជម្ងឺគ្រុនចាញ់ធៀបនឹងប្រទេសនានានៅអាស៊ី (CNM, ២០០៣) ។ តួលេខជាក់ស្ដែង នៃការបាត់បង់ជីវិត ដោយសារជម្ងឺគ្រុនចាញ់អាចមានពី ៥ ដល់ ១០ ដង ខ្ពស់ជាងតួលេខផ្លូវការ(RGC,២០០២)។"

## បទពិសោធន៍អំពីការប្រែប្រួលធាតុអាកាសនិងបរិស្ថាន

### ទស្សនៈសំខាន់ៗ

ប្រជាជនកម្ពុជាពោលថាធាតុអាកាស និងបរិស្ថានរបស់ពួកគេកំពុងប្រែប្រួល ហើយគ្រោះធម្មជាតិកើតឡើង កាន់តែញឹកញាប់ និងធ្ងន់ធ្ងរជាងអ្វី ដែលពួកគាត់ធ្លាប់ឃើញ។ សីតុណ្ហភាពបានកើនឡើង ហើយរបបទឹកភ្លៀង និងរដូវកាល បានផ្លាស់ប្តូរ។ ប្រជាជនកម្ពុជាទំនងជាយល់អំពី "ការប្រែប្រួលអាកាសធាតុ" នៅក្នុងបរិបទ នៃការប្រែប្រួលធាតុអាកាសនៅតាមមូលដ្ឋានទាំងនេះជាងការប្រែប្រួលអាកាសធាតុពិភពលោក។

## គ្រោះធម្មជាតិ

៩ នាក់ ក្នុងចំណោមប្រជាជនកម្ពុជា ១០ នាក់ (៩៣%) ពោលថា ពួកគេបានឆ្លងកាត់គ្រោះធម្មជាតិម្តងនៅក្នុងឆ្នាំមុន មុនការអង្កេតនេះ។

### ក្រាហ្វិចទី ទី ១




*សំណាក : អ្នកឆ្លើយតបទាំងអស់ : N =២៤០១*　　*ចម្លើយអាចច្រើនជាង*

ច្រើនជាងពាក់កណ្តាលបានពោលថាពួកគេបានប្រទះភ្លៀងធ្លាក់ខ្លាំង (៦១%) និងសត្វចង្រៃបំផ្លាញផលដំណាំកសិកម្ម (៥២%)។ ច្រើនជាង ៤០% អះអាងថា បានរងឥទ្ធិពលពីសីតុណ្ហភាពខ្លាំង (៤៤%) និង គ្រោះរាំងស្ងួត (៤១%) ហើយប្រហាក់ប្រហែលគ្នានេះបានជួបប្រទះខ្យល់ព្យុះ (៣៧%) និងទឹកជំនន់ (៣៧%)។ ៣ នាក់ ក្នុងចំណោម ១០ នាក់ បានពោលថាពួកគេបានជួបប្រទះសីតុណ្ហភាពត្រជាក់ខ្លាំង ចំណែកប្រមាណពាក់កណ្តាល នៃតួលេខនេះបានឃើញភ្លើងឆេះព្រៃនៅ ឆ្នាំកន្លងទៅ (១៧%)។ មានតែ៧% បានរាយការណ៍ថា ពុំប្រទះគ្រោះធម្មជាតិបែបនេះទេ។

បុរស និងស្ត្រីទំនងជាអាចរំលឹកអំពីគ្រោះធម្មជាតិខុសៗគ្នា។ បុរសត្រឹមតែ ២% ពោលថា ពួកគេមិនបានជួបប្រទះគ្រោះធម្មជាតិឡើយកាលពីឆ្នាំមុន មុនការអង្កេតនេះធៀបនឹងស្ត្រី ដែលមានដល់ ១២%។ សេចក្តីលម្អិតអំពីគ្រោះធម្មជាតិនីមួយៗទាំងនេះមានបង្ហាញក្នុងក្រាហ្វិចទី ១ លើកលែងតែសីតុណ្ហភាពត្រជាក់ខ្លាំង ដែលបុរសច្រើនជាងស្ត្រីបានពោលថា ពួកគេធ្លាប់ជួបប្រទះ។

ទិន្នន័យបង្ហាញថាប្រជាជននៅក្រុងភ្នំពេញ និងតំបន់ទំនាបរងផលប៉ះពាល់តិចជាងគេពីគ្រោះធម្មជាតិ ដោយមានប្រជាជនច្រើនជាងពីរដង (១២% នៅក្រុងភ្នំពេញ និង ១០% នៅតំបន់ទំនាប) រាយការណ៍ថាគ្មានគ្រោះធម្មជាតិឡើយ នៅក្នុងឆ្នាំកន្លងទៅ។ នៅតំបន់ភ្នំពេញសមាមាត្រ នៃអ្នកដែលមានដំណាំកសិកម្មខូចខាត ដោយសារសត្វល្អិតទឹកជំនន់ និងសីតុណ្ហភាពត្រជាក់ខ្លាំងមានចំនួនតិចតួច[២៧] ធៀបនឹងតំបន់ដទៃទៀត។

## *ព័ត៌មានអំពីគ្រោះធម្មជាតិ*

### ទស្សនៈសំខាន់ៗ

អ្នកឆ្លើយសម្ភាសស្ទើរតែទាំងអស់ពោលថាពួកគេបានប្រទះគ្រោះធម្មជាតិ នៅក្នុងឆ្នាំកន្លងទៅ។ ច្រើនជាងមួយភាគបី (៣៦%) នៃអ្នកទាំងនោះពុំបានទទួលព័ត៌មានណាមួយ អំពីព្រឹត្តិការណ៍នេះទេ ហើយអ្នកដែលបានទទួលគឺមានត្រឹមតែមួយភាគបួនប៉ុណ្ណោះ (២៥%) ដែលទទួលព័ត៌មាននៅមុនពេលគ្រោះធម្មជាតិបានកើតឡើង។

ក្រោយពីបានស្នើឲ្យជ្រើសយកអ្វីដែលពួកគេគិតថាមានឥទ្ធិពលខ្លាំងបំផុតមកលើការរស់នៅរបស់ពួកគេ អ្នកស្រាវជ្រាវក៏បានសួរសំណួរបន្ថែមមួយចំនួនផងដែរដែលទាក់ទងនឹងព័ត៌មានដែលពួកគេទទួលបានអំពីគ្រោះធម្មជាតិនេះ។ ច្រើនជាងមួយភាគបី (៣៦%) នៃអ្នកផ្តល់សម្ភាសន៍មិនបានទទួលព័ត៌មានណាមួយអំពីគ្រោះធម្មជាតិឡើយ ហើយក្នុងចំណោមអ្នកដែលបានទទួល ជិតបីភាគបួន (៧២%) បានទទួលព័ត៌មាននេះ នៅក្នុងពេល ឬក្រោយពេល ដែលព្រឹត្តិការណ៍នេះបានកើតឡើងរួចទៅហើយ។

- បុរស (៦៦%) ដែលច្រើនជាងស្ត្រីត្រឹមបន្តិចបន្តួច (៦០%) បានទទួលព័ត៌មាន ប៉ុន្តែមានភាពខុសគ្នាបន្តិចបន្តួចអំពីពេលវេលា ដែលបុរស និងស្ត្រីបានទទួលព័ត៌មានគ្រោះធម្មជាតិ
- អ្នកទីក្រុង (៧១%) និងយុវជន (៦៨%) ពោលថាពួកគេបានទទួលព័ត៌មានអំពីគ្រោះធម្មជាតិ
- អ្នករស់នៅភ្នំពេញ និងតំបន់ឆ្នេរបានរាយការណ៍ អំពីការទទួលបានព័ត៌មានជាញឹកញាប់បំផុតអំពីគ្រោះធម្មជាតិ (អ្នកនៅភ្នំពេញ ៦៨% និងតំបន់ឆ្នេរ ៧៨%)
- អ្នកសិក្សាថ្នាក់ឧត្តមមានចំនួនច្រើន (៨៨% នៃអ្នកដែលបានសិក្សាថ្នាក់សាកលវិទ្យាល័យ) និងក្នុងចំណោមក្រុមដែលមានរង្វាស់ PPI ខ្ពស់ (៧៧% ឡើងទៅ) គ្រូបង្រៀន (៩៣%) និស្សិត (៨៨%) និងមន្ត្រីរដ្ឋាភិបាល (៨៤%) ពោលថាពួកគេបានទទួលព័ត៌មានអំពីគ្រោះធម្មជាតិ។

[២៧] ក្នុងករណីដែលមានបង្ហាញពីភាពខុសគ្នាយ៉ាងខ្លាំងលទ្ធផល ក្នុងការវិភាគស្ថិតិក៏បង្ហាញពីភាពខុសគ្នាខ្លាំងផងដែរ។

កសិករ (៤៤%) ដែលច្រើនជាងអ្នកមានរបរផ្សេងទៀតមិនបានទទួលព័ត៌មានណាមួយ អំពីគ្រោះធម្មជាតិ ដែលពួកគេបានជួបប្រទះនោះឡើយ។ សិប្បករ (៤០%) និងអ្នកជំនួញ (៣៥%) ច្រើនជាងអ្នកមានរបរផ្សេងទៀត ដែលពុំបានទទួលព័ត៌មានឡើយ។

### ក្រាហ្វិចទី ២




ក្នុងចំណោមអ្នកដែលបានជួបប្រទះ និងទទួលបានព័ត៌មានអំពីគ្រោះធម្មជាតិនៅក្នុងឆ្នាំកន្លងទៅ មានចំនួនពាក់កណ្តាល (៥១%) បានទទួលព័ត៌មានក្រោយពីហេតុការណ៍នេះកើតឡើងប៉ុណ្ណោះ។ មានភាពខុសគ្នាខ្លះៗ ក្នុងចំណោមអនុក្រុមខុសៗគ្នាទាំងនេះ លើកលែងតែនៅតំបន់បឹងទន្លេសាប ដែលប្រជាជនយ៉ាងច្រើន (៥៧%) ពោលថាពួកគេបានទទួលព័ត៌មាននៅក្រោយគ្រោះធម្មជាតិបានកើតឡើង ហើយអ្នកផ្តល់សម្ភាសន៍ ក្នុងចំនួនតិចជាង (២០%) ដែលបានរាយការណ៍ថាបានទទួលព័ត៌មានអំពីព្រឹត្តិការណ៍នេះ។

ប្រជាជនជាច្រើននៅទីក្រុងភ្នំពេញ (៣៦%) និងតំបន់ទំនាប (៣១%) ពោលថាពួកគេបានទទួលព័ត៌មាននៅមុនពេលគ្រោះធម្មជាតិកើតឡើង។

ប្រជាជនច្រើនតែកត់សម្គាល់ទូរទស្សន៍ (៥៩%) វិទ្យុ (៥២%) និងការនិយាយពីមាត់ទៅមាត់មួយពីអ្នកជិតខាង (៣៧%) ថាជាប្រភពព័ត៌មានអំពីគ្រោះធម្មជាតិ។

ទូរទស្សន៍គឺជាប្រភពផ្តល់ព័ត៌មានចំពោះបុរស (៦២%) អ្នករស់នៅទីក្រុង (៧៥%) អ្នករស់នៅក្រុងភ្នំពេញ (៨៣%) និងអ្នករស់នៅតំបន់ទំនាប (៦៧%) និងអ្នកមានកម្រិតសិក្សាថ្នាក់ឧត្តម (៨៦% នៃអ្នក ដែលមានការសិក្សានៅសាកលវិទ្យាល័យធៀបនឹង ៣៥% នៃអ្នកមិនបានចូលរៀន) និងក្នុងចំណោមក្រុម ដែលមានរង្វាស់ PPI កម្រិតខ្ពស់ (៧៩% ជាក្រុមដែលមាន រង្វាស់ PPI កម្រិត "ខ្ពស់ជាងគេ" ធៀបនឹង ៣១% ជាក្រុម ដែលមានរង្វាស់ PPI កម្រិត "ទាបបំផុត" ) ។

វិទ្យុគឺជាប្រភពព័ត៌មានមួយអំពីគ្រោះធម្មជាតិ សម្រាប់សមាមាត្រខ្ពស់ក្នុងចំណោមបុរស (៥៨%) អ្នកជនបទ (៥៤%) និងកសិករ (៥៥%) នៅក្នុងអនុក្រុមនេះ។

អ្នកផ្តល់សម្ភាសន៍ ១ នាក់ ក្នុងចំណោម ១០ នាក់ពោលថាពួកគេទទួលបានព័ត៌មានអំពីគ្រោះធម្មជាតិនេះ តាមរយៈការសង្កេតផ្ទាល់ខ្លួន ដោយមានសមាមាត្រខ្ពស់ក្នុងចំណោមបុរស (១៣%) អ្នកនៅជនបទ (១១%) និងប្រជាជននៅបឹង

ទន្លេសាប (១៦%) តំបន់ឆ្នេរ (១៤%) និងតំបន់ភ្នំ (១២%)។ សមាមាត្រខ្ពស់ចំណោមសហគមន៍អ្នកនេសាទក៏បានពោលដូចគ្នានេះដែរ។[២៨]

មនុស្សភាគច្រើននៅជនបទពោលថាពួកគេទទួលបានព័ត៌មានពីអ្នកជិតខាង(៤៣%) និងសមាជិកគ្រួសារ (១៥%) ជាពិសេសអ្នក ដែលរស់នៅក្រៅក្រុងភ្នំពេញ និងក្រៅតំបន់ទំនាប។ មនុស្សភាគច្រើន ដែលមាន កម្រិតសិក្សាទាប (៤៩% មិនបានរៀន) និងក្រុមដែលមានរង្វាស់ PPI កម្រិតទាប (៤៧% ជាក្រុមដែលមានរង្វាស់ PPI "ទាបជាងគេ") ពោលថាពួកគេបានទទួលព័ត៌មានពីអ្នកជិតខាងដូចគ្នានេះដែរ ចំពោះកសិករ (៤១%) និងអ្នកជំនួញ (៤២%)។

## ក្រាហ្វិចទី ៣




*សំណាក : ទទួលបានព័ត៌មានពីគ្រោះធម្មជាតិ N =១៤១៥*

ទោះបីប្រជាជនមួយចំនួនតូច (៨%) កត់សម្គាល់ថា "អាជ្ញាធរ" (តំណាងក្រុមប្រឹក្សាឃុំ/សង្កាត់ ឬប្រធានភូមិ) គឺជាប្រភពព័ត៌មាន អំពីគ្រោះធម្មជាតិទាំងនេះក៏ដោយ ប៉ុន្តែអ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺប្រជាជននៅជនបទ (១០%) អ្នករស់នៅតំបន់ភ្នំ (១៤%) អ្នកមានការសិក្សាតិចតួច (១៦%) និងក្រុមអ្នកមានរង្វាស់ PPI កម្រិតទាប (១៧% ក្នុងក្រុម ដែលមានរង្វាស់ PPI កម្រិត "ទាបជាងគេ") ពោលថាពួកគេទទួលព័ត៌មានអំពីគ្រោះធម្មជាតិទាំងនេះ ពីប្រធានភូមិ ឬប្រធានឃុំ/សង្កាត់របស់ខ្លួន។

[២៨] គួរកត់សម្គាល់ថាសំណាក "បន្ថែម" សម្រាប់សហគមន៍អ្នកនេសាទតំបន់ឆ្នេរមិនអាចចាត់ទុកថា មានលក្ខណៈតំណាង ក្នុងប្រទេសឡើយ ដោយសារអ្នកឆ្លើយត្រូវបានជ្រើសរើស សម្រាប់គោលបំណងបំពេញបន្ថែមប៉ុណ្ណោះ។ ដោយសារការប្រើវិធីខុសគ្នា យើងមិនអាចប្រៀបធៀបសំណាកនេះ ជាមួយសំណាកសរុបទាំង ២.៤០១ តាមវិធីវិភាគស្ថិតិបានឡើយ ឬប្រៀបធៀបជាមួយលទ្ធផល សម្រាប់អនុក្រុមខុសៗគ្នាបានឡើយ។ ដូច្នេះយើងនឹងមិនបញ្ចូលលទ្ធផលពីការវិភាគស្ថិតិលើសំណាក "បន្ថែម" ទៅក្នុងរបាយការណ៍នេះឡើយ។ លទ្ធផលទាំងនេះមាននៅក្នុងតារាងទិន្នន័យទាំងមូលដែលភ្ជាប់ក្នុងឧបសម្ព័ន្ធ១។

## តើព័ត៌មានបានជួយប្រជាជនបែបណាខ្លះក្នុងការត្រៀមខ្លួនទប់ទល់នឹងគ្រោះធម្មជាតិ?

### ក្រាហ្វិចទី ៤




នៅពេលសួរថាតើព័ត៌មានបានជួយពួកគេបែបណា ក្នុងការត្រៀមខ្លួនទប់ទល់នឹងគ្រោះធម្មជាតិ ដែលពួកគេបានកត់សម្គាល់ មនុស្សជាច្រើននិយាយថាព័ត៌មានបានជួយពួកគេ ក្នុងការត្រៀមសម្ភារៈ[២៩] (៥២%) និងបានជួយពួកគាត់ ក្នុងការគាំទ្រគ្នា ក្នុងការត្រៀមខ្លួន សម្រាប់គ្រោះធម្មជាតិទាំងនោះ(៤៦%)។ ប្រមាណមួយភាគប្រាំ នៃអ្នកផ្តល់សម្ភាសន៍បានពោលថា នៅពេលពួកគេបានទទួលព័ត៌មានបែបនេះគឺអាចជួយពួកគេ ក្នុងការរៀបចំទិញថ្នាំគីមីកសិកម្ម (២១%) ភៀសខ្លួនទៅកាន់ទីទួលសុវត្ថិភាព (២០%) ឬត្រៀមស្បៀងអាហារឲ្យបានគ្រប់គ្រាន់ (២០%)។

[២៩] សំដៅលើអ្វីដែលអាចជួយសម្រួលដល់ការឆ្លើយតបទៅនឹងបាតុភូតធម្មជាតិដូចជាទូក ម៉ាស៊ីនភ្លើងឬឈើសម្រាប់សាងសង់។ល។

# ការប្រែប្រួលធាតុអាកាស

## ក្រាហ្វិចទី ៥

**សូមគិតពីនៅក្នុងឆាកជីវិតដែលបានជួបប្រទះ *(តាំងពីកើត ដល់បច្ចុប្បន្ន)* ហើយខ្ញុំនឹង *អានឃ្លា ឬប្រយោគ* ខាងក្រោមនេះ សូមប្រាប់ខ្ញុំថា *"ត្រូវ" ឬ "ខុស"***




*សំណាក : អ្នកឆ្លើយតបទាំងអស់ N =២៤០១*

ចម្លើយអាចច្រើនជាង ១

## ក្រាហ្វិចទី ៦

**តើអ្នកចាប់ផ្តើមកត់សម្គាល់ការប្រែប្រួលនេះតាំងពីពេលណាមក? (អានចម្លើយ)**




សំណាក : អ្នកឆ្លើយតបទាំងអស់ n= ២៤០១ (N គឺខុសៗគ្នាទៅតាមចម្លើយនីមួយៗដូចដែលបានបង្ហាញនៅក្នុងរង្វង់ក្រចក)

អ្នកឆ្លើយតបភាគច្រើន នៃក្រុមប្រជាពលរដ្ឋ ដែលបានយល់ថារដូវកាលកាន់តែលំបាក ក្នុងការព្យាករណ៍កំដៅកើនឡើង គ្រោះរាំងស្ងួតកើតមានកាន់តែញឹកញាប់ជាងមុន ទឹកភ្លៀងតិចជាងមុន និងភ្លៀងមិនសូវខ្លាំង និងពិបាកព្យាករណ៍បាន បានអះអាងថាពួកគេបានសង្កេតឃើញការប្រែប្រួលទាំងនេះ កាលពីឆ្នាំកន្លងទៅ។

សម្រាប់ការប្រែប្រួលជាច្រើនផ្សេងទៀតប្រជាជនពោលថា ពួកគេបានចាប់ផ្តើមសង្កេតមើលច្រើនជាងមួយឆ្នាំមកហើយ ហើយប្រជាជនស្ទើរតែទាំងអស់និយាយថា ពួកគេបានកត់សម្គាល់ថាមានទឹកជោរជាងមុននិងសំណឹកឆ្នេរសមុទ្រខ្លាំងជាងមុន និងរលកទឹកសមុទ្រធំជាងមុន ប៉ុន្តែមិនអាចចាំបានទេថាពួកគេបានចាប់ផ្តើមសង្កេតឃើញមានការប្រែប្រួលទាំងនេះតាំងពីពេលណាមក។

ប្រជាជនបានស្វែងយល់អំពីការប្រែប្រួលធាតុអាកាសតាមរបៀបខុសៗគ្នា ៖

- កសិករក្នុងសមាមាត្រខ្ពស់បានពោលថាភាពរាំងស្ងួតកើតមានកាន់តែញឹកញាប់ (កសិករ ៧៤%) និងកាន់តែខ្លាំង (៧០%)។ សមាមាត្រខ្ពស់ នៃអ្នកផ្តល់សម្ភាសន៍ពីទីជនបទ និងក្នុងចំណោមក្រុមមនុស្សចាស់បានសង្កេតឃើញដូចគ្នានេះ

- ភាគច្រើន នៃអ្នកនៅក្នុងក្រុមអ្នក ដែលមានរង្វាស់ PPI កម្រិតខ្ពស់ជាងធៀបនឹងក្រុមអ្នក ដែលមានកម្រិតទាបបាន ពោលថាភ្លៀង និងរដូវកាន់តែលែងព្យាករណ៍បានដូចពីអតីតកាល
- សមាមាត្រនៃមនុស្សចាស់ (៤៥-៥៥ឆ្នាំ) ខ្ពស់ជាងយុវជន (១៥-២៤ឆ្នាំ) រាយការណ៍ថាភាពរាំងស្ងួតកាន់តែធ្ងន់ធ្ងរជាងមុន (មនុស្សចាស់ចំនួន ៧២%, យុវជន ៤៨%) ហើយខ្យល់ព្យុះកើតមានកាន់តែញឹកញាប់ (មនុស្សចាស់ ៥០% និងយុវជន ៤០%)
- សមាមាត្រខ្ពស់ នៃសហគមន៍អ្នកនេសាទនៅតំបន់ឆ្នេរបានសង្កេតឃើញសំណឹកឆ្នេរខ្លាំងជាងមុន ក្នុងមួយអាយុកាលរបស់គាត់ និងបានបន្ថែមទៀតថាជំនោរ និងរលកសមុទ្រមានសភាពខ្ពស់ជាងកម្រិត ដែលធ្លាប់កើតមានពីមុន[៣០]។

## ការប្រែប្រួលបរិស្ថាន

ប្រជាជនកម្ពុជាបានកត់សម្គាល់ អំពីការប្រែប្រួលបរិស្ថាន ក៏ដូចជាការប្រែប្រួលធាតុអាកាសផងដែរ។ ការប្រែប្រួលបរិស្ថាន ដែលសាធារណជន និងបុគ្គលសំខាន់ៗបានកត់សម្គាល់ញឹកញាប់ជាងគេ គឺការបាត់បង់ព្រៃឈើ។

ប្រជាជនភាគច្រើនខ្វល់ខ្វាយពីការបាត់បង់ព្រៃឈើ ដោយពួកគាត់ចាត់ទុកព្រៃឈើថា ជាសម្បត្តិបរិស្ថានដ៏សំខាន់របស់ប្រទេស។នៅពេលសុំឲ្យជ្រើសយកធនធានធម្មជាតិសំខាន់បំផុតនៅកម្ពុជា អ្នកផ្តល់សម្ភាសន៍ចំនួនពាក់កណ្តាលពោលថាដើមឈើ ឬព្រៃឈើជាធនធានសំខាន់បំផុត ហើយបីភាគបួនបានចាត់ទុកដើមឈើ និងព្រៃឈើស្ថិតក្នុងចំណោមធនធានធម្មជាតិសំខាន់បំផុតចំនួនបី របស់ពួកគេ។

ដោយសារប្រជាជនឲ្យតម្លៃខ្ពស់ ចំពោះដើមឈើប្រជាជនជាច្រើនមានការព្រួយបារម្ភអំពីការបាត់បង់ព្រៃឈើ។ ជាក់ស្តែងប្រជាជនកម្ពុជាភាគច្រើនមើលឃើញការបាត់បង់ព្រៃឈើថាជាបញ្ហាអាទិភាពខ្ពស់បំផុតរបស់ប្រទេស។

[៣០] គួរកត់សម្គាល់ថាសំណាក "បន្ថែម" សម្រាប់សហគមន៍ នេសាទតំបន់ឆ្នេរមិនអាចចាត់ទុកថាជាតំណាង នៅក្នុងប្រទេសឡើយ ដោយសារអ្នកឆ្លើយត្រូវបានជ្រើសយកជាសំណាកបន្ថែមតែប៉ុណ្ណោះ។ សូមអាន*វិធីសាស្ត្រនៅទំព័រ ៦* ដោយសារប្រើប្រាស់វិធីខុសគ្នា យើងមិនអាចប្រៀបធៀបសំណាកនេះតាមវិធីវិភាគស្ថិតិ ជាមួយសំណាកសរុបទាំង ២.៤០១ ឡើយ និងមិនអាចប្រៀបធៀបជាមួយលទ្ធផល សម្រាប់អនុក្រុមខុសៗគ្នាឡើយ។ ដូច្នេះយើងនឹងមិនរួមបញ្ចូលលទ្ធផលស្ថិតិ សម្រាប់សំណាក "បន្ថែម" នៅក្នុងរបាយការណ៍នេះឡើយ។ លទ្ធផលទាំងនេះមាននៅក្នុងតារាងទិន្នន័យទាំងមូលក្នុងឧបសម្ព័ន្ធ២។

ក្រាហ្វិចទី ៧




## ចំណេះដឹងនិងការយល់ដឹងអំពី "ការប្រែប្រួលអាកាសធាតុ"

### ទស្សនៈសំខាន់ៗ

ការយល់ដឹង របស់ប្រជាជនកម្ពុជាភាគច្រើន អំពីបច្ចេកស័ព្ទ ដែលប្រើនៅក្នុង ការប្រែប្រួលអាកាសធាតុនៅមានកម្រិតទាបនៅឡើយ។ មនុស្សជាច្រើនស្គាល់ពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី"។ តែទោះជាយ៉ាងណាក៏ដោយ ការស្គាល់ពាក្យទាំងនេះមិនអាចបង្ហាញ នូវការយល់ដឹង អំពីការប្រែប្រួលអាកាសធាតុថា ជាបាតុភូតសកលឡើយ។

## *ពាក្យ ការប្រែប្រួលអាកាសធាតុ*

### ការបកប្រែពាក្យការប្រែប្រួលអាកាសធាតុ

នៅក្នុងការបកប្រែពាក្យពីភាសាអង់គ្លេសចំណុចសំខាន់គឺ ត្រូវយល់ថាពាក្យដែលប្រើប្រាស់ជាភាសាខ្មែរ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ អាចផ្តល់អត្ថន័យខុសពីពាក្យអង់គ្លេស។ ចំណុចសំខាន់មួយដែលបានរកឃើញពីការសិក្សាស្រាវជ្រាវថ្មីៗ លើទស្សនៈសាធារណជននៅអាហ្វ្រិច ពីការប្រែប្រួលអាកាសធាតុបង្ហាញថា ការបកប្រែពាក្យអាចជាឧបសគ្គ ដល់ការយល់ដឹងពីការប្រែប្រួលអាកាសធាតុ។*

ពាក្យ'climate' និង 'weather' ពោលគឺ "អាកាសធាតុ" និង "ធាតុអាកាស" មានន័យប្រហាក់ប្រហែលគ្នាក្នុងភាសាខ្មែរ។ ពាក្យទាំងនេះមានន័យដោយត្រង់ថា "ធាតុទាំងប្រាំ" ដែលជាទឹកដីភ្លើងខ្យល់និងអាកាស ឬបរិយាកាស។

អាស្រ័យហេតុនេះពាក្យ"ការប្រែប្រួលអាកាសធាតុ" (climate change) អាចយល់បានថាជាការប្រែប្រួលធាតុអាកាស (weather

changes)។ នេះជាចំណុចសំខាន់ដោយហេតុថា ការប្រែប្រួលធាតុអាកាស សំដៅលើការប្រែប្រួលរយៈពេលខ្លី នៃធាតុអាកាស ចំណែកការប្រែប្រួលអាកាសធាតុសំដៅលើការប្រែប្រួល នៃលក្ខខណ្ឌធាតុអាកាស នៅក្នុងរយៈពេលមួយវែង ។ មិនមានអ្វីគួរភ្ញាក់ផ្អើលនោះទេ ដែលបុគ្គលសំខាន់ៗច្រើនតែងតែនិយាយយោងទៅគ្រោះធម្មជាតិជាច់ដោយឡែក ដូចជាគ្រោះរាំងស្ងួត ការប្រែប្រួលទៅតាមរដូវកាល នៅក្នុងការពន្យល់ពាក្យ "ការប្រែប្រួលអាកាសធាតុ"។ ដូចដែលប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ម្នាក់ ពន្យល់ "*ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះអាកាសធាតុបានប្រែប្រួលយ៉ាងច្រើន ប៉ុន្តែឆ្នាំនេះវាបានប្រែប្រួលជាខ្លាំង...នៅក្នុងរយៈពេលជាង ៦៥ ឆ្នាំនេះ ខ្ញុំទើបតែជួបប្រទះការប្រែប្រួលអាកាសធាតុតែម្តងគត់។ ខ្ញុំមិនចាំឆ្នាំនោះទេ ប៉ុន្តែកាលខ្ញុំនៅអាយុរវាង ១៣ ឬ ១៤ ឆ្នាំ កាលនោះគ្មានភ្លៀងរហូតដល់ខែធ្នូ។ ពុំមានភ្លៀងធ្លាក់រយៈពេលមួយឆ្នាំ...យើងមិនដឹងហេតុអ្វីឡើយ ហើយយើងក៏មិនមែនជាអ្នកវិទ្យាសាស្ត្រដែរ។*"

"ការឡើងកម្តៅផែនដី" គឺជាពាក្យបកប្រែជាភាសាខ្មែរ សម្រាប់ពាក្យ "global warming" និងមានន័យថា "កំណើនកម្តៅនៅលើផែនដី"។ "ផែនដី" ជាពាក្យសំដៅលើ "planet earth" ចំណែក "ដី" មានន័យថា "earth" ក្នុងន័យស្របនឹងពាក្យ "soil"។ ពាក្យនេះអាចធ្វើឲ្យមានការយល់ច្រឡំជាមួយអត្ថន័យ "បង្កើនកម្តៅដី" ដូច្នេះអាចច្រឡំជាមួយពាក្យរាំងស្ងួត។

ពាក្យ "ផលផ្ទះកញ្ចក់" និង "ឧស្ម័នផ្ទះកញ្ចក់" ក៏មានភាពស្មុគស្មាញផងដែរ។ ទីមួយមានប្រជាជនកម្ពុជាមួយចំនួនតូចប៉ុណ្ណោះដែលធ្លាប់ឃើញផ្ទះកញ្ចក់ ដូច្នេះប្រយោគនេះមិនផ្តល់ការពន្យល់បានច្បាស់លាស់ អំពីដំណើរ នៃការឡើងកម្តៅផែនដីឡើយ នៅក្នុងបរិបទរបស់កម្ពុជា។ ផ្ទុយទៅវិញពាក្យ "greenhouse" ត្រូវបានបកប្រែទៅជាពាក្យថា ផ្ទះកញ្ចក់ហើយចំណុចនេះធ្វើឲ្យមនុស្សជាច្រើនយល់ថា កំណើនសីតុណ្ហភាពជាប់ទាក់ទងនឹងកំណើន ការសាងសង់នៅទីក្រុង ឬការប្រើកញ្ចក់កាន់តែច្រើន និងចំណាំងផ្លាតពីអាគារម៉ាស៊ីន និងយានយន្ត។ ដូចតំណាងមួយរូបពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានពន្យល់ថា "ខ្ញុំបានឮពាក្យនេះ។ មនុស្សជាច្រើននិយាយថា ដោយសារយើងប្រើប្រាស់កញ្ចក់ច្រើន វាចាំងផ្លាតកម្តៅព្រះអាទិត្យមកវិញ ដូច្នេះខ្ញុំមិនដឹងថាវាត្រូវ ឬខុសទេ។"

**BBC World Service Trust,* Africa Talks Climate, 2010

ប្រជាជនជិត ៩០% ស្គាល់យ៉ាងហោចណាស់ពាក្យមួយ "ការប្រែប្រួលអាកាសធាតុ" ឬពាក្យ "ការឡើងកម្តៅផែនដី"។ ច្រើនជាង ៨ នាក់ ក្នុងចំណោម ១០ នាក់ (៨៤%) ស្គាល់ពាក្យ "ការប្រែប្រួលអាកាសធាតុ" ចំណែក ៧ នាក់ ក្នុងចំណោម ១០ នាក់ (៧០%) ពោលថាពួកគេស្គាល់ពាក្យ "ការឡើងកម្តៅផែនដី"។ ក្នុងចំណោមអ្នក ដែលស្គាល់ពាក្យទាំងពីរនេះភាគច្រើន (៧៣%) និយាយថាពួកគេយល់ពាក្យ "ការប្រែប្រួលអាកាសធាតុ" ច្រើនជាង។

បុរសចំនួន ៨៨% អ្នកផ្តល់សម្ភាសន៍នៅទីក្រុងចំនួន ៩១% និងអ្នកមានអាយុ ១៥-២៤ឆ្នាំ ចំនួន ៨៧% មានការសិក្សាកម្រិតសាកលវិទ្យាល័យចំនួន ៩៩% និងមនុស្សក្នុងក្រុមអ្នក ដែលមានរង្វាស់ PPI កម្រិត "ខ្ពស់" ចំនួន ៩៣% ធ្លាប់ឮពាក្យ "ការប្រែប្រួលអាកាសធាតុ"។

អ្នកផ្តល់សម្ភាសន៍ត្រូវបានស្នើសុំឲ្យផ្តល់សេចក្តីកាន់តែលម្អិត អំពីបច្ចេកស័ព្ទ ដែលពួកគេបាននិយាយដើម្បីស្វែងយល់ថា តើពួកគាត់យល់ដឹងកម្រិតណាពីអត្ថន័យនៃបច្ចេកស័ព្ទទាំងនោះ ។ ក្រាហ្វិចខាងក្រោមបង្ហាញពីបច្ចេកស័ព្ទ ដែលបានរៀបរាប់ញឹកញាប់ជាងគេ និងធ្វើការស្វែងយល់របស់ពួកគាត់លើបច្ចេកស័ព្ទទាំងពីរ ខាងក្រោម។

## ក្រាហ្វិចទី ៨

**សំរាប់ឃ្លា ( ការប្រែប្រួលអាកាសធាតុ/ការឡើងកម្តៅផែនដី) : តើអ្នកអាចនិយាយប្រាប់ខ្ញុំអំពីឃ្លាហ្នឹងឱ្យបានច្រើនតាមដែលអ្នកអាចប្រាប់បាន? ( មិនអានចម្លើយ)**




*សំណាក : អ្នកធ្លាប់ឮឃ្លាការប្រែប្រួលអាកាសធាតុច្រើនជាងការឡើងកម្តៅផែនដីN =១៥៨២សំណាក : អ្នកធ្លាប់លឺឃ្លាការឡើងកម្តៅផែនដីច្រើនជាងការប្រែប្រួលអាកាសធាតុN =៥១៩*

*ចម្លើយអាចច្រើនជាង ១*

ប្រជាពលរដ្ឋទំនងជាយល់ទាំងពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី" ដោយផ្សារភ្ជាប់ទៅនឹងផលប៉ះពាល់ជាជាងមូលហេតុរបស់វា។ អ្នកឆ្លើយភាគច្រើនបង្ហាញពីការជាប់ទាក់ទង នៃអត្ថន័យរបស់ពាក្យទាំងពីរជាមួយជម្ងឺ កំណើនសីតុណ្ហភាព និងការបាត់បង់ព្រៃឈើ ក្នុងមូលដ្ឋាន។ អ្នកឆ្លើយច្រើនជាងពាក់កណ្តាលបានកត់សម្គាល់អំពីការបាត់បង់ព្រៃឈើនៅ មូលដ្ឋាន និងមានតែមួយភាគប្រាំមួយប៉ុណ្ណោះ ដែលបានកត់សម្គាល់ថាកំណើនឧស្សាហកម្មមានជាប់ទាក់ទងជាមួយពាក្យទាំងពីរនេះ។

## *ប្រភពព័ត៌មាន នៃបច្ចេកស័ព្ទការប្រែប្រួលអាកាសធាតុ*

មនុស្សជាច្រើនបានឮពាក្យការប្រែប្រួលអាកាសធាតុ តាមរយៈការផ្សព្វផ្សាយ (៦២% ពីទូរទស្សន៍ និង ៥៨% ពីវិទ្យុ)។ បន្ទាប់មក គឺការឮពាក្យនេះ តាមការនិយាយពីមាត់មួយទៅមាត់មួយ ដោយ ៥០% នៃអ្នកផ្តល់សម្ភាសន៍បានឮពាក្យការប្រែប្រួលអាកាសធាតុ ពីអ្នកជិតខាងរបស់ខ្លួន ហើយ ១៨% ផ្សេងទៀតពោលថា បានឮពាក្យនេះពីមិត្តភក្តិ ឬអ្នករួមការងារ។

## ក្រាហ្វិចទី ៩




*សំណាក : ធ្លាប់ឮយ៉ាងហោចឃ្លា ១ ក្នុងចំណោមឃ្លាទាំងពីរ N =២១០៩*

ទូរទស្សន៍គឺជាប្រភពមួយ នៃការឮពាក្យនេះ សម្រាប់ប្រជាជននៅទីក្រុង (៧៧%) និងជាពិសេសអ្នកនៅរាជធានីភ្នំពេញ (៨៧%)។ ក្នុងចំណោមក្រុម ដែលមាន PPI កម្រិតខ្ពស់ (៧៧% ក្រុមមាន PPI កម្រិត "ខ្ពស់") និងអ្នកមានការសិក្សាកម្រិតខ្ពស់ (៨៦% ជាអ្នកសិក្សានៅសាកលវិទ្យាល័យ) ពោលថាបានឮពាក្យនេះពីទូរទស្សន៍។

វិទ្យុគឺជាប្រភពសំខាន់មួយ សម្រាប់អ្នកនៅជនបទយ៉ាងច្រើន (៦២%)។

ភាគរយនៃស្ត្រី (៥៤%) ច្រើនជាងបុរស (៤៦%) និងប្រជាជនកម្ពុជានៅជនបទ (៥៣%) ច្រើនជាងអ្នកទីក្រុង (៤៤%) បានឮពាក្យ "ការប្រែប្រួលអាកាសធាតុ" ឬ "ការឡើងកម្ដៅផែនដី" ពីអ្នកជិតខាងរបស់ខ្លួន។

ក្នុងចំណោមអ្នក ដែលមាន PPI ទាបជាងគេ (៥៣% ពីក្រុមមាន PPI "ទាប") និងមានការសិក្សាកម្រិតទាប (៥៧% នៃអ្នកមិនបានចូលរៀន) បានពោលថាពួកគេឮពាក្យទាំងនេះពីអ្នកជិតខាងច្រើនជាងក្រុមដទៃទៀតនៅក្នុងសំណាក។

បុរស (២៤%) អ្នកទីក្រុង (២២%) និងអ្នកមានកម្រិតឧត្តមសិក្សា (៣៥% នៃអ្នកសិក្សាថ្នាក់សាកលវិទ្យាល័យ) ពោលថាបានឮពាក្យនេះពីមិត្តភក្តិ និងអ្នករួមការងារ។

សារព័ត៌មានគឺជាប្រភពនៃពាក្យនេះសម្រាប់ប្រជាជន ២១% នៅភ្នំពេញ និងភាគរយទាបជាងនេះ សម្រាប់អ្នកនៅតំបន់នានាផ្សេងទៀត។ អ្នកផ្ដល់សម្ភាសន៍ ដែលមានកម្រិតឧត្តមសិក្សា (៣០% នៃអ្នកសិក្សាកម្រិតសាកលវិទ្យាល័យ) និងអ្នកមានជីវភាពធូរធារ (២០% នៃក្រុមដែលមាន PPI កម្រិតខ្ពស់) បានឃើញពាក្យនេះ នៅក្នុងសារព័ត៌មាន និងទស្សនាវដ្ដី។

មនុស្សមួយចំនួនតូចបំផុតពោលថាពួកគេឮពាក្យនេះពីអាជ្ញាធរនានា (តំណាងក្រុមប្រឹក្សាឃុំ និងប្រធានភូមិ)។

មនុស្សមួយចំនួនតូចពោលថាបានឮពាក្យនេះនៅសាលារៀន ប៉ុន្តែមនុស្សជាច្រើនទៀត ដែលមានអាយុពី ១៥ ដល់ ២៤ ឆ្នាំ (២៣%) និងអ្នកដែលមានការសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ (២៣%) បានឮពាក្យនេះនៅសាលារៀន។ ប្រការនេះអាចឆ្លុះបញ្ចាំងពីការរួមបញ្ចូលវិទ្យាសាស្ត្រអាកាសធាតុទៅក្នុងមុខវិជ្ជាផែនដីវិទ្យា នៅថ្នាក់មធ្យមសិក្សាបឋមភូមិ។

## ការយល់ដឹងពីមូលហេតុ នៃការប្រែប្រួលអាកាសធាតុ

**ទស្សនៈសំខាន់ៗ**

ទោះបីមានតែភាគរយទាប នៃប្រជាជនកម្ពុជាបានកត់សម្គាល់ភ្លាមៗ ដោយងាយអំពីសកម្មភាពមនុស្ស ថាជាមូលហេតុនៃការប្រែប្រួលធាតុអាកាសក៏ដោយ នៅពេលសួរផ្ទាល់ មួយភាគបីបានឯកភាពថា សកម្មភាពរបស់ខ្លួនផ្ទាល់រួមចំណែកក្នុងបញ្ហានេះ។ អ្នកឆ្លើយភាគច្រើនបន្ទោសការបាត់បង់ព្រៃឈើថាជាមូលហេតុ នៃការប្រែប្រួលធាតុអាកាស។ អ្នកឆ្លើយមានសមាមាត្រទាប ប៉ុន្តែមានទំនាក់ទំនងយ៉ាងសំខាន់បានដាក់បន្ទុកលើការបំពុលពីឧស្សាហកម្ម រថយន្ត និងប្រេងឥន្ធនៈផូស៊ីលជាទូទៅ។

នៅពេលសួរដោយគ្មានការសួរដេញជាបន្ត អំពីអ្វីដែលពួកគេគិតថាបានបង្កឲ្យធាតុអាកាសប្រែប្រួលនៅកម្ពុជា អ្នកឆ្លើយពីរភាគបី (៦៧%) គិតថាការបាត់បង់ព្រៃឈើនៅកម្ពុជាបង្កឲ្យធាតុអាកាសប្រែប្រួល ចំណែកត្រឹមបីភាគរយកត់សម្គាល់ អំពីការបាត់បង់ព្រៃឈើនៅប្រទេសដទៃ។ អ្នកឆ្លើយត្រឹម ១៨% និយាយថាការបំពុលពីឧស្សាហកម្មគឺជាមូលហេតុមួយ ដែលបង្កឲ្យធាតុអាកាសប្រែប្រួល។

អ្នកផ្តល់សម្ភាសន៍ ២៩% ពោលថា ពួកគេពុំដឹងពីមូលហេតុ ដែលធ្វើឲ្យប្រែប្រួលធាតុអាកាសទេ ចំណែកត្រឹម ១១% ពោលអំពីការបើកបររថយន្ត និងយានយន្តនានា។

## ក្រាហ្វិចទី ១០




ក្រោយពីបានផ្តល់ចម្លើយតបនឹងសំណួរ ដែលគ្មានការសួរដេញជាបន្តដូចមានបង្ហាញជូន នៅក្នុងក្រាហ្វិចទី ១០ បន្ទាប់មកពួកគេត្រូវសួរដេញបន្ត តាមរយៈបញ្ជីសំណួរ។ បញ្ជីនេះមានចម្លើយត្រឹមត្រូវ និងមិនត្រឹមត្រូវអំពីមូលហេតុ នៃការប្រែប្រួលអាកាសធាតុពិភពលោក (ខ្លឹមសារនៃបញ្ជីសំណួរនេះបានមកពីការស្រាវជ្រាវពីមុនមករបស់អង្គការ BBC World Service Trust អំពីការប្រែប្រួលអាកាសធាតុ)។[៣១] អ្នកផ្តល់សម្ភាសន៍ត្រូវបានអនុញ្ញាតឲ្យឆ្លើយថាមែន ឬមិនមែន ឬមិនដឹង។ ចម្លើយមិនដឹងមានបង្ហាញក្នុងក្រាហ្វិចខាងក្រោម។

ទិន្នន័យនេះបង្ហាញថាអ្នកផ្តល់សម្ភាសន៍មិនបានយល់ច្បាស់ អំពីមូលហេតុត្រឹមត្រូវ នៃការប្រែប្រួលអាកាសធាតុឡើយ ក្នុងនោះ ៦៥% ពោលថាពួកគេមិនដឹង ឬដឹងមិនច្បាស់ថាតើការបំភាយឧស្ម័នផ្ទះកញ្ចក់ជាមូលហេតុធ្វើឲ្យប្រែប្រួលធាតុអាកាសឡើយ ហើយ ២៣% និយាយដូចគ្នានេះ អំពីការប្រើប្រាស់ប្រេងឥន្ធនៈផូស៊ីល (ចម្លើយត្រឹមត្រូវ សម្រាប់សំណួរទាំងពីរនេះគឺ "មែន")។ ៥២% ដឹងមិនច្បាស់ទេថាតើការធ្លុះធ្លាយស្រទាប់អូហ្សូនមានឥទ្ធិពលមកលើធាតុអាកាស ឬយ៉ាងណា។ គំនិតដែលថាការធ្លុះធ្លាយស្រទាប់អូហ្សូនជាប់ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ គឺជាការយល់ខុសដ៏សំខាន់មួយ

---

៣១ *Africa Talks Climate, 2009*. See www.africatalksclimate.com

ដែលបានរកឃើញដោយការស្រាវជ្រាវនៅចក្រភពអង់គ្លេស និងអាហ្វ្រិក[៣២] (ចម្លើយត្រឹមត្រូវចំពោះសំណួរនេះគឺ "មិនមែន")។

ក្រាហ្វិចទី ១១




## ការប្រែប្រួលធាតុអាកាស និងសកម្មភាពមនុស្ស

## តើសកម្មភាពរបស់មនុស្សម្នាក់ៗរួមចំណែកដល់ការប្រែប្រួលអាកាសធាតុដែរឬទេ?

តាមរយៈការសម្ភាសបង្ហាញថា អ្នកផ្តល់សម្ភាសន៍មួយភាគបី (៣៣%) ឆ្លើយថាសកម្មភាពផ្ទាល់របស់ពួកគេម្នាក់ៗរួមចំណែកដល់ការប្រែប្រួលអាកាសធាតុ។

- បុរសលើសពី ៤២% អ្នកទីក្រុង (៤០%) អ្នកមានការសិក្សាថ្នាក់ឧត្តម (៨២% សិក្សាថ្នាក់សាកលវិទ្យាល័យ) និងអ្នកមានកម្រិតជីវភាពលើសទ្ធស្សន៍ភាពក្រីក្រ (៤៨% មានកម្រិត "ខ្ពស់") ពោលថាសកម្មភាព របស់ពួកគេរួមចំណែកដល់ការប្រែប្រួលអាកាសធាតុ។
- អាយុក៏ជាកត្តាមួយជះឥទ្ធិពលដល់ការយល់ឃើញនេះផងដែរ។ លទ្ធផល នៃការសម្ភាសបង្ហាញថា អ្នកមានវ័យក្មេងច្រើនជាង ៣៩% (អ្នកមានអាយុ១៥ ទៅ ២៤ឆ្នាំ) ពោលថាសកម្មភាព របស់ពួកគេ រួមចំណែកដល់ការប្រែប្រួលអាកាសធាតុ។

---

[៣២] Ibid. សូមអានផងដែរ នូវការវាស់ស្ទង់ចំណេះដឹង នៃការប្រែប្រួលអាកាសធាតុ របាយការណ៍ដំណាក់កាលទី ១ នៃគម្រោងESPACE ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ: ការលើកកម្ពស់ចំណេះដឹងរបស់សហគមន៍ ក្នុង West Sussex ក្រុមប្រឹក្សា West Sussex County, UK ២០០៥

- គ្រូបង្រៀន (៦៣%) និស្សិត (៦៦%) អ្នកគ្រប់គ្រងបច្ចេកទេសវិជ្ជាជីវៈ (៤៣%) និងមន្ត្រីរាជការ (៥២%) ពោលថា សកម្មភាពរបស់ពួកគេរួមចំណែកក្នុងបញ្ហានេះ។
- ស្ត្រី (៦២%) អ្នកជនបទ (៥៨%) អ្នកមានកម្រិតសិក្សាទាប (៦២% មិនបានចូលរៀន) និងក្រុមមានកម្រិតជីវភាពទាបជាងរង្វាស់សន្ទស្សន៍ នៃភាពក្រីក្រ (៥៩% មកពីក្រុមរង្វាស់សន្ទស្សន៍ នៃភាពក្រីក្រកម្រិត "ទាបបំផុត" និង ៥៩% មកពីក្រុមរង្វាស់សន្ទស្សន៍ នៃភាពក្រីក្រកម្រិត "ទាប") ពោលថាសកម្មភាពរបស់ខ្លួនពុំរួមចំណែកដល់ការប្រែប្រួលអាកាសធាតុឡើយ ឬពោលថា ពួកគេមិនដឹងថាសកម្មភាព របស់ខ្លួនរួមចំណែកដែរឬមួយក៏អត់ទេ។
- កសិករ (៥៩%) ពោលថាសកម្មភាព របស់ខ្លួនពុំរួមចំណែក ចំពោះបញ្ហានេះឡើយ ឬពោលថាមិនដឹងថា មានការរួមចំណែក ឬមួយយ៉ាងណានោះទេ។
- មេផ្ទះ (៦៧%) និងសហគមន៍នេសាទតំបន់ឆ្នេរ (៧១%) ពោលថា សកម្មភាព របស់ខ្លួនមិនបានរួមចំណែកដល់ការប្រែប្រួលអាកាសធាតុឡើយ។

អ្នកដែលគិតថាសកម្មភាព របស់ខ្លួនរួមចំណែកដល់ការប្រែប្រួលអាកាសធាតុបានផ្តល់យោបល់ថា ការប្រើប្រាស់គ្រឿងម៉ាស៊ីន (៤៤%) ការដុតអុស សម្រាប់ចម្អិនអាហារ (៤០%) ការដុតកាកសំណល់ (៣៧%) ការចម្អិនអាហារ (២៧%) និងការប្រើប្រាស់សារធាតុគីមី (១៦%) គឺជាមូលហេតុធ្វើឲ្យមានការប្រែប្រួលអាកាសធាតុដោយឡែកៗពីគ្នា។

ក្រាហ្វិចទី ១២




សំណាក : អ្នកដែលគិតថាសកម្មភាពរបស់ខ្លួនចូលរួមធ្វើឱ្យមានការប្រែប្រួលអាកាសធាតុN= ៧៩៧ ចម្លើយអាចច្រើនជាង ១

## ការប្រើប្រាស់គ្រឿងម៉ាស៊ីន

បុរស (៥៣%) អ្នកទីក្រុង (៥៨%) អ្នកដែលបានសិក្សានៅសាកលវិទ្យាល័យ (៧៧%) និង អ្នកដែលនៅក្នុងក្រុម PPI កម្រិត ខ្ពស់ (អ្នកមាន) (៦៩%) និងកសិករ (៥៤%) ពោលថា ពួកគេរួមចំណែកដល់ការប្រែប្រួលអាកាសធាតុ តាមរយៈ

ការប្រើប្រាស់គ្រឿងយន្ត។ សមាមាត្រខ្ពស់ (៨០%) នៃអ្នករស់នៅក្រុងភ្នំពេញបានពោលថា ពួកគេរួមចំណែកដល់ការប្រែប្រួលអាកាសធាតុ តាមរយៈការប្រើប្រាស់គ្រឿងយន្ត។

### ការដុតអុស សម្រាប់ចម្អិនអាហារ

បុរសច្រើនជាងមុន (៤៥%) អ្នកជនបទច្រើនជាងមុន (៥២%) អ្នករស់នៅតំបន់ឆ្នេរ (៦៥%) និងអ្នកនៅតំបន់ភ្នំ (៥២%) និងអ្នកមានកម្រិតការសិក្សាទាប (៥៦% មិនបានចូលរៀន) និងអ្នកមកពីក្រុម PPI កម្រិតទាប (៧០% មកពី PPI កម្រិត "ទាបបំផុត") និងអ្នកមិនបានរៀននៅកម្រិតឧត្តមក៏ពោលដូចគ្នានេះដែរ។

### ការដុតសំរាម

ការយល់ឃើញរបស់បុរស និងស្ត្រី ឬក៏រវាងអ្នកនៅទីក្រុង និងជនបទ ចំពោះមូលហេតុថាការដុតសំរាមជាការរួមចំណែកមួយដល់ការប្រែប្រួលអាកាសធាតុ គឺពុំមានភាពខុសប្លែកគ្នាឡើយ។ ចំពោះអ្នករស់នៅភ្នំពេញ (៤៥%) អ្នករស់នៅតំបន់ទំនាប (៤៥%) និងអ្នករស់នៅតំបន់បឹងទន្លេសាប (៤០%) ក្រុមយុវជន (៤៤% មានអាយុ១៥ដល់២៤ឆ្នាំ) អ្នករៀនថ្នាក់មធ្យមសិក្សាបឋមភូមិ (៤០%) និងរៀនថ្នាក់មធ្យមសិក្សាទុតិយភូមិ (៤៩%) និងក្រុម PPI ខ្ពស់បំផុតលំដាប់ទីពីរ (ដែលមានពិន្ទុចាប់ពី ៥០ ទៅ ៧៤) យល់ថា ការដុតសំរាមជាមូលហេតុនាំឲ្យមានការប្រែប្រួលអាកាសធាតុ។

### ការចម្អិនអាហារ

អ្នកផ្តល់បទសម្ភាសន៍នៅភ្នំពេញ (៤៥%) និងតំបន់បឹងទន្លេសាប (៣៣%) យល់ឃើញថាការចម្អិនអាហារជាមូលហេតុ នៃការប្រែប្រួលអាកាសធាតុ ដោយអាយុ២៥ ដល់ ៣៥ឆ្នាំ មាន ២៩% និង៣៥ ដល់ ៤៤ឆ្នាំ មាន ៣៨% ។

### ការប្រើប្រាស់សារធាតុគីមី

បុរស (១៩%) អ្នកនៅជនបទ (២០%) និងអ្នករស់នៅតំបន់ទំនាប (២៦%) ជាសមាមាត្រមួយខ្ពស់បើធៀបនឹងអនុក្រុមនានា បានពោលថាការប្រើប្រាស់សារធាតុគីមីជាទង្វើមួយដែលរួមចំណែកដល់ការប្រែប្រួលអាកាសធាតុ។

## *ការយល់ដឹងអំពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ*

ក្នុងចំណោមអ្នក ដែលបានឮពាក្យថា "ការប្រែប្រួលអាកាសធាតុ" ស្ទើរតែទាំងអស់ (៩៨%) ពោលថាការប្រែប្រួលអាកាសធាតុកំពុងមានឥទ្ធិពលលើប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ហើយភាគច្រើន (៧៥%)បានរៀបរាប់ថាការប្រែប្រួលអាកាសធាតុនឹងបង្កផលប៉ះពាល់មកលើកម្ពុជានាពេលអនាគត។

**ទស្សនៈសំខាន់ៗ**

អ្នកឆ្លើយបទសម្ភាសន៍ ដែលធ្លាប់ឮពាក្យ "ការប្រែប្រួលអាកាសធាតុ" ស្ទើរតែទាំងអស់ (៩៨%) ពោលថាពួកគេគិតថាកម្ពុជាកំពុងរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ។ ពួកអ្នកទាំងនោះយល់ឃើញថាសុខភាពមនុស្ស និងវិស័យកសិកម្មទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ។ ប្រជាជនកម្ពុជាជាច្រើន (២២%) មានប្រសាសន៍ថាពួកគេមិនដឹងថាតើកម្ពុជានឹងរងផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុនាអនាគតឬយ៉ាងណានោះទេ ហើយពួកគាត់ក៏បានអះអាងថាប្រជាជនមិនបានដឹងច្បាស់ថាការប្រែប្រួល ដែលពួកគេបានជួបប្រទះក្នុងជីវិតប្រចាំថ្ងៃនឹងមានឥទ្ធិពលលើពួកគេក្នុងរយៈពេលវែង ឬមួយយ៉ាងណា។

## ក្រាហ្វិចទី ១៣

**នៅពេលបច្ចុប្បន្ននេះ តើអ្នកគិតថាការប្រែប្រួលអាកាសធាតុជះឥទ្ធិពលដល់ប្រទេសកម្ពុជាដែរឬទេ?**
**តើអ្នកគិតថាការប្រែប្រួលអាកាសធាតុនឹងមានឥទ្ធិពលមកលើប្រទេសកម្ពុជាទៅថ្ងៃអនាគតដែរឬទេ?**




សំណាកៈ ធ្លាប់ឮពាក្យថា "ការប្រែប្រួលអាកាសធាតុ N = ២០៧៧

ប្រជាជនកម្ពុជា ២២% ពោលថា ពួកគេមិនដឹងថាតើកម្ពុជានឹងរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនាពេលអនាគតឬមួយយ៉ាងណា ដោយសារប្រជាជនខ្លះនៅមិនទាន់យល់ពាក្យ "ការប្រែប្រួលអាកាសធាតុ" សំដៅលើបាតុភូតរយៈពេលវែងឡើយ។

អ្នកតាមទីជនបទ (២៥%) ធៀបនឹងអ្នកទីក្រុង (១៧%) មានប្រសាសន៍ថា ពួកគេមិនដឹងថាតើកម្ពុជានឹងរងផលប៉ះពាល់ដែរឬទេនាពេលអនាគត។

ប្រជាជនដែលមានកម្រិតការសិក្សាទាបជាងគេជាច្រើន (២៩% នៃអ្នកមិនបានចូលរៀន) បញ្ចេញមតិ ពួកគេមិនដឹងថាតើប្រទេសកម្ពុជានឹងរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែរឬទេនាពេលអនាគត។

ចំពោះអ្នក ដែលឆ្លើយថាពួកគេធ្លាប់បានឮពាក្យថា "ការប្រែប្រួលអាកាសធាតុ" ហើយបានផ្តល់ចម្លើយថាពួកគេគិតថាកម្ពុជាកំពុងរងផលប៉ះពាល់ ឬនឹងរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនោះ គឺត្រូវបានសួរផងដែរអំពីផលប៉ះពាល់អ្វីខ្លះ ដែលពួកគេគិតថាអាចកើតឡើងដោយសារការប្រែប្រួលធាតុអាកាស។

## ក្រាហ្វិចទី ១៤

*តើអ្វីជាផលប៉ះពាល់ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុដល់ប្រទេសកម្ពុជា? ( មិនអានចម្លើយ)*




*សំណាក : ធ្លាប់ឮពាក្យ ការប្រែប្រួលអាកាសធាតុ ហើយគិតថាវាជះឥទ្ធិពលមកប្រទេសកម្ពុជា បច្ចុប្បន្ន ឬ អនាគត N = ១៥0៥* *ចម្លើយអាចច្រើនជាង១*

អ្នកផ្តល់សម្ភាសន៍គិតថាសុខភាពមនុស្ស និងវិស័យកសិកម្មទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេពីការប្រែប្រួលធាតុអាកាស។ ប្រជាជន ៥៩% រៀបរាប់អំពីផលប៉ះពាល់មកលើសុខភាព ហើយ ៤៧% បញ្ជាក់ថាការដាំដំណាំមានភាពលំបាកជាងមុន និងមានអ្នកមួយចំនួនទៀត(៣៦%) បានរៀបរាប់អំពីបញ្ហា ភាពរាំងស្ងួត និង ៣៥% បញ្ជាក់អំពីកំណើនសីតុណ្ហភាព ។ ប្រមាណមួយភាគបួន (២៨%) កត់សម្គាល់អំពីការថយចុះទិន្នផលកសិកម្ម និង ២៤% រៀបរាប់អំពីបញ្ហាកង្វះទឹក ។

# កង្វល់អំពីការប្រែប្រួលធាតុអាកាស និងបរិស្ថាន

ការស្វែងយល់អំពីការយល់ឃើញរបស់ប្រជាជន ចំពោះការប្រែប្រួលធាតុអាកាស និង ទំនាក់ទំនងរវាងពាក្យថា "ការប្រែប្រួលអាកាសធាតុ" និង "ការកើនឡើងកំដៅផែនដី" ចំពោះក្តីបារម្ភរបស់ពួកគេ គឺជារឿងមួយសំខាន់។

វាជាការមួយសំខាន់ ដែលត្រូវស្វែងយល់អំពីវិធី ដែលប្រជាជនស្វែងយល់ដឹង អំពីការប្រែប្រួលធាតុអាកាស និងអំពីពាក្យ "ការប្រែប្រួលអាកាសធាតុ" និង"ការឡើងកម្តៅផែនដី" ដែលទាក់ទងនឹងការព្រួយបារម្ភសំខាន់ៗរបស់ពួកគេ។ ក្នុងពេលសម្ភាសន៍ អ្នកស្រាវជ្រាវបានអានបញ្ហាតាមចំណុចនីមួយៗ នៅក្នុងបញ្ជីអោយអ្នកឆ្លើយសំណួរស្តាប់ ហើយ អ្នកសម្ភាសន៍បានសួរថាតើការងារនោះជាការងារមានអាទិភាពខ្ពស់ ជាអាទិភាព ឬមិនមែនជាអាទិភាព សម្រាប់ប្រទេសកម្ពុជា។ នៅក្នុងការឆ្លើយតបទៅនឹងសំណួរទាំងនេះ ប្រជាជនបីភាគបួន ឆ្លើយថាការប្រែប្រួលអាកាសធាតុ និងការឡើងកម្តៅភពផែនដី គឺជាការងារអាទិភាព សម្រាប់ប្រទេសកម្ពុជា។ ចម្លើយនេះមានភាពស្របគ្នានឹងការស្រាវជ្រាវផ្សេង

ទៀត ដែលបានធ្វើឡើងលើប្រធានបទនេះ។[៣៣] ទោះជាយ៉ាងណាក៏ដោយ ក្រៅពីនេះក៏មានការព្រួយបារម្ភជាច្រើនផ្សេងទៀត ដែលតម្រូវឲ្យប្រជាជនយកចិត្តទុកដាក់ផងដែរ ដោយប្រជាជន ៩៣% យល់ឃើញថា នាពេលបច្ចុប្បន្ន សុខភាពគឺជាក្ដីបារម្ភដ៏ចំបងរបស់ប្រជាជន ចំពោះប្រទេសជាតិ។

**ក្រាហ្វិចទី ១៥**




បើប្រៀបធៀបនឹងបញ្ហាបរិស្ថានផ្សេងទៀត "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្ដៅផែនដី" មិនស្ថិតនៅជាអាទិភាពខ្ពស់បំផុតនៅឡើយ ទោះបីជាវាស្ថិតក្នុងចំណោមអាទិភាពខ្ពស់ទូទៅចំនួនដប់ ដែលអ្នកឆ្លើយសំណួរបានកត់សម្គាល់ក៏ដោយ។ ក្នុងបញ្ជីអាទិភាព ការបាត់បង់ព្រៃឈើ និងភាពរាំងស្ងួត មានអាទិភាពខ្ពស់ជាងវិស័យទាំងពីរចំនួន ១០ ភាគរយ ។ ក្នុងបញ្ជីខាងលើ ការឡើងកម្ដៅភពផែនដី មានអាទិភាពខ្ពស់ជាងការប្រែប្រួលអាកាសធាតុបន្តិចបន្តួច នេះប្រហែលជាប្រជាជនយល់ពាក្យ "ការកើនឡើងកំដៅផែនដី" ជាភាសាខ្មែរ[៣៤] ថាជាការកើនកំដៅសីតុណ្ហភាពដី ដូច្នេះវាមានទំនាក់ទំនងនឹងភាពរាំងស្ងួត។ លទ្ធផលលម្អិតខាងលើ ដែលបង្ហាញថាការបាត់បង់ព្រៃឈើ ជាបញ្ហាបរិស្ថានចំបងបំផុតនោះ មិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលឡើយ។

## *ជីវិតគ្រួសារ ការងារ និងកសិកម្ម*

នៅក្នុងបរិបទ នៃជីវិតគ្រួសារ ការងារ និងកសិកម្ម ប្រជាពលរដ្ឋពោលថាការប្រែប្រួលធាតុអាកាសបង្ក នូវជម្ងឺ ដែលធ្វើឲ្យមានការលំបាក ក្នុងការដាំដុះ និងលំបាកក្នុងការធ្វើការងារ។

---

[៣៣] *សូមអានការយល់ឃើញ និងការទទួលបានព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ៖ តើយើងបានដឹងអ្វីខ្លះហើយ?, ទំព័រ២*

[៣៤] *ការឡើងកម្ដៅផែនដី សូមអាន ការបកប្រែពាក្យការប្រែប្រួលអាកាសធាតុ, ទំព័រ២៣*

- បុរសជាច្រើនព្រួយបារម្ភថា ការប្រែប្រួលធាតុអាកាសនាំឱ្យកាន់តែលំបាកធ្វើការ (៤៨%) លំបាកដាំដុះ (៥៤%) និង លំបាកធ្វើដំណើរ (៣៩%) និងមួយចំនួនទៀត (១៤%) បារម្ភថា ការប្រែប្រួលធាតុអាកាសនឹងធ្វើឲ្យមានការចំណាយកាន់តែច្រើនលើអគ្គិសនី និងទឹក។

- ស្ត្រីចំនួន ១៧% មានកង្វល់អំពីកង្វះទឹក ៤% បារម្ភពីការធ្លាក់ភ្លៀងខ្លាំង និង ៣៩% ព្រួយបារម្ភថាការប្រែប្រួលធាតុអាកាសនឹងធ្វើឱ្យ លំបាកសំរាន្ត (៣៩%)។

- នៅជនបទប្រជាជន ៦២% មានការព្រួយបារម្ភថា ការប្រែប្រួលធាតុអាកាសនឹងធ្វើឱ្យកាន់តែលំបាកដាំដំណាំ ៤០% បារម្ភថាទិន្នផលកសិកម្មមានការធ្លាក់ចុះ និង ១៥% យល់ថានឹងជួបបញ្ហាខ្វះខាតទឹក ។

- ក្នុងទីក្រុងភ្នំពេញ មានប្រជាជនច្រើនជាងតំបន់ផ្សេងទៀត ដែលមានកង្វល់ថាការប្រែប្រួលធាតុអាកាសនាំឱ្យមានការលំបាក ក្នុងការធ្វើដំណើរ (៥៧%) កំណើនការចំណាយ (៣៤%) និងលំបាកសំរាន្ត (៧%)។

- ក្រុមមនុស្សចាស់មានការបារម្ភអំពីការប្រែប្រួលធាតុអាកាស ដែលបង្កឱ្យមានជម្ងឺ (៦៨% ក្នុងចំណោមមនុស្សមានអាយុពី ៤៥-៥៥ ឆ្នាំ)។

- អ្នកមានអាយុតិចបានពោលថាការប្រែប្រួលធាតុអាកាសធ្វើឱ្យកាន់តែលំបាកធ្វើការ (៤៩% នៃអ្នកមានអាយុ១៥-២៤ឆ្នាំ) និងធ្វើឲ្យមានភ្លៀងធ្លាក់ខ្លាំង (៤%)។

- ប្រជាជន ដែលមានកម្រិតសន្ទស្សន៍ភាពក្រីក្រទាបជាងគេ និងដែលមានការសិក្សាកម្រិតទាបមានការបារម្ភអំពីផលប៉ះពាល់ នៃការប្រែប្រួលធាតុអាកាសមកលើការដាំដំណាំ (៧០% ក្នុងចំណោមក្រុម ដែលមានកម្រិត "ទាបជាងគេ" និង ៦៥% ក្នុងចំណោមអ្នកមិនបានចូលរៀន) និងទិន្នផលកសិកម្ម (៤៤% ក្នុងចំណោមក្រុម "ក្រីក្រជាងគេ" និង ៤២% ក្នុងចំណោមអ្នកមិនបានចូលរៀន)។

- អ្នកដែលមានការសិក្សាត្រឹមកម្រិតបឋមសិក្សា (១៦%) និងក្រុមអ្នកក្រីក្រលំដាប់ទី២ និងទី៣ (២៩% នៃក្រុមដែលមានសន្ទស្សន៍ភាពក្រីក្ររវាង ២៥ និង៧៤) បង្ហាញពីក្តីបារម្ភចំពោះបញ្ហាកង្វះទឹក។

- អ្នកដែលបានកម្រិតឧត្តមចំនួន ៧៧% បារម្ភថាការប្រែប្រួលធាតុអាកាសអាចនាំមក នូវជម្ងឺ និង ៥៨% យល់ថាការធ្វើការនឹងមានភាព លំបាកជាងមុន ។

- ក្រុមអ្នក ដែលមានកម្រិតឧត្តម និងក្រុមដែលមានតួលេខនៃរង្វាស់សន្ទស្សន៍ភាពក្រីក្រខ្ពស់មានការបារម្ភថាការប្រែប្រួលធាតុអាកាសនេះនឹងធ្វើឱ្យការធ្វើដំណើរកាន់តែមានភាពលំបាក (៤៧% នៃអ្នកសិក្សានៅសាកលវិទ្យាល័យ និង៤៥% នៃអ្នកដែលស្ថិតក្នុងក្រុមមានរង្វាស់សន្ទស្សន៍នៃភាពក្រីក្រខ្ពស់) និងកំណើនការចំណាយលើសេវានានាដូចជាអគ្គិសនី និងទឹក (៣០% នៃអ្នកសិក្សានៅសាកលវិទ្យាល័យ និង៣១% នៃអ្នកនៅក្នុងក្រុម រង្វាស់សន្ទស្សន៍នៃភាពក្រីក្រខ្ពស់)។

- កសិករមានការបារម្ភថា ការប្រែប្រួលធាតុអាកាសនឹងនាំឱ្យមានការលំបាក ក្នុងការដាំដំណាំ (៧២%) និងទិន្នផលថយចុះ (៤៨%)។ មន្ត្រីរដ្ឋាភិបាលលើសពី ៥០% មានការបារម្ភអំពីទិន្នផល។ អ្នកធ្វើការដោយកម្លាំងពលកម្ម (៦៥%) បារម្ភថាការប្រែប្រួលធាតុអាកាសនឹងធ្វើឱ្យកាន់តែលំបាកធ្វើការ។

## ការចិញ្ចឹមជីវិត និងការប្រែប្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុ ទំនងជាមានផលប៉ះពាល់យ៉ាងខ្លាំង លើការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ដោយអ្នកសម្ភាសន៍ ៥៨% បានពោលថា ពួកគេទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និង ៣៧% ពោលថាពួកគេបានរងគ្រោះពីការប្រែប្រួលធាតុអាកាស។

### ក្រាហ្វិចទី ១៦




កសិករ ៧៤% និងអ្នករស់នៅក្នុងសហគមន៍នេសាទទឹកសាប ៧១% ពោលថាការប្រែប្រួលធាតុអាកាសបានបង្កឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់មុខរបរចិញ្ចឹមជីវិតរបស់ពួកគេ។ ។

- បុរស (៦០%) ច្រើនជាងស្ត្រី (៥៦%) ពោលថាការងាររបស់ពួកគេរងឥទ្ធិពលយ៉ាងខ្លាំងពីការប្រែប្រួលធាតុអាកាស។
- អ្នកផ្តល់សម្ភាសន៍នៅជនបទ (៦៧%) ច្រើនជាងនៅទីក្រុង (៤២%) ពោលថាពួកគេរងគ្រោះធ្ងន់ធ្ងរ។ ចំណែកឯអ្នកនៅទីក្រុង (៩%) ធៀបនឹង (៣%) នៃអ្នកនៅជនបទ ពោលថាពួកគេមិនទទួលរងគ្រោះដោយសារការប្រែប្រួលធាតុអាកាសឡើយ។

ប្រជាជនមកពីភ្នំពេញ ១២% និងតំបន់ទំនាប ៨% ពោលថាការងាររបស់ពួកគេមិនទទួលរងឥទ្ធិពលការប្រែប្រួលធាតុអាកាសឡើយ។ ចំណុចនេះទំនងជាស៊ីគ្នាជាមួយការឆ្លើយរបស់ពួកគេទាក់ទងនឹងការប្រែប្រួលធាតុអាកាសខ្លាំង។ មានអ្នករស់នៅក្រុងភ្នំពេញ និងតំបន់ទំនាបតិចតួចពោលថា ពួកគេបានជួបប្រទះបញ្ហាធាតុអាកាសធ្ងន់ធ្ងរខ្លាំងនៅ ឆ្នាំមុនការអង្កេតនេះបានធ្វើឡើង។ អ្នកផ្តល់សម្ភាសន៍ មកពីតំបន់ឆ្នេរ ៩៩% ពោលថាការងាររបស់ពួកគេរងឥទ្ធិពលពីការប្រែប្រួលធាតុអាកាស ហើយជិតពីរភាគបី (៦៥%) នៃអ្នករស់នៅតំបន់ភ្នំពោលថាការងាររបស់ពួកគេរងឥទ្ធិពលខ្លាំងក្លា ដោយសារការប្រែប្រួលធាតុអាកាស។

ក្រុមអ្នកឆ្លើយសំណួរ ដែលមានវ័យក្មេងជាងគេ (១៥-២៤ឆ្នាំ) គឺជាក្រុមមានចំនួនតិចតួចជាងគេ បានពោលថាការងាររបស់ខ្លួនរងគ្រោះធ្ងន់ធ្ងរ ដោយសារការប្រែប្រួលធាតុអាកាស។ ក្រុមវ័យចំណាស់ជាងគេ (៤៥-៥៥ឆ្នាំ) ជាក្រុមដែលមានសមាមាត្រខ្ពស់ជាងគេ បានឆ្លើយថាការងាររបស់ខ្លួនមិនទទួលរងផលប៉ះពាល់ពីការប្រែប្រួលធាតុអាកាសឡើយ។

ក្រុម ដែលមានកម្រិតការសិក្សាទាប (៧៣% មិនបានចូលរៀន) និង ក្រុមមានរង្វាស់សន្ទស្សន៍នៃភាពក្រីក្រទាប (៧៣% ជាក្រុមមានកម្រិតរង្វាស់សន្ទស្សន៍នៃភាពក្រីក្រ "ទាបជាងគេ") ពោលថាការងាររបស់ខ្លួនរងគ្រោះជាខ្លាំងដោយសារការប្រែប្រួលធាតុអាកាស។ ចំណែកក្រុម ដែលមានកម្រិតរង្វាស់សន្ទស្សន៍នៃភាពក្រីក្រខ្ពស់បំផុតទាំងពីរពោលថា ការងាររបស់ពួកគេមិនរងឥទ្ធិពលពីការប្រែប្រួលធាតុអាកាសឡើយ (៦,៩% និង១១,២%)។

## *ធនធានទឹក និងការប្រែប្រួលអាកាសធាតុ*

### លទ្ធភាពទទួលបានទឹកប្រើប្រាស់ និងគុណភាព

អ្នកផ្ដល់សម្ភាសន៍ ត្រូវបានស្នើសុំឲ្យផ្ដល់យោបល់អំពីការយល់ឃើញរបស់ខ្លួនថាតើពួកគេគិតថាការទទួលបានទឹក និងគុណភាពទឹកប្រើប្រាស់មានភាពប្រសើរឡើងដែរឬទេ នៅក្នុងកន្លែងដែលពួកគេរស់នៅ។ ជិតពាក់កណ្ដាលគិតថាលទ្ធភាពទទួលបានទឹកមានភាពប្រសើរឡើង (៤៧%) និងចំនួនប្រហែលគ្នានេះ (៤៥%) គិតថាគុណភាពទឹកកំពុងមានការកែលម្អ។[៣៥,៣៦]

ទោះជាយ៉ាងណាក៏ដោយ ការយល់ឃើញផ្សេងៗគ្នាគួរឲ្យកត់សម្គាល់រវាងក្រុមផ្សេងៗ ចំពោះបញ្ហានេះនៅកើតមានឡើង។ បុរស ២៦% គិតថាលទ្ធភាពទទួលបានទឹកប្រើប្រាស់មានភាពយ៉ាប់យ៉ឺនជាងមុន។ ស្ត្រីមានការយល់ឃើញជាវិជ្ជមាន ដោយមានស្ត្រី ៤៨% យល់ថាគុណភាពទឹកមានការកែលម្អជាងមុន ។

អ្នកនៅទីក្រុងជាច្រើនគិតថាលទ្ធភាពទទួលបានទឹក និងគុណភាពទឹកកំពុងកែលម្អ (៦៥% សម្រាប់លទ្ធភាពទទួលបានទឹក និង៧៥% សម្រាប់គុណភាពទឹក) ហើយចំពោះសំណួរដូចគ្នានេះ អ្នករស់នៅក្នុងទីក្រុងភ្នំពេញ ៦៩% ឆ្លើយថាលទ្ធភាពទទួលបានទឹកមានភាពប្រសើរឡើង និង៦៥% ឆ្លើយថាគុណភាពទឹកមានការកែលម្អ) និងអ្នកនៅតំបន់ទំនាប ៥៦% ឆ្លើយថាលទ្ធភាពទទួលបានទឹកមានភាពប្រសើរឡើង និង៥២% ឆ្លើយថាគុណភាពទឹកមានការកែលម្អ។ ចម្លើយមានភាពខុសគ្នាយ៉ាងខ្លាំងក្នុងចំណោមអ្នកឆ្លើយនៅជនបទ។ ចំពោះចម្លើយទាក់ទងនឹងលទ្ធភាពទទួលបានទឹក លទ្ធផលបង្ហាញនូវចម្លើយ បីផ្សេង ដែលមានសមាមាត្រអ្នកឆ្លើយប្រហាក់ប្រហែលគ្នា។ យ៉ាងណាមិញ ចំពោះគុណភាពទឹក អ្នកឆ្លើយនៅជនបទចំនួន ៣០% គិតថាមានភាពកខ្វក់ជាងមុន។

អ្នក ដែលមានកម្រិតការសិក្សាទាបបំផុត (៣៨% មិនបានចូលរៀន) និងក្នុងចំណោមក្រុមមានកម្រិតPPI ទាបបំផុត (៣៧% ជាអ្នកមាន PPI ពី០-២៤) គិតថាលទ្ធភាពទទួលបានទឹកមានភាពយ៉ាប់យ៉ឺនជាងមុន។ ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានទឹកនេះដែរ អ្នកឆ្លើយ ដែលមានកម្រិត PPI មធ្យម (២៥ ទៅ ៧៤) ចំនួន ៦២% ពោលថាស្ថានភាពមិនអាក្រក់ហើយក៏មិនល្អជាងមុនដែរ។

---

[៣៥] ការសិក្សានេះមិនបានកំណត់រង្វាស់លទ្ធភាពទទួលបានទឹក ឬគុណភាពទឹកឡើយ ប៉ុន្តែគ្រាន់តែស្វែងយល់ពីការយល់ដឹង អំពីលទ្ធភាពទទួលបាន និងគុណភាពទឹក នៅក្នុងកន្លែងដែលពួកគេរស់នៅតែប៉ុណ្ណោះ។

[៣៦] ជំរឿនដោយរាជរដ្ឋាភិបាលកម្ពុជាឆ្នាំ១៩៩៨បានប៉ាន់ស្មានថាប្រជាជន២៩% មានលទ្ធភាពទទួលបានទឹកពីប្រភព ដែលបានកែលម្អ។*National Census of Cambodia,* Royal Government of Cambodia, Ministry of Planning, National Institute of Statistics, 1998. នៅឆ្នាំ២០០៦ អ.ស.ប បានប៉ាន់ស្មានថាតួលេខនេះបានកើនឡើងដល់៦៥% នៃចំនួនប្រជាជនដែលប្រើប្រាស់ទឹកពីប្រភព ដែលបានកែលម្អ។ *World Population Prospects, the 2006 Revision,* UN Population Division.

កសិករជាច្រើនបានឆ្លើយថាលទ្ធភាពទទួលបានទឹក និងគុណភាពទឹកមានភាពយ៉ាប់យ៉ឺនជាងមុន (៣៥% និង ៣១%)។ ស្រដៀងគ្នានេះដែរ លទ្ធផលទទួលបានទឹក ត្រូវបានលើកឡើងដោយប្រជាសហគមន៍តំបន់ឆ្នេរថា មានភាពយ៉ាប់ជាងមុន ហើយគុណភាពទឹកត្រូវបានរៀបរាប់ដោយសហគមន៍នេសាទទឹកសាបថា កាន់តែកខ្វក់ជាងមុន។[៣៧]

## ទឹក សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន

ប្រជាជនភាគច្រើន (៧៩%) ពោលថាពួកគេមានទឹកគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន។[៣៨] អ្នកទីក្រុង (៨៩%) អ្នកមានអាយុតិចជាងគេ (៨៣% នៃអ្នកមានអាយុ១៥-២៤ឆ្នាំ) និង អ្នកមានការសិក្សាកម្រិតឧត្តម (៩៤% ជាអ្នកដែលបានសិក្សានៅសាកលវិទ្យាល័យ) និង អ្នកមានវង្វាស់សន្ទស្សន៍នៃភាពក្រីក្រខ្ពស់ (៩៤% ជាអ្នកដែលមានវង្វាស់សន្ទស្សន៍នៃភាពក្រីក្រពី ៧៥ ដល់ ១០០) ពោលថាពួកគេមានទឹកគ្រប់គ្រាន់ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន។

ប្រការសំខាន់ជាងនេះគឺមិនមានភាពខុសគ្នារវាងចម្លើយរបស់បុរស និងស្ត្រី ទាក់ទងនឹងបរិមាណទឹក ដែលពួកគេមាន សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន។ របកគំហើញនេះមិនបានឆ្លុះបញ្ចាំងអំពីទស្សនៈរបស់បុគ្គលសំខាន់ៗ ដែលបានសម្ភាស នៅក្នុងការស្រាវជ្រាវគុណវិស័យ[៣៩]ដែលយល់ថាស្ត្រីនឹងរងផលប៉ះពាល់ពីកង្វះទឹកធ្ងន់ធ្ងរជាងបុរសនោះឡើយ។

ផ្ទុយទៅវិញ ប្រជាជនរស់នៅតំបន់បឹងទន្លេសាប (២៤%) ប្រជាជនតាមតំបន់ឆ្នេរ (៣៧%) និងកសិករជាច្រើន ពោលថាពួកគេពុំមានទឹកគ្រប់គ្រាន់ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនឡើយ។ ប្រជានេសាទ តំបន់ឆ្នេរជាច្រើនបានរាយការណ៍ថាពួកគេពុំមានទឹកគ្រប់គ្រាន់ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនឡើយ។

ក្នុងពេល ដែលមនុស្សភាគច្រើនពោលថា ពួកគេមានទឹកគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ៦៧% ពោលថាពួកគេខ្វះទឹក ដែលពួកគេត្រូវការជាចាំបាច់ សម្រាប់ធ្វើកិច្ចការរបស់ពួកគេ។ អ្នកផ្តល់សម្ភាសន៍ មកពីតំបន់ទំនាប (៧៥%) តំបន់ឆ្នេរ (៦៥%) និងតំបន់ភ្នំ (៧៥%) ពោលថា ពួកគេពុំមានទឹកគ្រប់គ្រាន់ សម្រាប់ការងាររបស់ខ្លួនឡើយ។ កសិករ ៨០% ពោលថាពួកគេខ្វះទឹកសម្រាប់ការងាររបស់ខ្លួន ហើយសហគមន៍តំបន់ឆ្នេរជាច្រើនបានពោលដូចគ្នានេះដែរ។

## ទឹក សម្រាប់ការងារ

បុរស (៣៤%) អ្នកទីក្រុង (៤០%) និងក្រុមក្នុងវ័យក្មេង (៣៥% មានអាយុ ១៥-២៤ឆ្នាំ) និង អ្នកPPI ខ្ពស់ (៤៨% ជាអ្នកមាន PPI កម្រិត "ខ្ពស់បំផុត") និងអ្នកមានការសិក្សាកម្រិតឧត្តម (៥០% ជាអ្នកដែលបានសិក្សាថ្នាក់សាកលវិទ្យាល័យ) ពោលថាពួកគេ និងគ្រួសារមានទឹកគ្រប់គ្រាន់ សម្រាប់ការងាររបស់ខ្លួន។

[៣៧] គួរកត់សម្គាល់ផងដែរថាសំណាក"បន្ថែម" សម្រាប់សហគមន៍អ្នកនេសាទនៅតំបន់ឆ្នេរមិនអាចចាត់ទុកថាជាតំណាង នៅក្នុងប្រទេសបានទេ ដោយសារអ្នកឆ្លើយត្រូវបានជ្រើសយក ក្នុងគោលបំណងជាការបំពេញបន្ថែម។ ដោយសារតែការប្រើប្រាស់វិធីសាស្ត្រខុសគ្នា យើងមិនអាចប្រៀបធៀបសំណាកនេះជាមួយសំណាកសរុបទាំង ២៤០១ បានឡើយ ហើយក៏មិនអាចប្រៀបធៀបជាមួយលទ្ធផល សម្រាប់អនុក្រុមផ្សេងផងដែរទេ។ ក្នុងន័យនេះ យើងនឹងមិនរួមបញ្ចូលលទ្ធផលពីការវិភាគតាមរូបមន្តស្ថិតិ សម្រាប់សំណាក"បន្ថែម" នៅក្នុងរបាយការណ៍នេះឡើយ។ លទ្ធផលទាំងនេះអាចមើល ក្នុងតារាងទិន្នន័យពេញលេញ ក្នុងឧបសម្ព័ន្ធ ២។

[៣៨] សម្រាប់គោលបំណងនៃការសិក្សានេះ យើងឱ្យនិយមន័យ "ទឹកសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន" ថាជាទឹកសម្រាប់ផឹក ចម្អិន និងលាងសំអាត។

[៣៩] សូមអានតើបុគ្គលសំខាន់ៗនៅកម្ពុជាដឹង និងយល់អ្វីខ្លះអំពីការប្រែប្រួលអាកាសធាតុ? ទំព័រ ៥៩

## សុខភាព និងការប្រែប្រួលអាកាសធាតុ

អ្នកផ្តល់សម្ភាសន៍ជាច្រើនយល់ឃើញថា ពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅភពផែនដី" មានចំណាងទាក់ទងយ៉ាងជិតស្និទ្ធ ជាមួយនឹងកង្វល់អំពីកំណើនជម្ងឺ។ លទ្ធផលនេះស្របគ្នានឹងរបកគំហើញដែលមាន នៅក្នុងការស្រាវជ្រាវពីមុនមកផងដែរ។[40, 41]

ដោយសារតែអ្នកផ្តល់សម្ភាសន៍នានាយល់ឃើញថាសុខភាពជាការងារមានអាទិភាពខ្ពស់ សម្រាប់ប្រទេស នោះការស្វែងយល់អំពីវិធី ដែលប្រជាជនផ្សារភ្ជាប់ការប្រែប្រួលអាកាសធាតុទៅនឹងសុខភាព ជារឿងមួយដ៏សំខាន់ (ទំនាក់ទំនងទាំងនេះនឹងត្រូវពិនិត្យមើលបន្ថែម នៅក្នុងជំពូក "តើបុគ្គលសំខាន់ៗនៅកម្ពុជាដឹង និងយល់អ្វីខ្លះអំពីការប្រែប្រួលអាកាសធាតុ?")។

អ្នកផ្តល់សម្ភាសន៍ចំនួន ២២% ពោលថាជម្ងឺគ្រុនចាញ់ គឺជាការប្រែប្រួលខាងផ្នែកសុខភាពដែលបង្កដោយអាកាសធាតុហើយ១៨% ពោលដូចគ្នានេះសម្រាប់ករណីជម្ងឺគ្រុនឈាម។ ជម្ងឺគ្រុនចាញ់ និងគ្រុនឈាមស្ថិតនៅចំកណ្តាលតារាងបើទោះបីសហគមន៍អ្នកវិទ្យាសាស្ត្រ អាចនិយាយថាវាមានទំនាក់ទំនងដោយផ្ទាល់ជាមួយការប្រែប្រួលអាកាសធាតុក៏ដោយ។

### ក្រាហ្វិចទី ១៧




*សំណាក : អ្នកគិតថា ការប្រែប្រួលអាកាសធាតុជះឥទ្ធិពលសុខភាព N =១៥0១*

---

[40] សូមអាន*Indochina, iTrak, The Heat is On*

[41] សូមអាន Geres 2009 ប្រជាជនឯកភាពជាទូទៅអំពីកំណើន នៃជម្ងឺដល់មនុស្ស និងសត្វ។ ចំពោះមនុស្ស ជម្ងឺដូចជាផ្តាសាយ ក្អក ឈឺក្រពះ និងពោះវៀន ជម្ងឺផ្លូវដង្ហើម គ្រុនឈាម និងគ្រុនចាញ់ ត្រូវបានពិភាក្សាជាច្រើន។ កំណើនជម្ងឺត្រូវបានចាត់ទុកជាទូទៅថាទាក់ទងជាមួយកំណើនសីតុណ្ហភាព ការប្រែប្រួលយ៉ាងឆាប់រហ័ស នៃសីតុណ្ហភាព ខ្វះទឹក សារធាតុគីមីនៅក្នុងចំណីអាហារ និង កង្វះអនាម័យ និងនៅក្នុងកន្លែងខ្លះ ប្រជាជនត្រូវទៅធ្វើការក្នុងព្រៃ។ ប្រជាជន នៅក្នុងខេត្តពីរក្នុងចំណោមខេត្តចំនួនបួនបានរាយការណ៍អំពីកំណើនការលំបាកនៅក្នុងការព្យាបាលជម្ងឺ។ នៅខេត្តព្រៃវែងមានសេចក្តីរាយការណ៍ថាប្រភពថ្នាំបុរាណបានថយចុះ។

មានអ្នកឆ្លើយសំណួរចំនួន ២២% យល់ថាជម្ងឺគ្រុនចាញ់គឺជាជម្ងឺ ដែលអាចកើតមានឡើង ដោយសារការប្រែប្រួលអាកាសធាតុ និងមាន ១៨% យល់ថា ការប្រែប្រួលអាកាសធាតុបង្កឲ្យមានជម្ងឺគ្រុនឈាម។ ជម្ងឺគ្រុនចាញ់ និងជម្ងឺគ្រុនឈាម ស្ថិតនៅកណ្តាល នៃតារាង បើទោះបីជាសហគមន៍វិទ្យាសាស្ត្រយល់ថាជម្ងឺទាំង ២ នេះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងការប្រែប្រួលអាកាសធាតុក៏ដោយ។

## *ការឆ្លើយតប និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ*

**ទស្សនៈសំខាន់ៗ**

ប្រជាជនកម្ពុជាច្រើនជាងមួយភាគបួនពោលថា ពួកគេមិនដឹងពីរបៀបឆ្លើយតប ទៅនឹងការប្រែប្រួលធាតុអាកាសឡើយ ហើយមនុស្សជាច្រើនពោលថា ពួកគេមិនអាចធ្វើអ្វីបានឡើយក្នុងការឆ្លើយតបនឹងបញ្ហានេះ។ ទោះបីភាគច្រើនពោលថា ពួកគេ និងសហគមន៍របស់ខ្លួនបានចាប់ផ្តើមធ្វើការឆ្លើយតបហើយក៏ដោយ ក៏ច្រើនជាងពាក់កណ្តាលបានពោលថា ពួកគេពុំមានព័ត៌មាន ដែលពួកគេត្រូវការជាចាំបាច់ ដើម្បីធ្វើការងារនេះឡើយ។ ក្រុមដែលមានវ័យក្មេងជាងគេ (១៥-២៤ឆ្នាំ) មានការគិតជាវិជ្ជមាន ច្រើនជាងក្រុមដទៃទៀតអំពីគ្រប់វិធានការ ទាក់ទងនឹងសមត្ថភាពបុគ្គល និងសមត្ថភាពសហគមន៍ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស។

## *តើប្រជាជនកម្ពុជា គិតថាខ្លួនគេអាចឆ្លើយតបបែបណា?*

អ្នកស្រាវជ្រាវបានសួរដោយគ្មានការសួរដេញបន្តអំពីវិធី ដែលពួកគេយល់ថាពួកគេអាចឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស។ ចម្លើយក្នុងសមាមាត្រខ្ពស់ពោលថា ពួកគាត់អាចដាំដើមឈើ (២១%) និងបង្កើតបច្ចេកទេសកសិកម្មថ្មីៗ (១៤%)។ ចម្លើយដែលមានញឹកញាប់ជាបន្តបន្ទាប់ទាក់ទងនឹងវិធីធ្វើឱ្យត្រជាក់ ដូចជាបំពាក់ម៉ាស៊ីនត្រជាក់ (១៥%) ឬ ងូតទឹក និងប្រើប្រាស់កង្ហារ (១៤%)។ ចម្លើយផ្សេងទៀតផ្តោតលើការគ្រប់គ្រងទឹកដោយប្រជាជនបានកត់សម្គាល់អំពីការជីក ប្រឡាយស្រោចស្រព (១២%) រចនាសម្ព័ន្ធគ្រប់គ្រងទឹក (១១%) សាងសង់ទំនប់ (៨%) និងស្តាររចនាសម្ព័ន្ធស្តុកទឹកទុក (៦%)។ ចម្លើយដែលគួរអោយព្រួយបារម្ភខ្លាំងនោះគឺចម្លើយ "មិនធ្វើអ្វីសោះ" (៨%) និង "ដាំដំណាំតាមធម្មតា" (៦%)។

## ក្រាហ្វិចទី ១៨




*សំណាក : អ្នកឆ្លើយតបទាំងអស់ N =២៤០១* *ចម្លើយអាចច្រើនជាង*

ជិតមួយភាគបី (៣៣%) នៃអ្នកឆ្លើយសំណួរមិនអាចធ្វើការកំណត់អំពីសកម្មភាពណាមួយ ដែលពួកគេអាចអនុវត្ត ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុឡើយ។ អ្នកឆ្លើយសំណួរ ដែលបានពោលថាពួកគេមិនដឹងថាតើប្រជាជនអាចធ្វើអ្វីបាននៅក្នុងការឆ្លើយតបគឺអ្នករស់នៅតំបន់បឹងទន្លេសាប និងតំបន់ឆ្នេរ អ្នកដែលមាន កម្រិតការសិក្សាទាប និងអ្នកដែលមាន PPI ទាប។ សមាមាត្រ នៃចម្លើយក៏មានខ្ពស់ផងដែរ ចំពោះយុវជនធ្វើការជាកសិករ មេផ្ទះ និងអ្នកដែលធ្វើការតាមជំនាញវិជ្ជាជីវៈ ផ្នែកបច្ចេកទេស និងគ្រប់គ្រង។

ការដាំដើមឈើត្រូវបានលើកឡើង ក្នុងចំណោមបុរសជាច្រើន (២៩%) ព្រមទាំងអ្នកនៅភ្នំពេញ (២៦%) និងអ្នកនៅតំបន់បឹងទន្លេសាប (៣១%)។ អ្នកផ្តល់សម្ភាសន៍មានវ័យក្មេងជាងគេ (២៦% នៃអ្នកមានអាយុ១៥-២៤ឆ្នាំ) អ្នកមានការសិក្សាខ្ពស់ (៥១% ជាអ្នកសិក្សាថ្នាក់សាកលវិទ្យាល័យ) និងក្រុម ដែលស្ថិតក្នុងPPI (២៩% ជាអ្នក ដែលមានPPI ពី៧៥-១០០) ពោលថាប្រជាជនអាចដាំដើមឈើដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស។ ប្រហែលជាគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដែលថាដោយសារតែចំនួនដ៏ច្រើន នៃអ្នកផ្តល់សម្ភាសន៍មានវ័យក្មេងបានកត់សម្គាល់ថាការដាំដើមឈើ ដោយនិស្សិតសាកលវិទ្យាល័យ (៤៦%) និងសិស្សដទៃទៀត (៤០%) ក៏បានលើកស្នើឱ្យធ្វើសកម្មភាពដូចគ្នានេះដែរ។ គ្រូបង្រៀន (៤៦%) មន្ត្រីរដ្ឋាភិបាល (៣៨%) និងអ្នកដទៃទៀត ដែលធ្វើការក្នុងមុខរបរវិជ្ជាជីវៈបច្ចេកទេស និងគ្រប់គ្រង (៣០%) ក៏ស្នើឱ្យដាំដើមឈើផងដែរ សម្រាប់ជាការឆ្លើយតប។

ភាពចាំបាច់ឲ្យបង្កើតបច្ចេកទេសកសិកម្មថ្មីៗ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស ត្រូវបានកត់សម្គាល់ដោយប្រជាជននៅជនបទ (១៦%) អ្នកនៅតំបន់ភ្នំ (៣៨%) អ្នកដែលនៅក្នុងក្រុមដែលមានPPI ទាប (២២% មានPPI ពី ០-២៤) និងគ្រូបង្រៀន (២៨%)។

ស្ត្រី ១៧% និងអ្នកនៅទីក្រុង ២៤% បានលើកអំពីវិធីធ្វើឱ្យត្រជាក់ ដូចជាការប្រើម៉ាស៊ីនត្រជាក់ ខណៈស្ត្រី (១៦%) បានកត់សម្គាល់ការងូតទឹកញឹកញាប់ និងការប្រើប្រាស់កង្ហារ។ អ្នកមានការសិក្សាកម្រិតឧត្តម និងអ្នកដែលមានវង្វាស់នៃភាពក្រីក្រខ្ពស់ ក៏បានលើកឡើងថាប្រជាជនអាចប្រើប្រាស់វិធីនេះ សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាសផងដែរ។

វិធានការខុសៗគ្នាមួយចំនួន សម្រាប់ការគ្រប់គ្រងទឹក ត្រូវបានលើកឡើងដោយអ្នកផ្តល់សម្ភាសន៍ ហើយសមាមាត្រនៃអ្នកឆ្លើយ សម្រាប់វិធីនីមួយៗក៏ខុសៗគ្នាផងដែរ។ សមាមាត្រនៃបុរស១៤% អ្នករស់នៅបឹងទន្លេសាប ១៥% និងអ្នកដែលមានការសិក្សាកម្រិតឧត្តម (២០% ជាអ្នកដែលបានសិក្សាថ្នាក់សាកលវិទ្យាល័យ) អះអាងថាប្រជាជនអាចបង្កើតប្រព័ន្ធធារាសាស្ត្រ។ ទន្ទឹមនឹងគ្នានោះដែរ អ្នករស់នៅតំបន់ទំនាប (១៩%) ឆ្លើយថាប្រជាជនអាចកសាងរចនាសម្ព័ន្ធគ្រប់គ្រងទឹក។ អ្នកជនបទ (៩%) និងតំបន់ផ្សេងទៀតក្រៅពីភ្នំពេញ (៩% មកពីតំបន់ទំនាប ៨% មកពីតំបន់បឹងទន្លេសាបនិងតំបន់ឆ្នេរ និង១០% មកពីតំបន់ភ្នំ) រៀបរាប់ថាពួកគេអាចសាងសង់ទំនប់។ ស្រដៀងគ្នានេះ បុរស (៨%) និង អ្នកឆ្លើយសំណួរមកពីតំបន់ឆ្នេរ (១០%) និងអ្នក ដែលបានសិក្សាថ្នាក់សាកលវិទ្យាល័យ (១៤%) និងអ្នកមកពីក្រុមមាន PPI ខ្ពស់ (១០% មកពីក្រុមមាន PPI ខ្ពស់បំផុត) ពោលថាប្រជាជនអាចស្តាររចនាសម្ព័ន្ធស្តុកទឹក។

ការយល់ឃើញរបស់ប្រជាជន ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាសចំនួន ២ ដែលគួរអោយបារម្ភនោះគឺ ទីមួយគឺប្រជាជន "មិនធ្វើអ្វីសោះ" និងទីពីរ គឺ "ពួកគេអាចដាំដំណាំតាមធម្មតា"។ សមាមាត្រខ្ពស់ នៃប្រជាជននៅក្រុងភ្នំពេញ (១៨%) និងតំបន់ទំនាប (១៥%) និងកម្មករជំនាញ (១៧%) ឆ្លើយថាប្រជាជនអាចមិនធ្វើអ្វីសោះដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស។ ទន្ទឹមនឹងគ្នានេះ ក្រុមអ្នកឆ្លើយសំណួរ ដែលបានលើកឡើង ប្រជាជនអាចដាំដំណាំតាមធម្មតាមានសមាមាត្រខ្ពស់នៃស្ត្រី (៨%) អ្នកជនបទ (៧%) និងអ្នកតំបន់ភ្នំ (២៤%) ជាងសំណាកទាំងមូល។ ការយល់ឃើញនេះ ក៏មានសមាមាត្រខ្ពស់ផងដែរ ពីយុវជន ដែលជាអ្នកធ្វើការ (១០%) និងក្រុមដែលមានអាយុតិចជាងគេ (៨% មានអាយុ ១៥-២៤ឆ្នាំ) និងអ្នកដែលមានកម្រិតការសិក្សាទាប (១៤% អ្នកដែលមិនបានចូលរៀន) និងពីក្រុមដែលមាន PPI ទាប (១៤% នៃក្រុម ដែលមានPPI "ទាបបំផុត")។

## *តើប្រជាជនកម្ពុជាបានធ្វើអ្វីខ្លះ ក្នុងការឆ្លើយតប?*

អ្នកឆ្លើយសំណួរ ត្រូវបានសាកសួរថាតើពួកគេបានសង្កេតឃើញថា មាននរណាម្នាក់ធ្វើការឆ្លើយតបនឹងការប្រែប្រួលធាតុអាកាសឬនៅ ឬថាតើពួកគេផ្ទាល់ ឬសមាជិកក្នុងគ្រួសារ របស់ពួកគេបានធ្វើការឆ្លើយតប និងថាតើសមាជិកសហគមន៍បានចាត់វិធានការណាមួយក្នុងការឆ្លើយតប? ជិតបីភាគបួន (៧៣%) នៃប្រជាជនទាំងអស់ពោលថាពួកគេ ឬសមាជិកនៅក្នុងគ្រួសាររបស់ពួកគេបានចាត់វិធានការខ្លះៗរួចមកហើយ។ លើសពីពាក់កណ្តាល (៥៥%) នៃអ្នកផ្តល់សម្ភាសន៍ពោលថាសហគមន៍របស់ពួកគេបានចាប់ផ្តើមធ្វើការឆ្លើយតប។

នៅទីក្រុងប្រជាជន ៧៦% ធៀបនឹងនៅជនបទ ៧១% ពោលថាពួកគេ ឬសមាជិកគ្រួសាររបស់ពួកគេបានចាប់ផ្តើមធ្វើកិច្ចការខ្លះៗ ដើម្បីឆ្លើយតបនឹងការប្រែប្រួលធាតុអាកាស។ ផ្ទុយទៅវិញ ប្រជាជននៅជនបទជាច្រើន (៥៧%) ពោល

ថាពួកគេបានកត់សម្គាល់ នូវការឆ្លើយតប នៅក្នុងសហគមន៍របស់ខ្លួន ដែលតួលេខនេះមានច្រើនជាងប្រជាជននៅក្នុងទីក្រុង ដែលមានតែ ៥២% ។

នៅតំបន់ភ្នំ អ្នកឆ្លើយសំណួរច្រើនជាងតំបន់ផ្សេងទៀតឆ្លើយថាពួកគាត់បានឃើញសមាជិកគ្រួសារ (៧៨%) និងសហគមន៍ (៦៦%) របស់ខ្លួនបាន និងកំពុងចាត់វិធានការ។ ប្រជាជនជាច្រើន ក្នុងតំបន់ទំនាប និងតំបន់ឆ្នេរពោលថាពួកគេបានឃើញសកម្មភាពទាំងនោះក្នុងសហគមន៍របស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងតំបន់បឹងទន្លេសាបមានសមាមាត្រតិចជាងបើធៀបទៅនឹងតំបន់ផ្សេងទៀត ដែលពោលថាពួកគេបានឃើញសមាជិកគ្រួសារនិងសហគមន៍របស់ខ្លួនធ្វើសកម្មភាពនោះ ដោយមានមនុស្ស ៦៨% ឆ្លើយថាសមាជិកគ្រួសារធ្វើការឆ្លើយតប និងមនុស្ស ៤៤% ធ្វើការឆ្លើយតប ធៀបនឹង ៧៣% និង៥៥% នៃសំណាកសរុប។ អត្រាដ៏ទាប នៃប្រជាជនមកពីទីក្រុងភ្នំពេញ (៤៣%) បានបញ្ជាក់ថាពួកគេបានឃើញប្រជាជនក្នុងសហគមន៍ របស់ខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស។

ក្នុងចំណោមអ្នក ដែលមាន កម្រិតការសិក្សាទាប (៣៧% ដែលមិនបានចូលរៀន) និងក្រុមដែលមានPPI ទាប (៣១% ជាអ្នកមានPPI "ទាបបំផុត") អះអាងថាពួកគេមិនបានឃើញអ្នកណាម្នាក់នៅក្នុងគ្រួសាររបស់ខ្លួនចាត់វិធានការដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាសឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក៏មិនមានភាពខុសគ្នាដែលគួរឱ្យកត់សម្គាល់ទេ រវាង កម្រិតការសិក្សា ឬក្រុម PPI ក្នុងការឆ្លើយនៅកម្រិតសហគមន៍។

## *ការឆ្លើយតប របស់សហគមន៍ទៅនឹងការប្រែប្រួលធាតុអាកាស*

អ្នក ដែលបានសង្កេតឃើញការឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស នៅក្នុងគ្រួសារនិងសហគមន៍របស់ខ្លួនបានរៀបរាប់ អំពីការឆ្លើយតបស្រដៀងគ្នានេះ ក្នុងករណីទាំង ២។ វិធីនានា ធ្វើឱ្យត្រជាក់ ដូចជាការប្រើប្រាស់ម៉ាស៊ីនត្រជាក់ ឬកង្ហារ និងការពាក់អាវដៃវែងត្រូវបានលើកឡើងញឹកញាប់ជាងគេទាក់ទងនឹងការឆ្លើយតបនៅក្នុងគ្រួសារ និងក្នុងសហគមន៍។

ទោះជាយ៉ាងណាក៏ដោយ មានការឆ្លើយតបជាក់លាក់មួយចំនួនទាក់ទងនឹងការប្រែប្រួលធាតុអាកាស ដែលបានធ្វើឡើងនៅក្នុងសហគមន៍ ហាក់ដូចជាមានការរៀបរាប់ញឹកញាប់ជាងគេ។ ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងទឹក ប្រឡាយស្រោចស្រព ការសាងសង់ទំនប់ និងការស្តាររចនាសម្ព័ន្ធស្តុកទឹកទុកត្រូវបានឆ្លើយកាន់តែញឹកញាប់នៅថ្នាក់សហគមន៍។ ការដាំរុក្ខជាតិ និងការប្តូរ ឬបង្កើនមុខដំណាំ ក៏ដូចជាការរៀបចំពិធីសាសនាជាដើម ក៏ជាចម្លើយមួយញឹកញាប់ នៅកម្រិតសហគមន៍ផងដែរ។



ប្រភព BBC World Service Trust 2010

ចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍ត្រូវបានសាកសួរអំពីវិធីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

## ក្រាហ្វិចទី ១៩

**តើប្រជាជននៅក្នុង<u>សហគមន៍</u>របស់អ្នកបានធ្វើអ្វីខ្លះដើម្បីដោះស្រាយជាមួយ<u>ធាតុអាកាស</u>ប្រែប្រួល? (មិនអានចម្លើយ)**




*សំណាក : ដឹងថាមាននរណាម្នាក់ក្នុងសហគមន៍ ដែលទប់ទល់នឹងធាតុអាកាស N=១៣២៦* *ចម្លើយអាចច្រើនជាង ១*

## *តើប្រជាជនឆ្លើយតបបែបណាទៅនឹងផលប៉ះពាល់មកលើការងាររបស់ពួកគេ?*

ប្រជាជនភាគច្រើននៅកម្ពុជាពោលថា ការងាររបស់ពួកគេទទួលរងផលប៉ះពាល់ពីការប្រែប្រួលធាតុអាកាស។ មួយភាគបួន (២៦%) ពោលថាពួកគេមិនដឹងថា តើពួកគេគួរធ្វើអ្វីឡើយ ប្រសិនបើធាតុអាកាសប្រែប្រួលកាន់តែខ្លាំងជាងមុន។ នេះគឺជាការឆ្លើយតបដែលបានលើកឡើងញឹកញាប់ជាងគេ ពីសំណាក់អ្នកចូលរួមក្នុងការសម្ភាស។ អ្នកដទៃទៀតចំនួន ១៩% ឆ្លើយថាពួកគេនឹងដាំដើមឈើ (១៩%)។

## ក្រាហ្វិចទី ២០

**ប្រសិនបើការប្រែប្រួលធាតុអាកាសកាន់តែខ្លាំង តើអ្នកមានវិធីសាស្ត្រដោះស្រាយយ៉ាងដូចម្តេចខ្លះទៅនឹង ផលប៉ះពាល់ទាំងនេះលើ មុខរបរ របស់អ្នក? (មិនអានចម្លើយ)**




*សំណាក : អ្នកឆ្លើយតបទាំងអស់ N = ២៤០១* ចម្លើយអាចច្រើនជាង ១

## *កម្រិត នៃការជឿទុកចិត្តលើខ្លួនឯង និងការជឿទុកចិត្តជារួម នៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ*

អ្នកស្រាវជ្រាវបានសួរអ្នកឆ្លើយសំណួរថាតើពួកគេឯកភាព ឬមិនឯកភាព ទៅនឹងសំដីមួយចំនួន ដែលបានរៀបចំឡើង ដើម្បីវាយតម្លៃកម្រិតនៃការជឿទុកចិត្តលើខ្លួនឯង និងការជឿទុកចិត្តលើសមត្ថភាពរួម ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ តាមការឆ្លើយតប បង្ហាញថាប្រជាជនភាគច្រើនមានការសង្ស័យអំពីសមត្ថភាពរបស់ខ្លួន និងសមត្ថភាពរបស់សហគមន៍ ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស។

នៅពេលសួរបន្តស្ទើរតែ ៩ នៅក្នុងចំណោម ១០ នាក់(៨៩%) ពុំគិតថាការប្រែប្រួលធាតុអាកាសនាំមកនូវផលប្រយោជន៍ណាមួយសម្រាប់ពួកគេ ឬគ្រួសារឡើយ ហើយប្រជាជនលើសពីពាក់កណ្តាល (៥៩%) បានគិតថាពួកគេមិនអាច

ធ្វើការឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាសឡើយ ហើយមនុស្ស ៥២% គិតថាពួកគេមិនអាចស្វែងរកព័ត៌មាន ដែលពួកគេត្រូវការជាចាំបាច់ដើម្បីឆ្លើយតបឡើយ។ ស្ត្រី អ្នកជនបទ អ្នកក្រីក្រ និងអ្នកដែលមានការសិក្សាតិចតួចជាច្រើនបាន ពោលថា ពួកគេខ្វះព័ត៌មាន ដែលពួកគេត្រូវការជាចាំបាច់ សម្រាប់ការឆ្លើយតប។ ការយល់ឃើញរបស់សហគមន៍អំពីសមត្ថភាព ដើម្បីឆ្លើយតបមិនសូវមានលក្ខណៈអវិជ្ជមានឡើយ ប៉ុន្តែនៅតែបង្ហាញ នូវទិដ្ឋភាពដែលគួរឱ្យព្រួយបារម្ភនៅឡើយ។ មានប្រជាជនតិចជាងមួយភាគបី (៣១%) គិតថាសហគមន៍របស់ពួកគេអាចឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស ដែលក្នុងនោះមានតែ ២៨% ពោលថាសហគមន៍របស់ពួកគេមានធនធានសម្រាប់ធ្វើបែបនោះ។ មានប្រជាជនត្រឹមតែមួយភាគបួន នៃអ្នកឆ្លើយ (២៥%) គិតថាសហគមន៍របស់ពួកគេអាចឆ្លើយតបទៅនឹងទឹកជំនន់ និងភាពរាំងស្ងួត ហើយប្រជាជនជាច្រើនទៀតពោលថា សហគមន៍របស់ពួកគេមិនអាចធ្វើបែបនោះបានឡើយ។

## ទស្សនៈវិជ្ជមាន អំពីសមត្ថភាពក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

ក្រុមដែលមានអាយុតិចជាងគេ (១៥-២៤ឆ្នាំ) មានទស្សនៈវិជ្ជមាន ជាងក្រុមដទៃទៀតលើគ្រប់វិធានការ ទាក់ទងនឹងសមត្ថភាពរបស់បុគ្គល និងសហគមន៍ក្នុងការឆ្លើយតបនឹងការប្រែប្រួលធាតុអាកាស លើកលែងតែសមត្ថភាពរបស់សហគមន៍ពួកគេ ក្នុងការឆ្លើយតបនឹងទឹកជំនន់។ ដូចគ្នានេះដែរ យុវជនធ្វើការ(៣៥%) និងសិស្ស (៤៥%) គិតថា សហគមន៍របស់ពួកគេអាចធ្វើការឆ្លើយតប ហើយសិស្សមិនរៀននៅសាកលវិទ្យាល័យជាច្រើនពោលថា ពួកគេអាចស្វែងរកព័ត៌មានដែលខ្លួនត្រូវការ។

អ្នកផ្តល់សម្ភាសន៍នៅទីក្រុងពោលថា ពួកគេអាចរកព័ត៌មាន ដែលពួកគេត្រូវការជាចាំបាច់ និងគិតថាសហគមន៍របស់ពួកគេមានធនធាន ដែលពួកគេត្រូវការសម្រាប់ឆ្លើយតប។ ចម្លើយនេះក៏ត្រូវបានឆ្លើយដោយ អ្នកឆ្លើយសំណួរមកពីតំបន់បឹងទន្លេសាប និងតំបន់ភ្នំ។

អ្នកឆ្លើយសំណួរជាច្រើនមកពីតំបន់ភ្នំគិតថាសហគមន៍ របស់ពួកគេអាចឆ្លើយតបទៅនឹងភាពរាំងស្ងួត និងទឹកជំនន់ ហើយក៏បានអះអាងថាសហគមន៍របស់ពួកគេអាចធ្វើការឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាសជាទូទៅ។

អ្នកមានការសិក្សាកម្រិតឧត្តម និងអ្នកមានកម្រិត PPI ខ្ពស់ជាច្រើន គិតថាពួកគេអាចរកព័ត៌មាន ដែលពួកគេត្រូវការ ដើម្បីធ្វើការឆ្លើយតប។ ករណីដូចគ្នានេះក៏ដូចគ្នាផងដែរសម្រាប់មន្ត្រីរដ្ឋាភិបាល។

## ធនធានចាំបាច់ ដើម្បីជួយប្រជាជននៅក្នុងការដោះស្រាយបញ្ហា

ប្រជាជនពោលថាពួកគេត្រូវការប្រាក់ (២៥%) ឧបករណ៍ (១៨%) និងការគាំទ្រពីរដ្ឋាភិបាល (១២%) ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស។ ៥% ពោលថាពួកគេត្រូវការព័ត៌មាន និង ៥% ទៀត ពោលថាពួកគេត្រូវការចំណេះដឹង ដើម្បីអាចធ្វើការឆ្លើយតប។

## តើអ្នកណាខ្លះធ្វើការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ?

### ចំណេះដឹងអំពីការឆ្លើយតបជាលក្ខណៈបុគ្គល និងការឆ្លើយតបជាលក្ខណៈស្ថាប័ន

លទ្ធផល នៃការស្រាវជ្រាវបានបង្ហាញថា អ្នកឆ្លើយសំណួរស្ទើរតែទាំងអស់ (៩៣% នៃអ្នកឆ្លើយសំណួរ) មិនបានដឹងថាមានការឆ្លើយតប ដែលបានរៀបចំរួចជាស្រេច សម្រាប់ទប់ទល់នឹងការប្រែប្រួលធាតុអាកាស ។ ស្ថានភាព ដែលស្ទើរតែគ្មានអ្នកណាដឹងអំពីបុគ្គល ឬអង្គការណាមួយធ្វើការឆ្លើយតបទៅនឹងបញ្ហានានាបង្ហាញថា ប្រជាជនមិនដឹងអំពីកម្មវិធី

ដែលមានស្រាប់នៅថ្នាក់ជាតិ និងមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុឡើយ ហើយបច្ចុប្បន្នពួកគេកំពុងធ្វើសេចក្តីសម្រេចអំពីការឆ្លើយតបដោយមិនបានទទួលការគាំទ្រពីប្រភពណាមួយនៅក្រៅសហគមន៍របស់ពួកគេឡើយ។

### ការទទួលខុសត្រូវ

ចំពោះការសម្ភាសន៍ ពាក់ព័ន្ធនឹងការទទួលខុសត្រូវលើការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុបង្ហាញថា ការទទួលខុសត្រូវគឺជាបន្ទុករបស់រាជរដ្ឋាភិបាល (៣៥% នៃអ្នកឆ្លើយសំណួរ) នាយករដ្ឋមន្ត្រី (២៩% នៃអ្នកឆ្លើយសំណួរ) និងអង្គការមិនមែនរដ្ឋាភិបាល (២៥% នៃអ្នកឆ្លើយតបសំណួរ)។ ចំណែកឯចម្លើយផ្សេងទៀតនោះគឺមិនសូវមានអ្នកឆ្លើយឡើយ ដូចជាមានប្រជាជន ១០% ថាជាការទទួលខុសត្រូវរបស់ប្រធានភូមិ និង ១៦% យល់ថានេះជាការទទួលខុសត្រូវរបស់មេដឹកនាំផ្សេងៗទៀតនៅមូលដ្ឋាន និង ១៤% ឆ្លើយថាជាបន្ទុករបស់ប្រជាជនកម្ពុជា ។

ប្រជាពលរដ្ឋជាច្រើននៅមូលដ្ឋាន (១៨%) និងប្រជាជនមកពីតំបន់ភ្នំ (២៩%) និងអ្នកដែលមានកម្រិតការសិក្សាទាបបំផុត (២៦% នៃអ្នកមិនបានចូលរៀន) និង អ្នកមាន PPI ទាបបំផុត (២៧% នៃក្រុមដែលមាន PPI ពី0-២៤) បានលើកឡើងអំពីតួនាទីរបស់ប្រធានភូមិ ឬ មេដឹកនាំនៅមូលដ្ឋាន ក្នុងការទទួលខុសត្រូវលើការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

អ្នកផ្តល់សម្ភាសន៍នៅទីក្រុងចំនួន ១៨% អ្នករស់នៅក្នុងតំបន់បឹងទន្លេសាប ២០% និងអ្នកនៅតំបន់ភ្នំ ១៨% អ្នកឆ្លើយសំណួរ ដែលមានអាយុតិចជាងគេ (២០% អ្នកដែលមានអាយុ១៥-២៤ឆ្នាំ) និងអ្នកដែលមានការសិក្សាកម្រិតឧត្តម (៣៤% ជាអ្នកដែលបានសិក្សានៅសាកលវិទ្យាល័យ) បានពោលថាជាការទទួលខុសត្រូវរបស់ប្រជាជនកម្ពុជា។

### តួនាទី របស់រាជរដ្ឋាភិបាលកម្ពុជា

បីភាគបួន (៧៥%) ពោលថារដ្ឋាភិបាលអាចចាត់វិធានការ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស។ នៅពេលសុំឱ្យបញ្ជាក់ អំពីវិធីនានា ដែលរដ្ឋាភិបាលអាចជួយ អ្នកផ្តល់សម្ភាសន៍ពោលថារដ្ឋាភិបាលអាចបញ្ឈប់ការបាត់បង់ព្រៃឈើ (៤៨%) ផ្តល់ប្រាក់ដល់ពួកគេ (៤៣%) សាងសង់ប្រព័ន្ធស្រោចស្រព (៣០%) និងដាំដើមឈើបន្ថែមទៀត (៣០%)។

# ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងប្រភពព័ត៌មាន

ដើម្បីស្វែងយល់អំពីរបៀបទំនាក់ទំនងជាមួយប្រជាជនអំពីការប្រែប្រួលអាកាសធាតុ ប្រការសំខាន់គឺត្រូវយល់អំពីទម្លាប់របស់ប្រជាជន ក្នុងការទទួលព័ត៌មាន ក៏ដូចជាទស្សនៈរបស់ពួកគេអំពីប្រធានបទនេះផងដែរ។ បន្ទាប់ពីធ្វើការស្វែងយល់ពីវិធី ដែលប្រជាជនយល់ពីការប្រែប្រួលអាកាសធាតុ នៅផ្នែកខាងលើ ឥឡូវរបាយការណ៍នេះនឹងពិនិត្យមើលលើកម្រិត នៃការទុកចិត្តលើប្រភពព័ត៌មានផ្សេងៗ មុននឹងបង្ហាញអំពីទម្លាប់របស់អ្នកឆ្លើយ ក្នុងការប្រើប្រាស់ព័ត៌មាន។

## ប្រភពព័ត៌មាន

ប្រភពព័ត៌មានដែលពេញនិយមជាងគេ គឺការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ និងការនិយាយតគ្នាពីមាត់មួយទៅមាត់មួយ តាមរយៈមិត្តភក្តិ និងអ្នកជិតខាង។ ក្នុងចំណោមប្រភពព័ត៌មានទាំងបីនេះ ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ជាប្រភពដែលផ្តល់ទំនុកចិត្តច្រើនជាងពីមិត្តភក្តិ និងពីអ្នកជិតខាង។

## ក្រាហ្វិចទី២១ក ២១ខ







*សំណាក : អ្នកឆ្លើយតបទាំងអស់ N = ២៣៣៩ ចម្លើយអាចច្រើនជាង ១*

*សំណាក : អ្នកឆ្លើយតបទាំងអស់ N =១៣៣៩ (N គឺខុសគ្នាទៅតាមចម្លើយនីមួយៗ ដូចមានបង្ហាញនៅក្នុងរង្វង់ក្រចក)*

មិត្តភក្តិនិងអ្នកជិតខាង គឺជាប្រភពព័ត៌មាន សម្រាប់ក្រុមវ័យក្មេងនៅក្នុងសំណាក (៦៧% ដែលមានអាយុ ១៥-២៤ឆ្នាំ) និងប្រជាពលរដ្ឋនៅជនបទ (៦៥%)។

ស្ត្រី អ្នកនៅទីជនបទ កសិករ អ្នកដែលមានកម្រិតវប្បធម៌ទាប និងអ្នក ដែលមាន PPI ទាបពោលថាពួកគេទទួលព័ត៌មានតាមរយៈអាជ្ញាធរមានសមត្ថកិច្ច។

ការសែត និងទស្សនាវដ្តីគឺជាប្រភពព័ត៌មាន សម្រាប់អ្នកឆ្លើយសំណួរមានវ័យក្មេង។ ១៦% នៃក្រុម ដែលមានអាយុ ១៥-២៤ឆ្នាំ ទទួលព័ត៌មានពីការសែត និង១៤% មានអាយុពី ១៥-២៤ ទទួលព័ត៌មានពីទស្សនាវដ្តី។ អ្នកឆ្លើយសំណួរ ដែលមានការអប់រំខ្ពស់ក៏ទទួលព័ត៌មានពីឯកសារព័ត៌មានបោះពុម្ពផងដែរ ដោយ ៥៩% នៃអ្នកដែលមានការសិក្សាថ្នាក់សាកលវិទ្យាល័យអានកាសែត និង ៤០% នៃអ្នកដែលមានការសិក្សានៅថ្នាក់សាកលវិទ្យាល័យអានទស្សនាវដ្តី។ មានអ្នករស់នៅទីក្រុងច្រើនជាងអ្នកនៅជនបទអានឯកសារបោះពុម្ពដោយ ២២% នៃអ្នកនៅទីក្រុងអានការសែត និង១៤% អានទស្សនាវដ្តី។

## *ប្រភពព័ត៌មាន ដែលទុកចិត្ត*

ប្រភពព័ត៌មានដែលទុកចិត្តបានជាងគេ គឺទូរទស្សន៍ អាជ្ញាធរ អ៊ិនធឺណែត និងវិទ្យុ។ ក្នុងចំណោមប្រភពទាំងនេះ ទូរទស្សន៍ និងវិទ្យុ គឺជាប្រភពព័ត៌មាន ដែលពេញនិយមជាងគេ។

ការសែតមិនអាចប្រៀបផ្ទឹមជាមួយព័ត៌មាន ដែលផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយឡើយ។ ទស្សនាវដ្ដីគឺជាប្រភពដែលផ្ដល់ទំនុកចិត្តទាបជាងគេ។ ប្រភពទាំងពីរនេះត្រូវបានប្រើប្រាស់ញឹកញាប់ជាងគេដោយអ្នករស់នៅទីក្រុងភ្នំពេញ និងក្រុមអ្នក ដែលមានការសិក្សាខ្ពស់ និងអ្នករស់នៅទីក្រុង។

ទាក់ទងនឹងការប្រើប្រាស់ និងទំនុកចិត្ត ប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍ និងវិទ្យុ) និងអាជ្ញាធរមានការពេញនិយមច្រើន បើប្រៀបធៀបនឹងប្រភពព័ត៌មានផ្សេងទៀត។

## ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ

ប្រជាជនលើសពី ៨នាក់ ក្នុងចំណោមប្រជាជនកម្ពុជា ១០នាក់ គឺជាអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ។[៤២] ក្នុងចំណោមអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ អ្នកមើលទូរទស្សន៍មានច្រើនជាងអ្នកស្ដាប់វិទ្យុ ហើយប្រជាជន ១៧% មិនមើលទូរទស្សន៍ ឬស្ដាប់វិទ្យុឡើយ។

### ក្រាហ្វិចទី ២២



*សំណាក : អ្នកឆ្លើយតបទាំងអស់ N =២៤០១*

មនុស្សស្ទើរតែគ្រប់រូប (៩១%) មានលទ្ធភាពប្រើប្រាស់ទូរស័ព្ទចល័តដោយច្រើនជាងពាក់កណ្ដាល (៦០%) មានទូរស័ព្ទចល័តផ្ទាល់ខ្លួន។

---

[៤២] សម្រាប់គោលបំណងនៃការសិក្សានេះ "អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ" ត្រូវបានឱ្យនិយមន័យថាជាអ្នកដែលមើលទូរទស្សន៍ឬស្ដាប់វិទ្យុ ឬទាំងពីរយ៉ាងហោចណាស់ម្ដងនៅក្នុងខែមុនការអង្កេតនេះ។

### ក្រាហ្វិចទី២៣




*សំណាក : អ្នកឆ្លើយតបទាំងអស់ N =២៤០១*

*សំណាក : អ្នកដែលអាចទំនាក់ទំនងគ្នាតាមទូរស័ព្ទ N = ២១៧៩*

## ការរួមបញ្ចូលនៃប្រព័ន្ធផ្សព្វផ្សាយ

### ក្រាហ្វិចទី២៤




*សំណាក : អ្នកឆ្លើយតបទាំងអស់ N =២៤០១*

ពីរភាគប្រាំនៃប្រជាជន (៤១%) ប្រើប្រាស់ទាំងវិទ្យុ និងទូរទស្សន៍។ ប្រមាណមួយភាគបួន (២៦%) មើលតែទូរទស្សន៍ប៉ុណ្ណោះ ចំណែកមួយភាគប្រាំមួយ (១៦%) ស្តាប់តែវិទ្យុប៉ុណ្ណោះ។ មានមនុស្សមួយចំនួនតូចប៉ុណ្ណោះ (៦%) ដែលបានប្រើប្រាស់អ៊ិនធឺណែត។

## ទម្លាប់ប្រើប្រាស់វិទ្យុ

ប្រជាជន ៥៧% គឺជាអ្នកស្តាប់វិទ្យុ។ នៅក្នុងក្រុមនេះ បុរសមានសមាមាត្រខ្ពស់ (៦៦%) និងអ្នកមានអាយុតិចជាងគេ (៦៥% អ្នកមានអាយុ១៥-២៤ឆ្នាំ)។ ប្រជាជន ដែលរស់នៅក្នុងតំបន់ឆ្នេរ និងអ្នករស់នៅតាមតំបន់ភ្នំ (ក្រុមនីមួយៗមាន ៥០%) ប្រើប្រាស់វិទ្យុ ក្នុងកម្រិតទាបណាស់។ ភាគច្រើននៃអ្នកស្តាប់វិទ្យុគឺជាអ្នកមានការសិក្សាកម្រិតឧត្តម ដោយក្នុងនោះ ៦២% មានការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ ៧១% មានការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ និង ៧៥% ជាអ្នកមានការសិក្សាកម្រិតសាកលវិទ្យាល័យ។ អ្នកដែលមានPPI ខ្ពស់ពី ៥០ ដល់ ៧៥ ក៏មានតួលេខច្រើនផងដែរនៅក្នុងចំណោមអ្នកស្តាប់វិទ្យុ។

កម្មវិធីព័ត៌មានជាប្រភពដែលមានប្រជាប្រិយភាពជាងគេ ដោយមាន ៨៤% ពោលថាពួកគេស្តាប់ព័ត៌មានច្រើនបំផុត។ ក្រៅពីព័ត៌មាន កម្មវិធីចម្រៀងក៏ជាកម្មវិធីមានប្រជាប្រិយភាពផងដែរ។ ៤៩% ពោលថាពួកគេស្តាប់កម្មវិធីចម្រៀងទូទៅ ចំណែក៣៧% ពោលថាពួកគេស្តាប់កម្មវិធីសំណូមពរបទចម្រៀង។ កម្មវិធីអប់រំ និងសុខភាពក៏មានការទាក់ទាញ ក្នុងបរិមាណខ្ពស់ផងដែរ ដោយមានអ្នកស្តាប់ ២១% និង ១៧%។ កម្មវិធីបរិស្ថានទាក់ទាញអ្នកស្តាប់តិចតួចបំផុត។

ភាគច្រើននៃអ្នកស្តាប់ព័ត៌មានគឺ បុរស (៩១%) អ្នកទីក្រុង (៨៧%) និងច្រើនមានអាយុរវាង ២៥-៤៤ ឆ្នាំ (៨៧%)។

កម្មវិធីចម្រៀងទំនងជាមានប្រជាប្រិយភាពជាងគេ ក្នុងចំណោម អ្នកនៅជនបទ (៥១%) និងបុរស (៥២%) ហើយកម្មវិធីសំណូមពរបទចម្រៀងវិញមានប្រជាប្រិយភាពបំផុត ចំពោះអ្នកស្តាប់វ័យក្មេង (៥០% អ្នកដែលមានអាយុ១៥-២៤ឆ្នាំ)។

អ្នកនៅទីក្រុង (២៥%) ស្តាប់កម្មវិធីអប់រំ និង ស្ត្រី(២៣%) ស្តាប់កម្មវិធីសុខភាព។

## ស្ថានីយ៍វិទ្យុ

ស្ថានីយ៍វិទ្យុចំនួនបួន ដែលនាំមុខគេក្នុងចំណោមអ្នកស្តាប់កម្ពុជាគឺ៖

- វិទ្យុបាយ័ន (គ្រប់ប៉ុស្តិ៍) ២៨%
- វិទ្យុរាជធានី ១០៣ FM (ភ្នំពេញ) ២០%
- វិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា១០២FM (ភ្នំពេញ) ស្វាយរៀង (៩៤.៥ FM) កំពង់ធំ (១០២.២ FM) ១៣%
- វិទ្យុសំបុកឃ្មុំ១០៥ FM (ភ្នំពេញ) ១០%

ប្រការសំខាន់គឺត្រូវកត់សម្គាល់ផងដែរថា ប្រជាជន ១៨% មិនចាំឈ្មោះស្ថានីយ៍ ដែលពួកគេស្តាប់នោះឡើយ។

## រយៈពេល និងម៉ោងនៃការស្តាប់វិទ្យុ

អ្នកឆ្លើយ ៥៥% ពោលថាពួកគេស្តាប់វិទ្យុជារៀងរាល់ថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ ថ្ងៃដែលពួកគេនិយមស្តាប់វិទ្យុគឺនៅចុងសប្តាហ៍ដោយមាន ៦៩% ស្តាប់នៅថ្ងៃសៅរ៍ និង៧២% ស្តាប់នៅថ្ងៃអាទិត្យ។

បុរស និងអ្នកនៅទីក្រុងភាគច្រើនជាអ្នកស្តាប់វិទ្យុនៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។ មនុស្សចាស់ (៤៥-៥៥ឆ្នាំ) ជាអ្នកស្តាប់វិទ្យុជារៀងរាល់ថ្ងៃ។

ម៉ោង ដែលមានការនិយមស្តាប់ជាងគេ គឺនៅវេលាម៉ោង៦ព្រឹក និង៨ព្រឹក ដោយអ្នកឆ្លើយសំណួរច្រើនជាងពាក់កណ្តាល (៥៣%) បញ្ជាក់ថាបានស្តាប់វិទ្យុ។ អ្នកឆ្លើយសំណួរយ៉ាងច្រើនបានប្រាប់ថាបានស្តាប់វិទ្យុនៅពេលយប់ដោយភាគច្រើននៅវេលាម៉ោង ៦ ល្ងាចដល់ម៉ោង ៨ យប់ (៣៧%) និងមានអ្នកស្តាប់ក្នុងចំនួនតិចជាង ពោលគឺនៅវេលា ម៉ោង ៨ យប់ និង ១០ យប់ (២៧%)។ នៅចន្លោះម៉ោង ១២ ថ្ងៃត្រង់ និងម៉ោង ២ រសៀល ក៏ជាពេលដែលពេញនិយមផងដែរដោយអ្នកផ្តល់សម្ភាស ២៩% ពោលថាស្តាប់នៅម៉ោងនេះ។

ស្ត្រីក្នុងអត្រាទាបយ៉ាងខ្លាំង បើធៀបនឹងបុរសស្តាប់វិទ្យុនៅពេលល្ងាច។ បុរសស្តាប់នៅចម្លោះម៉ោង ៦ ល្ងាចដល់ ៨ យប់ (៤៣%) និងម៉ោង ៨ យប់ដល់ ១០ យប់ (៣១%) ធៀបនឹងស្ត្រី មានតែ ២៩% និង ២១% ប៉ុណ្ណោះ។

នៅម៉ោង ៦ ល្ងាចដល់ ៨ យប់ អ្នកស្តាប់នៅទីក្រុងមាន ៥៧% ច្រើនជាងនៅអ្នកនៅទីជនបទ ចំណែកអ្នកស្តាប់ជាច្រើននៅជនបទ (៣២%) បើកវិទ្យុស្តាប់នៅក្រោយបាយថ្ងៃត្រង់ពោលគឺពីម៉ោង ១២ ថ្ងៃត្រង់ ដល់ ម៉ោង ២ រសៀល។

យុវជនស្តាប់នៅពេលក្រោយបន្តិច (១៩% ស្តាប់នៅម៉ោង ៨ ព្រឹកដល់ម៉ោង ១០ ព្រឹក) ហើយយុវជនស្តាប់កាន់តែច្រើនចាប់ពីថ្ងៃត្រង់ ដល់ម៉ោង២រសៀល (៣៤%) និងចាប់ពីម៉ោង ២ រសៀល ដល់ម៉ោង ៤ ល្ងាច (១៥%) ដែលជាតួលេខខ្ពស់ជាងក្រុមដទៃទៀត។

អ្នកស្តាប់ភាគច្រើនបើកវិទ្យុស្តាប់តែម្តង (៤៨%) ឬពីរដង (៣៦%) ក្នុងមួយថ្ងៃ ដោយស្តាប់រហូតដល់មួយម៉ោងក្នុងមួយលើកៗ (៤២% ស្តាប់វិទ្យុដល់ត្រឹមកន្លះម៉ោង និង ៣៨% ស្តាប់ពីកន្លះម៉ោងដល់មួយម៉ោង)។

យុវជន ១៥-២៤ ឆ្នាំ ស្តាប់ញឹកញាប់ជាងគេ ដោយអ្នកទាំងនោះជាច្រើនស្តាប់បីដងក្នុងមួយថ្ងៃ ដែលច្រើនជាងក្រុមដទៃទៀត។

ការស្តាប់របស់ស្ត្រីទំនងជាមានភាពខុសគ្នា។ មានស្ត្រីច្រើនជាងបុរស ដែលស្តាប់រយៈពេលកន្លះម៉ោង ឬតិចជាងនេះ និងស្តាប់លើសពី ២ ម៉ោង។

មនុស្សមានវ័យពី ៣៥ ឆ្នាំ ដល់ ៤៤ ឆ្នាំទំនងជាស្តាប់វិទ្យុតិចជាងកន្លះម៉ោងក្នុងមួយថ្ងៃ។

## កម្មវិធីសំណេះសំណាលតាមទូរស័ព្ទ

កម្មវិធីទទួលការហៅចូលតាមទូរស័ព្ទមានការពេញនិយម ដោយមានបីភាគបួន (៧៦%) ស្តាប់កម្មវិធីទូរស័ព្ទជជែកកំសាន្ត នៅក្នុងខែមុនមុនការធ្វើអង្កេតនេះ។ កម្មវិធីនេះមានការពេញនិយម សម្រាប់ស្ត្រីអ្នកស្តាប់នៅជនបទ និងអ្នកស្តាប់ជាយុវជន។

## ការទូរស័ព្ទចូលក្នុងកម្មវិធីសំណេះសំណាលតាមទូរស័ព្ទ

ទោះបីមនុស្សភាគច្រើនស្តាប់កម្មវិធីសំណេះសំណាលតាមទូរស័ព្ទក៏ដោយ ក៏មានចំនួនតិចជាងមួយភាគប្រាំមួយ (១៤%) ទូរស័ព្ទចូលដោយខ្លួនឯង។ អ្នកស្តាប់ ដែលមានវ័យក្មេងជាងគេបំផុតជាអ្នកទូរស័ព្ទចូលកម្មវិធី (១៧%)។

ក្នុងចំណោមអ្នក ដែលបានទូរស័ព្ទចូលក្នុងកម្មវិធីណាមួយ ភាគច្រើនបានពោលថាពួកគេទូរស័ព្ទចូល ដើម្បីស្នើសុំបទចម្រៀង (៥៤%) ចំណែកអ្នកដទៃទៀតពោលថាបានទូរស័ព្ទចូល ដើម្បីពិភាក្សាអំពីបញ្ហាសុខភាព (២០%) ឬដើម្បីជជែកអំពីបញ្ហាសង្គម (១៩%)។

ការទូរស័ព្ទចូលដើម្បីសុំបទចម្រៀងមានការពេញនិយម ក្នុងចំណោមអ្នកស្តាប់វ័យក្មេង (៦៦%) ចំណែកការទូរស័ព្ទចូល ដើម្បីជជែកអំពីបញ្ហាសង្គមវិញមានបុរសច្រើនជាង (២៨%) ធៀបនឹងស្ត្រី (៥%)។

## *ទម្លាប់មើលទូរទស្សន៍*

ប្រជាជនកម្ពុជាប្រមាណ៦៧% មើលទូរទស្សន៍។[៤៣]

បុរស (៧៤%) អ្នកទីក្រុង (៩១%) យុវជន (៧២%) និងអ្នក ដែលមានកម្រិតការសិក្សាខ្ពស់ជាអ្នកមើលទូរទស្សន៍។ នៅតំបន់ភ្នំ អ្នកមើលទូរទស្សន៍មានអត្រាទាបជាងគេបំផុត (៥០%)។

កម្មវិធី ដែលមានការពេញនិយមជាងគេគឺៈ

- ភាពយន្តភាគអន្តរជាតិ៧៧%
- ព័ត៌មាន ៧៦%
- តន្ត្រី និងរឿងកំប្លែង ៦២%
- ភាពយន្តភាគខ្មែរ ៥២%
- កម្មវិធីកីឡា ៣៨%
- កម្មវិធីចម្រៀង ២៣%

ដូចនឹងកម្មវិធីតាមវិទ្យុដែរ កម្មវិធីបរិស្ថានមានការទាក់ទាញទស្សនិកជនតិចតួចណាស់។

ស្ត្រីនិយមមើលភាពយន្តភាគអន្តរជាតិ (៨៣%) និងភាពយន្តភាគខ្មែរ (៦៥%) និងយុវជនដែលមានអាយុ ១៥-២៤ឆ្នាំ (៨២% មើលភាពយន្តភាគអន្តរជាតិ និង៦០% មើលភាពយន្តភាគខ្មែរ)។

ព័ត៌មានមានការពេញនិយម ក្នុងចំណោមបុរស (៨៣%) ជាងស្ត្រី។

បុរស (៥៧%) និងក្រុមមនុស្សចាស់ (៤៥%) និយមមើលកម្មវិធីកីឡា។

ការប្រគុំតន្ត្រី និងរឿងកំប្លែង (៦៩%) និងកម្មវិធីចម្រៀង (៣១%) មានការពេញនិយមក្នុងចំណោមអ្នកឆ្លើយជាយុវជន។

## *រយៈពេល និងម៉ោងនៃការមើលទូរទស្សន៍*

មនុស្សភាគច្រើនមើលទូរទស្សន៍នៅចុងសប្តាហ៍ ដោយមាន ៨០%មើលទូរទស្សន៍នៅថ្ងៃសៅរ៍ និង៨១% មើលនៅថ្ងៃអាទិត្យ។ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រជាថ្ងៃ ដែលមានការមើលទូរទស្សន៍តិចជាងគេ ដោយទាក់ទាញទស្សនិកជនត្រឹមតែ ៧០% ប៉ុណ្ណោះ។

---

[៤៣] សម្រាប់គោលបំណងនៃការសិក្សានេះយើងឱ្យនិយមន័យ "អ្នកមើលទូរទស្សន៍" ថាជាអ្នកណាម្នាក់ដែលបានមើលទូរទស្សន៍នៅក្នុងខែមុនការអង្កេតនេះ។

អ្នកផ្តល់សម្ភាសន៍សំណួរភាគច្រើន (៥៥%) មើលទូរទស្សន៍ម្តងក្នុងមួយថ្ងៃ ក្នុងនោះភាគច្រើនមើលទូរទស្សន៍ច្រើនជាងកន្លះម៉ោង (៤២% ពោលថាពួកគេមើលទូរទស្សន៍នៅរវាងកន្លះម៉ោង និងមួយម៉ោង ចំណែក ៣៦% ទៀត ពោលថាពួកគេមើលទូរទស្សន៍ច្រើនជាងមួយម៉ោង)។

អ្នកដែលមើលទូរទស្សន៍ភាគច្រើន (៦៦%) មើលទូរទស្សន៍នៅរវាងម៉ោង ៦ ល្ងាច និងម៉ោង ៨ ល្ងាច ដោយមានច្រើនជាងពាក់កណ្តាល (៥២%) មើលនៅរវាងម៉ោង ៨ យប់ ដល់ ១០ យប់។ មួយភាគបួន (២៦%) មើលនៅពេលអាហារថ្ងៃត្រង់រវាងម៉ោង ១២ ថ្ងៃត្រង់ និងម៉ោង ២ រសៀល។

បុរសមើលទូរទស្សន៍នៅមុនម៉ោង ដែលស្ត្រីមើល។ បុរស (២៥%) ច្រើនជាងស្ត្រី (១៣%) មើលទូរទស្សន៍នៅរវាងម៉ោង ៦ ល្ងាច និងម៉ោង ៨ យប់។

ភាគច្រើននៃក្រុមដែលមានវ័យក្មេងជាងគេ (១៥-២៤ឆ្នាំ) មើលទូរទស្សន៍នៅពេលព្រឹក និងរសៀល ខណៈដែល ៣៣% ទៀតមើលនៅរវាងថ្ងៃត្រង់ និងម៉ោង ២ រសៀល។ ស្ត្រី (២៩%) និងអ្នកទីក្រុង (៣៤%) ក៏មើលទូរទស្សន៍នៅចន្លោះថ្ងៃត្រង់ និងម៉ោង ២ រសៀលផងដែរ។

## *ប៉ុស្តិ៍ទូរទស្សន៍*

ប៉ុស្តិ៍ទូរទស្សន៍ ដែលពេញនិយមជាងគេនៅកម្ពុជាគឺ៖

- ស៊ីធីអិន (CTN) ៧៤% - នៅទីក្រុង
- បាយ័ន (ប៉ុស្តិ៍២៧) ៦៩% - នៅទីក្រុង
- ទូរទស្សន៍ខេមរៈភូមិន្ទ (TV5) ៥៧% - នៅជនបទ

បន្ទាប់មកគឺប៉ុស្តិ៍ដូចខាងក្រោមនេះជាប៉ុស្តិ៍ ដែលមានការទាក់ទាញអ្នកមើលមួយភាគបី៖

- ទូរទស្សន៍រាជធានីភ្នំពេញ (TV3) ៣៦%
- ប៉ុស្តិ៍អាស៊ីអាគ្នេយ៍(SEA TV) ៣៥%
- ម៉ាយធីវី (My TV) ៣៥% - ក្រុមយុវជនអ្នកនៅទីក្រុង
- ទូរទស្សន៍ជាតិកម្ពុជា (TVK) ៣៣%
- ទូរទស្សន៍ខ្មែរ ទទខ (CTV9) ៣២% - ច្រើនតែនៅជនបទ

ប៉ុស្តិ៍ចំនួនពីរ ដែលទាក់ទាញទស្សនិកជនមួយចំនួនផងដែរ ទោះបីមិនបានច្រើនដូចប៉ុស្តិ៍ខាងលើក៏ដោយ៖

- អប្សរា (TV11) ២៥% - ភាគច្រើននៅជនបទ
- បាយ័ន(ថ្មី) ១៤%

អ្នកមើលទូរទស្សន៍ទាំងអស់អាចចងចាំប៉ុស្តិ៍ ដែលពួកគេមើលមិនដូចអ្នកស្តាប់វិទ្យុឡើយ។

## *ការប្រើប្រាស់ទូរស័ព្ទចល័ត*

ប្រជាជនកម្ពុជា ៩១% ប្រើប្រាស់ទូរស័ព្ទចល័ត ហើយច្រើនជាងពាក់កណ្តាល (៦០%) មានទូរស័ព្ទចល័តផ្ទាល់ខ្លួន។

## ការប្រើប្រាស់សេវាទូរស័ព្ទ

មានភាពខុសគ្នាតិចតួចរវាងបុរស និងស្ត្រីទាក់ទងនឹងការប្រើប្រាស់ទូរស័ព្ទចល័ត។

អ្នកនៅទីក្រុង និងអ្នក ដែលមានការសិក្សាកម្រិតឧត្តម និងក្រុមដែលមាន PPI ខ្ពស់មានលទ្ធភាពប្រើប្រាស់ទូរស័ព្ទចល័ត។ ជាក់ស្តែង ១០០% នៃអ្នកផ្តល់សម្ភាសន៍ ដែលមានការសិក្សាថ្នាក់មហាវិទ្យាល័យមានលទ្ធភាពប្រើទូរស័ព្ទចល័ត។

អ្នកឆ្លើយមកពីតំបន់ភ្នំមានលទ្ធភាពតិចតួចជាងគេ ក្នុងការប្រើប្រាស់ទូរស័ព្ទចល័តដោយមានត្រឹមតែ ៨២% ដែលអាចប្រើប្រាស់ទូរស័ព្ទចល័ត។

## ភាពជាម្ចាស់លើទូរស័ព្ទចល័ត

៦០% មានទូរស័ព្ទចល័តមួយគ្រឿង។

បុរស (៦៩%) អ្នកទីក្រុង (៧០%)អ្នក ដែលមានការសិក្សាកម្រិតឧត្តម និងអ្នកមកពីក្រុមមាន PPI ខ្ពស់មានទូរស័ព្ទចល័តប្រើប្រាស់។

ស្ត្រីក្នុងចំនួនតិច (ត្រឹម៥០% ជិត ២០% ទាបជាងតួលេខ សម្រាប់បុរស) មានទូរស័ព្ទចល័ត។

អត្រាទាបជាង នៃកម្មសិទ្ធិលើទូរស័ព្ទក៏ឃើញមាន ក្នុងចំណោមអ្នករស់នៅតំបន់បឹងទន្លេសាប (៥២%) តំបន់ឆ្នេរ (៥៨%) អ្នកផ្តល់សម្ភាសន៍ ដែលមានវ័យក្មេងបំផុត (៥៦%) អ្នក ដែលមានកម្រិតការសិក្សាទាប និងអ្នកមកពីក្រុមមាន PPI ទាបផងដែរ។

## តើអ្នកមិនប្រើប្រាស់ទូរស័ព្ទចល័តប្រើប្រាស់សេវាទូរស័ព្ទបែបណា?

ការប្រើប្រាស់ទូរស័ព្ទសាច់ញាតិ (៣០%) និងទូរស័ព្ទសាធារណៈ (២៣%) គឺជាការកត់សម្គាល់ទូទៅជាងគេ។ ការប្រើប្រាស់ទូរស័ព្ទ ដែលជាកម្មសិទ្ធិរបស់ប្តី ឬប្រពន្ធ (ដៃគូ) (១៣%) មិត្តភក្តិ (៨%) និងអ្នកជិតខាង (៦) ក៏កើតមានផងដែរ។

អ្នកជនបទ (៣២%) និងអ្នករស់នៅក្នុងតំបន់នានាក្រៅពីក្រុងភ្នំពេញ (១៧%) និងតំបន់ទំនាប (២៣%) (អ្នកក្នុងតំបន់ទាំងនេះ មានចំនួនតិចតួច ដែលជាអ្នកពឹងផ្អែកលើសាច់ញាតិ) ប្រើប្រាស់ទូរស័ព្ទរបស់សាច់ញាតិ។ អ្នកឆ្លើយសំណួរវ័យក្មេង (៤២%) ប្រើប្រាស់ទូរស័ព្ទរបស់សាច់ញាតិ ដូចអ្នកដែលមានការសិក្សាកម្រិតទាប និងអ្នកមកពីក្រុម ដែលមាន PPI ទាបផងដែរ។

មនុស្សជាច្រើន ដែលរស់នៅក្នុងតំបន់ឆ្នេរ (៣៨%) និងអ្នកដែលមកពីក្រុមមាន PPI កម្រិតទាបមានការពឹងផ្អែកលើទូរស័ព្ទសាធារណៈ។

សមាមាត្រស្ត្រី (២៣%) ខ្ពស់ជាងបុរស (៣%) ប្រើប្រាស់ទូរស័ព្ទជារបស់ដៃគូខ្លួន។ អ្នក ដែលមានអាយុ២៥-៤៤ ភាគច្រើនប្រើប្រាស់ទូរស័ព្ទដៃគូរបស់ខ្លួន ដូចអ្នកដែលមានកម្រិតសិក្សាទាបផងដែរ ។ ប្រហែលជារឿងមួយ ដែលគួរឱ្យភ្ញាក់ផ្អើល ដែលអ្នកស្ថិតនៅក្នុងក្រុម ដែលមាន PPI ខ្ពស់បញ្ជាក់ថាពួកគេប្រើប្រាស់ទូរស័ព្ទដៃគូរបស់ខ្លួន។ អ្នកនៅក្នុងក្រុមដែលមាន PPI ទាបភាគច្រើនពឹងផ្អែកលើអ្នកជិតខាង និងសាច់ញាតិ និងទូរស័ព្ទសាធារណៈផងដែរ (ប្រមាណ១០% ខ្ពស់ជាងតួលេខមធ្យម សម្រាប់ការឆ្លើយនីមួយៗ ក្នុងចំណោមអ្នក ដែលមានPPI កម្រិតទាបបំផុត។

បុរស (១១%) អ្នកទីក្រុង (៩%) និងអ្នកផ្តល់សម្ភាសន៍សំណួរវ័យក្មេង (១៥%) និងយុវជនធ្វើការ (១២%) ពោលថាពួកគេប្រើប្រាស់ទូរស័ព្ទរបស់មិត្តភក្តិ។

អ្នករស់នៅជនបទ (៨%) នៅតំបន់ឆ្នេរ (៧%) តំបន់ភ្នំ (១០%) និងអ្នកដែលមានការសិក្សាទាប និងអ្នកដែលមាន PPI កម្រិតទាប ពោលថាពួកគេប្រើប្រាស់ទូរស័ព្ទរបស់អ្នកជិតខាង។

## *បណ្តាញទូរស័ព្ទចល័ត*

ម៉ូប៊ីតែល និងមេតហ្វូនគឺជាបណ្តាញទូរស័ព្ទចល័តធំជាងគេចំនួនពីរ ដែលបានឆ្លើយដោយអ្នកផ្តល់សម្ភាសន៍សំណួរចំនួន ៥២% សម្រាប់បណ្តាញនីមួយៗ។ ទោះជាយ៉ាងណាក៏ដោយ មានភាពខុសគ្នាជាសំខាន់លើប្រវត្តិរូប នៃអ្នកប្រើប្រាស់បណ្តាញនីមួយៗ។

បុរសច្រើន (៥៥%) ជាងស្ត្រី (៤៧%) ប្រើប្រាស់ម៉ូប៊ីតែល។ ពុំសូវមានភាពខុសគ្នាឡើយខាងយ៉េនឌ័រ រវាងអ្នកប្រើប្រាស់បណ្តាញទូរស័ព្ទមេតហ្វូន។

រវាងអ្នកប្រើប្រាស់នៅទីក្រុង និងជនបទពុំមានភាពខុសគ្នាច្រើនឡើយ លើការប្រើប្រាស់បណ្តាញទូរស័ព្ទ។

ទោះជាយ៉ាងណាក៏ដោយ ម៉ូប៊ីតែលមានការប្រើប្រាស់ទាបជាខ្លាំងនៅតាមតំបន់ឆ្នេរ (២៣%) និងតំបន់ភ្នំ (៣១%) ចំណែកមេតហ្វូនមានការប្រើប្រាស់ខ្ពស់នៅក្នុងតំបន់ទាំងពីរនេះ (៦២% នៅតំបន់ឆ្នេរ និង៦៧% នៅតំបន់ភ្នំ)។

ខណៈ ដែលមនុស្សចាស់ប្រើប្រាស់ម៉ូប៊ីតែល (៥៧% នៃអ្នកប្រើប្រាស់ ដែលមានអាយុចំណាស់ធៀបនឹង ៣៩% នៃអ្នកប្រើប្រាស់មានវ័យក្មេងជាងគេ) យុវជនប្រើប្រាស់មេតហ្វូន (៦២% នៃអ្នកប្រើប្រាស់វ័យក្មេងបំផុតធៀបនឹង ៣៩% នៃអ្នកប្រើប្រាស់វ័យចាស់)។ ប្រការ ដែលសំខាន់នោះគឺអ្នកនៅក្នុងក្រុមដែលមាន PPI កម្រិតទាបបំផុត ជាអ្នកប្រើប្រាស់មេតហ្វូន (៦៩%) ចំណែកអ្នក ដែលនៅក្នុងក្រុម ដែលមាន PPI កម្រិតខ្ពស់ប្រើប្រាស់ម៉ូប៊ីតែល)។

អត្រាដ៏ខ្ពស់នៃយុវជនធ្វើការគឺប្រើប្រាស់មេតហ្វូន (៦០%)។

## *មុខនាទីនៃទូរស័ព្ទចល័ត*

អ្នកទាំងអស់ ដែលមានលទ្ធភាពប្រើប្រាស់ទូរស័ព្ទចល័តប្រើប្រាស់ទូរស័ព្ទ ដើម្បីហៅចេញនិងទទួលការហៅចូល។

ក្រៅពីមុខងារហៅចេញប្រជាជនប្រើប្រាស់ទូរស័ព្ទសម្រាប់៖

- ស្តាប់តន្ត្រី ៦០%
- ដាក់សម្លេងរោទ៍ ៥០%
- ថតរូប ៤៧%
- ផ្ញើ និងទទួលសារ ៤៥%
- លេងហ្គេម ៣៩%
- ស្តាប់សម្លេងរោទ៍ ៣៣%
- ស្តាប់វិទ្យុ ៣៣%

- ថតសម្លេង ២៩%

មានតែមួយចំនួនតូចប៉ុណ្ណោះប្រើប្រាស់អ៊ិនធឺណែតតាមទូរស័ព្ទ (៥%)។

## ការផ្ញើសារ

ក្នុងចំណោម អ្នកប្រើប្រាស់សេវាផ្ញើសារតាមទូរស័ព្ទចល័តភាគច្រើន (៨២%) ប្រើប្រាស់សម្រាប់ផ្ញើសារជាភាសាអង់គ្លេស។ មនុស្សប្រហែល ៤ នាក់ ក្នុង១០នាក់ (៣៩%) ផ្ញើសារ ដែលមានគំរូជាស្រេច និងមនុស្សលើសពី ២ នាក់ ក្នុង ១០នាក់ ផ្ញើសារជាភាសាខ្មែរ។

អ្នកនៅទីក្រុង (៩២%) ច្រើនផ្ញើសារជាភាសាអង់គ្លេស។

អ្នកនៅជនបទច្រើនបញ្ជូនសារជាភាសាខ្មែរ។

បុរស (៤២%) និងក្រុមមនុស្សមានវ័យក្មេង ជាពិសេសក្នុងអាយុ ២៥-៣៤ ឆ្នាំ បញ្ជូនគំរូសារ ដែលមានស្រាប់។

ទោះបីជាអ្នកប្រើប្រាស់ជិតពាក់កណ្តាល នៃអ្នកផ្តល់សម្ភាសន៍ទាំងអស់ពោលថាពួកគេប្រើប្រាស់ទូរស័ព្ទចល័តដើម្បីថតរូប (ដូចរៀបរាប់ក្នុងតួនាទីខាងលើ) មានមនុស្សមួយចំនួនតូច (២%) បញ្ជូនរូបភាពតាមសារខ្លី។

## សារព័ត៌មានបោះពុម្ព (Print Media)

អ្នកស្រាវជ្រាវមិនបានលើកសំណួរពិស្តារឡើយ ទាក់ទងនឹងការប្រើប្រាស់សារព័ត៌មានបោះពុម្ព។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានបោះពុម្ពពិតជាមានកម្រិត នៃការផ្សព្វផ្សាយមានកម្រិតកំណត់ បើធៀបនឹងវិសាលភាពគ្របដណ្តប់ នៃទូរទស្សន៍ និងវិទ្យុ ដោយមានត្រឹមតែ ១២% ពោលថាពួកគេធ្លាប់បានអានសារព័ត៌មាន និងត្រឹមតែ ៩% ដែលពោលថាបានអានទស្សនាវដ្តី ដើម្បីទទួលព័ត៌មាន។

ដូចគ្នានេះដែរ នៅពេលសួរថាតើពួកគេធ្លាប់បានប្រើប្រាស់ប្រភពព័ត៌មាន ដែលមិនមានរៀបរាប់នៅក្នុងតារាងសំណួរនេះដែរឬទេ? មានអ្នកឆ្លើយសំណួរតិចជាង ២% បានរៀបរាប់ពីប្រភពព័ត៌មានបន្ថែម។ ដោយសារតែទម្រង់ដទៃទៀតនៃព័ត៌មានបោះពុម្ព ដូចជាប័ណ្ណព័ត៌មាន ខិត្តប័ណ្ណ ប័ណ្ណប្រកាស។ល។ មិនបានរៀបរាប់ នៅក្នុងតារាងសំណួរ មានអ្នកឆ្លើយសំណួរ តិចជាង ១% ដែលនឹកឃើញភ្លាមៗ ហើយបានឆ្លើយ នូវ គំរូព័ត៌មានទាំងនេះ។

## ការប្រើប្រាស់អ៊ីនធឺណែត

មានប្រជាជនមួយចំនួនតូចប៉ុណ្ណោះ (៤%) ដែលបានប្រើប្រាស់អ៊ីនធឺណែត។ ក្នុងចំណោមអ្នកទាំងនោះ ភាគច្រើនជាអ្នករស់នៅទីក្រុង (៨% នៃអ្នករស់នៅទីក្រុងពោលថាពួកគេប្រើប្រាស់អ៊ីនធឺណែត) ដែលខ្ពស់ជាងនៅទីជនបទ (ដែលមានអត្រាទាបជាង ២% បានពោលថាពួកគេប្រើប្រាស់អ៊ីនធឺណែត)។

ក្រុមអ្នកប្រើប្រាស់អ៊ីនធឺណែតគឺជាយុវជនអ្នករស់នៅទីក្រុង អ្នកមានការសិក្សាខ្ពស់ និងអ្នកមាន PPI កម្រិតខ្ពស់។ អ្នកប្រើប្រាស់អ៊ីនធឺណែតមានអត្រាខ្ពស់ នៅក្នុងក្រុងភ្នំពេញ បើទោះជាមានអ្នកប្រើប្រាស់ខ្លះរស់នៅក្នុងតំបន់ផ្សេងទៀតក៏ដោយ។

អ្នកប្រើប្រាស់អ៊ីនធឺណែតច្រើនតែប្រើប្រាស់ដើម្បី៖

- ស្វែងរកព័ត៌មាន ៧៣%
- ទទួលដំណឹង ៦៥%
- ប្រើប្រាស់អ៊ីម៉ែល ៥៧%

ប្រជាជនប្រើប្រាស់អ៊ិនធឺណែតនៅៈ

- ហាងផ្តល់សេវាអ៊ិនធឺណែត ៥៩%
- តាមការិយាល័យ ២៦%
- នៅតាមគេហដ្ឋាន ១៥%។

## *ឌីវីឌី និងវីស៊ីឌី (DVD and VCD)*

ឌីវីឌីមានប្រជាប្រិយភាព ដោយ ៥៩% នៃអ្នកផ្តល់សម្ភាសន៍ពោលថាពួកគេបានមើលឌីវីឌី ឬវីស៊ីឌីនៅក្នុងខែកន្លងទៅ និង ៣៣% បានមើលឌីវីឌី/វីស៊ីឌីនៅក្នុងថ្ងៃ ឬនៅមុនថ្ងៃធ្វើការអង្កេតនេះ។

ពួកគេច្រើនតែប្រើប្រាស់ឌីវីឌីដើម្បីមើលៈ

- ភាពយន្តភាគ ៨៩%
- ចម្រៀង ៧១%
- រឿងកំប្លែង ៣៥%

ប្រជាជនភាគច្រើនមើលឌីវីឌី/វីស៊ីឌីនៅតាមផ្ទះផ្ទាល់ខ្លួន (៦៥%) ជាមួយមិត្តភក្តិ (២៦%) ជាមួយសាច់ញាតិ (១៩%) ឬនៅក្នុងហាងលក់កាហ្វេ (១៦%)។

## *ការផ្សព្វផ្សាយតាមរយៈសកម្មភាពផ្ទាល់*

ច្រើនជាងពាក់កណ្តាល(៥៦%) នៃអ្នកឆ្លើយបានប្រាប់ថាពួកគេបានពាក់ព័ន្ធ ក្នុងសកម្មភាពផ្សព្វផ្សាយនៅអំឡុងពេលខែមុននៃការអង្កេតនេះ។ មានតែ ១៥% ដែលពោលថាពួកគេពុំ ដែលពាក់ព័ន្ធនៅក្នុងការផ្សព្វផ្សាយបែបនេះ។

## *ចំណង់ចំណូលចិត្តលើការផ្សព្វផ្សាយផ្ទាល់*

សកម្មភាពផ្សព្វផ្សាយខុសៗគ្នាទំនងជាមានការទាក់ទាញសម្រាប់ក្រុមមនុស្សខុសគ្នា។

ស្ត្រីចូលចិត្តសកម្មភាពនានា ដែលប្រើប្រាស់ការបង្ហាញប័ណ្ណ (៣៣%) ឬការអប់រំនៅតាមផ្ទះ និងជាមួយគ្រួសារ (២៥%)។

ការអប់រំមានតួនាទីកាន់តែសំខាន់ ក្នុងចំណោមអ្នកឆ្លើយដែលមានវ័យក្មេង (២៩% នៃអ្នកដែលមានអាយុ១៥-២៤ ឆ្នាំ) និងដោយអ្នក ដែលមានការសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ (៣០%)។

សិក្ខាសាលាកាន់តែដើរតួនាទីសំខាន់ សម្រាប់អ្នករស់នៅក្នុងទីក្រុង (១៧%) ដែលមានការអប់រំខ្ពស់ (៤៤% អ្នកដែលមានការសិក្សាថ្នាក់សាកលវិទ្យាល័យ) និងមកពីក្រុមដែលមាន PPI ខ្ពស់ (២០% អ្នកដែលមាន PPI ពី ៧៥ ដល់ ១០០)។

# តើបុគ្គលសំខាន់ៗនៅកម្ពុជាដឹង និងយល់អ្វីខ្លះអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា?

ការស្រាវជ្រាវនេះផ្អែកលើការសម្ភាសចំនួន ១០១ រូប ជាមួយបុគ្គលសំខាន់ៗ មកពីខេត្តខុសៗគ្នាចំនួន ២០[៤៤]

- តំណាងរដ្ឋាភិបាលចំនួន ៥ រូប
- សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភាចំនួន ៥ រូប
- អភិបាលខេត្តចំនួន ៥ រូប
- ប្រធានក្រុមប្រឹក្សាឃុំចំនួន ២០ រូប
- ប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យចំនួន ៣០ រូប
- ពិធីករចំនួន ៥ រូប
- តំណាងមកពីវិស័យឧស្សាហកម្មចំនួន ៦ រូប
- តំណាងមកពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានចំនួន ៥ រូប
- តំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលចំនួន ៥ រូប
- មេដឹកនាំសាសនាចំនួន ១៥ រូប។

ការវិភាគដែលនឹងរៀបរាប់នៅខាងក្រោមនេះ គឺផ្អែកលើរបកគំហើញមកពីការសម្ភាសជាមួយបុគ្គលសំខាន់ៗចំនួន ១០១ រូប។ សំដីដកស្រង់ ដែលត្រូវបានប្រើប្រាស់ ដើម្បីបង្ហាញពីរបកគំហើញ គឺបានជ្រើសរើសចេញពីការសម្ភាសទាំង ១០១ ដោយប្រើប្រាស់លេខកូត នៅក្នុងកម្មវិធី Atlas.ti និងឆ្លុះបញ្ចាំងអំពីចំណុច ដែលគួរឱ្យចាប់អារម្មណ៍ និងដើរតួនាទីដ៏សំខាន់ ដែលកើតចេញពីទិន្នន័យនេះ។ ដើម្បីរក្សាការពារភាពអនាមិករបស់អ្នក ដែលផ្តល់សម្ភាសន៍ ដូចនេះឈ្មោះរបស់ពួកគេមិនបានដាក់បញ្ចូលនៅក្នុងការវិភាគឡើយ។ ការសម្ភាសខ្លះ ដែលបង្ហាញនៅទីនេះបង្ហាញពីការយល់ខុស របស់បុគ្គលខ្លះ ឬក្រុមខ្លះ នឹងមិនឆ្លុះបញ្ចាំងពីទស្សនៈ របស់អង្គការ BBC World Service Trust ឬក្រសួងបរិស្ថានឡើយ។ (ចំពោះសេចក្តីលម្អិតអំពីវិធីសាស្ត្រ សូមអានឧបសម្ព័ន្ធ ១)។

## ការយល់ដឹង អំពីការប្រែប្រួលអាកាសធាតុ

បុគ្គលសំខាន់ៗមួយចំនួនមានការយល់ដឹងពិស្តារ អំពីមូលហេតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុសកល។ ពាក្យថា "ឧស្ម័នផ្ទះកញ្ចក់" ឬ "ការបំភាយកាបូន" ត្រូវបានប្រើប្រាស់មិនសូវញឹកញាប់ឡើយ ដែលជាការបញ្ជាក់ថាចំណេះដឹងរបស់អ្នកឆ្លើយ អំពីមូលដ្ឋានវិទ្យាសាស្ត្រ នៃការប្រែប្រួលអាកាសធាតុនៅមានកម្រិតកំណត់។ អ្នកផ្តល់ សម្ភាសន៍មួយចំនួន ដែលមិនមែនជាមន្ត្រីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ បានកត់សម្គាល់អំពីការរីកចម្រើនមួយចំនួន នៃគោលនយោបាយអន្តរជាតិ ដូចជាអនុសញ្ញា UNFCCC ពិធីសារក្យូតូ និងសន្និសីទកំពូលលើកទី ១៥ នៃបណ្តាប្រទេសជាសមាជិក (COP 15) នៅទីក្រុងកូប៉េនហាក់ហ្គិន កាលពីខែធ្នូ ឆ្នាំ២០០៩។ ផ្ទុយទៅវិញការពន្យល់ របស់

[៤៤] មានខេត្តចំនួនបួនដែលការស្រាវជ្រាវមិនមានអ្នកតំណាង ៖ស្វាយរៀង ស្ទឹងត្រែង បន្ទាយមានជ័យ និងរតនគិរី។

ពួកគេ នូវពាក្យ "ការប្រែប្រួលអាកាសធាតុ" ច្រើនតែផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួន អំពីការប្រែប្រួលធាតុអាកាសនៅកម្ពុជា និងការសង្កេតរបស់ពួកគេអំពីការរេចរឹលបរិស្ថាននៅមូលដ្ឋាន។

## *ការយល់ដឹងអំពីបច្ចេកសព្ទ*

បុគ្គលសំខាន់ៗស្ទើរតែគ្រប់រូប ដែលបានសម្ភាសនៅក្នុងការស្រាវជ្រាវនេះ ពោលថាពួកគេធ្លាប់ឮពាក្យ "ការប្រែប្រួលអាកាសធាតុ"។ ពាក្យនេះទំនងជាមានការប្រើប្រាស់ញឹកញាប់ជាងពាក្យ "ការឡើងកម្តៅផែនដី" ដែលអ្នកខ្លះពោលថាពួកគេមិនដែលឮឡើយពីមុនមក។

ទោះបីបុគ្គលសំខាន់ៗភាគច្រើនឮពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី" ក៏ដោយ ក៏ពួកគេនៅពុំទាន់មានការយល់ដឹងទូលំទូលាយ នូវអត្ថន័យនៃពាក្យទាំងនេះឡើយ។ ដូចដែលតំណាងមួយរូបពីរដ្ឋាភិបាលបានពោល

> *...អ្នកនយោបាយប្រើពាក្យ..."ការប្រែប្រួលអាកាសធាតុ" តែពាក្យនឹងវាមិនបង្ហាញឲ្យច្បាស់ពីមូលហេតុ ឬឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ។ គ្រាន់តែថាយើងមានអារម្មណ៍ក្តៅ ត្រជាក់ ឬជួនណាទៅដូចយើងឃើញស្រាប់ហើយ គឺមានទឹកជំនន់ជាដើម។ ពាក្យហ្នឹងអត់បានប្រាប់យើងពីឥទ្ធិពលមកពីការប្រែប្រួលអាកាសធាតុ ឬប្រាប់ថានរណាដែលទទួលឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ ។*

បុគ្គលសំខាន់ៗមួយចំនួនតូចបានឮពាក្យ "ផលផ្ទះកញ្ចក់" ឬ "ឧស្ម័នផ្ទះកញ្ចក់"។ សូម្បីតែក្នុងចំណោមអ្នកឆ្លើយសំខាន់ៗ ដែលប្រើប្រាស់ពាក្យទាំងនេះជាញឹកញាប់ និងមានចំណេះដឹងបច្ចេកទេសពិស្តារ អំពីមូលហេតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុហើយក៏ដោយ ក៏នៅមានការយល់ច្របូកច្របល់ជាច្រើននៅជុំវិញពាក្យទាំងនេះដែរ។ ភាពច្របូកច្របល់នេះកើតចេញពីការបកប្រែជាភាសាខ្មែរនូវពាក្យ greenhouse effect ដែលប្រែថា *ផលផ្ទះកញ្ចក់* (សូមអាន *ការបកប្រែពាក្យការប្រែប្រួលអាកាសធាតុ* ទំព័រ២៣)។ ពាក្យនេះត្រូវបានប្រជាជនយល់ថាជា "ផលនៃផ្ទះ ដែលបង្កដោយកញ្ចក់" - ដោយប្រជាជនកម្ពុជាមួយចំនួនតូចប៉ុណ្ណោះ ដែលធ្លាប់បានឃើញផ្ទះកញ្ចក់ដែលសង់ សម្រាប់ការដាំដំណាំពីមុនមក។ ប្រការនេះបាននាំឱ្យមានការយល់ខុសមួយចំនួន។

> *បើអង់គ្លេសគេប្រើ "greenhouse"។ ម៉េចក៏យើងមិនព្រមបកតាមអង់គ្លេសទៅ? ខ្ញុំមិនយល់ថាហេតុអ្វីបានជាយើងបកប្រែថា "ឧស្ម័នផ្ទះកញ្ចក់"...ការបកប្រែដូចជាអត់ត្រឹមត្រូវ។ ខ្ញុំរៀននៅមហាវិទ្យាល័យ... ពីដំបូងខ្ញុំគិតថាឧស្ម័នផ្ទះកញ្ចក់គឺជាកម្តៅចេញពីផ្ទះកញ្ចក់ (សើច)។*
>
> **អ្នកតំណាងរដ្ឋាភិបាល**

ក្រៅពីនេះក៏មានការយល់ខុសមួយចំនួនផងដែរ ដែលភាគច្រើនជាទំនាក់ទំនងមិនត្រឹមត្រូវរវាងប្រយោគ "ការប្រែប្រួលអាកាសធាតុ" "ការឡើងកម្តៅផែនដី"និង"ផលផ្ទះកញ្ចក់" និងចំណេះដឹង របស់ប្រជាជនអំពីការធ្លុះធ្លាយស្រទាប់អូហ្សូន។

> *ដោយសារផែនដីរបស់យើងមានស្រទាប់អូហ្សូនការពារ។ ស្រទាប់អូហ្សូនហ្នឹងហើយ ដែលគេហៅថា "ផ្ទះកញ្ចក់"។ រីឯពាក្យ "greenhouse" គឺគេចង់និយាយពីកន្លែង ដែលគេថែទាំរុក្ខជាតិ។ បានន័យថាគេបណ្តុះរុក្ខជាតិអញ្ចឹងគេ*

*ត្រូវដាក់នៅក្នុងកញ្ចក់ ដើម្បីរក្សាកម្ដៅឲ្យបានល្អ។ ចំណែកផែនដីយើងក៏វាអញ្ចឹងដែរ។ ពន្លឺព្រះអាទិត្យ ដែលចាំង ចូលមកផែនដីវាអត់អាចចេញពីស្រទាប់អូហ្សូនទេ។ អញ្ចឹងកម្ដៅ ដែលចូលមកវាក្ដៅឡើងធំ។*

**អ្នកតំណាងខាងវិស័យឧស្សាហកម្ម**

បុគ្គលសំខាន់ៗបានពោលថាពួកគេឮពាក្យទាំងនេះពីប្រភពខុសៗគ្នា។ អ្នកផ្ដល់សម្ភាសន៍ស្ទើរតែទាំងអស់ ពោល ថាពួកគេបានឮពាក្យ "ការប្រែប្រួលអាកាសធាតុ" តាមទូរទស្សន៍ និងវិទ្យុ។ ភាគច្រើន នៃអ្នកទាំងនេះ ពោលថាទាំងប្រព័ន្ធ ព័ត៌មានជាតិ និងអន្តរជាតិគឺជាប្រភពព័ត៌មានអំពីប្រធានបទនេះ។

អ្នកខ្លះកត់សម្គាល់ ថាការសែត ជាប្រភពមួយ នៃព័ត៌មាននេះ ហើយមនុស្សមួយចំនួនតូចពោលថាពួកគេបានប្រើ ប្រាស់អ៊ីនធឺណែត ដើម្បីស្វែងរកព័ត៌មានបន្ថែមទៀតអំពីប្រធានបទនេះ។ ប្រធានភូមិខ្លះ និងចាស់ព្រឹទ្ធាចារ្យ បញ្ជាក់ថាពួក គាត់ស្ដាប់ព័ត៌មានតិចតួចប៉ុណ្ណោះ។

ប្រភពដទៃទៀតក្រៅពីប្រព័ន្ធផ្សព្វផ្សាយរួមមានក្រសួងបរិស្ថានកម្ពុជា កាកបាទក្រហមកម្ពុជា អង្គការមិនមែន រដ្ឋាភិបាល (មូលនិធិអភិរក្សធនធានធម្មជាតិ [WWF] និងអង្គការទស្សនៈពិភពលោក [World Vision] ត្រូវបានរៀបរាប់ចំ ឈ្មោះដោយអ្នកផ្ដល់សម្ភាសន៍) សិក្ខាសាលា ការសង្កេតផ្ទាល់ខ្លួន និងការនិយាយតគ្នាពីមាត់មួយទៅមាត់មួយ។ ដូចដែល អភិបាលខេត្តមួយរូបពន្យល់ៈ

*ខ្ញុំរស់នៅហ្នឹង ខ្ញុំអាចពិសោធន៍មើលដឹងដោយខ្លួនឯងតែម្ដង ហើយខ្ញុំឮពីមជ្ឈដ្ឋានប្រជាពលរដ្ឋ...ខ្ញុំបានឮពីប្រជា ពលរដ្ឋគ្រប់ស្រុកទាំង ៥ រួមទាំងក្រុងនេះផងដែរ។ គេតែងតែនិយាយត្អូញត្អែរពីការប្រែប្រួលអាកាសធាតុ។*

ប្រធានក្រុមប្រឹក្សាឃុំ និងប្រធានភូមិច្រើនតែពោលថា ពួកគេបានឮអំពីការប្រែប្រួលអាកាសធាតុពីចាស់ទុំនៅក្នុង សហគមន៍។

*ខ្ញុំឮនេះ (ការប្រែប្រួលអាកាសធាតុ) ឮតាមចាស់បុរាណ ដែលគាត់តែងតែនិយាយថាពីដើមមកវាមិនដែលមាន។*

**ប្រធានក្រុមប្រឹក្សាឃុំ**

ភាគច្រើន នៃតំណាងរដ្ឋាភិបាល ឧស្សាហកម្ម អង្គការមិនមែនរដ្ឋាភិបាលបានឮអំពីការប្រែប្រួលអាកាសធាតុ តាម រយៈការងាររបស់ខ្លួន។

## ការយល់ឃើញអំពីមូលហេតុ

អ្នកផ្ដល់សម្ភាសន៍ជាច្រើនបានឃើញ ឬឮរបាយការណ៍ អំពីគ្រោះធម្មជាតិ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរ ជាតិ។ ពួកគេរៀបរាប់ដោយផ្សារភ្ជាប់កំណើនសីតុណ្ហភាពនៅឥណ្ឌា ភាពរាំងស្ងួតនៅអាហ្វ្រិក និងការរលាយទឹកកកនៅ តំបន់ប៉ូលទៅនឹងពាក្យ "ការប្រែប្រួលអាកាសធាតុ"។ អ្នកខ្លះក៏អធិប្បាយអំពីការរញ្ជួយដី ព្យុះសមុទ្រ និងបន្ទុះភ្នំភ្លើងថាជា ផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុផងដែរ។

អ្នកផ្ដល់សម្ភាសន៍ទាំងអស់បានបង្ហាញពីចំណងទាក់ទង រវាងការប្រែប្រួលអាកាសធាតុទៅនឹងការបាត់បង់ព្រៃឈើៈ

*ការបាត់បង់ព្រៃឈើធ្វើឲ្យអាកាសធាតុប្រែប្រួល...វា...បណ្តាលឲ្យអត់មានភ្លៀងហើយកម្តៅក៏កាន់តែកើនឡើង...*
**ប្រធានក្រុមប្រឹក្សាឃុំ**

ការយល់ដឹងរបស់បុគ្គលសំខាន់ៗ អំពីការប្រែប្រួលអាកាសធាតុ ភាពរាំងស្ងួត និងការបាត់បង់ព្រៃឈើថាមាន ចំណងទាក់ទង ជាមួយគ្នាដូចពាក្យ របស់ចាស់ព្រឹទ្ធាចារ្យម្នាក់នៅក្នុងភូមិ ពោលថា:

*ការឡើងកម្តៅផែនដីហ្នឹងមានន័យថា អ្វីៗវាខូចខាតវារេចរឹលទៅហ្នឹងវាធ្វើឲ្យមានការប្រែប្រួល។ ទាំងនេះខ្ញុំគិតតាមអ្វី ដែលជាក់ស្តែងអ្វី ដែលខ្ញុំមើលឃើញ។ ដូចនៅព្រៃខាងជើងនេះពីដើមចូលអត់ចុះទេ តែឥឡូវក្រលេកមើលទៅវាលល្វឹង សូម្បីតែដើមឈើមួយដើមគ្មានផង។ ហើយអ្នកធ្លាប់ទៅមើលគោក៏អញ្ចឹងដែរ ពួកគាត់ទៅមើលគោពួកគាត់ជ្រកម្លប់ជ្រកអី ហើយគោស៊ីស្មៅស៊ីស្លឹកអីស្លឹកប្រិចតាមត្របូកតាមទួល។ តែឥឡូវនេះពួកគាត់ទៅមើលគោពួកគាត់អត់មានម្លប់ជ្រកទេ។*
**ចាស់ព្រឹទ្ធាចារ្យ**

ភាគច្រើន នៃបុគ្គលសំខាន់ៗ ដែលផ្តល់ សម្ភាសន៍ ផ្សារភ្ជាប់ការប្រែប្រួលអាកាសធាតុជាមួយការបំពុល នៅ មូលដ្ឋាន ដែលបណ្តាលពីឧស្សាហកម្មយានយន្ត និងគ្រឿងម៉ាស៊ីនផ្សេងទៀត ការប្រើប្រាស់សារធាតុគីមី ជាពិសេសជីគីមី និងការបញ្ចេញផ្សែង ជាពិសេសពីរថយន្ត និងយានយន្តដទៃទៀត:

*ដោយសារមានរោងចក្រច្រើនផ្សេងម៉ាស៊ីនឡានអីចឹងច្រើន...តាមអ្វីដែលខ្ញុំដឹងដូចថាតាមអ្វីដែលខ្ញុំដឹងឮមកកម្តៅផែនដី អីចឹងគឺដូចយើងមានម៉ាស៊ីនអីច្រើនពេក ចឹងទៅវាផ្សែងមានឡើងទៅលើ។ អាផ្សែងហ្នឹងវាប៉ះពពកហើយក៏ចុះមកក្រោមវិញ...*

មានតែបុគ្គសំខាន់ៗមួយចំនួនតូចទេ ដែលភាគច្រើនជាមន្រ្តីរដ្ឋាភិបាលនៅថ្នាក់ជាតិ និង ជាតំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលបញ្ជាក់ពីចំណងទាក់ទងដោយផ្ទាល់ រវាងមូលហេតុនិងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុនៅកម្រិតពិភពលោក:

*យើងក៏ចូលរួមចំណែកដល់ការប្រែប្រួលអាកាសធាតុ ប៉ុន្តែគ្រាន់តែថា យើងមិនទទួលខុសត្រូវលើការប្រែប្រួលអាកាសធាតុនេះទេ ព្រោះយើងទើបតែបំភាយមិនដូច...ប្រទេសអភិវឌ្ឍន៍គេបំភាយ...ដែលចាប់ពីសតវត្សរ៍ទី១៨។ វាច្រើនលើសលុបហើយ។*

**តំណាងអង្គការមិនមែនរដ្ឋាភិបាល**

បុគ្គលសំខាន់ៗខ្លះមកពីក្រុមខុសៗគ្នាបង្ហាញមិនត្រឹមត្រូវអំពីចំណងទាក់ទងរវាង "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី" ទៅនឹង ការឆ្លុះឆ្លាយស្រទាប់អូហ្សូនជាជាងបង្ហាញពីទំនាក់ទំនងត្រឹមត្រូវជាមួយនឹងផលផ្ទះកញ្ចក់។

*ប្រទេសទាំងអស់បានបង្កើត នូវថាមពលអគ្គិសនី។ រោងចក្រទាំងអស់នោះបានបង្កើតជាផ្សែងបង្ហើរទៅប៉ះពាល់ស្រទាប់អូហ្សូនដែលបណ្តាលឲ្យស្រទាប់អូហ្សូនស្តើង។ នៅពេល ស្រទាប់ស្តើងអញ្ចឹងទៅវាក្តៅយកតែម៉ែនទែន។ ហ្នឹងការប្រែប្រួលអាកាសធាតុអញ្ចឹង។*

**ប្រធានក្រុមប្រឹក្សាឃុំ**

បុគ្គលសំខាន់ៗខ្លះ ដែលមកពីគ្រប់សង្គមកម្ពុជា ដែលកាន់សាសនា ដូចជា សាសនាព្រះពុទ្ធ គ្រីស្ទ និងអ៊ីស្លាមបានពន្យល់អំពីគោលគំនិតនេះ ដោយផ្អែកលើជំនឿសាសនា របស់ពួកគេ ដូចដែលពាក្យរបស់មន្ត្រីរដ្ឋាភិបាលពន្យល់បង្ហាញ

*...យើងចាញ់ព្រះពុទ្ធទេ ព្រះពុទ្ធទាយតាំងពី ២៥០០ឆ្នាំ មុនថាវានឹងមានភ្លើងឆេះកាលមួយ...ងាប់ខ្មោចអស់។ គ្មាននរណាម្នាក់វាងវៃជាងព្រះពុទ្ធនោះទេ ឃើញទេឥឡូវអាកាសធាតុកំពុងប្រែប្រួលបន្តិចម្តងៗ។ នៅក្នុងជំនាន់យើងនេះ យើងឃើញហើយដូចខ្ញុំនេះអាចរស់យ៉ាងច្រើនណាស់ ៣០ ឬ ៤០ឆ្នាំទៀតចុះ ប៉ុន្តែក្មេងជំនាន់ក្រោយត្រូវគិតថាពួកគេត្រូវធ្វើអីក្នុងនាមមនុស្សជាតិម្នាក់ ក្នុងមួយថ្ងៃៗគិតត្រូវធ្វើអីឲ្យមានប្រយោជន៍ ដល់ផែនដីដើម្បី ទប់ទល់ការប្រែប្រួលអាកាសធាតុ។ អ្នកឯងអាចធ្វើអីបាននាំគ្នាធ្វើហ្នឹងទៅ ប្រហែលមិនមានមនុស្សច្រើនយល់ចឹងនោះទេ។*

**តំណាងរដ្ឋាភិបាល**

សេចក្តីពន្យល់ខ្លះៗ ដែលបានមកពីប្រធានភូមិ ប្រធានក្រុមប្រឹក្សាឃុំ មេដឹកនាំសាសនា និងអភិបាលខេត្ត មួយចំនួន បង្ហាញថាពួកគេមិនបានដឹងច្បាស់លាស់អំពីការប្រែប្រួលអាកាសធាតុដូចអ្នកធ្វើការ ក្នុងរដ្ឋាភិបាលថ្នាក់ជាតិឡើយ។ បុគ្គលសំខាន់ៗទាំងនេះយល់ឃើញថាទូរស័ព្ទចល័ត និងឧបករណ៍អេឡិចត្រូនិកចល័ត អាវុធ និងគ្រាប់បែកនុយក្លេអ៊ែរ អាចដើរតួនៅក្នុងការធ្វើឱ្យធាតុអាកាសប្រែប្រួលផងដែរ។

*ខ្ញុំសូមលើកឧទាហរណ៍មួយចំនួនពីអ្វី ដែលទាក់ទងនឹងកត្តាមនុស្សបង្កើតឡើង។ ឧទាហរណ៍ចង់និយាយពីរឿងនៅលើពិភពលោកមានកាំជ្រួចផ្លោង ដែលយើងហៅថាមីស៊ីល។ កាំជ្រួចហ្នឹងក៏ជះឥទ្ធិពលដល់ការប្រែប្រួលអាកាសធាតុដែរ។ ហើយមួយទៀត ការដែលបង្កើតជាគ្រាប់បែកបរិមាណូក៏ប៉ះពាល់ ដល់ធាតុអាកាសដែរ ព្រោះវាមានជាតិគីមីមិនអញ្ចឹង ដែលវាជះឥទ្ធិពលដល់អាកាសធាតុ។ ដូចជាអង់តែនផ្សព្វផ្សាយចង់និយាយពីអង់តែនទូរស័ព្ទពាសពេញក្នុងប្រទេសយើងហ្នឹងណា។*

**អភិបាលខេត្ត**

## ការយល់ឃើញអំពីផលប៉ះពាល់

បុគ្គលសំខាន់ៗស្ទើរទាំងអស់ ពោលថាពួកគេបានសង្កេតឃើញការប្រែប្រួលធាតុអាកាសពេញមួយជីវិតរបស់ពួកគេ។ ការប្រែប្រួលទាំងនោះរួមមាន រដូវ ដែលមិនសូវអាចព្យាករណ៍បានភ្លៀងធ្លាក់តិចតួចជាងមុន សីតុណ្ហភាពក្តៅ ព្យុះកាន់តែញឹកញាប់ ទឹកជំនន់កាន់តែញឹកញាប់ និងធ្ងន់ធ្ងរ ផ្គរ និងរន្ទះកាន់តែញឹកញាប់ជាងមុន។ អ្នកឆ្លើយសំខាន់ៗ ដែលធ្វើការនៅតំបន់ឆ្នេរបានកត់សម្គាល់ អំពីទឹកជំនន់កាន់តែញឹកញាប់ និងការកើនឡើងកម្ពស់ទឹកសមុទ្រ។ មនុស្សមួយចំនួន

ពោលថាកម្រិតកម្ពស់ទឹកនៅទន្លេមេគង្គទាបជាងធម្មតា ឬថាវាប្រែប្រួលមិនប្រក្រតីនៅក្នុងបណ្ដាឆ្នាំកន្លងទៅថ្មីៗនេះ។ យោបល់ពីអ្នកឆ្លើយសំខាន់ៗជាច្រើន ដែលរស់នៅក្នុងទីជនបទបង្ហាញថាការប្រែប្រួលរបបធាតុអាកាស អាចធ្វើឱ្យវិធីពីបុរាណដែលប្រើសម្រាប់ការស្វែងយល់ពីធាតុអាកាសលែងមានសុពលភាព:

*កាលពីមុនយើងអាចសន្និដ្ឋានបានមិនចាំបាច់ស្ដាប់ឧតុនិយមក៏យើងអាចសន្និដ្ឋានបាន។ ប៉ុន្តែឥឡូវអត់ទេ ខុសពីមុន ឥឡូវខ្យល់មែន ពពកឡើងខ្មៅមែន ផ្គរមែន តែអត់ភ្លៀងទេ ខ្យល់វ៉ូៗមួយសន្ទុះ បាត់អស់ហើយ។*
**មេដឹកនាំសាសនា**

បុគ្គលសំខាន់ៗទាំងអស់មានការបារម្ភថា ការប្រែប្រួលធាតុអាកាសនឹងមានឥទ្ធិពលអវិជ្ជមានមកលើផលិតកម្មកសិកម្មហើយប្រការនេះនឹងមានឥទ្ធិពលមកលើសន្តិសុខស្បៀង។ អ្នកឆ្លើយក្នុងចំនួនមធ្យមពោលថាការប្រែប្រួលអាកាសធាតុនឹងមានឥទ្ធិពលអវិជ្ជមានមកលើការរស់នៅ របស់ប្រជាជន និងគួរតែចាត់ទុកថាជាឧបសគ្គចំពោះការដោះស្រាយភាពក្រីក្រ។ ពួកគេក៏ផ្សារភ្ជាប់កំណើនសីតុណ្ហភាព ការបាត់បង់ទឹកភ្លៀង និងប្រភពទឹក និងកំណើនអសន្តិសុខស្បៀងជាមួយនឹងការកើនឡើង នៃជម្ងឺផងដែរ។ ជម្ងឺរាគត្រូវបានកត់សម្គាល់ជាពិសេស:

*ជម្ងឺរាគគ្រុនចាញ់ អាសន្នរោគ...បើប៉ុន្មានខែកន្លងមក លោកក៏ធ្លាប់ដឹងដែរវិទ្យុមានផ្សាយចេញពីខេត្តដទៃទៀតរាគរូសស្លាប់ភ្លាមៗ អាហ្នឹងសុទ្ធតែខ្វះអនាម័យ ដោយសារភ្លៀងខ្លាំង កន្លែងនោះ ឬមួយក៏ភាពរាំងស្ងួតប្រជាជនត្រូវតែហូបទឹក ដែលដងពីនេះពីនោះមកឲ្យតែមាន ហើយជារឿយៗមិនបានចំរោះអីទេគឺថាគាត់ខ្វះទឹកនៅតាមជនបទ។*
**មេដឹកនាំសាសនា**

ទោះបីបុគ្គលសំខាន់ៗជាច្រើនមានការព្រួយបារម្ភអំពីផលប៉ះពាល់ ដែលអាចកើតឡើងដោយសារការប្រែប្រួលអាកាសធាតុមកលើប្រទេសកម្ពុជាក៏ដោយ ក៏នៅមានមនុស្សចំនួនច្រើនទៀតគិតថាប្រទេសកម្ពុជានៅពុំទាន់ទទួលរងឥទ្ធិពលអាក្រក់ខ្លាំងដូចប្រទេសដទៃឡើយ។ សូម្បីតែក្នុងចំណោមអ្នក ដែលមានការយល់ដឹងក្នុងកម្រិតកំណត់អំពីគោលគំនិតនៃការប្រែប្រួលអាកាសធាតុក៏ដោយ ក៏ពួកគេមានអារម្មណ៍ថា នៅពេលណាមួយកម្ពុជានឹងជួបប្រទះផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដូចនៅក្នុងប្រទេសដទៃផងដែរ:

*វាមិនទាន់ផលប៉ះពាល់ធំទេ សម្រាប់កម្ពុជាវាមិនទាន់ជាបញ្ហាដ៏គួរឲ្យចាប់អារម្មណ៍ (តាមប្រព័ន្ធផ្សព្វផ្សាយ)ប៉ុន្តែអ្វីដែលពិភពលោកភ័យបារម្ភនេះ ដោយសារពីមុនវាស្ថិតនៅតំបន់សាហារ៉ាទេ ឃើញទេ ពេលដែលយើងនិយាយថា sub-Saharan យើងភ័យខ្លាចសាហារ៉ា តែឥឡូវវាមកក្បែរទីក្រុងប៉េកាំងហើយ។ អញ្ចឹងហើយបានជាគេភ័យខ្លាចតិចទៀតវាដល់វត្តភ្នំ។*
**តំណាងប្រព័ន្ធផ្សព្វផ្សាយ**

## តើសាធារណជនយល់បែបណា អំពីការប្រែប្រួលអាកាសធាតុ?

បុគ្គលសំខាន់ៗកត់សម្គាល់ថា "គម្លាត នៃចំណេះដឹង" ដែលមានក្នុងសង្គមកម្ពុជា មានឥទ្ធិពលមកលើការយល់ដឹងជាសាធារណៈ អំពីការប្រែប្រួលអាកាសធាតុ។ ដូចដែលតំណាងពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមួយរូបពន្យល់ៈ

> *អ្នកទីក្រុងដឹង។ ពួកគេដឹងមូលហេតុអ្វីបានជាវាក្តៅ អ្នកទីក្រុងគាត់ដឹងច្រើន ព្រោះគាត់បានអានកាសែត ទស្សនាវដ្តី...ប៉ុន្តែអ្នកស្រែគាត់ដឹង...តាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់។*
>
> **តំណាងប្រព័ន្ធផ្សព្វផ្សាយ**

ក្រៅពីចំណោទទាក់ទិននឹងលទ្ធភាពទទួលបានព័ត៌មាន បុគ្គលសំខាន់ៗ បានបង្ហាញបន្ថែមពីភាពខុសគ្នាច្បាស់លាស់ចំនួនពីរ រវាងវិធី ដែលសាធារណជនយល់ឃើញ អំពីការប្រែប្រួលអាកាសធាតុ។ បុគ្គលសំខាន់ៗខ្លះផ្តោតលើថាតើមានការយល់ដឹងច្បាស់លាស់ អំពីពាក្យថា "អាកាសធាតុ" ដែរឬទេ។ ក្នុងពេលនោះដែរ បុគ្គលសំខាន់ៗ ដទៃទៀតពន្យល់ថា ភាគច្រើន នៃពលរដ្ឋ ដែលរស់នៅតាមជនបទ យល់ដឹង អំពីការប្រែប្រួលអាកាសធាតុទៅតាមបទពិសោធន៍របស់ខ្លួន ដោយសារពួកគេបាន រស់នៅជាមួយឥទ្ធិពលរបស់វារួចទៅហើយ។

ទាក់ទងនឹងពាក្យបច្ចេកទេសនេះ បុគ្គលសំខាន់ៗជាច្រើន បញ្ជាក់ថាពួកគេមិនមែនយល់ពាក្យនេះ ដោយខ្លួនឯងទេ។ បុគ្គលសំខាន់ៗដទៃទៀតគិតថាការបកប្រែមកជាភាសាខ្មែរមិនបង្ហាញពីអត្ថន័យ នៃពាក្យនេះបានគ្រប់គ្រាន់ឡើយ។ អ្នកខ្លះបង្ហាញថា ពាក្យ "*អាកាសធាតុ*" មិនអាចបកស្រាយអត្ថន័យ នៃពាក្យ 'climate' បានឡើយ។ អ្នកមានប្រជាប្រិយភាពក្នុងប្រទេសកម្ពុជាម្នាក់កត់សម្គាល់ អំពីការប្រឈមមួយដែលកើតមាននៅពេល ដែលគាត់ប្រើពាក្យ "ការប្រែប្រួលអាកាសធាតុ" ដោយអ្នកដទៃ ស្តាប់ទៅហាក់ ដូចជាមានលក្ខណៈបច្ចេកទេសបន្តិច។

បុគ្គលដទៃទៀតបកស្រាយចំងល់នេះតាមបែបផ្សេងៗ។ ពួកគេពន្យល់ថាប្រជាជនកម្ពុជាបានសង្កេតមើលការប្រែប្រួលនានា នៃធាតុអាកាសជាបន្តបន្ទាប់រួចមកហើយ ប៉ុន្តែពួកគេមិនបានដឹងថាការប្រែប្រួលនេះអាចជាផ្នែកមួយ នៃបញ្ហាធំឡើយ។ ដូចដែលតំណាងមកពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមួយរូបពោលថា "ប្រជាជនបានចាប់ផ្តើមទទួលស្គាល់ថាមានការប្រែប្រួល ប៉ុន្តែពួកគេមិនបានដឹងថាហេតុអ្វីបានជាមានការប្រែប្រួលនោះឡើយ"។ ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់មួយរូបសង្កេតឃើញថាៈ

> *ប្រជាជនទូទៅគាត់យល់ថាឡើងកម្តៅ គាត់ថាអញ្ចឹងគាត់ថាឥឡូវមិនដូចពីមុនឡើយ។ ភ្លៀងមិនទៀងទាត់ទេ។ ពិបាកក្នុងការរស់នៅ។ គាត់យល់ថាជាទូទៅធាតុអាកាសវាប្រែប្រួលវាឡើងកម្តៅ ប៉ុន្តែបើប្រើភាសាដូចយើងធម្មតា ដែលជាអ្នកធ្វើការអញ្ចឹងគាត់មិនយល់ទេ។ គាត់ប្រើភាសារបស់គាត់ចឹងទៅតាមស្រុកភូមិ។ គាត់ថាឥឡូវវាក្តៅខុសពីធម្មតាមានសត្វល្អិតមកស៊ីដំណាំ។នេះជាភាសា ដែលគាត់ប្រើ។ គាត់ដឹងថាអាកាសធាតុបានប្រែប្រួល។*

យោបល់ របស់ពួកគេបង្ហាញថាបុគ្គលសំខាន់ៗភាគច្រើនឯកភាពជាមួយការវិភាគនេះ។ អ្នកខ្លះពោលថាសាធារណជនអាចយល់អំពីការប្រែប្រួលអាកាសធាតុ ប្រសិនបើមានការបង្ហាញឱ្យបានច្រើនបន្ថែមទៀត អំពីទំនាក់ទំនងនៃពាក្យ "ការប្រែប្រួលអាកាសធាតុ" ជាមួយផលប៉ះពាល់របស់វា។ តំណាងមួយរូបមកពីអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាពន្យល់ថា

*ខ្ញុំប្រាប់ អំពីឥទ្ធិពល ឬផលប៉ះពាល់ ព្រោះងាយស្រួលធ្វើឲ្យគាត់យល់។ ហេតុអ្វីយើងនិយាយពីរឿងឥទ្ធិពល? ឧទាហរណ៍ថា យើងពន្យល់គាត់ពីបំរែបំរួលអាកាសធាតុ ១ ថ្ងៃហ្នឹង គាត់អត់យល់ទេ ប៉ុន្តែបើយើងសួរគាត់ថាមូលហេតុអ្វីបានជាអត់មានភ្លៀង ហេតុអ្វីបានជាកម្តៅខ្លាំង ដោយសារអ្វីដែលជាមូលហេតុ របស់វា។*

**តំណាងអង្គការមិនមែនរដ្ឋាភិបាល**

ទោះជាយ៉ាងណាក៏ដោយ ការប្រឈម ក្នុងការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុមិនមែនកើតមាន ចំពោះតែប្រជាជនដែលរស់នៅតាមទីជនបទប៉ុណ្ណោះទេ។ តំណាងមួយរូបមកពីអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើកិច្ចការប្រែប្រួលអាកាសធាតុបានពន្យល់ថាវាជាការលំបាក ក្នុងការស្វែងរកឯកសារជាភាសាខ្មែរអំពីប្រធានបទនេះ សូម្បីតែចូលទៅក្នុងអ៊ីនធឺណែតហើយក៏ដោយ។ បុគ្គលដែលមានប្រជាប្រិយភាព ម្នាក់ដែលមានការ យល់ដឹង ច្រើន អំពីបញ្ហានេះពន្យល់ថាៈ

*ខ្ញុំឧស្សាហ៍និយាយជាមួយគាត់សំណេះសំណាលជាមួយគាត់លេងអំពី (ការប្រែប្រួលអាកាសធាតុ) ដើម្បីស្ទង់ជម្រៅចិត្ត និងការយល់ដឹង និង កង្វល់របស់គាត់។ ខ្ញុំជឿថាផ្នែកផ្លាស់ប្តូរអាកាសធាតុ សូម្បីខ្ញុំជាគ្រូបង្រៀនផងជាពិធីករផង ជាអ្នកចេះប្រើអ៊ិនធឺណែតផង នៅតែខ្ញុំមិនទាន់ជ្រួតជ្រាបបានច្រើន។*

**អ្នកមានប្រជាប្រិយភាព**

## តើការទទួលខុសត្រូវស្ថិតនៅឯណា?

អ្នកឆ្លើយតបសំខាន់ៗ ដែលបង្ហាញពីទំនាក់ទំនង រវាងការប្រែប្រួលអាកាសធាតុជាមួយការបំភាយឧស្ម័នផ្ទះកញ្ចក់សង្កត់ធ្ងន់ថាការទទួលខុសត្រូវ លើការបំភាយឧស្ម័នទាំងនេះភាគច្រើនជាបន្ទុករបស់ប្រទេសឧស្សាហកម្មៈ

*ប្រទេស ដែលមានប្រជាជនច្រើន ប្រទេស ដែលមានសេដ្ឋកិច្ចធំៗ ប្រទេស ដែលមានរោងចក្រច្រើន (ចូលរួមធ្វើឲ្យមានការប្រែប្រួលអាកាសធាតុ) ដែលធ្វើឲ្យមានការប្រែប្រួល។ តែយើងទេ ដែលជាប្រទេសក្រីក្រ យើងអត់ទាន់មានអភិវឌ្ឍន៍អ្វីផងបែរក្លាយ ជាអ្នករងគ្រោះ នៃការប្រែប្រួលអាកាសធាតុ។*

**តំណាងរដ្ឋាភិបាល**

នៅពេលសួរដោយផ្ទាល់ថា តើកម្ពុជាបានរួមចំណែក ក្នុងការធ្វើឲ្យប្រែប្រួលអាកាសធាតុដែរឬទេ? ឬថា តើការទទួលខុសត្រូវស្ថិតនៅឯណា ទាក់ទងនឹងការបង្កឱ្យមានការប្រែប្រួលអាកាសធាតុ? អ្នកឆ្លើយសំខាន់ៗផ្សេងទៀត ច្រើនមានភាពស្រពេចស្រពិល ហើយពោលថា ការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ គឺជាទំនួលខុសត្រូវ របស់ប្រទេសឧស្សាហកម្ម។

*ប្រទេសអ្នកមានទាំងអស់បង្កើតឲ្យមានបញ្ហា អញ្ចឹងប្រទេសទាំងនោះជាអ្នកត្រូវរ៉ែយ។ (...) ប្រទេសទាំងនោះត្រូវជួយយើងកុំឲ្យយើងដើរជាន់ដានតាមគន្លង របស់ប្រទេសទាំងនោះ។*

**តំណាងអង្គការមិនមែនរដ្ឋាភិបាល**

ទោះជាយ៉ាងណាក៏ដោយការពន្យល់ភាគច្រើន អំពីមូលហេតុ នៃការប្រែប្រួលអាកាសធាតុ គឺ ផ្តោតលើ ការបាត់បង់ព្រៃឈើនៅកម្ពុជា។ ការទទួលខុសត្រូវចំពោះការបាត់បង់ព្រៃឈើភាគច្រើនត្រូវបានសន្មត់ថាជាបន្ទុករបស់ប្រជាជននៅជនបទ ដែលកាប់ដើមឈើ ដើម្បីរានឆ្ការដីយកមកធ្វើកសិកម្ម ដុតធ្យូង ឬ លក់ធ្យូង ឬអុស។

ទោះបីមានការអះអាងថាប្រជាជននៅជនបទ គឺជាអ្នកទទួលខុសត្រូវលើការកាប់ដើមឈើក៏ដោយ បុគ្គលសំខាន់ៗភាគច្រើនទទួលស្គាល់ថាហេតុផល ដែលនាំឲ្យមានការបាត់បង់ព្រៃឈើមានភាពស្មុគស្មាញណាស់។ អ្នកខ្លះនិយាយថាការបាត់បង់ព្រៃឈើយ៉ាងច្រើនបានកើតឡើងចាប់ពីឆ្នាំ ១៩៧៩ មក ចំណែកអ្នកដទៃទៀតពន្យល់ថាប្រជាពលរដ្ឋក្រីក្រនៅជនបទពឹងផ្អែកលើការលក់អុស និងធ្យូង ដើម្បីបំពេញបន្ថែម សម្រាប់ការចិញ្ចឹមជីវិតរបស់ខ្លួន។ ពួកគេបង្ហាញពីការជាប់ទាក់ទងរវាងភាពក្រីក្រ និងការកាប់ដើមឈើ។

បុគ្គលសំខាន់ៗ ដទៃទៀតពន្យល់ថាច្បាប់ ដើម្បីទប់ស្កាត់ការកាប់ឈើល្មើសច្បាប់មិនត្រូវបានគេយកមកអនុវត្តឡើយ។

*(រដ្ឋាភិបាល) ប្រកាសហើយប្រកាសទៀតឲ្យឈប់កាប់ព្រៃ ប៉ុន្តែប្រជាជននៅតែកាប់ ចេះតែបំផ្លាញហើយអ្នកដាំចេះតែដាំទៅ។ ច្បាប់ចេញមក ប៉ុន្តែប្រជាជនអត់ធ្វើតាមច្បាប់។*

**ប្រធានភូមិ**

ការប្រែប្រួលអាកាសធាតុច្រើនតែត្រូវគេបញ្ចូលគ្នា ជាមួយការរេចរឹលនៃបរិស្ថាន និងការបំពុលជាទូទៅ។ ក្នុងន័យនេះ ការប្រែប្រួលអាកាសធាតុត្រូវបានផ្សាភ្ជាប់ជាមួយកង្វះយុទ្ធសាស្ត្រសមស្រប ដើម្បីគ្រប់គ្រងបរិស្ថាន។ ដោយឡែកអ្នកឆ្លើយសំខាន់ៗកត់សម្គាល់ថាភាពទន់ខ្សោយ នៃប្រព័ន្ធគ្រប់គ្រងសំណល់ និងការធ្វើឱ្យផ្លូវទឹកកខ្វក់ ដោយសារតែទឹកស្អុយ និងសារធាតុគីមី។

*ប្រជាជនកាន់តែច្រើនកាកសំណល់ក៏កាន់តែច្រើន ហើយកាកសំណល់ហ្នឹងហូរចូលទន្លេ។ ដល់អញ្ចឹងទៅមនុស្សកើតមានជម្ងឺអាសន្នរោគនៅពេលប្រើទឹកទន្លេ។ ចុះអ្នកទន្លេមានធ្វើអីកើតបត់ដៃបត់ជើង នៅក្នុងទន្លេទាំងអស់ព្រោះមានបង្គន់អីណានៅទីនោះ។*

**ប្រធានភូមិ**

គេមានចំណាប់អារម្មណ៍ជាទូទៅថាបរិស្ថានធម្មជាតិ នៃប្រទេសកម្ពុជាកំពុងប្រឈមនឹងហានិភ័យ នៃការធ្វើអាជីវកម្មពីសំណាក់ប្រទេសឧស្សាហកម្ម។ ជួនកាលប្រការនេះ ត្រូវបានបង្ហាញ តាមរយៈការសំដៅទៅលើការប្រើប្រាស់ និងការផលិតសម្ភារៈច្រើនហួសហេតុ។

*ផែនដីយូរៗទៅទ្រុឌទ្រោម ដោយសារតែការប្រើប្រាស់ របស់មនុស្ស ការគ្រប់គ្រងអីចឹងទៅ វាធ្វើឲ្យប៉ះពាល់អាកាសធាតុ និងមជ្ឈដ្ឋានអីចឹងទៅណា។*

**មេដឹកនាំសាសនា**

បុគ្គលសំខាន់ៗមួយចំនួនតូច សំដែងការព្រួយបារម្ភណ៍ថា ប្រទេសកម្ពុជាកំពុងរួមចំណែកធ្វើឱ្យមានការប្រែប្រួលអាកាសធាតុ និងធ្វើឲ្យខូចបរិស្ថាន ដោយនាំចូល "*ផលិតផលចាស់ៗ*" ដូចជារថយន្ត និងទោចក្រយានយន្ត ដែលប្រជាជននៅក្នុងប្រទេសដទៃចាត់ទុកថាលែងសមស្រប សម្រាប់ប្រើប្រាស់ទៅហើយ:

*មូលហេតុផ្សេងទៀត (របស់ការប្រែប្រួលអាកាសធាតុ) គឺថាយើងនាំអ្វីពីខាងក្រៅមក អាគ្រឿងរបស់ជផុះចូលមកក៏ធ្វើឲ្យប៉ះពាល់បរិស្ថាននៅក្នុងប្រទេស។ ឲ្យតែរបស់ចាស់ៗមកគឺសុទ្ធតែប៉ះពាល់បរិស្ថាន។ របស់មួយតឹក ពីរតឹកមាន ដូចជាម៉ូតូឡានជាដើម។ នៅប្រទេសគេៗឈប់ប្រើហើយតែយើងរត់គេចពន្ធចូលមកស្រុកខ្មែរ។ មកដល់ស្រុកខ្មែរផ្សេងចំហាយចេញមកខ្មៅហើយមានជាតិឧស្ម័នពុល។*

**អភិបាលខេត្ត**

## តើត្រូវឱ្យមានការឆ្លើយតបអ្វីខ្លះ?

បុគ្គលសំខាន់ៗកត់សម្គាល់ឃើញ ឧបសគ្គចំបងៗមួយចំនួនសម្រាប់ធ្វើការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ បុគ្គលសំខាន់ៗភាគច្រើនពោលថា កង្វះព័ត៌មាន អំពីការប្រែប្រួលអាកាសធាតុ ធ្វើឲ្យពួកគេខ្លួនឯងមិនដឹងថាតើត្រូវជួយគាំទ្រពលរដ្ឋ ក្នុងស្ថាប័ន ឬសហគមន៍របស់ពួកគេបែបណាឡើយ នៅក្នុងការដោះស្រាយបញ្ហានេះ។

*ខ្ញុំមិនដឹងថា ខ្ញុំត្រូវការធនធានអីបើខ្ញុំអត់យល់ផង (ការប្រែប្រួលអាកាសធាតុ)។ ប៉ុន្តែខ្ញុំគិតថាធនធាន ដែលសំខាន់ជាងគេគឺចំណេះដឹង។*

**ប្រធានក្រុមប្រឹក្សាឃុំ**

បុគ្គលសំខាន់ៗ ជាច្រើនពន្យល់ថា ដោយមានបញ្ហាជាច្រើនដទៃទៀត ដែលគួរឲ្យមានការយកចិត្តទុកដាក់ខ្លាំងដែរ ទាំងក្នុងកម្រិតរដ្ឋាភិបាល និងនៅក្នុងការរស់នៅ របស់ប្រជាជន ដូចនេះ ការប្រែប្រួលអាកាសធាតុមិនត្រូវបានចាត់ទុកថាជាអាទិភាពឡើយៈ

*មានបញ្ហាច្រើនមែនទែន (នៅទីនេះ) ដោយខ្មែរជាប្រទេសកំពុងអភិវឌ្ឍន៍។ ដូច្នេះមានបញ្ហាច្រើនមែនទែន ទាំងផ្នែកសុខភាព ទាំងផ្នែកស្បៀងអាហារ ទាំងអស់ហ្នឹងគឺសំខាន់ជាងគេ (ហើយ) ដូចជាបញ្ហាមេរោគអេដស៍ គ្រុនចាញ់។ ប៉ុន្តែវាមិនសំខាន់ដូចការប្រែប្រួលអាកាសធាតុនេះទេ។*

**មេដឹកនាំព្រះពុទ្ធសាសនា**

*យើងអត់ទាន់មានការអប់រំផ្សព្វផ្សាយឲ្យបានច្បាស់។ ហើយនយោបាយវានៅថ្នាក់លើ។ នៅថ្នាក់ក្រោមប្រជាជនធម្មតារវល់រឿងជីវិតរាល់ថ្ងៃច្រើនពេក។ ពួកគេគិតពីរឿងថ្លៃទឹក ថ្លៃភ្លើង លុយរឿងអតិផរណាទំនិញឡើងថ្លៃ ពុករលួយ។ល។ ពួកគេត្រូវគិតពីរឿងច្រើនណាស់ ដែលទាក់ទងនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ វាអត់មានពេលគិតពីរឿងហ្នឹងទេ។ អត់មាននរណាគិតពីរឿងហ្នឹងទេ អ្នកស្រុកគេអត់គិតសោះ។*

**តំណាងប្រព័ន្ធផ្សព្វផ្សាយ**

ការប្រឈមខាងហិរញ្ញវត្ថុគឺជាការព្រួយបារម្ភចំបងមួយ ដែលបុគ្គលសំខាន់ៗបានធ្វើការកំណត់។ មនុស្សជាច្រើនដែលរួមទាំងតំណាងពីអង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់អធិប្បាយទំនាក់ទំនងបំផ្លាញគ្នាទៅ

វិញទៅមករវាងការប្រែប្រួលអាកាសធាតុ និងភាពក្រីក្រ ដោយសារការព្យាយាមដោះស្រាយបញ្ហាមួយអាចនាំឲ្យមានការប៉ះពាល់ដល់បញ្ហាមួយ ទៀត។

*យើងអត់អាចប្រៀបធៀបបញ្ហាហ្នឹង (ការប្រែប្រួលអាកាសធាតុ) ជាមួយនឹងបញ្ហាដទៃទៀតទេ វាជារឿងអន្តរវិស័យ (cross-cutting issue)។ ហើយរឿងហ្នឹងវាត្រូវដោះស្រាយ នៅក្នុងចំណោមបញ្ហាដទៃ។ ឧទាហរណ៍ បើចង់និយាយពីរឿងភាពក្រីក្រគឺត្រូវផ្សារភ្ជាប់ជាមួយបញ្ហានេះ បានន័យថាអាហ្នឹងក៏ជាកត្តាមួយ ដែលនាំឲ្យមានភាពក្រីក្រ។*

**តំណាងរដ្ឋាភិបាល**

តំណាងពីរដ្ឋាភិបាលនៅថ្នាក់ជាតិ ច្រើនតែចង្អុលបង្ហាញពីកង្វះនិរន្តរភាព នៃធនធានហិរញ្ញវត្ថុថាជាឧបសគ្គនៅក្នុងការកសាងផែនការរបស់ជាតិ សម្រាប់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

*យើងចង់ឲ្យហិរញ្ញវត្ថុ ដែលមានហ្នឹងគឺជាហិរញ្ញវត្ថុ ដែលមានលក្ខណៈនិរន្តរភាពហើយយើងអត់ចូលចិត្តរបៀបដែលយើងត្រូវពឹងផ្អែកថវិកាពីម្ចាស់ជំនួយ ហើយបានតែមួយឆាវអញ្ចឹងទេ។ ដូច្នេះហើយយើងត្រូវកំណត់ ឬបែងចែកថវិកា សំរាប់បញ្ហាការប្រែប្រួលអាកាសធាតុ (ដោយមិនបាច់ពឹងផ្អែកលើជំនួយ) សូម្បីពួកខ្ញុំធ្វើ គម្រោង social protection (ការការពារសង្គម) គឺពួកខ្ញុំធ្វើដោយមិនសំអាងទៅលើជំនួយពីម្ចាស់ជំនួយទេ។*

*ពួកយើងចង់ធ្វើទាល់តែដល់ចំណុចមួយ ដែលរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុម័តថាមានកញ្ចប់ថវិកាមួយ ក្នុងមួយឆ្នាំ។ ឧទាហរណ៍ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរមានប៉ុន្មានភាគរយ នៃ GDP (ផលិតផលសរុបក្នុងស្រុក) ថា ១០% នៃ GDP សម្រាប់លើការងារការប្រែប្រួលអាកាសធាតុ។ នេះគឺជាអ្វី ដែលយើងចង់ឃើញនៅថ្ងៃអនាគត។*

**តំណាងរដ្ឋាភិបាល**

តំណាងពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមួយពោលថាកង្វះនិរន្តរភាព នៃធនធានហិរញ្ញវត្ថុក៏ជាឧបសគ្គមួយ នៅក្នុងការឆ្លើយតបទៅនឹងគ្រោះធម្មជាតិផងដែរ។

*វាមានគ្រោះថ្នាក់ សំរាប់ប្រទេស ដែលមានចំណូលទាបដូចយើង។ បើសិនជាមានគ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរណាមួយ យើងមិនងាយស្តារឡើងវិញទេ។ បើប្រៀបធៀបស៊ូណាមិនៅថៃ បើសេដ្ឋកិច្ចរបៀបយើងមិនអាចស្តារឡើងវិញ ក្នុងរយៈពេល ២ ឆ្នាំ ដូចថៃនោះទេ។ យើងមិនអាចធ្វើអញ្ចឹងបានទេ។ យើងខុសពីប្រទេសគេ បើប្រៀបធៀបប្រទេសជុំវិញយើង។ វៀតណាមសល់លុយពេញឃ្លាំង ហើយបើមានរឿងអីកើតឡើងវៀតណាមអត់ខ្វល់ទឹកជំនន់កើតឡើង។ ទឹកជំនន់ដាច់ថ្នល់ថ្ងៃនេះ ស្អែកឡើងគេធ្វើឡើងវិញហើយ។ តែចំពោះខ្មែរ បើដាច់យើងត្រូវតែពឹងពរអន្តរជាតិត្រូវតែពឹងពរមិត្តជិតខាង។ ហើយការពឹងពរលុយ ក្នុងហោប៉ៅគេមិនដូចលុយក្នុងហោប៉ៅយើងនោះទេ។*

**តំណាងប្រព័ន្ធផ្សព្វផ្សាយ**

បុគ្គលសំខាន់ៗភាគច្រើនគិតថាចំណេះដឹង អំពីបញ្ហានេះមានតែនៅក្នុងរដ្ឋាភិបាលថ្នាក់ជាតិតែប៉ុណ្ណោះ ហើយនៅពុំទាន់ផ្សព្វផ្សាយ ដល់ក្រុមដទៃទៀតឡើយ។ ដូចដែលតំណាងពីអង្គការមិនមែនរដ្ឋាភិបាលមួយពន្យល់ថា *"យើងមានព័ត៌មាននៅក្នុងក្រសួង ប៉ុន្តែការផ្សព្វផ្សាយមានកម្រិតកំណត់"*។ អ្នកឆ្លើយជាច្រើនរំពឹងថារដ្ឋាភិបាលនាំមុខនៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ហើយអ្នកទាំងនោះភាគច្រើនពោលថាការផ្តល់ព័ត៌មានគួរតែ ជាដំណោះស្រាយស្នូលនៃការឆ្លើយតបបញ្ហានេះ។ បុគ្គលសំខាន់ៗជាច្រើនពោលថាតំណាងមកពីរដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់ត្រូវតែចូលរួម ជាពិសេសអ្នក ដែលទទួលខុសត្រូវលើការដឹកនាំសហគមន៍។ បុគ្គលសំខាន់ៗភាគច្រើនគិតថាប្រព័ន្ធព័ត៌មានមានតួនាទីយ៉ាងសំខាន់ នៅក្នុងការឆ្លើយតបនៅកម្រិតជាតិ និងពោលថាឈុតអប់រំតាមវិទ្យុ និងទូរទស្សន៍គួរតែយកមកប្រើប្រាស់ ដើម្បីផ្តល់ព័ត៌មានដល់ប្រជាជន។

## បុគ្គលសំខាន់ៗគិតតាមក្រុម

### *តំណាងពីរដ្ឋាភិបាលសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភា*

សមាជិកគណៈរដ្ឋមន្ត្រី និងតំណាងរបស់ពួកគេស្ថិតក្នុងចំណោមបុគ្គលសំខាន់ៗ ដែលមានជំនាញបច្ចេកទេសកម្រិតខ្ពស់បំផុត លើប្រធានបទស្តីពីការប្រែប្រួលអាកាសធាតុ។ យោបល់នានាពីបុគ្គលសំខាន់ៗជាទូទៅបង្ហាញថា ជំនាញបច្ចេកទេស និងនយោបាយ នៅក្នុងវិស័យនេះនៅពុំទាន់បានផ្សព្វផ្សាយទូលំទូលាយគ្រប់គ្រាន់នៅឡើយទេ សំរាប់ប្រជាជននៅថ្នាក់មូលដ្ឋានខេត្ត ឬ ស្រុក។

សមាជិករដ្ឋាភិបាល និងអ្នកតំណាងរបស់ពួកគេ ព្រមទាំងសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភា មានការយល់ឃើញ និងការព្រួយបារម្ភ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាលើទិដ្ឋភាពជាច្រើន។ ក្នុងន័យនេះ យើងត្រូវចាត់ទុកពួកគេ នៅក្នុងក្រុមមួយ សម្រាប់គោលបំណងនៃការស្រាវជ្រាវនេះ។

សមាជិក និងតំណាងរដ្ឋាភិបាល ដែលបានសម្ភាស សម្រាប់ ការស្រាវជ្រាវនេះស្ថិត ក្នុងចំណោមបុគ្គលសំខាន់ៗ ដែលមានជំនាញបច្ចេកទេសកម្រិតខ្ពស់បំផុត ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ តំណាងស្ទើរតែទាំងអស់ពីរដ្ឋាភិបាលនៅថ្នាក់ជាតិទំនងជាមានចំណេះដឹងទូលំទូលាយ អំពីកម្មវិធីរបស់រដ្ឋាភិបាលលើការប្រែប្រួលអាកាសធាតុ ហើយអាចអធិប្បាយអំពីកិច្ចផ្តួចផ្តើមសម្របសម្រួល នៅក្នុងរដ្ឋាភិបាលថ្នាក់ជាតិបានពិស្តារ។ អ្នកទាំងនោះខ្លះបានដឹង អំពីទិដ្ឋភាពនានា នៃនយោបាយអន្តរជាតិ នៃការពិភាក្សា អំពីការប្រែប្រួលអាកាសធាតុ ដូចជាពិធីសារក្យូតូ និងសន្និសីទ នៃបណ្តាប្រទេសជាសមាជិក នៅទីក្រុងកូប៉េនហាក់ ដែលបានធ្វើឡើងនៅក្នុងខែធ្នូ ឆ្នាំ២០០៩។ ទោះជាយ៉ាងណាក៏ដោយ យោបល់នានាពីបុគ្គលសំខាន់ៗជាទូទៅបង្ហាញថាជំនាញបច្ចេកទេស និងនយោបាយ នៅក្នុងវិស័យនេះនៅពុំទាន់បានផ្សព្វផ្សាយទូលំទូលាយគ្រប់គ្រាន់ឲ្យដល់អ្នក ដែលធ្វើការនៅថ្នាក់មូលដ្ឋានខេត្ត ឬស្រុកនៅឡើយ។

តំណាងពីរដ្ឋាភិបាលអាចក្តាប់បានច្បាស់លាស់ អំពីពាក្យប្រែប្រួលអាកាសធាតុដោយអាចបង្ហាញពីភាពខុសគ្នារវាងពាក្យទាំងនេះដូចជា "ការប្រែប្រួលអាកាសធាតុ" និង "ការផ្លាស់ប្តូរអាកាសធាតុ" ហើយនឹងការសំដៅទៅពាក្យ "ផលផ្ទះ

កញ្ចក់" បានយ៉ាងងាយស្រួល នៅក្នុងអំឡុងពេល នៃការធ្វើសម្ភាស។ តំណាងមួយរូបពីរដ្ឋាភិបាលផ្តល់និយមន័យ ដែលមានសុក្រឹតបំផុតអំពីផលផ្ទះកញ្ចក់ធៀបនឹងនិយមន័យ ដែលផ្តល់ដោយអ្នកឆ្លើយដទៃទៀតៈ

*...វាជារបាំងមួយ ដែលអាចការពារ (ផែនដី) ពីកម្តៅថ្ងៃធ្លាត ហើយក្នុងនោះឧស្ម័នផ្ទះកញ្ចក់រួមផ្សំដោយឧស្ម័នជាច្រើន ហើយឧស្ម័នជាចំបងនោះគឺឧស្ម័នកាបូនិចហ្នឹងតែម្តង។ មនុស្សកំពុងយកចិត្តទុកដាក់ចំពោះឧស្ម័ននេះ។ ហេតុអីបានជាអញ្ចឹង? ពីព្រោះវាធ្វើឲ្យមានការកើនឡើងកម្តៅ។ ធម្មតាពេលកម្តៅព្រះអាទិត្យ ឬពន្លឺព្រះអាទិត្យចាំងលើផ្ទៃដី វាទៅមួយចំណែកចាំងធ្លាតទៅវិញទៅក្នុងបរិយាកាស ក៏ប៉ុន្តែហេតុដែលធ្វើឲ្យកម្តៅនៅលើផ្ទៃដីឡើងក្តៅដោយសារអ្វី? ដោយសារកំហាប់ឧស្ម័នកាបូនិច។ (ឥឡូវ) នៅពេលកម្តៅមកផ្ទៃដីហ្នឹងបំភាយទៅលើវាអត់ទៅលើវិញទេ វាទ្រឹងនៅក្នុងបរិយាកាស។*

តំណាងនានាពីរដ្ឋាភិបាលទំនងជាមានទស្សនៈត្រឹមត្រូវអំពីការប្រែប្រួលអាកាសធាតុថា ជាបញ្ហាមួយដែលជាប់ពាក់ព័ន្ធនឹងវិស័យជាច្រើន នៃជីវិតនយោបាយហើយវាជាប្រធានបទមួយ ដែលច្រើនតែត្រូវបានគេលើកយកមកផ្សារភ្ជាប់។ អ្នកទាំងនោះភាគច្រើនយល់ថា កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីសម្របសម្រួល ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ គឺជាប្រការចាំបាច់ដែលអាចជួយដោះស្រាយបញ្ហា ដែលពួកគេចាត់ទុកថាមានលក្ខណៈជាអន្តរវិស័យនេះ។

*បញ្ហាសំខាន់ៗ វាខុសគ្នាពីស្ថាប័នមួយទៅមួយ។ អ្វីដែលសំខាន់គឺថាយើងគួរតែមានយន្តការរួមមួយ ដើម្បីដោះស្រាយបណ្តាបញ្ហាទាំងអស់ព្រមគ្នា ព្រោះបញ្ហានីមួយៗមិនអាចកាត់ផ្តាច់ពីបញ្ហាដទៃទៀតទេ។*

*យើងចង់ឲ្យចាត់ទុកបញ្ហា ប្រែប្រួលអាកាសធាតុ ជាបញ្ហាអន្តរវិស័យមួយ។ មិនមែនជាបញ្ហាតែក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនមែនតែក្រសួងធនធានទឹក និងឧតុនិយម មិនមែនតែក្រសួងបរិស្ថាន ប៉ុន្តែជាបញ្ហាអន្តរវិស័យ។*

ជាការពិតណាស់ មានភ័ស្តុតាង ដែលបង្ហាញថា នាយកដ្ឋានផ្សេងៗគ្នាជាច្រើន នៅក្នុងរដ្ឋាភិបាលបានចងចាំសារនេះយ៉ាងមុតមាំ ដូចដែលបង្ហាញតាមរយៈយោបល់នានា របស់តំណាងមួយរូបពីរដ្ឋាភិបាលទាក់ទងនឹងតម្រូវការឱ្យមាន "សេដ្ឋកិច្ចបៃតង"។

*ខ្ញុំមិនទាន់និយាយដល់សេដ្ឋកិច្ចបៃតងទេ ប៉ុន្តែ (អេកូទេសចរណ៍) រួមចំណែកដល់សេដ្ឋកិច្ចបៃតងដែរ កាលណាយើងធ្វើអេកូទេសចរណ៍ខ្លាំងបានចំណូលមកពីទេសចរណ៍ធម្មជាតិ ក៏វាជាសេដ្ឋកិច្ចបៃតង។ ប៉ុន្តែនិយាយពាក្យ "សេដ្ឋកិច្ចបៃតង" មួយមាត់គឺអត់គ្រប់គ្រាន់នោះទេ។ សេដ្ឋកិច្ចបៃតងទាល់តែនិយាយពី green jobs (ការងារទាក់ទងនឹងបរិស្ថាន) ទាល់តែនិយាយអីផ្សេងគួបផ្សំទៀត ដូចជាសណ្ឋាគារទាំងអស់ហ្នឹង។ ពួកគេគួរតែឈប់ប្រើអគ្គិសនី គួរឈប់ប្រើម៉ាស៊ីនភ្លើងខ្លួនឯង ហើយគួរប្រើថាមពលពន្លឺព្រះអាទិត្យ នៅកន្លែងណាអាចប្រើថាមពលខ្យល់បានគួរតែប្រើវាទៅ។*

តំណាងមួយរូបពីរដ្ឋាភិបាលពន្យល់ពីមូលហេតុ ដែលការសម្របសម្រួលគឺជាប្រការចាំបាច់:

*រដ្ឋាភិបាលមានគោលបំណងជាច្រើន ប៉ុន្តែយើងគ្រាន់តែចង់ប្រមូលផ្តុំវាឲ្យនៅមួយកន្លែង។ ទី១ គឺរឿងឆ្លើយតបនឹងតម្រូវការបន្ទាន់។ ឧទាហរណ៍ទឹកជំនន់ខ្យល់ព្យុះ ឬគ្រោះរាំងស្ងួត។ រដ្ឋាភិបាលត្រូវមានយន្តការឆ្លើយតបមួយដែលអាចឆ្លើយតបទៅនឹងតម្រូវការប្រជាជនបានលឿនបំផុតដូចជាចែកស្បៀង។ ហើយដាច់ផ្លូវកន្លែងណា យើងត្រូវធ្វើផ្លូវ។ ហ្នឹងសុទ្ធតែទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ។ ទី២ រឿងការគាំពារសុខភាពមាតា និងទារក។ ខ្ញុំគិតថាវាមិនសូវទាក់ទងនឹងរឿងការប្រែប្រួលអាកាសធាតុប៉ុន្មានទេ។ គោលបំណងទី ៣ ដែលយើងកំពុងធ្វើគឺរឿងកម្មវិធីការងារសាធារណៈ។ ឧទាហរណ៍ថាប្រជាជនកំពុងតែអត់ការងារធ្វើក្នុងតំបន់ហ្នឹងដោយសារគ្រោះរាំងស្ងួត។ គ្រោះរាំងស្ងួតធ្វើឲ្យប៉ះពាល់ស្រែចំការ របស់គាត់ដូចនេះគាត់ត្រូវធ្វើចំណាកស្រុក ប៉ុន្តែយើងមិនចង់ឲ្យគាត់ធ្វើចំណាកស្រុកអញ្ចឹងទេគឺយើងចង់បង្កើតការងារនៅនឹងកន្លែង ដែលគាត់រស់នៅ។ ការងារក្នុងមូលដ្ឋានជួយដល់ការងារកសិកម្មផង និងវិស័យផ្សេងផង។ បើសិនយើងធ្វើផ្លូវប្រជាជននៅតំបន់ជនបទអាចធ្វើដំណើរទៅទីប្រជុំជន។ គំនិតមួយគឺថាបើយើងធ្វើផ្លូវយើងត្រូវគិតពីហេតុការណ៍ ដែលអាចមានឡើងពីការប្រែប្រួលអាកាសធាតុ។ បើទឹកត្រូវលិច ១ ម៉ែត្រ។ អញ្ចឹងផ្លូវត្រូវធ្វើ ២ ម៉ែត្រ នោះផ្លូវត្រូវលើកខ្ពស់ជាងមុន។ យើងមានផែនការរៀបចំដីសំរាប់ការដាំព្រៃឡើងវិញ។ ហើយគោលបំណងទី ៤ សំខាន់ដែរ សំរាប់ការប្រែប្រួលអាកាសធាតុគឺសុខភាពសាធារណៈ ការគាំពារសុខភាពសាធារណៈ។ ខ្ញុំជឿថាសូចនាករមួយៗ របស់ការប្រែប្រួលអាកាសធាតុគឺការផ្ទុះឡើងជម្ងឺគ្រុនចាញ់។ នោះមានន័យថាការប្រែប្រួលអាកាសធាតុកាន់តែធ្ងន់ធ្ងរទៅៗ។ អញ្ចឹងហើយយើងត្រូវផ្តោតខ្លាំង មុនពេលត្រូវធ្វើផ្លូវយើងត្រូវគិតពីជំនួយផ្នែកសង្គម ដើម្បីជួយការពារពួកគេពីជម្ងឺហ្នឹង។ ហើយគោលបំណងទី ៥ គឺទាក់ទងនឹងក្រុម ដែលងាយរងគ្រោះនៅក្នុងសង្គម។ គោលបំណងហ្នឹងយើងកំពុងតែពិនិត្យមើលជនងាយរងគ្រោះណា នៅក្នុងសង្គម ដែលរងផលប៉ះពាល់ខ្លាំងពី social shocks (ផលប៉ះពាល់ផ្នែកសង្គម)។*

ចំណេះដឹង របស់តំណាងពីរដ្ឋាភិបាល អំពីការងារ របស់ក្រសួងនានាបង្ហាញថា ការសម្របសម្រួលរបស់រដ្ឋាភិបាលលើការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុបានផ្តល់ជោគជ័យខ្លះៗ។ សមាជិកទាំងអស់ពីរដ្ឋាភិបាលបង្ហាញថាពួកគេមានទំនាក់ទំនងការងារជិតស្និទ្ធិជាមួយក្រសួង ដទៃទៀត ហើយពួកគេបានពោលថាពួកគេធ្វើការលើកិច្ចផ្តួចផ្តើមខុសៗ គ្នា។ កិច្ចការទាំងនោះរាប់បញ្ចូលទាំងសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា[៤៥] ការអនុម័តលើគម្រោងយន្តការអភិវឌ្ឍស្អាតចំនួនប្រាំមួយ ដែលធ្វើឱ្យកម្ពុជាស្ថិត នៅក្នុងជួរមុខក្នុងចំណោមប្រទេស ដែលមានការអភិវឌ្ឍតិចតួច ទាក់ទងនឹងចំនួនគម្រោងអភិវឌ្ឍន៍ស្អាត គម្រោងរួមបញ្ចូលការអប់រំ អំពីការប្រែប្រួលអាកាសធាតុ និងព័ត៌មានអំពីការឆ្លើយតបទៅនឹងភាពបន្ទាន់ ក្នុងកម្មវិធីសិក្សានៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា និងនៅសាកលវិទ្យាល័យ ធ្វើការចាត់ចែងវេទិកាជជែកវែកញែក ស្តីពីការប្រែប្រួលអាកាសធាតុផ្សព្វផ្សាយដោយក្រសួងបរិស្ថាន ធ្វើការជាមួយ UNDP និង UNICEF ក្នុងការរៀបចំឯកសារស្តីពីការប្រែប្រួលអាកាសធាតុ និងធ្វើការលើគម្រោងស្រាវជ្រាវ ដើម្បីប្រមូលទិន្នន័យ សម្រាប់បង្កើតពូជដំណាំថ្មីៗ និងការកែលម្អបច្ចេកទេសកសិកម្ម និងជូនដំណឹង អំពីនិទស្សន៍ នៃការប្រែប្រួលអាកាសធាតុ។ តំណាងមួយរូបពីរដ្ឋាភិបាលពន្យល់ពីមូលហេតុ ដែលការប្រមូលទិន្នន័យឧតុនិយមមានសារៈសំខាន់ៈ

---

[៤៥] ចំពោះព័ត៌មានបន្ថែមអំពីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាសូមអានៈ http://www.un.org.kh/undp/~docs/projects/docs/Prodoc_00073625_CCCA.pdf

*ឥឡូវនេះពេលគេនិយាយពីការប្រែប្រួលអាកាសធាតុគឺគេសំដៅទៅលើផលប៉ះពាល់អវិជ្ជមាន ដែលបណ្តាលមកពីគ្រោះធម្មជាតិ។ អញ្ចឹងគេគិតថាទាំងនេះគឺជាការប្រែប្រួលអាកាសធាតុ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ គេមើលឃើញថាផលប៉ះពាល់ចេះតែកើនឡើង។ ដំបូងឡើងយើងមិនរាប់បញ្ចូលជាការប្រែប្រួលអាកាសធាតុទេ។*

ទោះបីភាគច្រើន នៃជំនាញរបស់ពួកគេបានប្រមូលផ្តុំតែនៅថ្នាក់ជាតិ និងនៅថ្នាក់នយោបាយអន្តរជាតិក៏ដោយ តំណាងទាំងអស់មកពីរដ្ឋាភិបាល បានផ្តោតលើផលប៉ះពាល់ ដែលអាចកើតឡើងដោយសារការប្រែប្រួលអាកាសធាតុមកលើការចិញ្ចឹមជីវិត របស់ប្រជាជន។ យោបល់របស់ពួកគេបង្ហាញថាទំនាក់ទំនងអន្តរក្រសួងបានជួយតំណាងនានាពីរដ្ឋាភិបាល ក្នុងការបង្កើតចំណងទាក់ទងរវាងព្រឹត្តិការណ៍បច្ចុប្បន្ន និងការប្រឈមនានា ដែលបង្កដោយការប្រែប្រួលអាកាសធាតុ។

*ខ្ញុំបានមើលការរាយការណ៍ពីក្រសួង៣។ ដំបូងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទបានរាយការណ៍ពីរឿងភ្លៀងធ្លាក់មិនទាន់ពេល ដូចនេះរដូវដាំដុះត្រូវបានពន្យាពេល។ តាមខ្ញុំដឹងមកដល់ពេលហ្នឹងមានប្រជាជនតិចតួចណាស់បានបង្កបង្កើនផល។ បើយើងមើល (ស្ថានភាព) ឥឡូវនេះការបង្កបង្កើនផល សំរាប់ស្រូវតិចជាងឆ្នាំមុនឆ្ងាយណាស់។*

ឧបសគ្គចំបងៗចំនួនពីរ នៅក្នុងចំណាត់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្រិតជាតិ បានកើតចេញពីយោបល់ របស់តំណាងនានាពីរដ្ឋាភិបាល។ ឧបសគ្គមួយគឺកង្វះការគាំទ្រខាងហិរញ្ញវត្ថុ:

*ខ្ញុំគ្រាន់តែប្រាប់ក្លួយត្រួសៗទៅតាមអ្វី ដែលខ្ញុំបានដឹង។ គ្រាន់តែកម្មវិធី NAPA ហ្នឹងមួយតម្រូវការថវិកាប្រហែលជាង ២០០ លានដុល្លា តែសម្រាប់យើងយើងមានតែ ១០ លាន ទេឥឡូវនេះ សម្រាប់ ១៩ កម្មវិធី។*

បញ្ហាផ្សេងទៀត គឺកង្វះព័ត៌មាន អំពីការប្រែប្រួលអាកាសធាតុនៅទូទាំងសង្គមកម្ពុជា។ សមាជិករដ្ឋសភាមួយរូបដែលមានតួនាទីខ្ពស់ នៅក្នុងការឆ្លើយតប របស់ជាតិទៅនឹងការប្រែប្រួលអាកាសធាតុសង្កត់ធ្ងន់ថា "ការអប់រំ និងការផ្សព្វផ្សាយព័ត៌មាន អំពីការប្រែប្រួលអាកាសធាតុទៅដល់សាធារណជន" គឺជាអាទិភាពមួយ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP)។

តំណាងមួយរូបមកពីរដ្ឋាភិបាលចង្អុលបង្ហាញថាមានកង្វះការយល់ដឹង អំពីបញ្ហាប្រែប្រួលអាកាសធាតុនៅក្រៅរដ្ឋាភិបាលថ្នាក់ជាតិ:

*វាមិនមែនត្រឹមតែថ្នាក់កណ្តាល សូម្បីប្រជាជន នៅក្នុងមូលដ្ឋានក៏មានការភាន់ច្រឡំដែរ។*

កិច្ចប្រឹងប្រែងជាក់លាក់ខ្លះៗត្រូវបានធ្វើឡើង ដើម្បីលើកទឹកចិត្តឱ្យមានការអនុវត្ត ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាន:

*(អង្គភាពយើងខ្ញុំ) ព្យាយាមមិនពាក់ព័ន្ធនឹងការអនុវត្តគម្រោងការប្រែប្រួលអាកាសធាតុដោយផ្ទាល់នោះទេ ព្រោះថាជាតួនាទីរបស់ក្រសួង អញ្ចឹងធ្វើតាមរយៈការផ្ទេរសេវាទៅឲ្យស្ថាប័នថ្នាក់ក្រោម។ តាមរយៈការជំរុញការអនុវត្តនៅកម្រិតក្រុមប្រឹក្សាខេត្ត/ក្រុង ឬឃុំហ្នឹង។*

ទោះជាយ៉ាងណាក៏ដោយយោបល់ពីមន្ត្រីនានា ដែលធ្វើការនៅថ្នាក់ឃុំ/សង្កាត់ និងថ្នាក់ភូមិបង្ហាញថាមានកិច្ចការជាច្រើន ដែលត្រូវធ្វើ ដើម្បីបម្លែងផែនការ នៅក្នុងរដ្ឋាភិបាលនៅថ្នាក់ជាតិឱ្យទៅជាការអនុវត្តកម្មវិធីនៅតាមមូលដ្ឋាន ដូចដែលបង្ហាញ តាមរយៈយោបល់ពីប្រធានក្រុមប្រឹក្សាឃុំមួយរូបៈ

*ខ្ញុំមិនទាន់បានដឹងថាស្ថាប័នណាមួយ នៅក្នុងខេត្តនេះអាចយល់ដឹងពីការប្រែប្រួលអាកាសធាតុ ដែលទទួលបន្ទុកលើការងារការប្រែប្រួលអាកាសធាតុហ្នឹងទេ។*

## *អភិបាលខេត្ត*

វិសាលភាព នៃការយល់ដឹងរបស់អភិបាលខេត្ត អំពីទិដ្ឋភាពបច្ចេកទេស នៃការប្រែប្រួលអាកាសធាតុពិភពលោកគឺជាការលំបាកវាយតម្លៃណាស់ ដោយសារតែការយល់ដឹងអំពីបញ្ហានេះមានកម្រិតខុសៗគ្នាក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ដែលមានចំនួនតិចតួច សម្រាប់ការស្រាវជ្រាវនេះ។ ក្នុងពេលដែលអ្នកខ្លះមានការយល់ដឹងពិស្តារ អំពីមូលហេតុ នៃការប្រែប្រួលអាកាសធាតុ និងទទួលស្គាល់ថា វាជាបាតុភូតសកលដែលមានមូលហេតុសកល អ្នកដទៃទៀតទំនងជាមានការយល់ខុសអំពីការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេឯកភាពថាអាកាសធាតុកំពុងប្រែប្រួល ហើយអ្នកទាំងនោះជាច្រើនបានផ្តល់បទពិសោធន៍ផ្ទាល់ខ្លួន អំពីការប្រែប្រួល ដែលពួកគេបានសង្កេតឃើញដោយខ្លួនឯងៈ

*ខ្ញុំរស់នៅទីនេះតាំងពីឆ្នាំ ១៩៧៩ មកដល់ម៉ោងនេះ។ ពីមុនទឹក ដូចជានៅឆ្ងាយពីដើមឈើ ប៉ុន្តែឥឡូវទឹកដូចពេញឆ្នេរអស់រលើងសឹងតែរកឆ្នេរលេងមិនបាន។ បើយើងដាំដើមឈើថែមឲ្យបានច្រើនយើងនឹងពង្រីកឆ្នេររបស់យើង។ បញ្ហាត្រង់ថានីវ៉ូទឹកសមុទ្រមានការកើនឡើង។ ស្រូវភាគច្រើននៅតាមតំបន់សមុទ្រមិនដែលលិចជន់ខូចខាតនោះទេពីមុនមក តែឥឡូវឃើញថាទឹកលិចដូចទឹកជន់នៅព្រៃនប់បំផ្លិចបំផ្លាញស្រូវប្រជាពលរដ្ឋកាលពីឆ្នាំមុនៗ។ ការឡើងកម្ពស់ទឹកសមុទ្រ បង្កឲ្យទឹកប្រៃហូរចូល ក្នុងស្រែធ្វើឲ្យខូចខាតដំណាំ របស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងស្រុកនោះ។ វាហូរចូលស្រូវមិនអាចស៊ូទ្រាំដុះក្នុងទឹកប្រៃ។ ហើយម្យ៉ាងទៀតទោះ បើពេលដាក់ទឹកសាបវិញក៏ដោយ ក៏នៅតែខូចដែរ ព្រោះលិចទឹកប្រៃយូរហើយ។ (ប្រជាជន) គ្មានបានអីទេនៅពេលដំណាំស្រូវខ្ទេចខ្ទីអញ្ចឹង។ ដូចខ្ញុំបាននិយាយហើយ ទឹកសមុទ្រឡើងវាជាបច្ច័យអាក្រក់ដល់ប្រជាពលរដ្ឋ ដែលរស់នៅតាមតំបន់ឆ្នេរ ដែលប្រកបរបរកសិកម្មមានស្រូវជាដើមត្រូវខូចខាតគឺខូចរហូតដល់រាប់ពាន់ហិកតា។ ខ្ញុំរស់នៅ (ទីនេះ) តាំងពី ១៩៧៩ ខ្ញុំមិនដែលជួបប្រទះទឹកប្រៃហូរចូលនោះទេ។ ខ្ញុំចាត់ទុកថាការកើនឡើងទឹកសមុទ្រក៏ជាផលប៉ះពាល់មកពីការប្រែប្រួលអាកាសធាតុ ហើយអាហ្នឹងយើងអាចឲ្យនិយមន័យបានដែរតើ។*

*ដូចខ្ញុំនិយាយពីទន្លេមេគង្គពីដើមកម្ពស់ទឹកឡើងចុះតាមធម្មតា ប៉ុន្តែឥឡូវយើងមិនអាចកំនត់បានទេ។ ឧទាហរណ៍កាលពីឆ្នាំមុនទឹកទន្លេឡើងដល់ ២៣ ម៉ែត្រដែលពីមុនៗមកមិនដែលអញ្ចឹងទេ។ តាមធម្មតាវាឡើងត្រឹម ២០ ម៉ែត្រវាស្រក់ទៅវិញ។ ដោយសារកម្ពស់ទឹកទាបពេកធ្វើឲ្យទឹកអត់គ្រប់គ្រាន់ឲ្យប្រជាពលរដ្ឋគាត់បង្ហូរចូលស្រែឆ្នាំហ្នឹង (ទាំងពីរដូវ)។ មកទល់ថ្ងៃនេះទឹកទន្លេនៅឯបាត បើឆ្នាំកន្លងមកប្រហែល ២០ ឆ្នាំមុន ចូលខែហ្នឹងប្រជាជនត្រូវប្រញាប់កាច់ពោតបើមិនអញ្ចឹងទេទឹកច្រាំងទន្លេមុខជាយកពោតទៅអស់ហើយ។ នៅឆ្នាំ១៩៧៩។ ឆ្នាំ១៩៧៩ ខែ៦ ទឹកឡើងប្រៀបច្រាំង។ ដូចឆ្នាំ ១៩៧៨ ក្នុងខេត្តក្រចេះលើផ្លូវថ្នល់អីប្រជាជនបើកកាណូតអាធំ ២ ជាន់។ លើថ្នល់នេះទឹកឡើងប្រៀប។ ហើយឆ្នាំក្រោយៗមកទឹកលែងឡើងលិចខេត្ត។ ពីដើមភ័យណាស់ តែចូលខែទឹកឡើងខែវស្សានាំ*

*គ្នាត្រៀម អាជ្ញាធរ លោកត្រៀម គណៈកម្មាធិការ លោកត្រៀម ទូកជួយសង្គ្រោះប្រជាពលរដ្ឋ ព្រោះខ្លាចទឹកលិចលង់។ តែមកដល់ឥឡូវវាជារឿងធម្មតាយើងដឹងថាវាលែងមានកម្ពស់ខ្លាំងក្លាទៀតហើយ ប៉ុន្តែយើងមិនអត្តនោម័តសន្និដ្ឋានថាវាមិនអីដែរ ព្រោះដូចប្រទេសខ្លះមិន ដែលស្រាប់តែទឹកជោគជន់ឃើញកាលពីប៉ុន្មានថ្ងៃមុនទឹកឡើងលិចឡានលិចផ្ទះលិចអីចឹងណ៎ា។ ធាតុអាកាសវាមិនទៀង។*

ព័ត៌មានទាំងនេះបង្ហាញពីវិធី ដែលអភិបាលខេត្តស្វែងយល់ពីប្រធានបទ នៃការប្រែប្រួលអាកាសធាតុ។ ពួក គេច្រើនធ្វើការរៀបរាប់ដោយលើកយកផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុមកនិយាយដោយយោងទៅតាមការសង្កេតផ្ទាល់ខ្លួន ជាជាងផ្តោតលើ មូលហេតុ នៃការប្រែប្រួលអាកាសធាតុ ដូចអ្នកដែលមានជំនាញបច្ចេកទេសលើកឡើងឡើយ ។ ពួកគេពោលថាបច្ចុប្បន្ននេះភ្លៀងធ្លាក់ពុំទៀងទាត់ សីតុណ្ហភាពមានកម្រិតខ្ពស់ជាង និងមានព្យុះញឹកញាប់ជាងមុន។

*យើងមិនដែលមានទាល់តែសោះរឿងខ្យល់ព្យុះមានដែរ ប៉ុន្តែយូរៗម្តង។ ទឹកជំនន់ក៏អញ្ចឹងដែរកម្រមានណាស់។ មួយជីវិត ខ្ញុំកើតមកខ្ញុំឃើញជន់ម្តងកាលពីមុន ប៉ុន្តែឥឡូវនេះឃើញកើតញឹកញាប់ណាស់។ យើងឃើញមាននៅក្នុងឆ្នាំ ២០០០ ហើយ។ មានសឹងរាល់ឆ្នាំចាស់ក្នុងកំពង់ស្ពឺ។ អូនប្រហែលស្តាប់ឮហើយពីទឹកជំនន់កំពង់ស្ពឺ។ ប្រជាជនក្រីក្រ។ ស្រាប់តែទឹកជន់ដល់អស់ជន់ទឹកទៅបាត់ដែរ។ ទៅទាល់តែប្រជាជនអត់ទឹកធ្វើស្រែ។ ប្រជាជនជួបការលំបាកអញ្ចឹង។ ផលប៉ះពាល់ នៃទឹកជំនន់ផលប៉ះពាល់នៃគ្រោះរាំងស្ងួតគឺវាដូចគ្នា។*



ប្រជាជនកំពុងបូបទឹកដាក់ស្រែដើម្បីស្ទូងស្រូវ

ប្រភព BBC World Service Trust 2010

អ្នកឆ្លើយតបខ្លះនៅក្នុងក្រុមនេះ ពោលថា ទឹកជំនន់កើតឡើងកាន់តែញឹកញាប់ ចំណែកឯអ្នករស់ នៅក្នុងតំបន់ឆ្នេរ ពួកគេមានការព្រួយបារម្ភ អំពីកំណើនកម្ពស់ទឹកសមុទ្រ និងការជ្រាបចូល នៃទឹកសមុទ្រ។ មួយចំនួន នៃអ្នកឆ្លើយតបក្នុងក្រុមនេះបានកត់សម្គាល់ អំពីកម្រិតទាប នៃទឹកទន្លេមេគ្គ និងកម្រិតទាប នៃទឹក នៅក្នុងទំនប់ ដែលកត្តានេះអាចនាំឲ្យមានទឹកតិចតួច សម្រាប់ការស្រោចស្រពដំណាំ។ ពួកគេផ្សារភ្ជាប់ការប្រែប្រួលទាំងនេះទៅនឹងផលប៉ះពាល់មកលើសុខភាព

ដោយសំដៅទៅឧបទ្ទវហេតុ ដែលកើតឡើងនៅពេលថ្មីៗនេះដូចជាជម្ងឺ រាគរូស និងជម្ងឺផ្សេងៗទៀត ដែលទាមទារឱ្យមានការព្យាបាល នៅតាមមន្ទីរពេទ្យ និងមរណភាព ដែលបង្កដោយរន្ទះ នៅក្នុងពេលមានភ្លៀងផ្គរ ដែលពួកគេពោលថាកើតមានកាន់តែញឹកញាប់៖

*ជាធម្មតានៅខែកក្កដាហ្នឹងយើងមានទឹកបរិបូណ៌ណាស់ សម្រាប់ធ្វើស្រែ។ មានតែខ្វាចជន់ផងខែ ៧។ ប៉ុន្តែឥឡូវនេះ បើយើងសង្កេតមើលតាមផ្លូវ យើងអាចនិយាយបានថាមានស្រែតិចតួចណាស់ត្រូវបានស្ទូង ហើយមួយចំនួននោះបានស្ទូងលើដីគោក យើងមិនមានទឹកគ្រប់គ្រាន់ ដូចនេះយើងឃើញពីផលប៉ះពាល់ ប្រជាជនមិនអាចធ្វើស្រែចម្ការបានទេ។ ប្រជាជនមានជម្ងឺការប្រែប្រួលទាំងអស់ហ្នឹងធ្វើឲ្យយើងឈឺ។ ការប៉ះពាល់ទាំងនេះបានទាញប្រជាជនទៅរកភាពក្រីក្រ។*

ពួកគេទាំងអស់សំដែងការព្រួយបារម្ភថាកង្វះការព្យាករណ៍ អំពីរបបធាតុអាកាសរួមផ្សំជាមួយកង្វះការត្រៀមខ្លួនក្នុងចំណោមសហគមន៍នៅជនបទធ្វើឱ្យពួកគេងាយរងគ្រោះ៖

*ប្រជាជនកម្ពុជាណា៎ បើធ្វើបានច្រើនក៏ដោយ ធ្វើហើយលក់ ហើយលៃទុកល្មម ១ ឆ្នាំ លៃទុកល្មមមួយគ្រប់មាត់គាត់ ១ ថ្ងៃៗ។ បើអត់ភ្លៀងអត់ធ្វើស្រែបាន តើគាត់គិតយ៉ាងម៉េច គាត់ត្រូវបានអីហូបតទៅមុខទៀត។ អញ្ចឹងវាជាបញ្ហាមួយ សម្រាប់ពួកគាត់។ មួយទៀតគាត់និយាយថាមិនត្រឹមតែមនុស្សឈឺទេគួយ គោក៏ឈឺ ជ្រូកក៏ឈឺ មាន់ក៏ឈឺ ខ្ញុំមិនដឹងត្រូវធ្វើម៉េច។ ចិញ្ចឹមមាន់ទៅងាប់អស់អោយតែក្តៅខ្លាំងមាន់ងាប់ហើយ។*

*ជនបទទទួលរងផលប៉ះពាល់ខ្លាំងជាង ព្រោះថាជនបទគឺជាអ្នកផលិត អ្នកធ្វើកសិកម្ម។ បើកាលណាគ្មានទឹកមកនោះគឺចប់ហើយ។ មិនដឹងបានអីសង្ឃឹមទេ។ កសិករសង្ឃឹមលើទឹកភ្លៀង ព្រោះខេត្តនេះគ្មានប្រឡាយទឹកដូចខេត្តពោធិ៍សាត់គ្មានមេទឹកអីចឹង។ (នៅនេះ) ដីវាខ្ពង់រាបកាលណាភ្លៀងមកវាហូរទៅក្រោមអស់ហើយ។*

*បើនិយាយទៅជីវភាពប្រជាជនភាគច្រើនពឹងផ្អែកលើវិស័យកសិកម្មដាំដុះ របស់គាត់ អញ្ចឹងគាត់ជួបការលំបាកច្រើន ព្រោះគាត់មិនសូវមានជម្រើសឯណាដោយគេបិទការកាប់ឈើ និងអនុផលព្រៃផ្សេងៗទៀត។*

អភិបាលខេត្តបានបង្ហាញពីចំណងទាក់ទងជាច្រើនបែប រវាងការប្រែប្រួលអាកាសធាតុ និងទិដ្ឋភាពនានាផ្សេងទៀត នៃសង្គមក្នុងចំណោមអ្នកឆ្លើយសំខាន់ៗទាំងអស់។ មិនត្រឹមតែពួកគេអាចបង្ហាញពីចំណងទាក់ទងទាំងនោះទៅនឹងផលប៉ះពាល់មកលើកសិកម្ម និងសុខភាពប៉ុណ្ណោះទេ អ្នកឆ្លើយសំខាន់ៗដទៃទៀតក៏បានបង្ហាញដូចគ្នានេះដែរ។ ពួកគេក៏បានឃើញការពាក់ព័ន្ធ នៃការប្រែប្រួលអាកាសធាតុមកលើវិស័យដឹកជញ្ជូន ដោយសារទាំងការបំផ្លាយកាបូនដែលកើតចេញពីវិស័យនេះនិងដោយសារផលវិបាកនានានៃទឹកជំនន់មកលើការដឹកជញ្ជូននៅក្នុងប្រទេសផងដែរ។ ពួកគេបង្ហាញពីចំណងទាក់ទង រវាងការប្រែប្រួលអាកាសធាតុទៅនឹងកំណើនឧបទ្ទវហេតុ និងភាពធ្ងន់ធ្ងរ នៃភាពរាំងស្ងួត និងធ្វើការកំណត់ប្រការទាំងនេះថាជាគន្លឹះនាំឱ្យមានការបន្ទូរបន្ថយ។

អភិបាលខេត្តក៏ពិនិត្យមើលផងដែរ នូវសក្តានុពលដែលការប្រែប្រួលអាកាសធាតុអាចមានផលប៉ះពាល់មកលើស្ត្រីក្នុងសមាមាត្រខុសគ្នា។ ពួកគេយល់ថាស្ត្រីអាចងាយរងគ្រោះដោយសារកង្វះទឹកដោយសារតែការទទួលខុសត្រូវរបស់ពួកគេ

នៅក្នុងគ្រួសារដែលរួមទាំងការដងទឹក។ អ្នកឆ្លើយម្នាក់ពោលថា "សមធម៌យេនឌ័រនៅតែជាបញ្ហានៅឡើយក្នុងសហគមន៍នេះ"។អ្នកឆ្លើយម្នាក់ទៀត សង្កេតឃើញថា "ភាគច្រើនជាមេផ្ទះ" ដែលជាអ្នកចេញមកសុំជំនួយពីអាជ្ញាធរនៅក្នុងករណីមានទឹកជំនន់ ខ្យល់ព្យុះ ឬបញ្ហានៅក្នុងកសិដ្ឋានរបស់ពួកគេ។ លោកបានពោលថាសូម្បីតែ "ស្ត្រីខ្លះមិនហ៊ាននិយាយ" ទៅកាន់អាជ្ញាធរណាម្នាក់ក៏ដោយ ពួកគេព្យាយាមស្វែងរក "សុំឱ្យបុរសមកជំនួសពួកគេ" នៅក្នុងការពិភាក្សាអំពីបញ្ហាប្រភេទនេះដែរ។

ក្រៅពីការសង្កេតរបស់ពួកគេ ប្រភពជាទូទៅបំផុតនៃព័ត៌មានអំពីការប្រែប្រួលអាកាសធាតុសម្រាប់អភិបាលខេត្តអាចជា ប្រព័ន្ធព័ត៌មាននៅថ្នាក់ជាតិ និងអន្តរជាតិ ជាពិសេសវិទ្យុ។ អភិបាលខេត្តទាំងអស់ក៏បានកត់សម្គាល់អំពីអង្គការផ្សេងៗទៀតដែលធ្វើការលើបញ្ហានេះផងដែរ។ ពួកគេកត់សម្គាល់ក្រសួងរបស់រដ្ឋាភិបាលដែលរួមមាន ក្រសួងបរិស្ថាន ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងកិច្ចការនារី។ បុគ្គលសំខាន់ៗមួយចំនួនបានឲ្យដឹងថា ពួកគេទទួលព័ត៌មានមកពីសុន្ទរកថារបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ**កម្ពុជា** នៅក្នុងឆ្នាំ២០០៩។ អង្គការមិនមែនរដ្ឋាភិបាលក៏ត្រូវបានកត់សម្គាល់ ថាជាប្រភពព័ត៌មានមួយផងដែរ ដូចជាអង្គការ WWF អង្គការទស្សនៈពិភពលោក ហើយនិងកាកបាទក្រហមកម្ពុជា។ កាកបាទក្រហមកម្ពុជា គឺជាស្ថាប័នមួយដែលធ្វើការនៅក្នុងបរិបទនៃការឆ្លើយតបនឹងគ្រោះមហន្តរាយ។ អ្នកខ្លះពោលថាពួកគេបានរៀនសូត្រអំពីការប្រែប្រួលអាកាសធាតុតាមរយៈសិក្ខាសាលា វេបសាយ និងមួយចំនួនតូចតាមរយៈសារព័ត៌មាន។ អ្នកឆ្លើយម្នាក់ ដែលលើកឡើងអំពីសមាគមស្ត្រីដើម្បីសន្តិភាព និងការអភិវឌ្ឍ បានពន្យល់ថាការងាររបស់ពួកគេផ្តោតជាសំខាន់លើ "ការទប់ស្កាត់ផ្សេង"។

ប្រភពខុសៗគ្នាអំពីការប្រែប្រួលអាកាសធាតុដែលអភិបាលខេត្តធ្វើការកំណត់ ជាការបង្ហាញថាកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីឱ្យថ្នាក់ខេត្តចូលរួមក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ កំពុងសម្រេចជោគជ័យខ្លះៗ។

អភិបាលខេត្តនៅក្នុងតំបន់ខ្លះ ធ្វើសេចក្តីយោងជាក់លាក់ទៅតាមការឆ្លើយតបនៅថ្នាក់ជាតិទៅនឹងការប្រែប្រួលអាកាសធាតុ។ នៅពេលសួរថាតើគាត់ដឹងអ្វីខ្លះអំពីសកម្មភាពរបស់រដ្ឋាភិបាលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ អភិបាលខេត្តមួយរូបឆ្លើយថា:

> *ខេត្តត្រូវអនុវត្តគោលនយោបាយរដ្ឋាភិបាលមួយៗ...ព្រោះខេត្ត១ ជាផ្នែកមួយរបស់រដ្ឋាភិបាល។ យើងបានអនុវត្ត (កម្មវិធីដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ) ចាប់តាំងពីអាណត្តិទី៣មក។*

អ្នកដទៃទៀតពោលថា ពួកគេមិនបានអនុវត្តកម្មវិធីជាតិនៅក្នុងខេត្តរបស់ខ្លួនឡើយ។ ទោះជាយ៉ាងណាក៏ដោយ អភិបាលខេត្តទាំងអស់ កត់សម្គាល់យ៉ាងហោចណាស់កិច្ចផ្តួចផ្តើមមួយរបស់រដ្ឋាភិបាល ដែលរួមទាំងការកាត់បន្ថយនូវការបំភាយឧស្ម័នផ្ទះកញ្ចក់ ការវិនិយោគលើថាមពលវារីអគ្គិសនី កម្មវិធីអប់រំដើម្បីឲ្យប្រជាជនកាត់បន្ថយការប្រើប្រាស់ជីគីមី និងការដុតជញ្ជ្រាំងស្រូវរបស់ពួកគេ កម្មវិធីដាំដើមឈើ និងគោលនយោបាយរបស់រដ្ឋាភិបាលអំពីការបង្កើនការយល់ដឹងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងចំណោមសាធារណជន។

នៅថ្នាក់ខេត្ត អ្នកខ្លះពោលថាពួកគេធ្វើការនៅក្នុងកម្មវិធីនានាដើម្បីកាត់បន្ថយការប្រើប្រាស់អុស និងធ្យូងបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និង"កែប្រែការយល់ឃើញរបស់ប្រជាជន" ជ្រើសរើស និងណែនាំឱ្យប្រើប្រាស់ពូជដំណាំថ្មីៗ បង្កើនផលិតភាពស្រូវ និងធ្វើការដាំដើមឈើ និងកោងកាង។

នៅពេលសួរអំពីឧបសគ្គនៅក្នុងការអនុវត្តកម្មវិធីនានា អភិបាលខេត្តធ្វើការកំណត់ឧបសគ្គមួយចំនួន។ ឧបសគ្គចំបង ដែលអ្នកឆ្លើយជាច្រើន បានកត់សម្គាល់ឃើញគឺ ភាពក្រីក្រដែលរារាំងប្រជាជនភាគច្រើនពីការគិតអំពីអ្វីដែលហួសពីតម្រូវការបន្ទាន់ប្រចាំថ្ងៃរបស់ពួកគេ។ ឧបសគ្គមួយជាក់លាក់ចំពោះការសម្របសម្រួលអំពីការប្រែប្រួលអាកាសធាតុនៅថ្នាក់ខេត្ត និងឃុំត្រូវបានអភិបាលខេត្តមួយរូបធ្វើការកំណត់ និងបានពន្យល់ថា ពួកគេបានប៉ុនប៉ងប្រមូលតំណាងពីភូមិខុសៗគ្នានៅក្នុងឃុំដើម្បីប្រជុំ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការប៉ុនប៉ងក្នុងការសម្របសម្រួលបានជួបនឹងការលំបាកដោយសារថ្លៃចំណាយលើការដឹកជញ្ជូន ដោយម្នាក់ៗជួបផលលំបាកក្នុងការធ្វើដំណើរពីភូមិរបស់ពួកគេដើម្បីចូលរួមនៅក្នុងការប្រជុំ។

ស្របគ្នាជាមួយនឹងយោបល់ទាំងអស់នេះ វាគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដែលអភិបាលខេត្តពោលថា គេត្រូវការមូលនិធិបន្ថែមទៀតសម្រាប់គម្រោងប្រែប្រួលអាកាសធាតុនានា។ ពួកគេក៏ពោលផងដែរថា ពួកគេត្រូវការឱ្យមានការគាំទ្រហិរញ្ញវត្ថុ និងការផ្តល់ធនធានឲ្យបានប្រសើរជាងមុន។ អ្នកឆ្លើយមួយចំនួនពន្យល់ថា សហគមន៍របស់ពួកគេត្រូវការគ្រាប់ពូជដែលអាចបន្សុាំទៅនឹងសីតុណ្ហភាពខ្ពស់ ធន់នឹងជម្ងឺ និងភាពរាំងស្ងួត។ ទន្ទឹមនឹងធនធាន និងការគាំទ្រហិរញ្ញវត្ថុដែលបានលើកឡើងនេះ ក៏មានការសង្កត់ធ្ងន់លើតម្រូវការឱ្យមានការផ្តល់ព័ត៌មាន ដែលរួមទាំងតាមរយៈប្រព័ន្ធផ្សព្វផ្សាយផងដែរ។

ដោយឡែកអភិបាលខេត្តស្នើយោបល់ថា គេត្រូវការឲ្យមាន "គំរូតួនាទី" នានាដើម្បីធ្វើការផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុដែលអាចជាឈុតអប់រំអំពីការប្រែប្រួលអាកាសធាតុ។ វិទ្យុគួរត្រូវបានប្រើប្រាស់ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ ហើយអង្គការសហប្រជាជាតិគួរតែប្រឹងប្រែងបន្ថែមទៀត ដើម្បីផ្សព្វផ្សាយអំពីអ្វីដែលកំពុងអនុវត្តនៅលើពិភពលោក ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ អភិបាលមួយរូបពន្យល់ពីមូលហេតុដែលលោកគិតថាក្រសួងកសិកម្មគួរតែចូលរួមនៅក្នុងការផ្សព្វផ្សាយដល់ប្រជាជនអំពីការប្រែប្រួលអាកាសធាតុ។

> *ក្រសួងកសិកម្ម...ដើរតួនាទីសំខាន់។ព្រោះនៅពេលប្រជាជនជួបនូវផលលំបាកនៃការផលិតទិន្នផលគាត់ទាបគាត់ធ្វើមិនបានក្រសួងអាចបង្ហាញហេតុផលហ្នឹងពីការប្រែប្រួលអាកាសធាតុទៅពួកគាត់។គាត់ងាយទទួលយកបាន។ កាលណាស្អីគាត់ធ្វើមិនបានវាប៉ះពាល់លុះគេពន្យល់ប្រាប់ទៅពីបញ្ហាហ្នឹងគាត់ទទួលយកបាន។ប្រជាជនមិនខ្វល់ពីអ្វីដែលមិនប៉ះពាល់គាត់(ដោយផ្ទាល់) នោះទេ។*

## ប្រធានក្រុមប្រឹក្សាឃុំ

ទោះបីប្រធានក្រុមប្រឹក្សាឃុំ បង្ហាញពីការពាក់ព័ន្ធនៃពាក្យ "ការប្រែប្រួលអាកាសធាតុ" ជាមួយបាតុភូតសកល ដូចជាភាពរាំងស្ងួត និងសីតុណ្ហភាពទាប ឬ ខ្ពស់ខ្លាំង នៅតាមតំបន់នានាលើពិភពលោក ក៏ការពន្យល់របស់ពួកគេអំពីការប្រែប្រួលអាកាសធាតុ ទំនងជាផ្តោតលើការបាត់បង់ព្រៃឈើ នៅតាមកន្លែងក្នុងមូលដ្ឋានជាមួយនឹង ការប្រែប្រួលធាតុអាកាសនៅកម្ពុជា។

តំណាងទាំងអស់មកពីក្រុមប្រឹក្សាឃុំ/សង្កាត់បានឮពាក្យ "ការប្រែប្រួលអាកាសធាតុ" ។ ពួកគេទំនងជាពន្យល់ពាក្យនេះដោយយោងទៅការប្រែប្រួលធាតុអាកាសដូចជាកំណើនសីតុណ្ហភាព និងការប្រែប្រួលរបបទឹកភ្លៀង។ ការប្រែប្រួលនៃធាតុអាកាសទាំងនេះ ច្រើនតែត្រូវបានពិពណ៌នាថាបានកើតឡើងនៅក្នុងអតីតកាលថ្មីៗនេះ។ សមាជិកក្រុមប្រឹក្សា

ឃុំ/សង្កាត់បានកត់សម្គាល់ថា ទូរទស្សន៍ វិទ្យុ និងការនិយាយតគ្នាពីមាត់មួយទៅមាត់មួយ ជាពិសេសក្នុងចំណោមមនុស្សចាស់ គឺជាប្រភពដែលពួកគេបានឮពាក្យ "ការប្រែប្រួលអាកាសធាតុ":

*ខ្ញុំឮពាក្យនេះតាមរយៈចាស់បុរាណដែលគាត់តែងតែលើកថាពីដើមមកមិនដែលមាន។*

តំណាងពីក្រុមប្រឹក្សាឃុំខ្លះពោលថាពួកគេបានឮពាក្យ "ការប្រែប្រួលអាកាសធាតុ" ពីព័ត៌មានអន្តរជាតិ:

*យើងមើលព័ត៌មានអន្តរជាតិ ក្តៅរហូតដល់ថ្នាក់ស្លាប់ អាកាសធាតុក្តៅខ្លាំងពេកធ្វើឲ្យមនុស្សស្លាប់តែម្តង។*

សមាជិកក្រុមប្រឹក្សាឃុំស្ទើរតែទាំងអស់គិតថា "ការប្រែប្រួលអាកាសធាតុ" គឺជាបញ្ហាសកល ប្រហែលមកពី ពួកគេបានទទួលដំណឹងជុំវិញបញ្ហានេះពីព័ត៌មានទាំងនោះ។ សមាជិកក្រុមប្រឹក្សាឃុំ មួយចំនួនតូចពោលថាពួកគាត់ស្គាល់ពាក្យ "ការឡើងកម្តៅផែនដី"។មានតែមួយចំនួនតូចបំផុតដែលស្គាល់ពាក្យ "ផលផ្ទះកញ្ចក់"ហើយគ្មានអ្នកណាម្នាក់អាចពន្យល់បានឡើយ:

| | |
|---|---|
| *អ្នកឆ្លើយ:* | *ផ្ទះកញ្ចក់...ដូចជាផ្ទះសំណាក់ហ្នឹងអី?* |
| *អ្នកសម្ភាស:* | *មិនមែនទេ គឺវាគឺជាផលប៉ះពាល់នៃផ្ទះកញ្ចក់។ តើលោកពូធ្លាប់ឮគេផ្សាយទាក់ទងនឹងពាក្យនេះដែរឬទេ?* |
| *អ្នកឆ្លើយ:* | *ទេ ខ្ញុំអត់យល់ឧស្ម័នផ្ទះកញ្ចក់ហ្នឹងអីផង...* |

បុគ្គលសំខាន់ៗទាំងនោះភាគច្រើននិយាយថា ធាតុអាកាសកំពុងប្រែប្រួល។ ប្រធានក្រុមប្រឹក្សាឃុំភ្ជាប់បញ្ហានេះទៅនឹងមូលហេតុធម្មជាតិនិងសកម្មភាពមនុស្ស។ គេមិនអាចញែកដាច់គ្នានូវការអធិប្បាយរបស់ពួកគាត់អំពីលំនាំដែលធាតុអាកាសប្រែប្រួលដាច់ចេញពីការរេចរឹលបរិស្ថានទូទៅបានឡើយ:

*បើយើងមិនធ្វើទាំងអស់នេះវាមិនប្រែប្រួលទេ។បើបច្ចេកទេសធ្វើហើយដូចជាចាក់កង់ឡានវាធំក្លិនប៉ុណ្ណាជះឥទ្ធិពលប៉ុណ្ណា ផ្សែងឡើងប៉ុណ្ណា ឡើងទាំងអស់។ តែក្នុងម្ចាស់នីមួយៗ មិនទាន់ដឹងថាយើងច្នៃប្រឌិតខាង ថាមពលហ្នឹង បានជះឥទ្ធិពលដល់បរិស្ថានជុំវិញទាំងអស់។ផលប៉ះពាល់ទីមួយរបស់អាកាសធាតុប្រែប្រួលគឺលើសុខភាពរបស់មនុស្ស។ បើអត់ធ្វើដូចខ្ញុំហ្នឹង នោះអត់មានការប្រែប្រួលអ្វីទាំងអស់...ប៉ុន្តែពួកគេប្រើបច្ចេកទេស ច្នៃប្រឌិតគំនិតផ្តើម...។*

នៅពេលសួរអំពីមូលហេតុនៃការប្រែប្រួលធាតុអាកាសទាំងអស់គ្នាសុទ្ធតែបានកត់សម្គាល់ពីការបាត់បង់ព្រៃឈើ។ បុគ្គលទាំងនោះភាគច្រើនសំដៅទៅលើការកាប់ឈើពីសំណាក់ប្រជាជននៅក្នុងសហគមន៍របស់ពួកគេ ប៉ុន្តែអ្នកខ្លះពោលថាការបាត់បង់ព្រៃឈើអាចទាក់ទងផងដែរទៅនឹងការកាប់ឈើល្មើសច្បាប់ជាទ្រង់ទ្រាយធំ។ ប្រធានក្រុមប្រឹក្សាឃុំជាច្រើនផ្សារភ្ជាប់ការប្រែប្រួលធាតុអាកាសទៅនឹងការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត ដែលពួកគេគិតថា ក៏មានការជាប់ទាក់ទងផងដែរជាមួយជម្ងឺដែលកើតឡើងក្នុងចំណោមប្រជាជននិងការកើនឡើងនៃសត្វចង្រៃបំផ្លាញដំណាំ។ ការទាក់ទងជាមួយមូលហេតុដទៃទៀតក៏ត្រូវបានកត់សម្គាល់ផងដែរតែមិនសូវញឹកញាប់រវាងការប្រែប្រួលធាតុអាកាស និងការចោលសំណល់និងការបំពុលទឹក។ ប្រធានក្រុមប្រឹក្សាឃុំមួយចំនួនបាននិយាយអំពីផលប៉ះពាល់ពីការបញ្ជូនសញ្ញានៃទូរស័ព្ទចល័តនៅក្នុងការពន្យល់របស់ពួកគេអំពីមូលហេតុនៃការប្រែប្រួលធាតុអាកាស:

*ខ្ញុំឮប្រជាជននិយាយគ្នាថា អង់តែនទូរស័ព្ទបានធ្វើឲ្យស្លឹកត្នោតខ្លោច ដល់ពេលខ្ញុំពិនិត្យឃើញដូចគេថាមែន។*

បុគ្គលសំខាន់ៗទាំងនោះជាច្រើនបង្ហាញពី *ទំនាក់ទំនងផ្ទាល់* រវាងការបញ្ចេញផ្សែងតាមរយៈការប្រើប្រាស់យានយន្ត គ្រឿងម៉ាស៊ីន និងសកម្មភាពនៅតាមរោងចក្រ និងកំណើនសីតុណ្ហភាព។

*កម្តៅនៅលើផែនដីកើនឡើងដោយសារម៉ូតូ រថយន្តបញ្ចេញផ្សែងច្រើនទៅ*

ប្រធានក្រុមប្រឹក្សាឃុំភាគច្រើនផ្សារភ្ជាប់ពាក្យ "ការប្រែប្រួលអាកាសធាតុ" ទៅនឹងការរេចរឹលនៃបរិស្ថានធម្មជាតិតាមរយៈការអភិវឌ្ឍ។ បុគ្គលម្នាក់ពោលថា "ធម្មជាតិនឹងប្រែប្រួលដោយសារការអភិវឌ្ឍ"។

បុគ្គលសំខាន់ៗខ្លះក៏ពោលអំពីកំណើនសីតុណ្ហភាពថា ជាប់ទាក់ទងផងដែរជាមួយការធ្លុះធ្លាយស្រទាប់អូហ្សូនៈ

*កាលណាស្រទាប់អូហ្សូនកាន់តែស្តើង កម្តៅព្រះអាទិត្យមកកាន់ផែនដីកាន់តែខ្លាំង។ នៅពេលដែលវាកាន់តែខ្លាំងចំហាយផែនដីកាន់តែបុកឡើង វាអាចធ្វើឲ្យមិនស្រួលផ្នែកសុខភាព។ នៅពេលយើងបង្កើតរោងចក្របង្កើតថាមពលអគ្គិសនីទាំងអស់នេះ កាន់តែធ្វើឲ្យមានជាតិឧស្ម័នដែលជាតិទាំងនេះអាចរំលាយស្រទាប់អូហ្សូនបាន។ នៅពេលដែលយើងបង្កើតហើយ ផ្សែងបានចេញឡើងពួនបន្តិចៗម្តង ដែលនេះធ្វើឲ្យប៉ះពាល់ដល់ស្រទាប់អូហ្សូន។*

បុគ្គលសំខាន់ៗទាំងអស់គ្នា សុទ្ធតែបង្ហាញពីទំនាក់ទំនងពាក្យ "ការប្រែប្រួលអាកាសធាតុ" ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលធាតុអាកាសពេល ដែលពួកគេបានសង្កេតឃើញ ដូចជាផលប៉ះពាល់អវិជ្ជមានមកលើសុខភាពមនុស្ស ធនធានទឹក ទិន្នផលកសិកម្ម និងការចិញ្ចឹមសត្វ។ នៅក្នុងសហគមន៍ខ្លះ ភាពរាំងស្ងួតកាលពីឆ្នាំមុនត្រូវបានពោលផងដែរថាមានលក្ខណៈអាក្រក់ខ្លាំង។ ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់មួយរូបពោលថា យុទ្ធសាស្ត្រនៅមូលដ្ឋានសម្រាប់ដោះស្រាយភាពរាំងស្ងួត មិនអាចដំណើរការបានដូចទម្លាប់ជាធម្មតានោះទេ។ ចូរកត់សម្គាល់អំពីកម្រិតនៅតាមមូលដ្ឋាននៅក្នុងការពិពណ៌នារបស់គាត់។

*តាមពិតទៅ រាល់ឆ្នាំប្រសិនបើមេឃអត់ភ្លៀង ហើយទឹកនៅពេញទំនប់ គឺប្រជាជនអាចបើកទឹកយកមកប្រើ ប៉ុន្តែដូចខ្ញុំបានជំរាបជូនក្មួយពីខាងដើម គឺទឹកបានដល់បាតទំនប់ ហើយទឹកអត់អាចបើកបាន ហើយមិនអាចបង្ហូរបានតាមដៃប្រឡាយ អញ្ចឹងត្រូវរាំងស្ទះទាំងអស់។ ខាងនេះអត់ទេ ប៉ុន្តែក្មួយទៅមើលខាងលើស្រែខ្លះចេញហើយ ព្រោះគេអាចបើកទឹកដាក់បានខ្លះៗ។*

ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ភាគច្រើនពោលថា ពួកគាត់បានឮអំពីកម្មវិធីរបស់រដ្ឋាភិបាល ស្តីពីការដាំដើមឈើ ហើយអ្នកទាំងនោះជាច្រើន បានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពដាំដើមឈើនៅក្នុងឃុំរបស់ខ្លួន។ អ្នកខ្លះកត់សម្គាល់អំពីកម្មវិធីផ្សេងៗទៀត ដែលរួមទាំងការស្រោចស្រពនិងការដាំដំណាំចំរុះផងដែរ។ ទោះជាយ៉ាងណាក៏ដោយគ្មានអ្នកណាម្នាក់បានឮ អំពីកម្មវិធីណាមួយរបស់រដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុឡើយ ទោះនៅលំដាប់ថ្នាក់ណាមួយក៏ដោយ។ អ្នកទាំងនោះភាគច្រើន បានអនុវត្តកិច្ចផ្តួចផ្តើមដាំដើមឈើ និងមួយចំនួនបានឮខ្លះៗ អំពីកម្មវិធីកាត់បន្ថយការបំពុល សូម្បីតែប្រការទាំងអស់នេះ មិនត្រូវបានអធិប្បាយបានទូលំទូលាយ និងច្បាស់លាស់ក៏ដោយ ឧទាហរណ៍ដូចជាការលើកយកគម្រោង "ការបញ្ជូនរោងចក្រចេញពីទីក្រុង" មកអធិប្បាយ។

ប៉ុន្តែអ្នកទាំងនោះភាគច្រើន បានរំពឹងថារដ្ឋាភិបាលគឺជាប្រភពព័ត៌មាន អំពីប្រធានបទនេះ។ នៅពេលសួរថាពួកគេអាចទៅរកព័ត៌មាននៅទីណាខ្លះ អ្នកទាំងនោះជាច្រើនស្នើថា ពួកគេអាចស្តាប់វិទ្យុ និងមើលទូរទស្សន៍ ជាពិសេសកម្មវិធីព័ត៌មាន ដើម្បីអាចទទួលព័ត៌មានបានច្រើនបន្ថែមទៀតអំពីបញ្ហានេះ។ ក្នុងចំណោមអ្នកដែលបានកត់សម្គាល់អំពីនាយកដ្ឋាននានារបស់រដ្ឋាភិបាលភាគច្រើនបានពោលថា ពួកគេអាចផ្តល់ឈ្មោះក្រសួងរួមមាន ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និង/ឬក្រសួងបរិស្ថាន។ មួយចំនួនតូចពោលអំពីឈ្មោះ ក្រសួងអភិវឌ្ឍន៍ជនបទ និងអ្នកខ្លះធ្លាប់បានធ្វើការជាមួយកាកបាទក្រហមកម្ពុជា។

ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ពោលថា ពួកគាត់ត្រូវការប្រាក់ និងឧបករណ៍នានា។ ប៉ុន្តែភាគច្រើននៃអ្នកទាំងនោះពោល ថាធនធានដែលសំខាន់បំផុតសម្រាប់តួនាទីរបស់ខ្លួនជាប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់គឺព័ត៌មាន៖

*ខ្ញុំមិនដឹងថាធនធានអ្វីដែលខ្ញុំត្រូវការ ព្រោះអីខ្ញុំអត់យល់ពាក្យការប្រែប្រួលអាកាសធាតុផងហ្នឹង។ ប៉ុន្តែខ្ញុំគិតថា ចំណេះដឹងគឺសំខាន់បំផុត។*

ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់មួយរូប បានផ្តល់ ទស្សនៈដ៏មានប្រយោជន៍អំពីវិធីដែលអ្នកទាំងឡាយដែលមានតំណែងដូចគាត់អាច ស្វែងរកព័ត៌មានស្តីពីប្រធានបទប្រែប្រួលអាកាសធាតុ ៖

*អ្នកសម្ភាសៈ* *រាល់ថ្ងៃប្រសិនបើពូចង់បានព័ត៌មានទាក់ទងជាមួយការប្រែប្រួលអាកាសធាតុហ្នឹង តើលោកពូគិតថាស្ថាប័នណា ឬពូត្រូវជួបអ្នកណាដែលគាត់អាចផ្តល់ព័ត៌មានហ្នឹងបាន?*

*អ្នកឆ្លើយៈ* *អានេះបើខ្ញុំគិតទៅ គឺមានតែខ្សែរយៈបណ្តោយរបស់ខ្ញុំទេ។ ឧទាហរណ៍ បើយើងចង់ឲ្យអង្គការមកផ្សព្វផ្សាយពីការប្រែប្រួលអាកាសធាតុយ៉ាងនឹង បើតាមផ្លូវច្បាប់ គឺយើងត្រូវដាក់សំណើឡើងទៅស្រុក ស្រុកទៅខេត្ត ហើយខេត្តទាក់ទងអង្គការ។ វាមិនត្រូវធ្វើតាមផ្លូវកាត់បានទេ យើងត្រូវសុំច្បាប់។*

*អ្នកសម្ភាសៈ* *តើលោកពូគិតថា អ្នកណាដែលអាចផ្តល់ ឬ ស្ថាប័នណាមួយដែលនិយាយពីការប្រែប្រួលអាកាសធាតុហើយសាធារណជនជឿទុកចិត្តនិងចូលរួមដោះស្រាយ?*

*អ្នកឆ្លើយៈ* *ការពិតទៅនៅក្នុងមូលដ្ឋានរបស់ខ្ញុំ ក៏ដូចជាខេត្តទាំងមូល បើនិយាយពីរឿងជឿជាក់ គឺមានតែថ្នាក់ដឹកនាំធំៗ ដើម្បីធ្វើការផ្សព្វផ្សាយ ដូចជាអភិបាលខេត្ត អភិបាលខេត្តរង អភិបាលស្រុក អភិបាលស្រុករងដែលមានចំណេះដឹងដែលអាចផ្សព្វផ្សាយ ក្នុងនោះក៏មានការចូលរួមរបស់ក្រុមប្រឹក្សាឃុំយើងដែរ មិនមែនអត់ទេ។ អ្វីៗទាំងពួង គឺតែងតែធ្លាក់ចុះមកដល់ថ្នាក់ឃុំសង្កាត់ ហើយឃុំសង្កាត់ត្រូវបន្ត។ ប៉ុន្តែសកម្មភាពដំបូងក្នុងការផ្សព្វផ្សាយ គឺត្រូវថ្នាក់ខេត្តជាមុនសិន។*

យោបល់ជាច្រើនរបស់ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់បង្ហាញថា ការឆ្លើយតបទៅនឹងគ្រោះធម្មជាតិ គឺទើបតែធ្វើប្រតិកម្មតបនៅពេលថ្មីៗនេះ៖

*នៅពេលនេះ យើងមិនទាន់ជួបបញ្ហាតែនៅពេលជួបបញ្ហាធ្ងន់ធ្ងរ ប្រហែលជាយើងដឹងថាអ្នកណាដែលត្រូវទាក់ទងជាដៃគូ។*

ទោះជាយ៉ាងណាក៏ដោយ បញ្ហានៃការផ្សព្វផ្សាយព័ត៌មាន ត្រូវបានលើកឡើង ហើយសារមួយដែលត្រូវតែផ្សព្វផ្សាយគឺថា ការឆ្លើយតបនានាទៅនឹងការប្រែប្រួលអាកាសធាតុត្រូវតែគ្រោងទុកជាមុន។

## ប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិ

អ្នកទាំងនេះភាគច្រើនពោលថា ពួកគេស្គាល់ពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី" ។ ប្រភពព័ត៌មានបឋម នៃពាក្យនេះសម្រាប់ប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យ គឺការនិយាយតគ្នាពីមាត់មួយទៅមាត់មួយ ទោះបីគាត់ធ្លាប់ បានឮពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី" តាមរយៈទូរទស្សន៍ និងវិទ្យុក៏ដោយ។ ក្រុមនេះព្រួយបារម្ភ អំពីផលប៉ះពាល់នៃការប្រែប្រួលធាតុអាកាស មកលើសហគមន៍របស់ខ្លួន ហើយពោលថាពួកគេមិនដឹងត្រូវឆ្លើយតបបែបណាឡើយ។

សម្រាប់ប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យ ប្រភពបឋមនៃព័ត៌មានស្តីពីការប្រែប្រួលធាតុអាកាស គឺការនិយាយតគ្នាពីមាត់មួយទៅមាត់មួយ។ ភាគច្រើននៃប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យពោលថា ការប្រែប្រួលធាតុអាកាស ដែលពួកគេបានជួបប្រទះ គឺជាប្រធានបទទូទៅនៃការសន្ទនានៅក្នុងសហគមន៍របស់ពួកគេ។ អ្នកទាំងនោះជាច្រើន ក៏និយាយផងដែរថាពួកគេបានឮពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី" តាមរយៈទូរទស្សន៍ និងវិទ្យុបើទោះជាមួយចំនួនពោលថាលទ្ធភាពរបស់ពួកគេ ក្នុងការទទួលព័ត៌មានពីបណ្តាញផ្សព្វផ្សាយនៅមានកម្រិតក៏ដោយ។

ប្រធានភូមិជាច្រើនពោលថា ពួកគាត់បានឮអ្នកភូមិ ជាពិសេសចាស់ៗ នៅក្នុងភូមិពិភាក្សាអំពីការប្រែប្រួលធាតុអាកាស។

*អ្វីដែលខ្ញុំបានឮ គឺពេលមានកម្មវិធីបុណ្យ ឬ ក៏មានការអ្វីហ្នឹងដែលចាស់ៗជជែកគ្នាលេងជាក្រុម។ ក្នុងភូមិ ក្មេង និង ក្មេងស្របាលខ្ញុំជជែកគ្នាពីការប្រែប្រួលអាកាសធាតុ និងការរួមចំណែកបណ្តាលមកពីផ្ទះកញ្ចក់ខ្លះ ហើយផ្នែកដែលសង្កត់ធ្ងន់នោះ គឺមូលហេតុបណ្តាលមកពីការថយចុះព្រៃឈើ ផ្សេង គ្រឿងចក្រវាច្រើនបណ្តាលឲ្យយើងក្តៅទ្វេដង។ ខ្ញុំមិនយល់ច្បាស់ទេ (ន័យរបស់ពាក្យឧស្ម័នផ្ទះកញ្ចក់) ព្រោះនៅខាងស្រែនេះនៅពេលនិយាយពីឧស្ម័នប្រជាជនមិនយល់វិទ្យាសាស្ត្រឲ្យបានច្រើន។*

ទោះជាយ៉ាងណាក៏ដោយ ប្រភពព័ត៌មានរបស់ពួកគេ មិនទំនងជាសុទ្ធតែមានភាពច្បាស់លាស់ សម្រាប់ប្រធានបទនេះឡើយ។

*ខ្ញុំឮតែចាស់ៗនិយាយថាឡើងកម្តៅផែនដីថា មិនដឹងឆ្នាំណាទេ គេថាភ្លើងឆេះកាល។ គេថាភ្លើងឆេះកាល ឆេះទាំងអស់។*

ការយល់ដឹងអំពីបាតុភូតនេះ មានលក្ខណៈចម្រុះខ្លាំងណាស់ ក្នុងចំណោមក្រុមនេះ។ ទាំងអស់គ្នាសុទ្ធតែពោលថា ការប្រែប្រួលធាតុអាកាស មានជាប់ទាក់ទងទៅនឹងការបាត់បង់ព្រៃឈើនៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ យោបល់របស់ពួកគេក៏បានផ្សារភ្ជាប់ការបាត់បង់ព្រៃឈើនៅក្នុងមូលដ្ឋាន ទៅនឹងការប្រែប្រួលបរិស្ថាននៅតាមតំបន់ និងជាលទ្ធផលគឺការ នាំឲ្យមានការប្រែប្រួលធាតុអាកាស។

*បរិស្ថានត្រូវបានប្រែប្រួលដោយសារមនុស្សយើង។ ក្នុងឆ្នាំ ១៩៧៩ យើងមានព្រៃឈើក្រាស់ប៉ុន្តែឥឡូវនេះ អត់ព្រៃឈើឬព្រៃលិចទឹកទេ។ ម្ល៉ោះហើយដីដែលអត់ម្លប់ វាក្តៅហួតហែង។*

ប្រធានភូមិជាច្រើនផ្សារភ្ជាប់ ការបាត់បង់ព្រៃឈើក្នុងមូលដ្ឋានទៅនឹងសកម្មភាពរបស់បុគ្គលនានា ជាងការកាប់ឈើទ្រង់ទ្រាយធំ។ ពួកគាត់ពន្យល់ថាប្រជាជនកាប់ដើមឈើដោយសារតែភាពចាំបាច់របស់ពួកគាត់:

*ទង្វើរបស់មនុស្សកើតឡើងដោយសារការខ្វះខាតផ្នែកជីវភាពលុយកាក់។ ប្រជាជនខ្លះមិនដឹងថាត្រូវរកលុយដោយរបៀបណា ក្រៅអំពីកាប់អុស ឈើលក់ជាអុសម៉ែត្រដែលធ្វើឲ្យកាន់តែវាលទៅ។ ហេតុអ្វី ប្រជាជនមិនយល់។ គាត់មិនយល់ពីបញ្ហាដែលកើតឡើងបន្ទាប់ពីនោះទេ។ គាត់ដឹងតែពីប្រយោជន៍ផ្ទាល់ខ្លួន គាត់មិនគិតពីប្រយោជន៍អនាគត អញ្ចឹងក៏កាប់ព្រៃឈើ។*

អ្នកទាំងនោះជាច្រើនបានស្គាល់ពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី" ។ បន្ថែមលើការផ្សារភ្ជាប់ជាមួយការបាត់បង់ព្រៃឈើពួកគេនិយាយថា "ការប្រែប្រួលអាកាសធាតុ" ទាក់ទងនឹងការបំភាយឧស្ម័ន និងផ្សែងចេញពីឧស្សាហកម្ម និងយានយន្តៈ

*វាជារឿងម្យ៉ាងដូចជាយើងមានរោងចក្រក៏ច្រើនបញ្ចេញឧស្ម័ន ម្យ៉ាងទៀតព្រៃឈើកាន់តែអស់កាប់ទៅកាន់តែវាលដល់អញ្ចឹងតាមគំនិតរបស់ខ្ញុំដោយសារក្តៅខ្លាំងអស់ព្រៃឈើហើយរោងចក្រជាចំហាយឧស្ម័នក៏ច្រើន។*

អ្នកដទៃទៀតពន្យល់អំពីការប្រែប្រួលធាតុអាកាសខុសពីនេះ៖

*វាក្តៅខ្លាំងឡើងនៅពេលកម្តៅផែនដីកើនឡើង។ ខ្ញុំគិតថាវាធ្វើឲ្យផែនដីស្ងើងទៅៗ វាអាចផ្ទុះមកចេញជាចំហាយ តែខ្ញុំមិនប្រាកដពីរឿងនេះ។ ពួកគេនិយាយថាផែនដី និង ព្រះអាទិត្យខិតជិតគ្នាស្ទើរតែប៉ះគ្នា។ ដូចនេះ អ្នកវិទ្យាសាស្ត្របានធ្វើការបំបែក ឬ ក៏ផែនដីអាចផ្ទុះ...ខ្ញុំមិនប្រាកដទេរឿងហ្នឹង។ ខ្ញុំគ្រាន់តែឮតាមការផ្សាយរបស់វិទ្យុ។ ខ្ញុំមិនដែលទៅកន្លែងទាំងនោះទេ។*

ប្រធានភូមិមួយរូបពិពណ៌នាអំពីការមិនសប្បាយចិត្តដែលកើតមានឡើងនៅក្នុងសហគមន៍ ដោយសារពុំមានព័ត៌មានគ្រប់គ្រាន់អំពីមូលហេតុនៃការប្រែប្រួលធាតុអាកាសៈ

*ខ្ញុំមិនដឹងរកព័ត៌មានបែបនេះនៅឯណាទេ ប៉ុន្តែចង់ស្វែងយល់ដែរ។ ខ្ញុំមិនដឹងទៅសួរពីកន្លែងណាឲ្យដឹងពីការប្រែប្រួលធាតុអាកាសហ្នឹងថាក្តៅមូលហេតុអ្វីឲ្យច្បាស់លាស់។ ចង់ដឹងមិនត្រឹមតែខ្ញុំទេ អ្នកភូមិខ្ញុំក៏ចង់ដឹងច្រើនដែរ។ ដូចខ្ញុំបានរៀបរាប់ជូនលោកគ្រូថាកម្តៅ និង ធាតុអាកាសដែលប្រែប្រួលពីត្រជាក់ទៅក្តៅនេះនាំឲ្យមានបញ្ហានៅស្រុកយើង។...វាប៉ះពាល់ដល់សត្វធាតុ ដល់ដំណាំដែលដាំដុះហើយ។ អញ្ចឹងគាត់មានការបារម្ភដែរហើយចង់ដឹងពីមូលហេតុដែលក្តៅ ចង់ដឹងថាក្តៅពីមូលហេតុអ្វី។ ប្រសិនបើគេដឹងថាលោកគ្រូ បង្កើតកម្តៅនោះ លោកគ្រូប្រហែលជាអាចឈរជើងមិនបានទេ។*

ក្រៅពីផលប៉ះពាល់មកលើការចិញ្ចឹមជីវិតដែលពឹងផ្អែកលើកសិកម្មនិងការផលិតស្បៀងប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យពោលថាការប្រែប្រួលធាតុអាកាសមានផលប៉ះពាល់មកលើសុខភាពរបស់សហគមន៍របស់ពួកគាត់។

*ការប្រែប្រួលអាកាសធាតុធ្វើឲ្យសុខភាពចុះខ្សោយតាមរយៈជម្ងឺ និងតាមរយៈការខ្វះខាតខាងជីវភាព។ យ៉ាងម៉េចបានជាដូចនេះ? ពីព្រោះដល់ពេលប្រែប្រួលអព្ញឹងទៅយើងកំណត់រដូវកាលមិនបាន យើងដាំដុះអត់ត្រូវតាមស្តង់ដារខែ ថ្ងៃរបស់វា។ រដូវស្រូវប្រមូលផលបែរជាអត់មានភ្លៀងធ្វើឲ្យស្ងួត ដល់រដូវដាំដុះវាត្រូវជាជន់លិចវិញ។ នៅពេលយើងខ្វះទឹក ទឹកតិចយើងប្រើទឹកសន្សំសំចៃ។ ប្រសិនបើយើងមិនបានមើលគុណភាពឲ្យដិតដល់ទេ យើងផឹកទឹកដែលមានមេរោគ នោះយើងនឹងរាក។*

ការព្រួយបារម្ភអំពីសន្តិសុខស្បៀង ក៏ត្រូវបានលើកឡើងជាញឹកញាប់ផងដែរ។

*សព្វថ្ងៃនេះ បើនិយាយពីការខ្វះស្បៀង ប្រជាជននៅភូមិនេះក៏មិនមែនជាអ្នកមានប៉ុន្មានដែរ អ្នកខ្លះក៏ខ្វះស្បៀងចាប់ពីខែនេះទៅហើយ។*

អ្នកទាំងនេះជាច្រើនពោលថាភាពរាំងស្ងួតមានផលប៉ះពាល់មកលើការសិក្សារបស់សិស្ស

*ប៉ះការប្រែប្រួលអាកាសធាតុដូចជាក្តៅ ធ្វើជារាំងស្ងួតដល់ពេលអព្ញឹងម៉ែឪក្មេងលោកភ័យ ដល់ពេលហ្នឹង ទាញកូនឲ្យជួយ ដូចជាជួយយកម៉ាស៊ីន និងយកសំភារៈផ្សេងៗដើម្បីអូសទាញទឹកដាក់ស្រែ។ ខ្ញុំចំណាំមើលកាលពីនៅពេលច្រូតកាត់ ក្មេងនៅស្រុកខ្ញុំទៅរៀនមិនសូវបាន១០០ភាគរយទេ ដោយមូលហេតុគាត់ធ្វើស្រែខ្វល់តែជាមួយទឹក*

បើទោះជាពួកគេ មានការព្រួយបារម្ភបែបនេះក៏ដោយ ប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យជាច្រើនពោលថាពួកគេ និងសហគមន៍ មិនដឹងថាធ្វើបែបណាឡើយ ដើម្បីឆ្លើយតបនឹងការប្រឈមបង្កដោយធាតុអាកាសៈ

*គាត់ស្រែកថាអាកាសធាតុក្តៅ ប៉ុន្តែមិនដឹងត្រូវកាត់បន្ថយយ៉ាងណា ហើយត្រូវការពារយ៉ាងម៉េច។ ពួកគាត់គ្រាន់តែទទួលក្រមា ឬ ឆ័ត្រដើម្បីការពារកម្តៅ។*

ការឆ្លើយតបនានាដែលបានលើកឡើងទំនងជាទាក់ទងនឹងការគ្រប់គ្រងទឹក។

*ឆ្នាំនេះប្រជាជនដែលគ្មានអណ្តូងខំជីកអណ្តូងចំនួន ២ ឬ ៣ ដើម្បីទប់ទល់ការប្រែប្រួលអាកាសធាតុ គេប្រើតាមគ្រួសារ ហើយអណ្តូងនឹងវាអត់រីងទេ។ គេបានជីកប្រឡាយដើម្បីយកទឹក ដើម្បីទប់ទល់ភាពរាំងស្ងួត។*

នៅពេលសួរអំពីធនធានណាខ្លះ ដែលអាចជួយពួកគេដើម្បីធ្វើការឆ្លើយតប ប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យភាគច្រើនពោលថា ពួកគេត្រូវការជីកសិកម្ម ព័ត៌មានអំពីរបៀបកែលម្អបច្ចេកទេសកសិកម្ម ទំនប់ ប្រឡាយទឹក និងប្រភពទឹកដែលកែលម្អឱ្យប្រសើរជាងមុន ផ្លូវថ្នល់ល្អជាងមុន និងព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ។

ប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យភាគច្រើន រំពឹងថារដ្ឋាភិបាល នឹងផ្តល់ព័ត៌មានដល់ពួកគេ អំពីប្រធានបទនៃការប្រែប្រួលអាកាសធាតុៈ

*ខ្ញុំមានគោលគំនិត និង អារម្មណ៍ដោយខ្លួនឯងថាវាចេះតែប្លែកទៅៗ ប៉ុន្តែវាមិនចេញថា មានវិធីអ្វីដើម្បីទប់ស្កាត់បាន។ ចង់...រដ្ឋាភិបាលប្រាប់ឲ្យបានច្បាស់ៗដើម្បីឲ្យខ្ញុំជម្រាបប្រជាជនឲ្យបានដឹង។*

*ខ្ញុំចង់បានឲ្យរដ្ឋាភិបាលដែលដឹកនាំរដ្ឋសព្វថ្ងៃហ្នឹង ធ្វើយ៉ាងម៉េចផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋបានដឹងថា សព្វថ្ងៃហ្នឹង នៅក្នុងប្រទេសវាក្តៅខុសប្លែកដោយមូលហេតុអ្វី។ ឲ្យប្រជាជនមានជំនឿថាក្តៅបែបនេះ មកពីឧស្ម័នផ្ទះកញ្ចក់ ឬ ក៏អស់ព្រៃឈើ។ ឲ្យរដ្ឋាភិបាលប្រាប់ពាក្យពិតដល់ប្រជាជន។*

មានតម្រូវការយ៉ាងច្បាស់លាស់នូវព័ត៌មាន អំពីការប្រែប្រួលអាកាសធាតុនៅថ្នាក់ភូមិ ដែលអ្នកដឹកនាំតាមមូលដ្ឋានបច្ចុប្បន្ន ពុំដឹងអ្វីសោះ អំពីការឆ្លើយតបរបស់រដ្ឋាភិបាល ទៅនឹងការប្រែប្រួលអាកាសធាតុៈ

*ខ្ញុំគិតថារាជរដ្ឋាភិបាលកំពុងរកដំណោះស្រាយប៉ុន្តែខ្ញុំមិនដឹងថាគាត់កំពុងធ្វើអ្វីទេ។*

ប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យជាច្រើន ស្នើថារដ្ឋាភិបាលគួរតែធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយ ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការប្រែប្រួលអាកាសធាតុជាសាធារណៈ។

*ខ្ញុំជឿថា មានរាជរដ្ឋាភិបាលដែលលោក ដាក់ភ្នាក់ងារផ្សព្វផ្សាយ ដូចនេះពួកខ្ញុំនឹងបានជ្រាបទៅតាម។ បើសិនមិនអាចមកដល់មូលដ្ឋាន គេអាចធ្វើជាពាណិជ្ជកម្មតាម ទូរទស្សន៍ វិទ្យុដែលធ្វើឲ្យប្រជាជនលោកបានដឹង។*

## បុគ្គលដែលមានប្រជាប្រិយភាព

ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ មានលក្ខណៈចម្រុះនៅក្នុងក្រុមនេះ។ ការពន្យល់របស់បុគ្គលដែលមានប្រជាប្រិយភាព អំពីការប្រែប្រួលអាកាសធាតុ ផ្តោតលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ជាជាងមូលហេតុរបស់វា។ សេចក្តីលំអិតអំពីការពន្យល់របស់បុគ្គលដែលមានប្រជាប្រិយភាព បង្ហាញពីការយល់ខុស ជាសំខាន់ខ្លះៗ។ បុគ្គលដែលមានប្រជាប្រិយភាពទាំងអស់ ដឹងថាការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាដែលទាក់ទងនឹងផលវិបាកជាសកល។ ទោះជាយ៉ាងណាក៏ដោយ ចំណេះដឹងអំពីវិសាលភាពនយោបាយ នៃបញ្ហានេះមានតិចតួចណាស់។ លក្ខណៈដោយឡែកសម្រាប់ក្រុមនេះ គឺគេជឿថាការប្រាស្រ័យទាក់ទង អំពីការប្រែប្រួលអាកាសធាតុគួរតែប្រើប្រាស់ "វិធីដែលស្តាប់ទៅគួរឲ្យភ័យខ្លាច" ដើម្បីបញ្ចុះបញ្ចូលប្រជាជនអំពីសារៈសំខាន់នៃបញ្ហានេះ។

បុគ្គលដែលមានប្រជាប្រិយភាព ដែលបានសម្ភាស សុទ្ធតែបានស្គាល់ពាក្យ "ការប្រែប្រួលអាកាសធាតុ" ។ ពួកគេពន្យល់ពាក្យនេះ ដោយយោងទៅការប្រែប្រួលទឹកភ្លៀង និងកំណើនសីតុណ្ហភាព និងផលប៉ះពាល់នៃកត្តាទាំងនេះ មកលើការដាំដំណាំ និងសុខភាពនៅកម្ពុជា។ ពួកគេក៏បង្ហាញពីទំនាក់ទំនងនៃពាក្យនេះ ជាមួយគ្រោះធម្មជាតិផងដែរ ទាំងនៅក្នុង និងនៅក្រៅប្រទេសៈ

*វាទាក់ទងជាមួយរដូវមិនទៀង ជាមួយធាតុអាកាសកាន់តែក្តៅ និងទាក់ទងជាមួយគ្រោះធម្មជាតិ ដូចជាគ្រោះធម្មជាតិ ដូចជាគ្រោះរលកយក្សស៊ូណាមី។ ពីមុនមកយើងមានដែរ ប៉ុន្តែវាមិនធ្ងន់ធ្ងរដូចឥឡូវនេះទេ ជាឧទាហរណ៍ ប្រទេសខ្លះដែលមិនដែលមានរញ្ជួយដី ប៉ុន្តែឥឡូវមានហើយ។*

ទាំងអស់គ្នាសុទ្ធតែបានឮពាក្យ "ការឡើងកម្តៅផែនដី" បើទោះជាពួកគេមិនសូវយល់ច្បាស់ពីអត្ថន័យ និងការពាក់ព័ន្ធសម្រាប់កម្ពុជាក៏ដោយ។ បុគ្គលដែលមានប្រជាប្រិយភាពម្នាក់ពន្យល់ថា គាត់មិនហ៊ានអះអាងទេ អំពីបាតុភូតនេះ។

*បងមិនសូវយល់ច្បាស់ពីបញ្ហាហ្នឹង បើគេនិយាយ មិនដឹងថាជាពាក្យចចាមអារាមឬយ៉ាងណាមួយនោះទេ។ គេថា ផែនដីយើងនឹងឡើងកម្តៅ ហើយប៉ះពាល់ដល់អនាគត ពេលក្តៅខ្លាំង មិនដឹងថាមកពីមូលហេតុអ្វីដែរ។...នៅពេល ខ្ញុំទៅសហរដ្ឋអាមេរិក ខ្ញុំឃើញតាមទូរទស្សន៍ មានការផ្សព្វផ្សាយពីការរលាយផ្ទាំងទឹកកក យ៉ាងឆាប់រហ័សដែល នេះជាការព្រួយបារម្ភរបស់ពិភពលោក។ ទោះជាយ៉ាងណា យើងមិនទាន់ជឿជាក់ទាំងស្រុងទេ ប៉ុន្តែទូរទស្សន៍បាន ផ្សព្វផ្សាយអញ្ចឹង ថាបើសិនជារលាយលឿនយ៉ាងហ្នឹង វាធ្វើឲ្យប៉ះពាល់ដល់ពិភពលោក។ មិនថាសហរដ្ឋអាមេរិក ឬ ប្រទេសជឿនលឿន ក៏ជួបមហន្តរាយនេះ ប៉ុន្តែមិនដឹងថាព័ត៌មានហ្នឹងច្បាស់ប៉ុណ្ណានោះទេ។*

គ្មានអ្នកណាម្នាក់យល់ពាក្យ "ផលផ្ទះកញ្ចក់ឡើយ" ។

ការពន្យល់របស់បុគ្គលដែលមានប្រជាប្រិយភាព អំពីការប្រែប្រួលអាកាសធាតុ បានផ្តោតតែលើ*ផលប៉ះពាល់* នៃការប្រែប្រួលអាកាសធាតុ ជាងមូលហេតុ។ នៅពេលសាកសួរជាបន្ត អំពីមូលហេតុ ពួកគេបង្ហាញពីការជាប់ពាក់ព័ន្ធនៃការប្រែប្រួលអាកាសធាតុ ជាមួយការអភិវឌ្ឍ។ អ្នកទាំងនេះស្ទើរតែទាំងអស់គ្នា ពោលថាភាគច្រើននៃការទទួលខុសត្រូវ ស្ថិតនៅជាមួយប្រទេសជឿនលឿន ដោយសារតែការអភិវឌ្ឍឧស្សាហកម្មមានទំហំធំ និងចំនួនប្រជាពលរដ្ឋមានចំនួនច្រើន។

សេចក្តីលម្អិត អំពីការពន្យល់របស់បុគ្គលដែលមានប្រជាប្រិយភាព បង្ហាញអំពីការយល់ខុសខ្លះៗ។ ការប្រែប្រួលអាកាសធាតុ ច្រើនតែត្រូវបានដាក់បញ្ចូលគ្នា ជាមួយការរេចរឹលបរិស្ថានជាទូទៅ ដោយយោងទៅទម្លាប់អនុវត្តប្រកបដោយគ្រោះថ្នាក់ដូចជាការនេសាទត្រី[៨៦] និងការដុតភ្លើងនៅតាមផ្ទះ។ ការប្រែប្រួលធាតុអាកាស ជួនកាលមានការទាក់ទងនឹង ការស្ងើងជាងមុន និងការធ្លុះធ្លាយ "ស្រទាប់"មួយដែលសំដៅលើការធ្លុះធ្លាយស្រទាប់អូហ្សូន បើទោះជាអូហ្សូនមិនត្រូវបានកត់សម្គាល់ជាឈ្មោះក៏ដោយ។

*ប្រជាជនបានធ្វើអ្វីមួយ ដែលធ្វើឲ្យស្រទាប់នោះ វាខូចនៅពេលដែលថ្ងៃចាំងមក គឺដោយផ្ទាល់មកកាន់ផែនដី កាលពីមុនផែនដីមានស្រទាប់ការពាររបស់វា។*

អ្នកខ្លះគិតថា ការបង្កើតផ្សែងនាំឱ្យមានការប្រែប្រួលធាតុអាកាស។

*វាក្តៅដោយសាររោងចក្រច្រើនផ្សែងម៉ាស៊ីនឡានច្រើន...តាមការដឹងកម្តៅផែនដីដូចខ្ញុំបាននិយាយជួនកាលនៅស្រុកក្រៅឬមនុស្សមិនបានរៀនសូត្រអីមើលតាមជាក់ស្តែងដូចជាឃើញម៉ាស៊ីនផ្សែងអីទៅលើផ្សែងនឹងវាបាំងនឹងពពកវាបានកំសួលចុះមកក្រោមវិញ។*

ផ្សែងទំនងជាអាចយល់បានថា បង្កឱ្យមានការប្រែប្រួលធាតុអាកាស នៅតាមកន្លែងនានា។

*នៅស្រុកគេ សំបូររោងចក្រ និងផ្សែងច្រើន ប៉ុន្តែប្រទេសយើងមានផលប៉ះពាល់តិច បើប្រៀបធៀបជាមួយប្រទេសទាំងនោះ។*

---

[៨៦] ការនេសាទត្រីដោយប្រើប្រាស់អគ្គិសនីដើម្បីចាប់ត្រី។

បុគ្គលដែលមានប្រជាប្រិយភាពច្រើនជាងម្នាក់ បានលើកស្នើថា ការប្រែប្រួលធាតុអាកាសអាច ជាលទ្ធផលដែលផែនដី និងព្រះអាទិត្យ កាន់តែខិតទៅជិតគ្នា។

បុគ្គលដែលមានប្រជាប្រិយភាពទាំងអស់ដឹងថា ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាមួយដែលមានផលវិបាកជាសកល។ ទោះជាយ៉ាងណាក៏ដោយ ចំណេះដឹងអំពីទិដ្ឋភាពនយោបាយ នៃបញ្ហានេះនៅមានកម្រិតទាប។ បុគ្គលដែលមានប្រជាប្រិយភាពមួយចំនួនដឹងអំពី "ការប្រជុំអន្តរជាតិ" ដើម្បីពិភាក្សាអំពីការប្រែប្រួលអាកាសធាតុ ប៉ុន្តែការប្រជុំនោះមិនត្រូវបានឱ្យឈ្មោះឡើយ។ មានការយល់ដឹងតិចតួចអំពីបញ្ហានយោបាយសំខាន់ៗ។ បុគ្គលដែលមានប្រជាប្រិយភាពមួយរូប ដឹងថាការពិភាក្សាអន្តរជាតិមានទាក់ទងនឹង "កម្រិតនៃការបំភាយ" អ្នកផ្សេងទៀតគិតថា វាទាក់ទងនឹងការផលិត "សារធាតុគីមីនិងអាវុធ" ដែលគាត់គិតថា ត្រូវបានគេរកឃើញថា បានបង្កឱ្យមានការប្រែប្រួលអាកាសធាតុ។

ទាំងអស់គ្នាពោលថា ពួកគេបានឮពាក្យ "ការប្រែប្រួលអាកាសធាតុ" តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ជាពិសេសតាមទូរទស្សន៍។ ភាគច្រើនពោលថា ពួកគេបានមើលទូរទស្សន៍អន្តរជាតិ នៅក្នុង និងនៅក្រៅប្រទេស ហើយប៉ុស្តិ៍អន្តរជាតិ ត្រូវបានកត់សម្គាល់ជាញឹកញាប់បំផុត ថាជាប្រភពមួយនៃព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ។

បុគ្គលដែលមានប្រជាប្រិយភាព មានចំណាប់អារម្មណ៍លើតួនាទី ដែលប្រព័ន្ធផ្សព្វផ្សាយអនុវត្ត នៅក្នុងការបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ។ ពួកគាត់បានលើកសំណើឲ្យមានវិធីនានា ដែលក្នុងនោះប្រព័ន្ធព័ត៌មានអាចផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ ដែលគួរតែធ្វើឱ្យប្រជាជន "ភ័យខ្លាច" ដើម្បីឱ្យមានឥទ្ធិពលៈ

*ខ្ញុំសំណូមពរ ឲ្យរកពាក្យដែលធ្ងន់ជាងនេះ ដែលធ្វើឲ្យពួកគាត់មានអារម្មណ៍ភ័យខ្លាច។*

*យើងអាចធ្វើកម្មវិធីចាក់ផ្សាយតាមទូរទស្សន៍។...ប្រជាជនយើងបានដឹង នោះវាល្អហើយ អញ្ចឹងគាត់ខ្លាច ពួកគាត់នឹងស្វែងរកដំណោះស្រាយ ព្រោះខ្លាចប៉ះពាល់ដល់កូនគាត់ជំនាន់ក្រោយ អស់ដើមឈើ។ យើងយករូបមួយចំនួនមក យើងមិនចង់បន្លាចទេ ព្រោះការផ្សាយមួយចំនួនមិនអវិជ្ជមានទាំងអស់នោះទេ ប៉ុន្តែបើយើងមិនប្រើវិធីហ្នឹង យើងមិនបានផលឡើយ។*

យោបល់ទាំងនេះបង្ហាញពី ចំណុចមួយផ្សេងទៀត ដែលបុគ្គលមានប្រជាប្រិយភាពច្រើនតែបានធ្វើៈ ភាពចាំបាច់ដើម្បីសង្កត់ធ្ងន់លើឥទ្ធិពល នៃការខូចខាតខាងបរិស្ថាន មកលើមនុស្សជំនាន់ក្រោយៗ

*ភាពសឹករេចរឹលនៃធម្មជាតិ មានពីមួយតំណទៅមួយតំណ។*

បុគ្គលដែលមានប្រជាប្រិយភាពមួយរូប យោងទៅតួនាទីរបស់ព្រះធម៌អំពី *កម្ម* ថាអាចមាននាទី ក្នុងការលើកទឹកចិត្តប្រជាជនឱ្យថែរក្សាបរិស្ថាន។

*ខ្ញុំជឿលុះត្រាតែយើងបង្ហាញថា នេះងាប់ឥឡូវហ្នឹង។ ដូចព្រះពុទ្ធបានដាក់ច្បាប់ថា កុំវាយគេប្រយ័ត្នគេឈឺ អាហ្នឹងថាខ្ញុំឈប់ឬទេ ផ្លាស់ប្តូរការគិតឬអត់អត់ទេ។ គាត់មានទ្រឹស្តីកម្មផលមួយថា កុំវាយគេជាតិក្រោយគេវាយអ្នកវិញឬពៀរដល់កូន អញ្ចឹងគេខ្លាចបំផុត គឺខ្លួនឯងមនុស្សអាត្មានិយមទាំងអស់។ ដូចនេះ បើគាត់ដឹងថាខ្លួនគាត់នឹងរងផលអាក្រក់បំផុតពីអ្វីមួយ គឺគាត់ត្រូវឈប់។*

បុគ្គលដែលមានប្រជាប្រិយភាពខ្លះ គូសបញ្ជាក់អំពីដែនកំណត់នៃការផ្សព្វផ្សាយព័ត៌មានពីមុនមក អំពីបរិស្ថាន។ យោបល់របស់គាត់ ឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់លើការបាត់បង់ព្រៃឈើ ដូចអ្នកឆ្លើយសំខាន់ៗ និងសាធារណជនៈ

> *ខ្ញុំមិនឃើញមានអង្គការណាមួយ ដែលផ្តល់ព័ត៌មានជាលម្អិតដល់ប្រជាជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ គេគ្រាន់តែនិយាយថាចូរនាំគ្នាថែរក្សាបរិស្ថានទាំងអស់គ្នា គេគ្រាន់តែនិយាយបែបនេះ... អ្វីខ្លះជាបរិស្ថាន ធ្វើយ៉ាងដូចម្តេចដើម្បីថែបរិស្ថាន គាត់អត់យល់។ គាត់យល់ថាមានតែដាំដើមឈើ គាត់យល់តែមួយចំនុចហ្នឹង គាត់អត់ខ្វល់ពីរឿងផ្សេងៗទៀតទេ គាត់មិនខ្វល់គាត់ចាក់សាំងបង្ហុយផ្សែង និងស្អីៗផ្សេងទៀតផង។*

## តំណាងមកពីវិស័យឧស្សាហកម្ម

> តំណាងពីវិស័យឧស្សាហកម្ម ស្ថិតក្នុងចំណោមអ្នកដែលដឹងច្រើនជាងគេបំផុត អំពីបញ្ហានេះ ដោយអ្នកទាំងនេះជាច្រើនសំដៅទៅលើផលផ្ទះកញ្ចក់ និងការបំភាយកាបូន នៅក្នុងពេលជាមួយគ្នា។ អ្នកទាំងនេះភាគច្រើនពោលថាពួកគាត់បានឮពាក្យនានាពីប្រព័ន្ធព័ត៌មាន ជាពិសេសកម្មវិធីព័ត៌មាន ពីប៉ុស្តិ៍នានានៅកម្ពុជានិងអន្តរជាតិ។ ចំណែកអ្នកដទៃទៀតពន្យល់អំពីគោលគំនិតនៃការប្រែប្រួលអាកាសធាតុ ធៀបទៅនឹង *ផលប៉ះពាល់* របស់វាមកលើប្រទេសនេះ។ តំណាងវិស័យឧស្សាហកម្ម ទំនងជាផ្សារភ្ជាប់ប្រធានបទនេះទៅនឹងសំណួរអំពី*មូលហេតុ* នៃបញ្ហានេះ ជាពិសេសការប្រើប្រាស់ថាមពល ហើយពួកគេដឹងថា ការប្រែប្រួលអាកាសធាតុពិភពលោក បង្កឲ្យមានការប្រឈម មកលើវិស័យឧស្សាហកម្ម។

តំណាងពីវិស័យឧស្សាហកម្ម ស្ថិតក្នុងចំណោមអ្នកដែលបានដឹងច្រើនបំផុតអំពីបញ្ហានេះ។ តំណាងទាំងអស់ពីវិស័យឧស្សាហកម្មមានការយល់ដឹងអំពីពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី"។ អ្នកទាំងនេះមួយចំនួនកត់សម្គាល់ពាក្យ "ផលផ្ទះកញ្ចក់" ឬ "ឧស្ម័នផ្ទះកញ្ចក់" នៅក្នុងពេលជាមួយគ្នាៈ

> *ការប្រែប្រួលអាកាសធាតុ គឺការឡើងកម្តៅធាតុអាកាស បើភាសាអង់គ្លេសហៅថា Global warming (ការឡើងកម្តៅផែនដី)។ មូលហេតុធំរបស់វា គឺផលផ្ទះកញ្ចក់...វាចេញពីកាបូនឌីអុកស៊ីត ដែលចេញពីរថយន្តនិងឧស្សាហកម្មទាំងអស់ហ្នឹង...និយាយឲ្យចំគឺចេញពីអំពើរបស់មនុស្ស។*

ភាគច្រើនពោលថា ពួកគាត់បានឮពាក្យទាំងនេះ ពីប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសកម្មវិធីព័ត៌មាន នៅតាមប៉ុស្តិ៍ផ្សព្វផ្សាយកម្ពុជា និងអន្តរជាតិ។ ពួកគេសុទ្ធតែបានផ្សារភ្ជាប់ រវាងពាក្យទាំងនេះ និងការប្រើប្រាស់ថាមពល និងតាមរបៀបខុសៗគ្នា ទៅនឹងការអភិវឌ្ឍឧស្សាហកម្មវិទ្យាសាស្ត្រ និងសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ ពួកគេមានសមត្ថភាពខុសគ្នាយ៉ាងច្រើន នៅក្នុងការពន្យល់ពាក្យទាំងនេះ។ មេដឹកនាំវិស័យឧស្សាហកម្មខ្លះ មានការយល់ដឹងខាងបច្ចេកទេសបានល្អអំពីមូលហេតុនៃការប្រែប្រួលអាកាសធាតុ ដោយសំដៅលើការបំភាយឧស្ម័នកាបូនិក និងឧស្ម័នផ្ទះកញ្ចក់។ អ្នកដទៃទៀតអធិប្បាយបាតុភូតនេះទាក់ទងនឹងការបំពុលជាទូទៅ ដោយប្រើប្រាស់ពាក្យដែលមិនសូវជាក់លាក់ដូចជា "ឧស្ម័នពុល"។ អ្នកទាំងនេះមួយចំនួនតូច បង្ហាញពីការទាក់ទងនៃការប្រែប្រួលអាកាសធាតុ ទៅនឹងការធ្លុះធ្លាយស្រទាប់អូហ្សូន ប៉ុន្តែប្រការនេះមិនសូវបង្ហាញច្បាស់លាស់ ដូចក្នុងចំណោមក្រុមផ្សេងទៀត ដែលបានសម្ភាសសម្រាប់ការស្រាវជ្រាវនេះឡើយ។

ក្នុងពេលដែលបុគ្គលសំខាន់ៗជាច្រើន ពន្យល់គោលគំនិតនៃការប្រែប្រួលអាកាសធាតុ ទាក់ទងនឹង*ផលប៉ះពាល់របស់វា* មកលើប្រទេសកម្ពុជាតំណាងពីវិស័យឧស្សាហកម្ម ផ្សារភ្ជាប់ប្រធានបទនេះទៅនឹងសំណួរអំពី*មូលហេតុ* នៃបញ្ហាជាពិសេសការប្រើប្រាស់ថាមពលៈ

*ដោយសារអាកាសធាតុក្តៅខ្លាំង យើងត្រូវប្រើថាមពលខ្លាំង វារឹតតែជះឥទ្ធិពលអាក្រក់ដល់បរិស្ថានទៀត ដោយសារយើងប្រើប្រាស់ថាមពល យើងត្រូវទាញយកថាមពលឥន្ទនៈ ហើយមួយទៀតគឺការបញ្ចេញឧស្ម័នទៅក្នុងបរិយាកាស។ សព្វថ្ងៃខ្ញុំសង្កេតឃើញសង្គមយើងក៏ដូចជាសកលលោក យកចិត្តទុកដាក់លើការប្រើប្រាស់ថាមពលកកើតឡើងវិញ។*

តំណាងទាំងអស់មកពីឧស្សាហកម្មដឹងថា វិស័យឧស្សាហកម្មលើពិភពលោក មានការពាក់ព័ន្ធជាមួយការប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះតំណាងពីវិស័យឧស្សាហកម្មភាគច្រើនពោលថា ឧស្សាហកម្មរបស់កម្ពុជា គួរតែត្រូវបានគិតគូរអំពីបញ្ហាពាក់ព័ន្ធទាំងនេះៈ

*ក្រសួងឧស្សាហកម្ម ក៏ត្រូវមានការគិតពីការបំរែបំរួលពីឧស្សាហកម្មធុនធ្ងន់។*

ពួកគេគិតអំពីវិធីនានា នៃការប្រើប្រាស់ថាមពលតិចជាងមុន និងការប្រើប្រាស់ថាមពលខុសពីមុន។

*ខ្ញុំបានរៀន និងអនុវត្តនៅក្នុងក្រុមហ៊ុនរបស់ខ្ញុំ។ ក្រុមហ៊ុនខ្ញុំជាក្រុមហ៊ុនគំរូក្នុងការអនុវត្តគម្រោង...គម្រោងឲ្យឈ្មោះថា clean of production (ផលិតកម្មស្អាត) ក្នុងគោលបំណងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ តាមរយៈការកាត់បន្ថយការប្រើប្រាស់វត្ថុធាតុដើមខ្ជះខ្ជាយ និងការខូចខាតវត្ថុធាតុដើម ដែលយើងយកទៅបោះចោល ព្រោះវាប៉ះពាល់បរិស្ថាន។ ការហុយផ្សែងចោលចេញពីម៉ាស៊ីនភ្លើង និងម៉ាស៊ីនផ្សេងៗ ជាប្រភពនៃឧស្ម័នផ្ទះកញ្ចក់។*

ដោយសារឧស្សាហកម្មរបស់កម្ពុជា មានចំណាប់អារម្មណ៍រួចហើយទាក់ទិននឹងការប្រើប្រាស់ថាមពល ដូច្នេះវាអាចមានសក្តានុពលក្នុងការទាញយកវិស័យនេះឲ្យចូលរួមនៅក្នុងសកម្មភាពនានា ដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

*ប៉ុន្តែខ្ញុំប្រើ Solar (ថាមពលពន្លឺព្រះអាទិត្យ) តាំងពីឆ្នាំ១៩៩៩។ Solar ខ្ញុំប្រើ 50 KWsនៅដើររាល់ថ្ងៃហ្នឹង។ Biogas (ជីវឧស្ម័ន) ដើរដោយថាមពលលាមកសត្វ 50 KWs ដែរបូកបញ្ចូលគ្នា 112 KVA ដើររាល់ថ្ងៃ។*

ពួកគេដឹងថា ការប្រែប្រួលអាកាសធាតុ បង្កឱ្យមានការប្រឈមជាអន្តរជាតិ មកលើឧស្សាហកម្ម។

*តាមខ្ញុំដឹងមក សូម្បីតែសហរដ្ឋអាមេរិកដែលមានភាពចម្រូងចម្រាស់ជាមួយនឹងការប្រែប្រួលអាកាសធាតុ និងឧស្សាហកម្ម ក៏មិនកាត់បន្ថយទេ គឺគេកែតម្រូវវិញ...គេហៅថាកាបូនក្រេឌីត។ អញ្ចឹងប្រទេសធំៗទាំងអស់ហ្នឹងយកមូលនិធិដើម្បីទៅជួសជុលផលប៉ះពាល់ទាំងអស់នោះវិញ។*

ផលប៉ះពាល់ ក៏ដូចជាមូលហេតុ ត្រូវគេយល់បាននៅក្នុងបរិបទអន្តរជាតិ។ ភាគច្រើនមានអារម្មណ៍ថា កម្ពុជាមិនរងឥទ្ធិពលធ្ងន់ធ្ងរ ដោយសារការប្រែប្រួលអាកាសធាតុដូចនៅក្នុងប្រទេសដទៃឡើយៈ

*ក៏មិនទាន់មានព្ញព័ត៌មាន ដែលថាប្រទេសកម្ពុជាទទួលរងគ្រោះ ដោយសារកម្ដៅកើនឡើងក៏អត់មាន។ អញ្ចឹងវាអត់មានឥទ្ធិពលលើយើងទេ មិនដូចជានៅប្រទេសឥណ្ឌាមើលឃើញថ្មីៗ គឺប្រជាជនស្លាប់ជាច្រើនដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។*

នៅកម្ពុជា តំណាងពីវិស័យឧស្សាហកម្ម សង្កត់ធ្ងន់អំពីផលប៉ះពាល់ដែលអាចកើតមានមកលើសេដ្ឋកិច្ច ទាំងនៅកម្រិតគ្រួសារ និងនៅថ្នាក់ជាតិ។ ពួកគេផ្សារភ្ជាប់ការប្រែប្រួលអាកាសធាតុ ជាមួយកង្វះទឹក ដោយមានផលវិបាកមកលើទិន្នផលកសិកម្ម និងសមត្ថភាពរបស់ប្រជាជនដើម្បីធ្វើការ។ កង្វល់របស់ពួកគេអំពីការថយចុះនៃផលិតភាពកសិកម្មត្រូវបានបង្ហាញនៅក្នុងបរិបទនៃផលប្រយោជន៍ខាងជំនួញរបស់ពួកគេផ្ទាល់ ក៏ដូចជាការជាប់ទាក់ទងទៅនឹងការព្រួយបារម្ភអំពីសន្តិសុខស្បៀង និងការចិញ្ចឹមជីវិតរបស់ប្រជាជនកម្ពុជាក្រីក្រផងដែរ។

## *តំណាងពីប្រព័ន្ធផ្សព្វផ្សាយ*

តំណាងពីប្រព័ន្ធផ្សព្វផ្សាយ ទំនងជាមានចំណាប់អារម្មណ៍លើប្រធានបទអំពីការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះការប្រែប្រួលអាកាសធាតុ ទំនងជាបានទទួលការយកចិត្តទុកដាក់ត្រឹមតិចតួច ពីប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា និងច្រើនតែត្រូវបានចាត់ទុកថាជាបញ្ហាបរិស្ថានមួយ។ ប៉ុន្តែទាំងអស់គ្នាបានលើកឡើងថា ប្រព័ន្ធព័ត៌មានអាចដើរតួនៅក្នុងការផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ។ តំណាងពីប្រព័ន្ធព័ត៌មានចង្អុលបង្ហាញពីភាពចាំបាច់ ដើម្បីបង្ហាញរឿងរ៉ាវអំពីការប្រែប្រួលអាកាសធាតុ តាមរយៈទស្សនៈបែបថ្មី ដើម្បីផ្ដល់ឱ្យអ្នកសារព័ត៌មានទទួលនូវការបណ្ដុះបណ្ដាល អំពីប្រធានបទនេះ និងដើម្បីផ្ដល់ការណែនាំអំពីរបៀបរាយការណ៍អំពីប្រធានបទនេះ។

អ្នកឆ្លើយជាច្រើនទទួលស្គាល់ថាប្រព័ន្ធផ្សព្វផ្សាយ ដើរតួនៅក្នុងការផ្ដល់ព័ត៌មាន និងទាក់ទាញការយកចិត្តទុកដាក់របស់ប្រជាជន អំពីការប្រឈមដែលបង្កដោយការប្រែប្រួលអាកាសធាតុ។ សម្រាប់ពួកគេ តំណាងពីប្រព័ន្ធព័ត៌មានទំនងជាមានចំណាប់អារម្មណ៍លើប្រធានបទនេះ និងមានការព្រួយបារម្ភដោយសារអ្វីដែលពួកគេបានឮទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ពួកគេផ្ដល់យោបល់មួយចំនួនសម្រាប់កែលម្អរបៀបធ្វើសេចក្ដីរាយការណ៍ព័ត៌មាន។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះការប្រែប្រួលអាកាសធាតុបានទទួលការយកចិត្តទុកដាក់តិចតួចពីប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា និងច្រើនតែត្រូវបានចាត់ទុកថាជាកិច្ចការបរិស្ថានប៉ុណ្ណោះ។

ក្នុងពេលដែលបុគ្គលសំខាន់ៗពីប្រព័ន្ធផ្សព្វផ្សាយ និងបុគ្គលសំខាន់ៗមកពីវិស័យមិនមែនផ្សព្វផ្សាយ ផ្ដល់គំនិតអំពីវិធីនានាដែលប្រព័ន្ធផ្សព្វផ្សាយ អាចគាំទ្រដល់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុក៏ដោយ សក្ដានុពលរបស់ពួកគេសម្រាប់កិច្ចការនេះសព្វថ្ងៃ មានកម្រិតកំណត់ដោយសារកត្តាមួយចំនួន។

ទីមួយការប្រែប្រួលអាកាសធាតុ ទំនងជាត្រូវបានចាត់ទុកថាជាបញ្ហាបរិស្ថានតែមួយប៉ុណ្ណោះ។ យោបល់នានាពីតំណាងប្រព័ន្ធផ្សព្វផ្សាយ ដែលទាក់ទងនឹងការធ្វើសេចក្ដីរាយការណ៍ព័ត៌មាន អំពីការប្រែប្រួលអាកាសធាតុមានលក្ខណៈដោយឡែក:

*យើងមើលត្រឹមសំរាមស្ទឹងមានជ័យហ្នឹងទៅ...នេះជារឿងជាក់ស្ដែងតែម្ដង ដែលជាប់ទាក់ទងជាមួយបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។*

បើទោះជាមានការឯកភាពលើចំណាត់ថ្នាក់នេះ ឬមិនឯកភាពក៏ដោយប្រការនេះទាក់ទងនឹងការប្រឈមសំខាន់មួយផ្សេងទៀត៖ សាច់រឿងអំពីបរិស្ថាន "មិនអាចលក់បានឡើយ"

*យើងមានរឿង ៥ ឬ ៦ អញ្ចឹងអ្នកត្រួតពិនិត្យចាប់ផ្តើមធ្វើចំណាត់ថ្នាក់ព័ត៌មានដែលគេចង់ដឹងច្រើនជាងគេ។ បរិស្ថានជាបញ្ហាមួយ ហើយវានៅក្រោយគេ។ នៅពេលដែលពេញទំព័រគឺគេកាត់ចោលហើយ ទាល់តែមាននយោបាយមួយតំរូវថាស្ថាប័នត្រូវធ្វើយ៉ាងម៉េច ឬរដ្ឋមានលុយមួយកញ្ចប់ថាអ្នកកុំកាត់ ទុកម៉ោងហ្នឹងកុំផ្សាយពាណិជ្ជកម្ម។*

តំណាងខ្លះៗមកពីប្រព័ន្ធព័ត៌មានចង្អុលបង្ហាញថា គេត្រូវបណ្តុះបណ្តាលអ្នកសារព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ ដែលជាការចាំបាច់សម្រាប់ឆ្លុះបញ្ចាំង អំពីកម្រិតខុសគ្នានៃចំណេះដឹងអំពីប្រធានបទនេះនៅក្នុងចំណោមតំណាងប្រព័ន្ធព័ត៌មានដែលបានសម្ភាសសម្រាប់ការស្រាវជ្រាវនេះ។ អ្នកសារព័ត៌មានក៏ទំនងជាបាត់បង់ឱកាសនានាដើម្បីបង្កើតឱ្យមានចំណងទាក់ទងរវាងប្រធានបទនានាដែលពួកគេរាយការណ៍នឹងការប្រែប្រួលអាកាសធាតុផងដែរ។ ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់មួយរូបទំនងជាបាន*យោង*ទៅសារមួយអំពីការប្រែប្រួលអាកាសធាតុដែលបានពីកម្មវិធីវិទ្យុជាជាងសារជាក់លាក់:

*ថ្ងៃមួយខ្ញុំបានឮថានៅប្រទេសបារាំងគេកាត់បន្ថយការប្រើឡាន។ គេលើកទឹកចិត្តឲ្យប្រជាជនប្រើកង់។ គេមិនចង់ឲ្យប្រើឡាន ម៉ូតូ ព្រោះបញ្ចេញផ្សែងធ្វើឲ្យពុល។ ដូចនេះប្រជាជនត្រូវធ្វើបែបនេះដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ។*

តំណាងម្នាក់ពន្យល់ថាគេត្រូវការឱ្យមានគោលការណ៍ណែនាំសម្រាប់អ្នកសារព័ត៌មានអំពីការសរសេរ។

*អ្នកកាសែតត្រូវមានបច្ចេកទេសលើកិច្ចការទាំងអស់ហ្នឹង គេមានជាសំណួរគន្លឹះ គេហាមមិនឲ្យប្រើពាក្យជនរងគ្រោះដោយសារជម្ងឺអេដស៍។ គេអនុញ្ញាតឲ្យប្រើពាក្យនេះ មិនប្រើពាក្យនេះ។ ដូចគ្នានេះដែរគេក៏ត្រូវមានសំណួរគន្លឹះសម្រាប់ធ្វើការជាមួយការប្រែប្រួលអាកាសធាតុ។*

បើទោះជាមានកម្រិតកំណត់ ក្នុងការធ្វើសេចក្តីរាយការណ៍អំពីការប្រែប្រួលអាកាសធាតុ នៅក្នុងព័ត៌មានបច្ចុប្បន្ននេះក៏ដោយ តំណាងទាំងអស់មកពីប្រព័ន្ធផ្សព្វផ្សាយដែលបានសម្ភាសបានលើកស្នើឱ្យមានវិធីនានា ដែលក្នុងនោះប្រព័ន្ធផ្សព្វផ្សាយអាចគាំទ្រដល់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

អ្នកខ្លះចង្អុលបង្ហាញអំពីលទ្ធភាព ដែលប្រព័ន្ធផ្សព្វផ្សាយផ្តល់ការសង្គ្រោះជីវិតអំពីគ្រោះធម្មជាតិ:

*សម្រាប់ខ្ញុំ ខ្ញុំយល់ថាការប្រែប្រួលអាកាសធាតុដែលប៉ះទង្គិចសំខាន់បំផុត គឺសម្រាប់ប្រជាពលរដ្ឋនៅតាមតំបន់ឆ្ងាយដាច់ស្រយាល។ សម្រាប់យើងមាន website និង internet យើងបើកមើលពីធាតុអាកាស។ យើងដឹងថាថ្ងៃស្អែកឬខានស្អែកមកដល់កាត់តាមសមុទ្រហ្វីលីពីន បោកបក់តាមឡាវ និងថៃ ដូចនេះយើងមានការយល់ដឹងមានការបង្ការមុន ចុះចំណែកគាត់រស់នៅដោយមិនដឹងអ្វីគ្មានព័ត៌មាន?*

**តំណាងពីប្រព័ន្ធផ្សព្វផ្សាយ**

យោបល់មកពីអ្នកនយោបាយមួយរូបបង្ហាញថាប្រព័ន្ធផ្សព្វផ្សាយ អាចមានតួនាទីនៅក្នុងការគាំទ្រអ្នកនយោបាយ និងអ្នកដែលមានជំនាញបច្ចេកទេសអំពីការប្រែប្រួលអាកាសធាតុ ដើម្បីផ្សព្វផ្សាយតាមវិធីដែលប្រជាជនងាយស្រួលយល់៖

*ជួនកាលអ្នកជំនាញនិយាយពាក្យជ្រៅពេកធ្វើឲ្យប្រជាជនយល់មិនច្បាស់។ នេះជាហេតុអ្វីដែលតម្រូវឲ្យមានអ្នកជំនាញជាវាគ្មិន វាក៏តម្រូវឲ្យមានការចូលរួមផ្នែកនយោបាយដែរ...អ្នកបច្ចេកទេសច្បាស់ជាងអ្នកនយោបាយ ប៉ុន្តែគេអាចជួយគ្នាទៅវិញទៅមក។*

**តំណាងរដ្ឋាភិបាល**

ភាគច្រើននៃតំណាងពីប្រព័ន្ធផ្សព្វផ្សាយ ឯកភាពថាកង្វះលទ្ធភាពទទួលព័ត៌មានគឺជាឧបសគ្គសម្រាប់សហគមន៍ដែលរួមទាំងស្ត្រី និងអ្នកនៅជនបទ ក្នុងការទទួលបានព័ត៌មាន ដូច្នេះពួកគេបានលើកស្នើឱ្យមានវិធីខុសប្លែកពីមុននៅក្នុងការផ្សព្វផ្សាយ៖

*អ្វីដែលសំខាន់ដែលខ្ញុំចង់បានគឺការអប់រំចល័ត។ ឥឡូវវាបានបាត់បង់អស់រលីង។ ពីព្រោះស្ត្រីនៅក្នុងផ្ទះ លោកអត់មានពេលអានទេ ប៉ុន្តែលោកទទួលការទាក់ទាញថាគេកំពុងធ្វើអ្វី ផ្សាយអ្វី នៅខាងមុខផ្ទះរបស់ពួកលោក។*

**តំណាងពីប្រព័ន្ធផ្សព្វផ្សាយ**

ទោះបីមានភស្តុតាងដែលបង្ហាញថា ការប្រែប្រួលអាកាសធាតុច្រើនតែត្រូវបានចាត់ទុកថាជាបញ្ហាបរិស្ថានក៏ដោយ តំណាងមួយរូបពីប្រព័ន្ធផ្សព្វផ្សាយស្នើឱ្យមានការកែប្រែលើការយកចិត្តទុកដាក់

*យើងបញ្ចូលរឿងទាក់ទងជាមួយសង្គមនិងសេដ្ឋកិច្ច...។ ទាក់ទងរឿងការស្រាវជ្រាវវិទ្យាសាស្ត្រ...វាជាផ្នែកមួយរបស់ព័ត៌មានអន្តរជាតិ។*

**តំណាងពីប្រព័ន្ធផ្សព្វផ្សាយ**

អ្នកដទៃទៀតស្នើថា ការប្រែប្រួលអាកាសធាតុអាចផ្សព្វផ្សាយតាមរយៈ "ល្ខោនឬប្រលោមលោក" ហើយអ្នកដទៃថាតាមរយៈរឿងកំប្លែង។ តំណាងមួយរូបយោងទៅវិធីដែលអ្នកនិពន្ធ **នេត្រ សុភណ្ឌ** ដែលបានសរសេរអំពីការបាត់បង់ព្រៃឈើ ដើម្បីបង្ហាញអំពីសក្តានុពល ក្នុងការដោះស្រាយប្រធានបទនៃការប្រែប្រួលអាកាសធាតុ នៅក្នុងរឿងប្រលោមលោក។ តំណាងមួយចំនួនពោលថា អ្នកនាំពាក្យល្អបំផុតអំពីការប្រែប្រួលអាកាសធាតុគួរតែជា"សិល្បករ"។ តំណាងមួយចំនួនពោលថា ពួកគេមានចំណាប់អារម្មណ៍លើការប្រើប្រាស់ "មនុស្សចាស់" ជាប្រភពព័ត៌មាន ឬសាច់រឿងអំពីការប្រែប្រួលអាកាសធាតុ។

## *តំណាងពីអង្គការមិនមែនរដ្ឋាភិបាល*

តំណាងពីអង្គការមិនមែនរដ្ឋាភិបាល បានដឹងឮយ៉ាងច្បាស់អំពីការប្រែប្រួលអាកាសធាតុ។ ពួកគេទំនងជាបានយល់ដឹងអំពីពាក្យការប្រែប្រួលអាកាសធាតុ និងមិនដូចអ្នកឆ្លើយជាច្រើននោះឡើយ ពួកគេផ្តល់នូវការពន្យល់ប្រកបដោយទំនុកចិត្តអំពីមូលហេតុ និងផលវិបាក។ ពួកគេមានការបារម្ភអំពីទម្រង់នៃផលប៉ះពាល់ពីការប្រែប្រួលមកលើកសិកម្ម ធនធានទឹក និងការចិញ្ចឹមជីវិត ដែលនឹងមានឥទ្ធិពលមកលើប្រជាជនដែលងាយរងគ្រោះបំផុត។ ពួកគេមានអារម្មណ៍ថា ប្រជាជនខ្វះព័ត៌មាន និងធនធាន ដែលពួកគេត្រូវការជាចាំបាច់ដើម្បីធ្វើការឆ្លើយតប។ ពួកគេសង្កត់ធ្ងន់អំពីតម្រូវការដើម្បីឱ្យមេដឹកនាំនៅថ្នាក់ភូមិ និងឃុំ ចូលរួមក្នុងការផ្សព្វផ្សាយដល់សាធារណជនអំពីការប្រែប្រួលអាកាសធាតុ។

តំណាងភាគច្រើន មកពីអង្គការមិនមែនរដ្ឋាភិបាល គូសបញ្ជាក់អំពីភាពងាយរងគ្រោះរបស់ប្រជាជនកម្ពុជាដែលរស់នៅតាមជនបទ ដោយសារការប្រែប្រួលអាកាសធាតុ។ ពួកគេទទួលស្គាល់ថារាល់ការគំរាមកំហែងដែលមានមកលើកសិកម្ម នឹងធ្វើឲ្យមានការគំរាមកំហែងដល់ការផ្គត់ផ្គង់ស្បៀងអាហារ និងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅជនបទ:

*ភាពរាំងស្ងួតបានប៉ះពាល់ដល់ដំណាំរបស់កសិករ អាហ្នឹងយើងនិយាយតែពីផលប៉ះពាល់ផ្នែកកសិកម្មផង។ វាកាន់តែធ្ងន់ធ្ងរទៅទៀត បើនិយាយពីផលប៉ះពាល់លើអាយុជីវិតរបស់យើង។*

បុគ្គលខ្លះ បារម្ភអំពីការគ្រប់គ្រងទឹកមិនបានល្អនៅក្នុងប្រទេស ហើយបានសំដែងកង្វល់អំពីការពាក់ព័ន្ធនឹងអសន្តិសុខទឹក:

*នៅពេលខាងមុខ យើងប្រហែលជាមានជម្លោះដោយសារទឹក។...ខ្មែរមិនខ្វះទឹកទេ ទឹកមាននៅគ្រប់ទីកន្លែង។ អ្វីដែលជាបញ្ហានោះគឺ យើងខ្វះសកម្មភាពក្នុងការគ្រប់គ្រងធនធានទឹក។ យើងមានទន្លេធំដែលនៅរដូវវស្សាមានទឹកគ្រប់ទីកន្លែង។ នៅប្រទេសវៀតណាម និងថៃគេមានប្រព័ន្ធស្រោចស្រព។*

ពួកគេពោលថា ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ អាចកែប្រែរបៀបរស់នៅតាមជនបទ។

*ដោយសារការប្រែប្រួលអាកាសធាតុ បានធ្វើឲ្យនៅតាមភូមិមួយចំនួនរាំងភ្លៀង អញ្ចឹងប្រជាពលរដ្ឋមួយចំនួនត្រូវបង្ខំខ្លួនស៊ីឈ្នួលជាកម្មកររោងចក្រ ដើម្បីបានចំណូលយកទៅទប់ទល់គ្រួសារនៅតាមជនបទ។*

ពួកគេអំពាវនាវឱ្យរដ្ឋាភិបាល និងអង្គការម្ចាស់ជំនួយ ផ្តល់ការគាំទ្រដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត

*ប្រជាជននៅតាមជនបទ ទទួលរងផលប៉ះពាល់បំផុត...រដ្ឋាភិបាល និងម្ចាស់ជំនួយត្រូវគាំទ្រពួកគេ។*

ពួកគេយល់ថា ប្រជាពលរដ្ឋភាគច្រើននៅកម្ពុជា មិនយល់អំពីមូលហេតុនៃបញ្ហានេះ និងខ្វះព័ត៌មាន និងធនធានដែលពួកគេត្រូវការ សម្រាប់តស៊ូទល់នឹងការប្រែប្រួលអាកាសធាតុ ដោយសារតែកង្វះទាំងការអប់រំ និងទាំងលទ្ធភាពទទួលព័ត៌មាន។ ពួកគេពន្យល់ថាការប្រែប្រួលអាកាសធាតុ គឺជាការប្រឈមសម្រាប់ប្រជាជនដែលរស់នៅក្នុងភាពក្រីក្រៈ

*ខ្ញុំគិតថាប្រជាជននៅតាមជនបទ មិនសូវដឹងរឿងហ្នឹងប៉ុន្មានទេ ដោយពួកគេមិនមានលទ្ធភាពទទួលព័ត៌មាន ដែលបញ្ហានោះមិនមែនជាបញ្ហាសំខាន់។ អ្វីដែលគាត់ខ្វល់ខ្វាយគឺជីវភាពរបស់គាត់។ ប្រជាជនដែលក្រីក្រ មិនមានលទ្ធភាពទៅនឹងការបន្សាំនោះទេ។*

ការបាត់បង់ព្រៃឈើ ត្រូវបានតំណាងពីអង្គការមិនមែនរដ្ឋាភិបាលមើលឃើញថា ជាវិភាគទានយ៉ាងចំបងដែលនាំឲ្យកម្ពុជាមានការប្រែប្រួលអាកាសធាតុ រួមជាមួយការបំពុលពីការប្រើប្រាស់ថាមពលៈ

*យើងមិនគួរបំផ្លាញព្រៃឈើ វាជាបញ្ហាដ៏ធំវាមានលក្ខណៈសំខាន់សំរាប់ខ្មែរយើង។ បញ្ហាមួយទៀត គឺដោយសារការប្រើប្រាស់ថាមពល។ បើទោះជាវាមិនមានលក្ខណៈសំខាន់ ក៏យើងបានបង្កឲ្យមានតាមរយៈការដុត ជាពិសេសរោងចក្រអគ្គិសនី។ វាមិនមែនជារឿងធម្មតានោះទេ គឺសុទ្ធតែប្រើឥន្ធនៈ។ នៅពេលដែលគេលែងប្រើរោងចក្រទាំងនោះ កាកសំណល់ជាសំរាម និងប្លាស្ទិកត្រូវដុតចោល។*

សំណួរអំពីវិសមភាពយេនឌ័រ កាន់តែបង្ហាញច្បាស់នៅក្នុងការសម្ភាសន៍ជាមួយអង្គការមិនមែនរដ្ឋាភិបាលជាងជាមួយក្រុមណាមួយទាំងអស់ ក្នុងចំណោមអ្នកឆ្លើយសំខាន់ៗ។ ទោះបីតំណាងភាគច្រើនពីអង្គការមិនមែនរដ្ឋាភិបាល គិតថាការប្រែប្រួលអាកាសធាតុអាចមានផលប៉ះពាល់មកលើមនុស្សគ្រប់រូបក៏ដោយ ពួកគេពោលថាស្ត្រីនឹងងាយរងគ្រោះទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុជាងបុរស ដោយសារតែពួកគាត់ មានការទទួលខុសត្រូវដែលទាក់ទងនឹងការដាំដំណាំកិច្ចការក្នុងគ្រួសារ និងការថែទាំកូន។

*នៅពេលដែលមានអាកាសធាតុប្រែប្រួល ស្ត្រីជាអ្នកទទួលរងគ្រោះជាងបុរស។ ពួកគាត់ជាអ្នករកអុស ត្រី សាច់ និងធ្វើស្រែនៅក្បែរផ្ទះ។ ដូចនេះធនធាន គឺកម្រណាស់។*

*ប្រសិនបើគាត់មិនមានធនធាន និងសមត្ថភាពបន្សាំ គឺស្ត្រីជាអ្នកទទួលធ្ងន់ធ្ងរ។ ឧទាហរណ៍ ពេលជួបភាពរាំងស្ងួត ស្ត្រីត្រូវធ្វើការជាមួយគ្រួសារ បើសិនជាបានផលតិច សុខចិត្តអត់ហូបខ្លួនឯងដើម្បីឲ្យកូន និងប្តីហូប។*

អ្នកទាំងនេះភាគច្រើន មើលឃើញចំណងទាក់ទងច្បាស់លាស់រវាងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍ។ តំណាងពី NGO មិនចង់ឱ្យកម្ពុជាបង្កើនការបំភាយកាបូនឡើយ ប៉ុន្តែទទួលស្គាល់ថាកម្ពុជាត្រូវការឱ្យមានការអភិវឌ្ឍៈ

*កុំឲ្យប្រទេសដែលកំពុងអភិវឌ្ឍ ធ្វើតាមប្រទេសដែលអភិវឌ្ឍ ហើយបញ្ចេញកាបូនច្រើន។*

តំណាងភាគច្រើនពីNGO ដឹងខ្លះៗអំពីកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) ដែលបានរៀបរៀងឡើងដោយរដ្ឋាភិបាលកម្ពុជា ប៉ុន្តែពួកគេពោលថា សកម្មភាពរបស់រដ្ឋាភិបាលនៅពុំទាន់បានផ្សព្វផ្សាយដល់ថ្នាក់មូលដ្ឋាននៅឡើយទេ។

*មានស្ថាប័នជាច្រើនដែលធ្វើការទាក់ទងជាមួយបញ្ហានេះ ប៉ុន្តែភាគច្រើនកើតឡើងនៅថ្នាក់កណ្តាល និងថ្នាក់ជាតិ។ នៅថ្នាក់តំបន់ ខេត្ត និងមូលដ្ឋាន មិនទាន់មាននៅឡើយ។*

ពួកគេពន្យល់ថា សកម្មភាពណាមួយនៅថ្នាក់មូលដ្ឋាន ត្រូវតែចាប់ផ្តើមដោយការផ្តល់ព័ត៌មានដល់មេដឹកនាំនៅមូលដ្ឋានៈ

*ប្រជាជនធម្មតា មិនមានលទ្ធភាពយល់ពីបញ្ហាហ្នឹងទេ ទាល់តែមន្ត្រីមូលដ្ឋានយល់ពីបញ្ហាហ្នឹងសិន ទើបអាចបញ្ជ្រាបដល់ប្រជាជនបាន។*

## មេដឹកនាំសាសនា

មេដឹកនាំសាសនា មានការយល់ដឹងអំពីការប្រែប្រួលធាតុអាកាសប្រហាក់ប្រហែលនឹងអ្វីដែល ប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យយល់ផងដែរ ប៉ុន្តែមានភាពខុសគ្នាខ្លះៗអំពីអ្វីដែលគាត់យល់អំពីការប្រែប្រួលអាកាសធាតុ និងការយល់ខុសប្រហាក់ប្រហែលគ្នា។ ភាគច្រើនសំដៅលើការសង្កេតផ្ទាល់ខ្លួនដើម្បីពន្យល់អំពីពាក្យ"ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី" ទោះបីការប្រៀនប្រដៅខាងសាសនា មានឥទ្ធិពលមកលើការយល់ឃើញរបស់ពួកគេ អំពីបញ្ហានេះក៏ដោយ។ ប៉ុន្តែមេដឹកនាំសាសនាជាច្រើន សំដែងភាពមោះមុតនៅពេលសួរអំពីតួនាទីរបស់សាសនា នៅក្នុងការផ្សព្វផ្សាយទៅសាធារណជនអំពីការប្រែប្រួលអាកាសធាតុ។

ក្នុងចំណោមមេដឹកនាំសាសនា ក៏ដូចជាក្នុងចំណោមប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យផងដែរ ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ មានលក្ខណៈចម្រុះ។ ភាគច្រើនយោងទៅការសង្កេតផ្ទាល់ខ្លួន ដើម្បីពន្យល់ពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការឡើងកម្តៅផែនដី" ទោះបីការប្រៀនប្រដៅខាងសាសនា មានឥទ្ធិពលលើការយល់ឃើញរបស់ពួកគេអំពីបញ្ហានេះក៏ដោយ។ មេដឹកនាំសាសនាភាគច្រើនពោលថា ពួកគេមានតួនាទីមួយនៅក្នុងការជួយផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ បើទោះបីជាយោបល់របស់ពួកគេបង្ហាញថា ពួកគេត្រូវការព័ត៌មានបន្ថែមទៀតដើម្បីឲ្យពួកគេធ្វើកិច្ចការនេះឱ្យមានភាពជោគជ័យ។

ទោះបីមេដឹកនាំសាសនាយល់ឃើញថា សកម្មភាពមនុស្សបានបង្កឱ្យមានការប្រែប្រួលធាតុអាកាសក៏ដោយ ព្រះសង្ឃ និងមេដឹកនាំសាសនាមូស្លីមភាគច្រើន យល់ថាជាការដាក់ទណ្ឌកម្មរបស់ព្រះ ឬ ការសងសឹករបស់ធម្មជាតិ។ ព្រះសង្ឃមួយអង្គពន្យល់ថា ធម្មជាតិកំពុងដាក់ទណ្ឌកម្មមនុស្ស ដោយសារតែការប្រព្រឹត្តខុសរបស់មនុស្ស។

*ធម្មជាតិដាក់ទណ្ឌកម្មដល់សត្វលោក ដោយសារមនុស្សលោកសព្វថ្ងៃធ្វើអំពើបាបច្រើន ធ្វើឲ្យធម្មជាតិដាក់ទណ្ឌកម្មមនុស្ស សត្វ និងរុក្ខជាតិនៅលើផែនដីនេះ បើតាមអាត្មាយល់។*

ដូចគ្នានេះដែរ មេដឹកនាំសាសនាមូស្លីមមួយរូបពោលថា កង្វះទឹកភ្លៀង និងកំណើនសីតុណ្ហភាព គឺជាការដាក់ទណ្ឌកម្មរបស់ព្រះ មកលើការប្រព្រឹត្តខុសឆ្គងរបស់មនុស្ស

*មនុស្សមិនចេះស្រឡាញ់គ្នា ស្រឡាញ់តែមនុស្សគ្នាឯង មិនចេះស្រឡាញ់សត្វដើមឈើ។ មនុស្សបានរំលោភសេចក្តីទុកចិត្តរបស់ព្រះដែលមានលើមនុស្ស ព្រះបានឲ្យយើងរស់នៅជាមួយគ្នា ទាំងមនុស្ស ទាំងសត្វ ទាំងរុក្ខជាតិ។ ដោយមនុស្សរំលោភលើសេចក្តីទុកចិត្តហ្នឹង ដែលបណ្តាលឲ្យព្រះដាក់បណ្តាសាធ្វើឲ្យកើតមានកម្តៅនៅលើផែនដីហ្នឹង។*

ពុទ្ធសាសនិកជនខ្លះ ក៏ចាត់ទុកថាជាកម្មពៀររវាងជំនាន់មនុស្សផងដែរ ដែលធម្មជាតិតម្រូវឲ្យមានបែបនេះ

*ទណ្ឌកម្មពីធម្មជាតិ បណ្តាលមកពីមនុស្សមិនសូវចេះគោរពស្តាប់ការទូន្មានរបស់ចាស់ទុំ មាតាបិតា និងជាធំគឺជាការប្រមាថ។*

ព្រះសង្ឃខ្លះពន្យល់ថា ការប្រៀនប្រដៅរបស់ព្រះពុទ្ធ បានប្រមើលអំពីការប្រែប្រួលដូចជាអ្វីៗដែលប្រជាជនកម្ពុជាបានសង្កេតឃើញ នៅក្នុងពេលបច្ចុប្បន្ននេះ។ ព្រះសង្ឃមួយអង្គយោងទៅធម្មទេសនា អំពីព្រះអាទិត្យទាំងប្រាំពីរ

*នៅក្នុងអដ្ឋកថា ឬ ព្រះក្នុងត្រៃបិតក លោកបានសំដែងថាផែនដីអាចនឹងឆេះនៅថ្ងៃណាមួយ នៅពេលមានព្រះអាទិត្យចំនួន៧។*

ការប្រៀនប្រដៅរបស់ព្រះពុទ្ធ ផ្តល់ជាស្មារតីខ្លះៗដល់ព្រះសង្ឃក្នុងការឆ្លើយតបទៅនឹងសំណួរអំពីការបាត់បង់ព្រៃឈើ។ ព្រះសង្ឃមួយអង្គបានមានពុទ្ធដីការថា *"(ព្រះពុទ្ធ) ហាមព្រះសង្ឃ និងពុទ្ធសាសនិកជនពីការកាប់ឈើ"*។

ព្រះសង្ឃដទៃទៀតពន្យល់អំពីគំនិតនេះផងដែរ

*ព្រះពុទ្ធសាសនាឲ្យតម្លៃខ្ពស់លើបរិស្ថាន ព្រោះថាព្រះពុទ្ធជាម្ចាស់នៃយើងតាំងពីព្រះអង្គប្រសូត ត្រាស់ដឹង រហូតដល់បរិនិពាន្ទ ព្រះអង្គអាស្រ័យនឹងបរិស្ថាន អាស្រ័យនៅក្រោមដើមឈើ។*

ក្រៅពីអ្វីដែលសាសនាជះឥទ្ធិពលលើជំនឿរបស់គាត់ មេដឹកនាំសាសនាមានការយល់ដឹងច្រើនអំពីការប្រែប្រួលធាតុអាកាសដូចប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យផងដែរ ដោយមានភាពខុសគ្នាអំពីវិធីដែលពួកគេយល់ប្រធានបទនេះ និងការយល់ខុសប្រហាក់ប្រហែលគ្នាផងដែរ។

ប៉ុន្តែមេដឹកនាំសាសនាជាច្រើនសំដែងភាពក្លាហាន នៅពេលឆ្លើយនឹងសំណួរអំពីតួនាទីរបស់ជំនឿសាសនា និងមេដឹកនាំសាសនានៅក្នុងការផ្សព្វផ្សាយដល់សាធារណជនអំពីការប្រែប្រួលអាកាសធាតុ។

*ព្រះសង្ឃយើងអាចសំដែង លុះត្រាថ្នាក់ក្រសួងធម្មការចាត់ចែងឲ្យវិទ្យាសាស្រ្តចូលជាមួយគ្នាហ្នឹងដែរ ការសំដែងព្រះធម៌អាចលើកពីរឿងនេះរឿងនោះហើយ បញ្ចូលពីអាកាសធាតុបន្តិចបន្តួចទៅ ថាកាលពីសម័យព្រះនោះវាអញ្ចេះ ហើយសម័យឥឡូវនេះវាអញ្ចុះទៅ។ អាហ្នឹងទាល់តែមានការអនុញ្ញាត។ អាត្មាបានជួយប្រាប់ប្រជាជនឲ្យដាំដើមឈើដើម្បីការពារកម្តៅថ្ងៃ ហើយគេធ្វើតាម។ អ្នកខ្លះដាំតាមផ្ទះ ទីទួល ហើយក៏មិនសូវហ៊ានកាប់នៅតាមស្រែចំការអី។*

មេដឹកនាំសាសនាភាគច្រើន ក៏មើលឃើញផងដែរថាសាលារៀន និងប្រព័ន្ធផ្សព្វផ្សាយមានតួនាទីនៅក្នុងការបង្កើននូវការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ:

*មធ្យោបាយដំបូងក្នុងការអប់រំ គឺតាមរយៈសាលារៀនរដ្ឋ ការពិតដោយសារកុមារយុវវ័យក្មេងភាគច្រើនទៅសាលា។ ជំហានទី២ គឺតាមរយៈវិទ្យុ និងទូរទស្សន៍ព្រោះប្រជាជនភាគច្រើនមានវិទ្យុ ទោះបីបើគាត់ក្រ។*

មេដឹកនាំសាសនាមួយរូប គូសបញ្ជាក់ថា ព័ត៌មានអំពីបញ្ហានេះត្រូវតែបង្ហាញដល់ប្រជាជនឲ្យយល់ច្បាស់លាស់អំពីអ្វីដែលពួកគេអាចធ្វើបាន សម្រាប់ដោះស្រាយចំពោះបញ្ហានានា ដែលពួកគេប្រឈមៈ

*ប្រសិនបើគ្រាន់តែបង្រៀន ហើយមិនស្វែងរកដំណោះស្រាយដើម្បីទប់ស្កាត់បញ្ហាហ្នឹង ពួកគេនឹងមិនមានផលអ្វីពីការចូលរួមនេះទេ។ វាចាំបាច់ណាស់ដែលយើងត្រូវផ្តល់ឲ្យពុទ្ធបរិស័ទពីការការពារខ្លួន។*

មេដឹកនាំសាសនាជាច្រើន គូសបញ្ជាក់អំពីតម្រូវការរបស់ប្រជាពលរដ្ឋដែលងាយរងគ្រោះជាងគេៈ

*មានគ្រួសារខ្លះដែលក្រីក្រ និងមិនបានទទួលព័ត៌មានពីគ្រោះធម្មជាតិ ឬការប្រែប្រួលអាកាសធាតុ ដោយសារគេមិនមានលុយដើម្បីទិញវិទ្យុ។*

*អាត្មាគិតថា អ្នកដែលដឹងពីការប្រែប្រួលអាកាសធាតុហ្នឹង ច្រើនជាអ្នករស់នៅទីក្រុង ព្រោះពួកគេមានការអប់រំ ទទួលការអប់រំផ្សព្វផ្សាយ...ប៉ុន្តែប្រជាជននៅតំបន់ដាច់ស្រយាលមិនមានការអប់រំ អត់បានឮការអប់រំផ្សព្វផ្សាយពីបញ្ហាហ្នឹង។*

ដោយចងចាំអំពីតម្រូវការរបស់សហគមន៍ក្រីក្រ និងអ្នកជនបទ មេដឹកនាំសាសនាមួយចំនួនសង្កត់ធ្ងន់ថា ការឆ្លើយតបរបស់រដ្ឋាភិបាលទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវតែពង្រីកទៅដល់សហគមន៍នៅថ្នាក់ឃុំ/សង្កាត់និងភូមិ

*រដ្ឋាភិបាលរួមមានអភិបាលស្រុក អភិបាលខេត្ត មិនមែនតែរដ្ឋមន្ត្រីនោះទេ។ បើនិយាយពីវចនាសម្ព័ន្ធថ្នាក់ជាតិ រួមមានតាំងពីមេឃុំ មេភូមិ។ ពួកគេមានតួនាទីសំខាន់ក្នុងការដឹកនាំសហគមន៍។ អ្វីដែលអាត្មាចង់សំដៅ គឺការចូលរួមពីគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធ។*

# សេចក្ដីសន្និដ្ឋាន

បើទោះជាបុគ្គលសំខាន់ៗយល់បានពេញលេញ ឬមិនយល់អំពីបាតុភូតនេះក៏ដោយ ពួកគេមានការព្រួយបារម្ភថា ការប្រែប្រួលអាកាសធាតុ កំពុងមានផលប៉ះពាល់មកលើសហគមន៍របស់ពួកគេ ហើយប្រជាជនពុំមានព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើការឆ្លើយតបឡើយ។ ចាប់ពីរដ្ឋាភិបាលនៅថ្នាក់ជាតិ និងតំណាងប្រព័ន្ធផ្សព្វផ្សាយ រហូតដល់ប្រធានភូមិ និងប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ បុគ្គលសំខាន់ៗ ពោលថាពួកគេចង់រៀនសូត្រច្រើនបន្ថែមទៀតអំពីការប្រែប្រួលអាកាសធាតុ ហើយពួកគេចង់ដើរតួនាទីនៅក្នុងការផ្សព្វផ្សាយព័ត៌មាននេះដល់សាធារណជនកម្ពុជា។

ទោះបីបុគ្គលសំខាន់ៗ បង្ហាញអត្ថន័យនៃការប្រែប្រួលអាកាសធាតុ តាមរយៈការពន្យល់បន្តិចបន្តួចក៏ដោយ ក៏ឥរិយាបថរបស់ពួកគាត់ ស្តែងចេញនូវការព្រួយបារម្ភយ៉ាងខ្លាំងទៅលើឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុមកលើប្រជាជនកម្ពុជា ថ្វីត្បិតតែមានក្រុមបុគ្គលមួយចំនួនដូចជា បុគ្គលដែលមានប្រជាប្រិយភាព និងអ្នកតំណាងមកពីប្រព័ន្ធផ្សព្វផ្សាយខ្លះៗ ដែលនៅមានភាពមិនប្រាកដក្នុងចិត្តចំពោះបញ្ហានេះក៏ដោយ។

ទោះជាយ៉ាងណាក៏ដោយ ទន្ទឹមនឹងកង្វល់ទាំងនេះ បុគ្គលសំខាន់ៗជាច្រើន នៅមានការភណ្ឌច្រលំអំពីបញ្ហាប្រែប្រួលអាកាសធាតុនៅឡើយ។ បុគ្គលសំខាន់ៗដែលមានតួនាទីសមស្របក្នុងការផ្ដល់ព័ត៌មានដល់សហគមន៍របស់ពួកគេ ដូចជាប្រធានភូមិ មេដឹកនាំសាសនា ប្រធានក្រុមប្រឹក្សាឃុំពោលថា ពួកគេមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីជួយផ្សព្វផ្សាយអំពីបញ្ហាដែលគួរឲ្យព្រួយបារម្ភនេះឡើយ។

អ្នកទាំងអស់ដែលទទួលបន្ទុកផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ ត្រូវការឱ្យមានការគាំទ្រ និងព័ត៌មានដើម្បីពួកគេអាចផ្ដល់សារដែលស៊ីសង្វាក់គ្នានិងដែលអាចទុកចិត្តបានដល់សាធារណជនកម្ពុជា។

# អនុសាសន៍

ប្រជាជនកម្ពុជាភាគច្រើនបានទទួលព័ត៌មានពី**ទូរទស្សន៍ វិទ្យុ និងការនិយាយតគ្នាពីមាត់មួយទៅមាត់មួយ**។ នេះជាការពិតសម្រាប់ព័ត៌មានទូទៅ និងឆ្លុះបញ្ចាំងអំពីកន្លែងដែលពួកគេបានឮពាក្យការប្រែប្រួលអាកាសធាតុ និងជាកន្លែងដែលពួកគេបានទទួលព័ត៌មានអំពីព្រឹត្តិការណ៍ធាតុអាកាសអាក្រក់។ ព័ត៌មានដែលបានពីការចាក់ផ្សាយ គឺជាប្រភពព័ត៌មានដែលគួរឲ្យទុកចិត្តបំផុត។ ប្រជាជន ៩១% មានលទ្ធភាពប្រើប្រាស់ទូរស័ព្ទចល័ត ប្រជាជន៤០% ប្រើប្រាស់ទូរស័ព្ទដែលមិនមែនជារបស់ខ្លួន។ អ្នកដែលងាយរងគ្រោះជាងគេដែលរួមទាំងស្ត្រី និងអ្នកដែលរស់នៅក្នុងភាពក្រីក្រ ពោលថាខ្លួនពឹងផ្អែកលើប្រធានភូមិ ជាអ្នកផ្តល់ព័ត៌មាន។

- បង្កើតព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ នៅជុំវិញប្រភពព័ត៌មានដែលប្រជាជនកម្ពុជាភាគច្រើនប្រើប្រាស់ និងទុកចិត្ត ពោលគឺទូរទស្សន៍វិទ្យុ និងការនិយាយតគ្នាពីមាត់មួយទៅមាត់មួយ។ បង្កើនវិសាលភាព ទំនាក់ទំនងនៃនិយាយតពីមាត់មួយទៅមាត់មួយតាមរយៈទូរស័ព្ទចល័ត។
- បង្កើតយុទ្ធសាស្ត្រផ្សព្វផ្សាយដោយឡែកសម្រាប់ប្រជាពលរដ្ឋដែលពុំមានលទ្ធភាពស្តាប់ព័ត៌មានពីការចាក់ផ្សាយ។
- បង្កើតយុទ្ធសាស្ត្រផ្សព្វផ្សាយដាច់ដោយឡែក សម្រាប់ប្រជាជនដែលពុំមានទូរស័ព្ទចល័តដោយខ្លួនឯងផ្ទាល់។

ប្រជាជនកម្ពុជា ពន្យល់អំពីការប្រែប្រួលអាកាសធាតុដោយសំដៅលើផលប៉ះពាល់របស់វា ជាងលើមូលហេតុ។ អ្នកទាំងនោះភាគច្រើនមានការយល់ដឹង តាមការជួបប្រទះបាតុភូតនោះផ្ទាល់ ប៉ុន្តែមិនយល់អំពីមូលដ្ឋានគ្រឹះខាងវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុពិភពលោកឡើយ។ ពួកគេមិនបានយល់ច្បាស់អំពីមូលហេតុនៃការប្រែប្រួលអាកាសធាតុ និងមិនយល់អំពីពាក្យដែលប្រើប្រាស់សម្រាប់អធិប្បាយអំពីបាតុភូតនេះឡើយ។

- បង្កើនការយល់ដឹងពីមូលដ្ឋានវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ
    - បង្កើត អនុវត្តសាកល្បង និងចែកចាយកូនសៀវភៅនានាដែលសរសេរជាភាសាខ្មែរដល់អ្នកសារព័ត៌មាន និងគោលការណ៍ណែនាំដែលបង្ហាញគំរូល្អដែលធ្លាប់បានអនុវត្តក្នុងការធ្វើសេចក្តីរាយការណ៍អំពីការប្រែប្រួលអាកាសធាតុ
    - បង្កើតមណ្ឌលចែកផ្សាយព័ត៌មានសំបូរដោយឯកសារជាភាសាខ្មែរ ដែលបានមកពីការប្រែសម្រួលពីឯកសារគោលនយោបាយ ការស្រាវជ្រាវ សន្ធិសញ្ញា និងបទដ្ឋានអន្តរជាតិនានាដែលមានស្រាប់
    - បង្កើតឯកសារណែនាំងាយៗ អំពីវិទ្យាសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅថ្នាក់មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ។
- កែលម្អទំនាក់ទំនងសាធារណៈអំពីវិទ្យាសាស្ត្រ
    - ផ្តល់ការបណ្តុះបណ្តាលដល់អ្នកសារព័ត៌មាននូវរបៀបរាយការណ៍អំពីវិទ្យាសាស្ត្រ

- ផ្តល់ការបណ្តុះបណ្តាលដល់អ្នកវិទ្យាសាស្ត្រអំពីរបៀបផ្តល់ព័ត៌មាន ដើម្បីងាយស្រួលក្នុងការផ្តល់ព័ត៌មានវិទ្យាសាស្ត្រទៅសាធារណជន
- បង្កើតឲ្យមានក្រុមអ្នកវិទ្យាសាស្ត្រដែលប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអាចទាក់ទងសុំយោបល់សម្រាប់ផ្តល់ការអត្ថាធិប្បាយ និងការបង្ហាញអំពីវិទ្យាសាស្ត្រទៅកាន់សាធារណជន
- ផលិតព័ត៌មាន និងការផ្សព្វផ្សាយ ដែលបង្ហាញអំពីភាពពាក់ព័ន្ធនៃវិទ្យាសាស្ត្រនៅក្នុងវិស័យសំខាន់ៗដូចជាវិស័យកសិកម្ម សុខភាព ការកាត់បន្ថយគ្រោះមហន្តរាយ និងការគ្រប់គ្រងទឹកជាដើម
- ស្វែងរកមើលព័ត៌មានវិទ្យាសាស្ត្រជាក់លាក់ ដើម្បីផ្សព្វផ្សាយឲ្យចំក្រុមគោលដៅនៅក្នុងចំណោមប្រជាជនទូទៅ ដោយផ្អែកលើភាពខុសៗគ្នានៃតួនាទីរបស់ពួកគេនៅក្នុងសង្គម និងក្នុងមុខរបរដូចជាទៅតាមអាយុ ភេទ មុខរបរ និងកន្លែងរស់នៅ
  - បង្កើតកម្មវិធីទទួលទូរស័ព្ទតាមវិទ្យុសម្រាប់ប្រជាជននៅជនបទ ដែលអាចឱ្យកសិករ និងអ្នកដែលមានជំនាញពាក់ព័ន្ធ ចែករំលែកបទពិសោធន៍ និងបង្កើតដំណោះស្រាយតបនឹងការព្រួយបារម្ភដែលកើតមានជាទូទៅ
- ពិនិត្យមើល និងបង្កើតកម្មវិធីសម្រាប់កុមារ ដើម្បីបង្កើនតួនាទីរបស់កុមារ ក្នុងនាមជាអ្នកនាំសារដ៏មានប្រសិទ្ធភាពទៅដល់មិត្តភ័ក្តិ និងគ្រួសាររបស់ពួកគេ
  - ផលិតព័ត៌មាន និងការផ្សព្វផ្សាយដែលផ្តោតលើកុមារ ដែលនឹងអាចឱ្យពួកគេរៀនសូត្រអំពីវិទ្យាសាស្ត្រតាមរយៈ ការផលិតវត្ថុនានា ដោះស្រាយចំណោទ និងប្រើប្រាស់វិទ្យាសាស្ត្រងាយៗនៅក្នុងដំណោះស្រាយចំពោះការប្រឈមរបស់ពួកគេ។

- បង្កើនចំណេះដឹងវិទ្យាសាស្ត្រអំពីការប្រែប្រួលធាតុអាកាស និងព្រឹត្តិការណ៍នានាដែលជួបប្រទះជាទូទៅ
  - ផ្តល់ឱ្យប្រជាជន នូវព័ត៌មានដែលពាក់ព័ន្ធសម្រាប់ការធ្វើសេចក្តីសម្រេចផ្ទាល់ខ្លួនរបស់ពួកគេ
  - ផ្សារភ្ជាប់វិទ្យាសាស្ត្រកសិកម្ម ទៅនឹងវិទ្យាសាស្ត្រអាកាសធាតុ
- បង្កើនចំណេះដឹងវិទ្យាសាស្ត្ររបស់ប្រជាជន ដោយផ្អែកលើបទពិសោធន៍របស់ពួកគេផ្ទាល់
  - បង្ហាញ "សាច់រឿងស្តីអំពីអាកាសធាតុ" ដើម្បីនាំយកបទពិសោធន៍របស់មនុស្សចាស់ និងយុវជនមកបញ្ចូលគ្នា និងដើម្បីផ្សារភ្ជាប់រវាងចំណេះដឹងប្រពៃណី បទពិសោធន៍ទូទៅ និងជំនាញវិទ្យាសាស្ត្រ
- ផ្តោតលើទស្សនៈមន្ត្រីជាន់ខ្ពស់ និងបញ្ហាសំខាន់ៗព្រមទាំងព្រឹត្តិការណ៍ដែលបានជួបប្រទះទូទៅជាងគេ សម្រាប់ការផ្សព្វផ្សាយឲ្យបានច្រើនជាងគេ
  - ពង្រឹងបន្ថែមនូវការយល់ដឹងជាទូទៅអំពីតួនាទីដើមឈើនៅក្នុងប្រព័ន្ធធាតុអាកាស
    - ប្រើប្រាស់ទម្រង់ព័ត៌មាន និងការផ្សព្វផ្សាយដើម្បីពន្យល់អំពីតួនាទីរបស់ដើមឈើ និងព្រៃឈើនៅកម្ពុជា និងនៅជុំវិញពិភពលោក និងប្រើប្រាស់ទម្រង់ទាំងនេះជាចំណុចចាប់ផ្តើមដើម្បីណែនាំប្រជាជនឱ្យស្គាល់អំពីគោលគំនិតនៃប្រព័ន្ធធាតុអាកាសពិភពលោក និងការប្រែប្រួលអាកាសធាតុ

- បង្ហាញពីការប្រើប្រាស់ចំណេះដឹងសំខាន់ៗ អំពីកង្វល់ដែលបានលើកឡើងជាទូទៅដែលទាក់ទងនឹងកសិកម្ម សុខភាព កាត់បន្ថយគ្រោះមហន្តរាយធម្មជាតិ និងការគ្រប់គ្រងទឹក
- ប្រើប្រាស់វិស័យសំខាន់ៗដែលជាការព្រួយបារម្ភជា "មូលដ្ឋាន" នៃសេចក្តីរាយការណ៍អំពីការប្រែប្រួលអាកាសធាតុនៅក្នុងខ្សែរឿងនិងកម្មវិធីព័ត៌មានផ្សេងទៀត។

ប្រជាជនកម្ពុជាឯកភាពថាធាតុអាកាសនៅកន្លែងរបស់ពួកគេកំពុងប្រែប្រួល។ ប្រជាជនកម្ពុជាស្ទើរគ្រប់រូបបានជួបប្រទះយ៉ាងហោចណាស់គ្រោះធម្មជាតិម្តងនៅក្នុងឆ្នាំមុន មុនការអង្កេតនេះ។ ប៉ុន្តែមនុស្សច្រើនជាងមួយភាគបី ពុំបានទទួលព័ត៌មានអំពីព្រឹត្តិការណ៍ ដែលមានឥទ្ធិពលមកលើពួកគេឡើយ ហើយបីភាគបួននៃអ្នកដែលបានទទួលព័ត៌មាននេះ បានទទួលព័ត៌មាននៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ ឬ នៅក្រោយព្រឹត្តិការណ៍នោះតែប៉ុណ្ណោះ។ ប្រជាជននិយាយថាពួកគេអាចប្រើប្រាស់ព័ត៌មានដើម្បីត្រៀមខ្លួន និងជួយអ្នកដទៃ។

- កាត់បន្ថយចំនួនប្រជាជនដែលពុំបានទទួលព័ត៌មានទាល់តែសោះ។
- បង្កើនចំនួនប្រជាជនដែលទទួលបានព័ត៌មាននៅមុនព្រឹត្តិការណ៍កើតឡើង។
- បង្កើតប្រព័ន្ធជាតិសម្រាប់ការផ្តល់ដំណឹងជាមុនដែលមានការទទួលស្គាល់ទូលំទូលាយជាសាធារណៈ។
  - រួមផ្សំការចាក់ផ្សាយតាមទូរទស្សន៍ និងវិទ្យុ នូវការផ្តល់ដំណឹងជាមុន អំពីគ្រោះធម្មជាតិជាមួយការនិយាយតគ្នាពីមាត់មួយទៅមាត់មួយ។ បង្កើនការជូនដំណឹងដល់អ្នកដែលទទួលព័ត៌មានតាមការនិយាយតគ្នាពីមាត់មួយទៅមាត់មួយ ដោយធ្វើឱ្យទូរស័ព្ទចល័តក្លាយជាមធ្យោបាយសំខាន់មួយនៃប្រព័ន្ធជូនដំណឹងជាមុនរបស់ជាតិ។ ពិនិត្យមើលលទ្ធភាពក្នុងការចែកចាយទូរស័ព្ទចល័ត។
    - កសាងសមត្ថភាពផ្សាយនៅតាមស្ថាប័នវិទ្យុ និងទូរទស្សន៍ ដូចនេះកម្មវិធីផ្សាយនានាអាចបញ្ជ្រៀតចូលបានក្នុងគោលបំណងផ្សព្វផ្សាយព័ត៌មានទាន់ហេតុការណ៍
    - បង្កើតសញ្ញាសម្គាល់ជាសកលដែលអាចយកទៅប្រើប្រាស់នៅក្នុងព័ត៌មានព្យាករណ៍ធាតុអាកាស និងជាសញ្ញាសម្រាប់ផ្តល់ព័ត៌មានអំពីការប្រកាសជាមុននៃគ្រោះធម្មជាតិតាមរយៈការផ្ញើសារខ្លីៗតាមទូរស័ព្ទ។
    - បង្កើតគំរូផ្តល់ព័ត៌មានជាមុនជាភាសាខ្មែរអំពីខ្យល់ព្យុះ/ទឹកជំនន់នៅលើទូរស័ព្ទចល័ត ។
    - ស្វែងរកលទ្ធភាព ដែលអាចឱ្យបណ្តាញទូរស័ព្ទចល័តភ្ជាប់ទៅនឹងប្រព័ន្ធផ្តល់ដំណឹងជាមុនអោយបានទូលំទូលាយ តាមរយៈការបញ្ចូលនូវកម្មវិធីប្រកាសភាពអាសន្ននៃគ្រោះធម្មជាតិនៅក្នុងគ្រប់ទូរស័ព្ទ និងគ្រប់បណ្តាញផ្តល់ព័ត៌មាន ដែលអនុញ្ញាតឱ្យសារនានា អាចទំនាក់ទំនងនៅក្នុងពេលមានករណីបន្ទាន់
    - ធ្វើការកំណត់វិធីនានាសម្រាប់ធ្វើការជាមួយបណ្តាញទូរស័ព្ទចល័ត ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីធាតុអាកាស និង/ឬផ្តល់ការជូនដំណឹងជាមុន។ ពិនិត្យមើលលទ្ធភាពនៃការដាក់ឱ្យអ្នកប្រើប្រាស់នៅតំបន់ដាច់ស្រយាលនៅក្នុងទីតាំងជាក់លាក់នៃផ្ទៃប្រទេស សម្រាប់ការផ្សព្វផ្សាយព័ត៌មានដែលជាការជូនដំណឹងជាមុន។

- គ្រោងឱ្យមានទំនាក់ទំនងជាប់ជាបន្តរវាងសេវាកម្មឧតុនិយម និងដៃគូនានា ដែលរួមទាំងក្រុមហ៊ុនផ្សព្វផ្សាយព័ត៌មាន។ ត្រូវធានាឱ្យមានការផ្សព្វផ្សាយដល់ខេត្ត ឃុំ និងភូមិ។ ត្រួតពិនិត្យប្រព័ន្ធនេះជាទៀងទាត់ និងបង្កើតឱ្យមានប្រព័ន្ធបម្រុង និងយន្តការផ្ទៀងផ្ទាត់។ បង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់ព័ត៌មានដាស់តឿន និងបណ្តុះបណ្តាលប្រជាជនទាំងអស់អំពីលក្ខណៈវិនិច្ឆ័យទាំងនេះ។
- បង្កើតយុទ្ធសាស្ត្រច្បាស់លាស់នៅថ្នាក់ភូមិ ស្តីពីការត្រៀមលក្ខណៈ និងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។ ចាត់ជាអាទិភាពនូវការផ្តល់ព័ត៌មានទៅប្រធានភូមិនៅក្នុងតំបន់ងាយរងគ្រោះ នៅក្នុងបណ្តាញទំនាក់ទំនងរបស់ជាតិ។
  - ត្រូវធ្វើឲ្យប្រាកដថា ប្រធានភូមិគ្រប់រូបនៅកម្ពុជាមានទូរស័ព្ទចល័តមួយគ្រឿង អាចតាមរយៈការចែកចាយទូរស័ព្ទដែលផ្តោតឲ្យចំគោលដៅ
  - តែងតាំង "ជនបង្គោលខាងធាតុអាកាស" នៅគ្រប់ភូមិដើម្បីគាំទ្រដល់តួនាទីរបស់ប្រធានភូមិនៅក្នុងបណ្តាញទំនាក់ទំនងរបស់ជាតិ។ ត្រូវបណ្តុះបណ្តាលជននេះឱ្យចេះប្រមូល និងបញ្ជូនព័ត៌មានអំពីធាតុអាកាសនៅមូលដ្ឋាន ទៅការិយាល័យកណ្តាលដើម្បីគាំទ្រដល់ការកសាងសមត្ថភាពនៅក្នុងសេវាកម្មឧតុនិយម និងនៅក្នុងករណីដែលមានគ្រោះធម្មជាតិត្រូវបញ្ជូនដំណឹងទៅភូមិនៅជិតខាង
  - បង្កើតប្រព័ន្ធផ្តល់ដំណឹងជាមុន(EWS) និងក្រុមការងារនៅថ្នាក់ឃុំ ដើម្បីបង្កើនលទ្ធភាពទទួលបានព័ត៌មានអំពីធាតុអាកាសនៅថ្នាក់ជាតិ និងមូលដ្ឋាន និងដើម្បីគាំទ្រដល់ប្រជាជននៅក្នុងការត្រៀមបង្ការ និងជួយអ្នកដទៃត្រៀមខ្លួនទល់នឹងគ្រោះមហន្តរាយនានា ដូចជាទឹកជំនន់គ្រោះរាំងស្ងួត និងខ្យល់ព្យុះ។
- បង្កើតឱ្យមានការចាក់ផ្សាយព័ត៌មានអំពីការព្យាការណ៍ធាតុអាកាស ឲ្យបានទូទាំងផ្ទៃប្រទេស
  - គ្រោង និងផ្តល់ការផ្សាយឲ្យបានទៀងទាត់អំពីធាតុអាកាស សម្រាប់ការស្តាប់ប្រចាំថ្ងៃ និងការពិនិត្យមើលទម្លាប់ និងលើកទឹកចិត្តដល់សាធារណជនឱ្យទស្សនា ឬ ស្តាប់ប្រចាំថ្ងៃ។
  - ធ្វើការស្រាវជ្រាវលើទស្សនិកជនអំពីការផ្សព្វផ្សាយធាតុអាកាស។
  - ស្រាវជ្រាវអំពីការយល់ដឹងរបស់ប្រជាជនលើសញ្ញាសម្គាល់ និងថាតើប្រជាជនចេះអានផែនទីផ្លូវថ្នល់ដែរឬទេ។ សិក្សាថាតើមានការយល់ដឹងជាទូទៅអំពីសញ្ញានានាសម្រាប់ធាតុអាកាសជាទូទៅឬទេ។
  - ធានាថាកម្មវិធីនៅតាមកម្រិតបឋម និងមធ្យមសិក្សាផ្តល់ឱ្យសិស្សនូវចំណេះដឹងដែលពួកគេត្រូវការជាចាំបាច់សម្រាប់អានផែនទី និងបកស្រាយជំពូកព័ត៌មាន និងសញ្ញាដែលមានប្រើប្រាស់នៅក្នុងការផ្សព្វផ្សាយអំពីធាតុអាកាស។

ប្រជាជនមិនដឹងច្បាស់ទេ ថាតើការប្រែប្រួលធាតុអាកាសដែលពួកគេបានជួបប្រទះនៅក្នុងមូលដ្ឋានរបស់ពួកគេ ជាការប្រែប្រួលរយៈពេលវែង ឬ យ៉ាងណា។ អ្នកទាំងនោះ ៩៨% ពោលថាការប្រែប្រួលអាកាសធាតុកំពុងមានឥទ្ធិពលមកលើប្រទេសរបស់ពួកគេនាពេលបច្ចុប្បន្ននេះ ប៉ុន្តែ ២២% មិនដឹងថាតើការប្រែប្រួលអាកាសធាតុនឹងមានឥទ្ធិពលមកលើប្រទេសរបស់ពួកគេឡើយទៅអនាគត។ បុគ្គលសំខាន់ៗ ជាពិសេសប្រធានភូមិ មេដឹកនាំសាសនា និងប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់មានការអល់អែកចំពោះប្រធានបទអំពីការប្រែប្រួលអាកាសធាតុ។ យោបល់របស់ពួកគេបង្ហាញថារឿងនេះកើតឡើងពិតមែន មកលើសហគមន៍របស់ពួកគេ។ ការសង្កេត និងយោបល់របស់ប្រជាជនអំពីការឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាសច្រើនតែសម្រាប់រយៈពេលខ្លី។ នៅពេលសួរអំពីវិធានការសម្រាប់រយៈពេលវែង ពួកគេមិនដឹងថាតើត្រូវធ្វើអ្វីឡើយ។

- សិក្សាអំពីការប្រែប្រួលអាកាសធាតុ ឥទ្ធិពលរបស់វា និងការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុសម្រាប់រយៈពេលវែង។ បង្កើតចំណុចដៅសម្រាប់រយៈពេលបី ប្រាំ ប្រាំពីរ និងដប់ឆ្នាំ ដើម្បីតាមសង្កេតមើលការកើតឡើងនៃឥទ្ធិពល និងការឆ្លើយតប។
- បង្កើតសារដែលបង្ហាញ ថាការប្រែប្រួលអាកាសធាតុគឺជាបញ្ហារយៈពេលវែង សម្រាប់ជាស្នូលនៃទំនាក់ទំនងនានា និងយុទ្ធនាការព័ត៌មាន។
- ចូរពន្យល់ថាការព្យាករណ៍ខ្លះៗអំពីការប្រែប្រួលអាកាសធាតុ មិនបង្ហាញច្បាស់លាស់ទេ ដូច្នេះវិធានការសម្រាប់រយៈពេលវែង ត្រូវតែមានលក្ខណៈចំរុះ និងអាចបន្សាំបាន។
- ត្រូវទទួលស្គាល់ថាវិទ្យាសាស្ត្រស្តីពីប្រែប្រួលអាកាសធាតុ គឺជាប្រធានបទស្មុគស្មាញហើយត្រូវធ្វើឱ្យសារនេះងាយស្រួលយល់និងមានភាពស៊ីសង្វាក់គ្នាដើម្បីបញ្ចៀសការយល់ច្រឡំក្នុងចំណោមមេដឹកនាំនៅមូលដ្ឋាននិងសាធារណជនទូទៅ។
- ពន្យល់ថាការប្រែប្រួលអាកាសធាតុ គឺជាបាតុភូតរយៈពេលវែង និងផ្តោតលើតម្រូវការចាំបាច់ដើម្បីស្វែងរកការឆ្លើយតបខុសៗគ្នាជាច្រើន ដែលមានភាពបត់បែនបាន។ នៅក្នុងទំនាក់ទំនងអំពីការប្រែប្រួលអាកាសធាតុ ត្រូវផ្តោតលើដំណោះស្រាយជាក់ស្តែង ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនកម្ពុជា។

ឧបសគ្គសំខាន់បំផុតចំនួនបី នៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស គឺ**កង្វះប្រាក់ ឧបករណ៍ និងព័ត៌មាន**។ អ្នកឆ្លើយច្រើនជាងពាក់កណ្តាលពោលថា ពួកគេពុំមានព័ត៌មានដែលពួកគេត្រូវការដើម្បីធ្វើការឆ្លើយតបឡើយ។ បុគ្គលសំខាន់ៗពីខាងវិស័យឧស្សាហកម្ម អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាលនៅថ្នាក់ជាតិបង្ហាញថា ការឆ្លើយតបដែលមានជោគជ័យ សម្រាប់ការប្រែប្រួលអាកាសធាតុ កំពុងរៀបចំឡើង និងអនុវត្តនៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយសមាជិកមួយចំនួនតូចប៉ុណ្ណោះក្នុងចំណោមសាធារណជន បានឮអំពីប្រការទាំងនេះ។

- ផ្សព្វផ្សាយប្រវត្តិនៃកិច្ចប្រឹងប្រែង ប្រកបដោយជោគជ័យនាពេលបច្ចុប្បន្ន ក្នុងចំណោមសាធារណជនទូទៅ។

- ប្រើប្រាស់ព័ត៌មាន និងវិធីសាស្ត្រទំនាក់ទំនងនានា ដើម្បីជួយប្រជាជនលើអាទិភាពខាងហិរញ្ញវត្ថុ និងការកសាងផែនការសម្រាប់ឆ្លើយតបរយៈពេលវែងទៅនឹងការប្រែប្រួលអាកាសធាតុ
- ចូរប្រើប្រាស់ព័ត៌មាន និងទំនាក់ទំនងនានាដើម្បីជួយប្រជាជននៅក្នុងការប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រ និងបង្កើតបច្ចេកវិទ្យាថ្មីៗ និងការផ្តួចផ្តើមថ្មីដើម្បីឆ្លើយតបទៅនឹងវិស័យសំខាន់ៗដែលគួយឲ្យយកចិត្តទុកដាក់ ពោលគឺកសិកម្ម គ្រោះមហន្តរាយ សុខភាព ការចិញ្ចឹមជីវិត និងការគ្រប់គ្រងទឹក
    - ប្រើប្រាស់ទម្រង់ព័ត៌មាននិងការអនុវត្តជាក់ស្តែង ដើម្បីផ្សព្វផ្សាយអំពីការស្រាវជ្រាវកសិកម្មដល់កសិករ
    - ប្រើប្រាស់ព័ត៌មានដើម្បីបង្ហាញពីកិច្ចប្រឹងប្រែងប្រកបដោយជោគជ័យនៅកម្ពុជា និងនៅទីកន្លែងផ្សេងក្នុងពិភពលោក អំពីការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ បង្កើតកញ្ចប់ព័ត៌មាន និងលៃទុកផ្នែកនានានៃព័ត៌មាន និងកម្មវិធីដទៃទៀតសម្រាប់បង្ហាញអំពីការផ្តួចផ្តើមថ្មី និងការឆ្លើយតបនានា ដែលមានជោគជ័យ
    - ជម្រុញបច្ចេកវិទ្យាបៃតង ការបង្កើតថ្មី និងការឆ្លើយតបដែលបង្កើតឡើងដោយប្រជាជនកម្ពុជាសម្រាប់កម្ពុជា
    - ប្រើប្រាស់ព័ត៌មាន និងទំនាក់ទំនងនានា ដើម្បីពិនិត្យមើលប្រព័ន្ធឥណទាន និងការសន្សំរបស់សហគមន៍ និងការធានារ៉ាប់រងខ្នាតតូច ដើម្បីជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចរបស់ប្រជាជនអំពីហិរញ្ញវត្ថុ។
        - ចាត់ចែងឱ្យមានការពិភាក្សា និងការផ្សព្វផ្សាយនៅកម្រិតសហគមន៍ ដែលក្នុងនោះសហគមន៍ធ្វើការសម្រេចលើរបៀបចំណាយប្រាក់ សម្រាប់ការឆ្លើយតបនៅកម្រិតសហគមន៍របស់ពួកគេ។ សហគមន៍ដាក់បញ្ចូលកម្មវិធីប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន ជាពិសេសការគ្រប់គ្រងទឹក និងដែលសហគមន៍អាចបង្ហាញពីសម្លេងរបស់ស្ត្រី។
    - បង្កើតឱ្យមានអ្នកនាំពាក្យជាច្រើន នៅទូទាំងសង្គមកម្ពុជា ដែលប្រព័ន្ធផ្សព្វផ្សាយអាចប្រើប្រាស់ជាមូលដ្ឋាន ដើម្បីពន្យល់ ធ្វើអត្ថាអធិប្បាយ និងបង្ហាញអំពីកិច្ចផ្តួចផ្តើមប្រកបដោយជោគជ័យ ដែលអាចយកទៅអនុវត្តសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។
    - បង្កើតឱ្យមាន និងផ្តល់ការបណ្តុះបណ្តាលជាលក្ខណៈបទដ្ឋាន និងជំនាញព័ត៌មានងាយៗសម្រាប់អ្នកនាំពាក្យទាំងនោះ។

ប្រជាជនកម្ពុជារំពឹងថា **រដ្ឋាភិបាល នាយករដ្ឋមន្ត្រី និងអង្គការមិនមែនរដ្ឋាភិបាល** ផ្តល់ការដឹកនាំនៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលធាតុអាកាស នៅក្នុងមូលដ្ឋានរបស់ពួកគេ។ ប្រធានភូមិ ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ និងមេដឹកនាំសាសនា គឺជាប្រភពព័ត៌មានដែលអាចទុកចិត្តបាន និងស្ថិតក្នុងតំណែងសមស្របក្នុងការជូនដំណឹងដល់សហគមន៍របស់ពួកគេអំពីបញ្ហានេះ ប៉ុន្តែយោបល់ពីបុគ្គលសំខាន់ៗបង្ហាញថា ពួកគេក៏នៅពុំទាន់យល់ច្បាស់នៅឡើយទេអំពីការប្រែប្រួលអាកាសធាតុ ក្នុងនាមជាតំណាងមកពីរដ្ឋាភិបាលនៅថ្នាក់ជាតិ។ អភិបាលខេត្តអាចដើរតួយ៉ាងសំខាន់ ដោយសារអភិបាលខេត្តដែលបានចូលរួមនៅក្នុងការស្រាវជ្រាវនេះ បានបង្ហាញពីចំណេះទាក់ទងច្រើនបែបបំផុត រវាងការប្រែប្រួលអាកាសធាតុ និងទិដ្ឋភាពនានានៃសង្គមរបស់អ្នកផ្តល់ព័ត៌មានសំខាន់ៗដែលបានសម្ភាស។

- បង្កើនការយល់ដឹងជាសាធារណៈអំពីកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ(NAPA)។
  - ជូនដំណឹងនិងបណ្តុះបណ្តាលដល់មេដឹកនាំនៅមូលដ្ឋានអំពីផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ។
  - បណ្តុះបណ្តាលអភិបាលខេត្តអំពីការប្រែប្រួលអាកាសធាតុទន្ទឹមនឹងផ្តល់ការណែនាំនិងការគាំទ្រដើម្បីជម្រុញការបណ្តុះបណ្តាលនេះជាបន្តទៅថ្នាក់ឃុំនិងភូមិ។
- បង្កើត និងចែកចាយកូនសៀវភៅស្តីពីកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់មេដឹកនាំនៅថ្នាក់ខេត្តឃុំនិងភូមិ។ នៅក្នុងកូនសៀវភៅទាំងនេះគួរប្រើប្រាស់ពាក្យសមស្រប និងធ្វើការសាកល្បងជាមុនដោយហ្មត់ចត់។
- ចាត់តាំងមន្ត្រីទំនាក់ទំនងព័ត៌មានអំពីការប្រែប្រួលអាកាសធាតុនៅក្នុងតំណែងរបស់រដ្ឋាភិបាល។ អ្នកទាំងនេះនឹងផ្តល់ព័ត៌មានដល់អ្នកសារព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ ដោយប្រើប្រាស់ភាសាដែលងាយយល់ និងមិនមែនវិទ្យាសាស្ត្រ និងស្វះស្វែងរកព័ត៌មានសមស្របនៅថ្នាក់តំបន់ឃុំ និងជាតិ។
- គ្រប់អង្គភាពផ្សព្វផ្សាយព័ត៌មាន គួរតែមានបញ្ជីអ្នកជំនាញផ្នែកប្រែប្រួលអាកាសធាតុ ដែលរួមទាំងមន្ត្រីព័ត៌មានខាងការប្រែប្រួលអាកាសធាតុមកពីរដ្ឋាភិបាល ដែលអាច "ពិនិត្យ" ព័ត៌មានមុនធ្វើការផ្សព្វផ្សាយ។

# ឯកសារពិគ្រោះ

*A fair share for women: Cambodia Gender Assessment*, UNIFEM, WB, ADB, UNDP, DFID/UK, 2004, Phnom Penh, Cambodia

*A survey of rural Cambodian households*, Cambodia Ministry of Environment, 2005, Phnom Penh, Cambodia

*Africa Talks Climate*, អង្គការBBC World Service Trust, 2010, London

*Blowing hot or cold?: South African attitudes to climate change*, J. Seager, 2008, HSRC Review, South Africa

*Climate Change in the American Mind,* A Leiserowitz et al, Centre for Climate Change Communication, George Mason University, 2009

*Climate Change Vulnerability Mapping for Southeast Asia*, A.A.Yusuf & H. Francisco, EEPSEA, 2009, Singapore

*Measuring Awareness of Climate Change,* Report on Stage 1 of ESPACE project Adapting to Climate Change: Raising Community Awareness in West Sussex, West Sussex County Council, UK, 2005

*Micro-Level Analysis of Farmers' Adaptation to Climate Change in Southern Africa,* Nhemachena, C., and R. Hassan, IFPRI DiscussionPaper No. 714, Washington, DC: International Food PolicyResearch Institute, 2007.

*National Adaptation Programme of Action to Climate Change*, Cambodia Ministry of Environment, 2006, Phnom Penh, Cambodia

*National Census of Cambodia*, Royal Government of Cambodia, Ministry of Planning, National Institute of Statistics, 1998

*National Strategic Development Plan,* Royal Government of Cambodia, Phnom Penh, 2006

*National Survey: Perception of climate change in Cambodia*, Elizabeth Smith and Nop Polin, Geres, 2007

*People's Recommendations on Climate Change via Radio Talk*, Cambodian Centre for Independent Media, 2009

*The Perception of and Adaptation to Climate Change in Africa*, David J Maddison, World Bank Policy Research Working Paper no. 4038, 2007

*Public perceptions of Climate Change in Cambodia*, Geres, for Danish Church Aid and Christian Aid, Cambodia, 2009

*The Anatomy of a Silent Crisis,* Global Humanitarian Forum, 2009

*The Contribution of Working Group II to the Fourth Assessment Report of the Intergovernmental Panel on Climate Change*, M.L. Parry, O.F. Canziani, J.P. Palutikof, P.J. van der Linden and C.E.

Hanson (eds), 2007, Cambridge University Press, Cambridge, United Kingdom and New York, NY, USA.

*The Heat is On*, I-TRAK survey, Indochina Research, 2010

*Time to Adapt? Media Coverage of Climate Change in Non-Industrialised Countries*, Mike Shanahan, 2009

*‘Hungry Cambodians at the Mercy of Climate Change’*: http://www.ens-newswire.com/ens/nov2002/2002-11-26-02.asp

# ឧបសម្ព័ន្ធ១៖ វិធីសាស្ត្រ

## គំរូប្លង់នៃការសិក្សា

ការសិក្សានេះ បានប្រើប្រាស់បង្គុំនៃវិធីសិក្សា បែបបរិមាណវិស័យ និងគុណវិស័យ។

### *១. ការសិក្សាបែបគុណវិស័យ*

ការសម្ភាសស៊ីជម្រៅ ត្រូវបានធ្វើឡើងជាលក្ខណៈបុគ្គល ជាមួយតំណាងចំនួន១០១នាក់ មកពីប្រព័ន្ធផ្សព្វផ្សាយ ឧស្សាហកម្ម រដ្ឋាភិបាលនៅថ្នាក់ជាតិ និងខេត្ត បុគ្គលដែលមានប្រជាប្រិយភាព និងមេដឹកនាំនៅមូលដ្ឋាន ដែលរួមទាំងប្រធានក្រុមប្រឹក្សាឃុំ ប្រធានភូមិ ចាស់ព្រឹទ្ធាចារ្យ និងមេដឹកនាំសាសនា។

បុគ្គលសំខាន់ៗទាំងនេះត្រូវបានជ្រើសរើសតាមរយៈបង្គុំនៃបច្ចេកទេសជ្រើសសំណាក តាមគោលបំណង (Purposive Sampling) និងការបង្កើនសំណាក (snowbal sampling) តាមរយៈការពិគ្រោះយោបល់ជាមួយក្រុមការងារពីនាយកដ្ឋានប្រែប្រួលអាកាសធាតុ(CCD), អង្គការ Oxfam និងUNDP ការណាត់ជួបបានធ្វើឡើងតាមទូរស័ព្ទជាមួយអ្នកផ្តល់សម្ភាសន៍ ដែលអាចមានពេលជួបបាន និងដែលមានឆន្ទៈជួបនិយាយជាមួយអ្នកធ្វើសម្ភាសន៍របស់យើង អំពីការប្រែប្រួលអាកាសធាតុ។

ការសម្ភាសស៊ីជម្រៅ បានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រសម្ភាសន៍ពាក់កណ្តាលគ្រោងទុក។ ការសម្ភាសត្រូវបានកត់ត្រាទុក ដោយមានការឯកភាពពីអ្នកចូលរួម។ អ្នកកត់ត្រាម្នាក់ធ្វើការសង្កេតដោយកត់ត្រាចម្លើយនានា ការសំដែងកាយវិការ និងរាល់ការទំនាក់ទំនង និងអារម្មណ៍ និងភាពតានតឹងនៃការនិយាយរបស់អ្នកចូលរួម។

ការសម្ភាសនីមួយៗត្រូវបានសង្ខេបជាឯកសារខ្លីមួយ នៅក្នុងថ្ងៃដែលបានសម្ភាសនោះ។ ឯកសារសង្ខេបនេះគូសបញ្ជាក់អំពីរបកគំហើញសំខាន់ៗក៏ដូចជាបញ្ហាដែលកើតឡើងទាក់ទងនឹងវិធីសាស្ត្រផងដែរ។

ការថតសម្លេងពីការសម្ភាសស៊ីជម្រៅនីមួយៗ ត្រូវសរសេរឡើងវិញគ្រប់ពាក្យទាំងអស់ ជាភាសាខ្មែរហើយត្រូវបានពិនិត្យឡើងវិញ ដើម្បីពិនិត្យមើលភាពសុក្រឹត ហើយភាគច្រើនត្រូវបានប្រែសម្រួលទៅជាភាសាអង់គ្លេស ដើម្បីអាចឲ្យក្រុមអ្នកស្រាវជ្រាវនៅទីក្រុងឡុងដ៍ អាចពិនិត្យបានផងដែរ។

#### *ការវិភាគទិន្នន័យ*

គំរូកូដត្រូវបានរៀបចំឡើង តាមរយៈដំណើរការពិគ្រោះយោបល់មួយ ជាមួយក្រុមអ្នកស្រាវជ្រាវនៅក្នុងចក្រភពអង់គ្លេស និងនៅកម្ពុជា។ គំរូកូដនេះបានធ្វើឡើងដោយផ្អែកលើសំណួរស្រាវជ្រាវ និងត្រូវបានពង្រីកជាបន្ថែមទៀតតាមរយៈកូដចំហរ នៃការជ្រើសរើសយកអត្ថបទចម្លង។ សម្រាប់កូដនីមួយៗ អ្នកស្រាវជ្រាវបានធ្វើការជាមួយគ្នាដើម្បីបង្កើតនិយមន័យ និងសេចក្តីដកស្រង់ដើម្បីបង្ហាញពីកូដ។ និយមន័យ និងឧទាហរណ៍អំពីសេចក្តីដកស្រង់ត្រូវបានដាក់បន្ថែមទៅក្នុងតារាងកូដដើម្បីបង្កើតជាក្របខ័ណ្ឌកូដចុងក្រោយ។ ក្របខ័ណ្ឌកូដចុងក្រោយត្រូវបានអ្នកស្រាវជ្រាវទាំងអស់នៅក្នុងក្រុមយកទៅប្រើប្រាស់។ កូដនានានៅក្នុងគំរូកូដត្រូវបានបញ្ចូលទៅក្នុងកម្មវិធី Atlas.ti ដែលបន្ទាប់មកអ្នកស្រាវជ្រាវយកទៅប្រើប្រាស់ ដើម្បីដាក់សញ្ញាសម្គាល់ និងជ្រើសរើសនៅក្នុងអត្ថបទអំពីការសម្ភាសស៊ីជម្រៅ។ ការដាក់កូដបានពឹងផ្អែកលើការសម្រេចរបស់អ្នកស្រាវជ្រាវម្នាក់ៗ។ អ្នកស្រាវជ្រាវអានអត្ថបទ ដោយគូសបញ្ជាក់អំពីផ្នែកសំខាន់ៗនៃអត្ថបទ និងដាក់ស្លាកសម្គាល់នៅលើអត្ថបទទាំងនោះ ដោយប្រើប្រាស់កូដមួយឬច្រើន ដែលយកចេញពីគំរូកូដ។ ពិន្ទុអំពីកម្រិតទុកចិត្តបានរវាងកូដនានា ដែលក្រុមអ្នកស្រាវជ្រាវសម្រេចបានគឺ ០,៧៤ ។ ពិន្ទុនេះត្រូវបានគណនា

ដោយប្រៀបធៀបលទ្ធផលពីអ្នកស្រាវជ្រាវម្នាក់ៗ ដែលធ្វើការនៅលើការដាក់កូដ និងគណនាចំនួនដងជាមធ្យមដែលកូដដូចគ្នា ឬ កូដខុសគ្នា ត្រូវបានអ្នកស្រាវជ្រាវយកមកប្រើប្រាស់នៅក្នុងផ្នែកដែលជ្រើសរើសយកនៃអត្ថបទ។

នៅពេលដែលដំណើរការដាក់កូដត្រូវបានអនុវត្តរួចរាល់ហើយ សម្រាប់គ្រប់អត្ថបទ កម្មវិធីនេះអនុញ្ញាតឱ្យអ្នកស្រាវជ្រាវធ្វើការកំណត់គំរូកូដនានា ដែលលេចធ្លោជាងគេបំផុតនៅក្នុងចំណោមអត្ថបទទាំងអស់ និងធ្វើការជ្រើសរើស និងចាត់បញ្ចូលជាក្រុមនូវរាល់សេចក្តីដកស្រង់ទាំងអស់ដែលទាក់ទងជាមួយសំណួរស្រាវជ្រាវ ដើម្បីពួកគេអាចធ្វើការប្រៀបធៀប និងវិភាគជាមួយគ្នា។ ការសម្ភាសនានាត្រូវបានវិភាគដោយផ្អែកលើកូដនៅក្នុង Atlas ក៏ដូចជាការវិភាគអត្ថបទជាទូទៅផងដែរ។ នៅពេលដែលការដាក់កូដបានធ្វើរួចរាល់ហើយសម្រាប់គ្រប់អត្ថបទ អ្នកស្រាវជ្រាវអាចជ្រើសយកពីក្នុង menu នៅក្នុង Atlas ដែលបានបង្កើតជាបញ្ជីសេចក្តីដកស្រង់ ដែលត្រូវបានគូសបញ្ជាក់សម្រាប់កូដជាក់លាក់ណាមួយនោះ។ បន្ទាប់មកអ្នកស្រាវជ្រាវអានសេចក្តីដកស្រង់ទាំងនេះ និងជ្រើសយកសេចក្តីដកស្រង់ណាដែលតំណាងឱ្យកូដនោះបានសមស្របជាងគេ។

## ២. ការស្រាវជ្រាវបរិមាណវិស័យ

បញ្ជីសំណួរសម្រាប់ការអង្កេតបែបបរិមាណវិស័យនៅតាមគេហដ្ឋាន ត្រូវបានប្រើប្រាស់ដើម្បីស្រង់យកព័ត៌មានពីសមាជិក ២៤០១ នាក់នៅក្នុងចំណោមសាធារណជនពី ក្នុងខេត្ត/ក្រុងចំនួន២៤ នៅក្នុងប្រទេសកម្ពុជា។

អ្នកឆ្លើយដែលជាគោលដៅសម្រាប់ការអង្កេតនេះ គឺជាបុរស និងស្ត្រីកម្ពុជា ដែលមានអាយុ ១៥ ដល់ ៥៥ ឆ្នាំ ដែលរួមទាំងប្រជាជនងាយរងគ្រោះ ដោយសារផលវិបាកនៃការប្រែប្រួលអាកាសធាតុផងដែរ។

ដោយសារតែចំនួនអ្នកឆ្លើយមកពីតំបន់ឆ្នេរ និងសហគមន៍អ្នកនេសាទ មានចំនួនតិចនៅក្នុងសំណាកពីដំបូង សំណាកបន្ថែមចំនួនពីរត្រូវបានធ្វើឡើង ដើម្បីបំពេញបន្ថែមសំណាកឲ្យបានមនុស្សចំនួន ៣៥ នាក់ នៅក្នុងក្រុមទាំងនេះ។ ដោយសារនេះជាសំណាកដែលត្រូវបានជ្រើសរើស សម្រាប់គោលបំណងនៃការបំពេញបន្ថែម របកគំហើញដែលទាក់ទងនឹងសហគមន៍អ្នកនេសាទទាំងពីរនេះ មិនអាចប្រៀបធៀបជាមួយនឹងរបកគំហើញសម្រាប់សំណាកទាំងមូលបានឡើយ និងមិនមែនជាសំណាកដែលមានលក្ខណៈតំណាងនៅក្នុងប្រទេសឡើយ។

### ការជ្រើសសំណាក

ការជ្រើសសំណាកជាច្រើនដំណាក់កាល ដោយប្រើប្រាស់ប្រូបាប៊ីលីតេសមាមាត្រទៅនឹងទំហំ (PPS) [៤៧] ត្រូវបានប្រើប្រាស់សម្រាប់ជ្រើសរើសយកឯកតាសំណាកដំបូងនីមួយៗ។ ឯកតាសំណាកបឋមគឺជាភូមិ។ ទិន្នន័យពីការជំរឿននៅថ្នាក់ជាតិក្នុងឆ្នាំ២០០៨ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការជ្រើសរើសសំណាកទាំងនេះ។

#### ដំណាក់កាលទី១ - ការជ្រើសយកឯកតាសំណាកបឋម (PSU)

ឯកតាសំណាកបឋមសរុបចំនួន ២៣៣ ត្រូវបានជ្រើសយកនៅទូទាំងខេត្ត/ក្រុង២៤ ដូចមានបង្ហាញជូននៅក្នុងតារាងខាងក្រោម។ នៅក្នុងឯកតាសំណាកដំបូងនីមួយៗ អ្នកឆ្លើយចំនួន ១២ ឬ ១៣ នាក់ត្រូវបានជ្រើសយកលើកលែងតែខេត្តចំនួនប្រាំពីរ [៤៨] ដែលបានជ្រើសយកតែអ្នកឆ្លើយត្រឹមចំនួន ១០ ។

---

[៤៧] *ប្រូបាប៊ីលីតេសមាមាត្រទៅនឹងទំហំ* (PPS) គឺជាបច្ចេកទេសជ្រើសរើសសំណាក ដែលត្រូវបានប្រើប្រាស់ជាទូទៅនៅក្នុងការជ្រើសរើសសំណាកជាក្រុមជាច្រើនដំណាក់កាល ដែលនៅក្នុងនោះប្រូបាប៊ីលីតេដែលឯកតាសំណាកណាមួយនឹងត្រូវជ្រើសរើសយកនៅក្នុងសំណាកនោះ ត្រូវតែសមាមាត្រនឹងអថេរដែលបានដឹងជាមុនខ្លះៗ (ដូចជានៅក្នុងការអង្កេត ប្រជាជនតាមធម្មតា គឺចំនួនប្រជាជននៅក្នុងឯកតាសំណាកនោះ)។ http://www.cdc.gov/cogh/dgphcd/modules/MiniModules/PPS/page09.htm. វិធីនេះមិនសូវចំណាយច្រើន និងអាចអនុវត្តបានរហ័សជាងការយកសំណាកងាយដោយចៃដន្យ ប៉ុន្តែនៅតែបង្កើតបានសំណាកមួយដែលតំណាងប្រជាជនសរុប។

[៤៨] ព្រៃវែង សៀមរាប តាកែវ កំពង់ស្ពឺ បន្ទាយមានជ័យ កំពង់ធំ និងភ្នំពេញ។

អ្នកឆ្លើយនៅក្នុងទីក្រុង និងជនបទត្រូវបានជ្រើសយកដាច់ដោយឡែកពីគ្នា ដោយចំនួននៃចំណុចចាប់ផ្តើមសម្រាប់ជនបទ និងទីក្រុងបានផ្អែកលើសមាមាត្រដែលមានបង្ហាញនៅក្នុងតារាងនេះ។

*តារាងជ្រើសរើសសំណាក*

| | ចំនួនអ្នកចូលរួម | | | |
|---|---|---|---|---|
| ខេត្ត | ទីប្រជុំជន | ជនបទ | សរុប | ចំនួនភូមិ |
| កំពង់ចាម | ១០០ | ១៥១ | ២៥១ | ២៥ |
| កណ្តាល | ៥០ | ១០០ | ១៥០ | ១៥ |
| បាត់ដំបង | ៥០ | ១០០ | ១៥០ | ១៥ |
| បន្ទាយមានជ័យ | ៤០ | ៦០ | ១០០ | ១០ |
| ពោធិ៍សាត់ | ២០ | ៥៥ | ៧៥ | ៧ |
| ប៉ៃលិន | ២០ | ៥៥ | ៧៥ | ៧ |
| កំពង់ស្ពឺ | ៤០ | ៦០ | ១០០ | ១០ |
| កំពត | ២០ | ៥៥ | ៧៥ | ៧ |
| ព្រះសីហនុ | ២០ | ៥៥ | ៧៥ | ៧ |
| កោះកុង | ២០ | ៥៥ | ៧៥ | ៧ |
| កែប | ២០ | ៥៥ | ៧៥ | ៧ |
| ក្រចេះ | ២០ | ៥៥ | ៧៥ | ៧ |
| រតនគិរី | ២០ | ៥៥ | ៧៥ | ៧ |
| ស្ទឹងត្រែង | ២០ | ៥៥ | ៧៥ | ៧ |
| មណ្ឌលគិរី | ២០ | ៥៥ | ៧៥ | ៧ |
| កំពង់ធំ | ៤០ | ៦០ | ១០០ | ១០ |
| ភ្នំពេញ | ១០០ | ១០០ | ២០០ | ២០ |
| ព្រៃវែង | ៤០ | ៦០ | ១០០ | ១០ |
| តាកែវ | ៤០ | ៦០ | ១០០ | ១០ |
| សៀមរាប | ៤០ | ៦០ | ១០០ | ១០ |
| ឧត្តរមានជ័យ | ២០ | ៥៥ | ៧៥ | ៧ |
| ព្រះវិហារ | ២០ | ៥៥ | ៧៥ | ៧ |
| ស្វាយរៀង | ២០ | ៥៥ | ៧៥ | ៧ |
| កំពង់ឆ្នាំង | ២០ | ៥៥ | ៧៥ | ៧ |
| *សរុប* | ៧០០ | ១៣៧៥ | ២៤០១ | ២៣៣ |

ដោយប្រើប្រាស់បញ្ជីឈ្មោះភូមិទាំងអស់នៅក្នុងទីក្រុង និងឯកតាសំណាកដំបូងទាំងអស់នៅជនបទក្នុងខេត្តនោះ ចំនួនប្រជាជនសរុបសម្រាប់ទីតាំងនីមួយៗនៅក្នុងទីក្រុង និងជនបទត្រូវបានគណនា។

ប្រជាជនសរុបត្រូវបានបែងចែកជាពាក់កណ្តាល នៃចំនួននៅចំណុចចាប់ផ្តើមក្នុងខេត្តនីមួយៗ ដោយប្រើប្រាស់តារាងដាច់គ្នាសម្រាប់ទីតាំងនៅទីក្រុង និងនៅជនបទ។

លេខជ្រើសដោយចៃដន្យមួយ និងលេខសំណាក ត្រូវបានជ្រើសយកដោយប្រើប្រាស់ប៊ូតុង Excel random number function (RAND) នៅលើកុំព្យូទ័រ។ ក្រុមដំបូងគឺ PSU ដែលនៅក្នុងនោះមានលេខចៃដន្យនេះ។ ចំណុចចាប់ផ្ដើមបន្ទាប់ទៀតត្រូវបានធ្វើការកំណត់ដោយបន្ថែមចន្លោះសំណាកទៅក្នុងលេខចៃដន្យពីលើកមុន។

សម្រាប់គោលបំណងនៃការសិក្សានេះ ប្រព័ន្ធមួយត្រូវបានបង្កើតឡើងដែលក្នុងនោះ PSU នីមួយៗ ត្រូវបានជ្រើសយកដោយចៃដន្យ នៅក្នុងឃុំជាមួយគ្នា ដើម្បីប្រមូលយកអ្នកចូលរួមជាច្រើន ក្នុងកម្រិតដែលវត្ថុមានហិរញ្ញវត្ថុ និងភស្តុភា អាចអនុញ្ញាតឱ្យធ្វើទៅបាន។ នៅក្រោយបានជ្រើសយក PSU ដំបូងដោយចៃដន្យ រួចឈ្មោះឃុំត្រូវបានពិនិត្យឡើងវិញ។ បន្ទាប់មក PSUs ដែលនៅសល់ទាំងអស់ក្នុងឃុំនោះត្រូវបានចុះក្នុងតារាងសម្រាប់ជ្រើសយក PSU ផ្សេងទៀតដោយចៃដន្យនៅក្នុងកន្លែងដូចគ្នានោះ។

*ដំណាក់កាលទី២ - ការជ្រើសយកគ្រួសារនៅក្នុងភូមិនីមួយៗ*

*ការយកសំណាកដោយចៃដន្យជាលក្ខណៈប្រព័ន្ធ ត្រូវបានប្រើប្រាស់ដើម្បីជ្រើសយកគ្រួសារចំនួន ១០/១២/១៣ សម្រាប់ PSU នីមួយៗ។*[៤៩]

ចន្លោះរវាងសំណាកដែលបានប្រើប្រាស់ដើម្បីជ្រើសយកគ្រួសារនានានៅក្នុង PSU មួយ ត្រូវបានគណនាដោយចែកចំនួនសរុបនៃគ្រួសារ នៅក្នុង PSU នោះ ជាមួយចំនួនគ្រួសារ (១០/១២/១៣) ដែលត្រូវជ្រើសរើសនោះ។ នៅក្នុងភូមិនីមួយៗ ផែនទីមួយត្រូវបានគូសដោយមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន ឬ ប្រធានភូមិដើម្បីបង្ហាញពីរាងសណ្ឋានរបស់ភូមិនោះ។ នៅក្នុងភូមិ តាមទីក្រុង ផែនទីផ្លូវ ក៏ត្រូវបានយកមកប្រើប្រាស់ផងដែរ។ អ្នកសម្ភាស បានចាប់ផ្ដើមពីចំណុចចាប់ផ្ដើមនៅចំកណ្ដាលភូមិនោះ តាមទិសនៃការធ្វើដំណើរដែលខុសគ្នាសម្រាប់អ្នកសម្ភាសន៍នានា។

ដំណាក់កាលនេះមិនបានរួមបញ្ចូលៈ

- ភូមិនានាដែលត្រូវធ្វើដំណើរយូរជាងមួយថ្ងៃ ដើម្បីចូលដល់តាមផ្លូវថ្នល់ចេញពីទីរួមខេត្ត
- ភូមិនានាដែលមានចំនួនគ្រួសារតិចជាង២៥
- បុគ្គលណាម្នាក់ដែលបានចូលរួមនៅក្នុងការស្រាវជ្រាវណាមួយ អំពីការប្រែប្រួលអាកាសធាតុនៅក្នុងរយៈពេល៣ខែមុនការអង្កេតនេះ ដែលកំណត់តាមរយៈសំណួរជ្រើសដំបូងនៅពេលចាប់ផ្ដើមបញ្ជីសំណួរ។

*ដំណាក់កាលទី៣ - ការជ្រើសយកអ្នកឆ្លើយ*

នៅតាមគ្រួសារនីមួយៗ KISH grid[៥០] ត្រូវបានយកមកប្រើប្រាស់ដើម្បីជ្រើសរើសយកសមាជិកគ្រួសារសម្រាប់បញ្ចូលទៅក្នុងការអង្កេតនេះ។ KISH grid ត្រូវបានប្រើប្រាស់ដើម្បីចុះឈ្មោះសមាជិកទាំងអស់ ក្នុងគ្រួសារដែលបន្ទាប់មកត្រូវបានប្រើប្រាស់ដើម្បីធ្វើការកំណត់សមាជិកទាំងអស់ ដែលមានអាយុពី ១៥ ទៅ ៥៥ ឆ្នាំ។ អ្នកឆ្លើយម្នាក់ត្រូវបានជ្រើសយកពីគ្រួសារនីមួយៗ។

---

[៤៩] ចំនួនគ្រួសារនៅក្នុងភូមិនោះត្រូវបានបញ្ជាក់ដោយអាជ្ញាធរមូលដ្ឋាន និងប្រធានភូមិនៅពេលដែលក្រុមនានាទៅដល់ភូមិ ដោយសារជួនកាលចំនួនគ្រួសារនៅក្នុងបញ្ជីឈ្មោះខុសគ្នាពីចំនួនគ្រួសារជាក់ស្ដែង ដោយសារតែប្រជាជនផ្លាស់ទីលំនៅ។ ប្រសិនបើមានភាពខុសគ្នាបែបនោះចំនួនជាក់ស្ដែងដែលប្រធានភូមិផ្ដល់ឱ្យត្រូវបានប្រើប្រាស់តែមិនមែនតួលេខនៅក្នុងបញ្ជីឈ្មោះឡើយ។

[៥០] Kish grid: ជាការចុះឈ្មោះសមាជិកទាំងអស់នៅក្នុងគ្រួសារមួយ ដែលត្រូវយកមកប្រើប្រាស់សម្រាប់ជ្រើសយកអ្នកឆ្លើយពីក្នុងគ្រួសារនីមួយៗ តាមរយៈការជ្រើសដោយចៃដន្យ ដើម្បីឱ្យសំណាកទាំងមូលឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធនៃប្រជាជនទូទៅទាក់ទងនឹងអាយុ ភេទ និងស្ថានភាពនៅក្នុងគ្រួសារ។

ដំណាក់កាលនេះមិនរាប់បញ្ចូលៈ

- អ្នកដែលមិនអាចនិយាយភាសាខ្មែរ
- ប្រជាជនដែលមិននៅផ្ទះនៅក្នុងថ្ងៃ/ល្ងាចដែលក្រុមសម្ភាសស្ថិតនៅក្នុង PSU នោះ។

*ការធានាគុណភាព*

អ្នកដឹកនាំក្រុមស្រាវជ្រាវមានភារៈកិច្ចទទួលខុសត្រូវ លើការណែនាំនៅក្នុងការអង្កេតនៅតាមភូមិសាស្ត្រ និងគុណភាពនៅទូទាំងការអង្កេតទាំងមូល ដែលរួមទាំងការសាកល្បង បរិធានសម្រាប់ការស្រាវជ្រាវនេះ។

ការធានាគុណភាពបានធ្វើឡើងតាមរយៈ ការសង្កេតការចុះពិនិត្យ និងការប្រជុំជាក្រុម នៅចុងថ្ងៃធ្វើការនីមួយៗ។ អ្នកដឹកនាំក្រុមធ្វើការសង្កេតលើការសម្ភាសមួយៗ។ គោលបំណងនៃការសង្កេត គឺដើម្បីវាយតម្លៃ និងកែលម្អការងាររបស់អ្នកសម្ភាស និងរកមើលកំហុសឆ្គង និងការបកស្រាយខុសចំពោះសំណួរដែលមិនអាចមើលឃើញនៅក្នុងពេលពិនិត្យផ្ទៀងផ្ទាត់។

អ្នកដឹកនាំក៏សង្កេតមើលនៅក្នុងពេលពិនិត្យផ្ទៀងផ្ទាត់ផងដែរ។ បញ្ជីសំណួរនីមួយៗត្រូវបានពិនិត្យដើម្បីឱ្យមានសុក្រឹតភាពពេញលក្ខណៈសមស្រប និងភាពស៊ីសង្វាក់គ្នា នៅក្នុងពេលដែលក្រុមការងារនៅតាមទីតាំងភូមិសាស្ត្រនៅឡើយ។

ការចុះពិនិត្យ ត្រូវបានធ្វើឡើងដោយអ្នកដឹកនាំ ដែលបានចុះពិនិត្យគ្រួសារនីមួយៗ ដើម្បីបញ្ជាក់ថាការសម្ភាសបានធ្វើឡើង និងដើម្បីវាយតម្លៃអាកប្បកិរិយារបស់អ្នកសម្ភាសចំពោះមុខសមាជិកគ្រួសារ និងអ្នកឆ្លើយ។

*ការវាយបញ្ចូលទិន្នន័យ*

បច្ចេកទេសបញ្ចូលទិន្នន័យទ្វេដង ត្រូវបានយកមកប្រើប្រាស់តាមរយៈទិន្នន័យ Epi ហើយទិន្នន័យនេះត្រូវបានវាយបញ្ចូល និងពិនិត្យនៅទូទាំងដំណើរការប្រមូលទិន្នន័យ។ វិធីនៃការវាយបញ្ចូលទិន្នន័យទ្វេដងបែបនេះ អាចអនុញ្ញាតឱ្យធ្វើការប្រៀបធៀប និងផ្ទៀងផ្ទាត់។

នៅលើបញ្ជីសំណួរ និងនៅក្នុងពេលវាយបញ្ចូលទិន្នន័យ គេពុំមានព័ត៌មានដែលអាចឱ្យធ្វើការកំណត់អ្នកឆ្លើយបានឡើយ។ ហើយលេខសម្គាល់ត្រូវបានប្រើប្រាស់ជំនួសឲ្យឈ្មោះអ្នកចូលរួមនៅលើកម្រងបញ្ជីសំណួរ។

*ការវិភាគទិន្នន័យ*

ការវិភាគទិន្នន័យតាមវិធីបរិមាណវិស័យត្រូវបានធ្វើឡើងដោយប្រើប្រាស់កម្មវិធី SPSS software។

បច្ចេកទេសវិភាគដែលប្រើប្រាស់រួមមានការពិពណ៌នា (ប្រេកង់) និងស្ថិតិអញ្ញតពីរ(t-tests, z-tests, chi-square) ដើម្បីអធិប្បាយ និងប្រៀបធៀបភាពខុសគ្នានៃរង្វាស់សំខាន់ៗមួយចំនួន លើចំណេះដឹងឥរិយាបថ និងការអនុវត្តដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ Chi-square tests ត្រូវបានយកមកប្រើប្រាស់ដើម្បីធ្វើការសាកល្បងស្តីអំពីការជាប់ពាក់ព័ន្ធរវាងគ្នា នៃអញ្ញតធម្មតាដែលមិនមែនជាប៉ារ៉ាម៉ែត។ Z-tests ត្រូវបានយកមកប្រើប្រាស់ដើម្បីពិនិត្យមើលភាពខុសគ្នាសំខាន់ៗ រវាងចម្លើយសមាមាត្រនៃអនុក្រុមនៅក្នុងសំណាកនៃការអង្កេត។ T-tests ត្រូវបានប្រើប្រាស់ដើម្បីពិនិត្យមើលភាពខុសគ្នាសំខាន់ៗ នៃពិន្ទុមធ្យមរវាងអនុក្រុមជាក់លាក់នៅក្នុងសំណាកនៃការអង្កេតនេះ។ នៅក្នុងគ្រប់ករណីទាំងអស់ចន្លោះប្រូបាប៊ីលីតេត្រូវបានកំណត់យកត្រឹម០,៩៥។

សំណាកនេះត្រូវបានវិភាគ ស្របតាមជំពូកនៃការប្រៀបធៀបដូចតទៅ:

- សំណាកសរុប
- តំបន់ភូមិសាស្ត្រចំបងៗ
- ទីកន្លែងដែលប្រជាជនរស់នៅ (ទីក្រុង/ជនបទ)
- ភេទ (បុរស/ស្ត្រី)
- ក្រុមអាយុ (១៥-២៤ឆ្នាំ ២៥-៣៤ឆ្នាំ ៣៥-៤៤ឆ្នាំ ៤៥-៥៥ឆ្នាំ)
- កំរិតវប្បធម៌: មិនបានទទួលការអប់រំ បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ និងបរិញ្ញាបត្រ
- រង្វាស់សន្ទស្សន៍នៃភាពក្រីក្រ: ក្របំផុត ក្រ មធ្យម និង មាន
